លេខ/No: D359

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 16 / 08 / 2018
ម៉ោង (Time/Heure): 08:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស

| | | |
|---|---|---|
| ចំពោះមុខ | ៖ | សហចៅក្រមស៊ើបអង្កេតជាតិ |
| កាលបរិច្ឆេទ | ៖ | ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ |
| ភាសា | ៖ | ខ្មែរ |
| ចំណាត់ថ្នាក់ឯកសារ | ៖ | សាធារណៈ |

---

# ដីកាសម្រេចលើកលែងចោទប្រកាន់ អោ អាន

---

__ផ្ញើជូន៖__

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**
មុំ លុជ្ជ
Richard ROGERS
Göran SLUITER

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ជេត វណ្ណលី
ហុង គីមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ
Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Daniel MCLAUGHLIN
Lyma NGUYEN
Nushin SARKARATI

CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

# មាតិកា

ទំព័រ

I. **សេចក្តីផ្តើម** ....................................................................................៤

ក. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ ..........................................................៤

ខ. ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ..........................................៨

គ. អនិយ័តភាពនៃនីតិវិធីស៊ើបអង្កេតបឋម ..........................................................៨

ឃ. ការរំលឹកឡើងវិញពីនីតិវិធី ....................................................................១០

ង. អនិយ័តភាពនៃកិច្ចដែលបំពេញដោយ ស.ច.ស.អ.ប ..........................................១៧

ច. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ..................................................១៨

II. **ការកត់សម្គាល់ឃើញអំពីអង្គហេតុ** ..........................................................២១

ក. អំពីគោលនយោបាយទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ......................................២១

ខ. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិមបក្ស ........................................................៣៣

១. គណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ..............................................៣៣

២. គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា ..........................................៣៥

៣. ស្ថាប័នដទៃទៀត ................................................................................៣៦

គ. គោលនយោបាយរបស់ ប.ក.ក ចំពោះជនជាតិចាម ............................................៣៩

១. ការប្រព្រឹត្តជាទូទៅលើជនជាតិចាម ..........................................................៣៩

២. ការជម្លៀសជនជាតិចាម ........................................................................៤២

ឃ. គោលនយោបាយនៃការបោសសម្អាតនៅភូមិភាគកណ្តាល ....................................៤៣

ង. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ............................................................៤៧

ច. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន ..........................................................៥១

១. ភូមិភាគ ..........................................................................................៥១

២. ខ្សែបញ្ជា ..........................................................................................៥២

៣. ភូមិភាគនិរតី ....................................................................................៥២

៣-១- តំបន់ ១៣ ........................................................................................៥៣

៣-២- តំបន់ ២៥ ........................................................................................៥៣

៣-៣- តំបន់ ៣៥ ........................................................................................៥៤

៤. ភូមិភាគកណ្តាល ................................................................................៥៥



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C *C.E.T.C*

៤-១- អំណាចលេខាភូមិភាគកណ្ដាល កែ ពក ....................................៥៨

៤-២- ការបោសសម្អាតនៅភូមិភាគកណ្ដាល ....................................៦០

៤-៣- អវត្តមាន កែ ពក ....................................៦៣

៤-៤- តួនាទី **តា អាន** ....................................៦៥

៤-៥- ប្រព័ន្ធទំនាក់ទំនងការងារនៅភូមិភាគកណ្ដាល ....................................៦៥

៤-៦- តំបន់ ៤១ ....................................៦៨

៤-៧- តំបន់ ៤២ ....................................៧៤

៤-៨- តំបន់ ៤៣ ....................................៧៦

៥. តំបន់ស្វយ័ត ....................................៧៦

៦. តំបន់ ....................................៧៧

III. **សាវតារ តួនាទី និងការចូលរួមរបស់ អោ អាន** ....................................៧៧

ក. សាវតាររបស់ **អោ អាន** ....................................៧៧

ខ. ការចូលរួមរបស់ **អោ អាន** ....................................៨០

១. ទីតាំងឧក្រិដ្ឋកម្ម ....................................៨១

១-១- កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស ....................................៨១

១-២- មន្ទីរសន្តិសុខវត្តអូរត្រកួន ....................................៨៣

១-៣- មន្ទីរសន្តិសុខវត្តបាធាយ ....................................៨៨

១-៤- មន្ទីរសន្តិសុខមិត្តសុប (គរ) ....................................៩១

១-៥- ទីកន្លែងសម្លាប់មនុស្សគោកព្រីង ....................................៩៣

១-៦- ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ ....................................៩៤

១-៧- មន្ទីរសន្តិសុខវត្តតាមះ ....................................៩៥

១-៨- មន្ទីរសន្តិសុខទួលតាផ្លុង ....................................៩៨

១-៩- មន្ទីរសន្តិសុខវត្តកណ្ដាល ....................................១០០

១-១០- មន្ទីរសន្តិសុខចំការស្វាយចន្ទី ....................................១០០

១-១១- មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ....................................១០៣

១-១២- មន្ទីរសន្តិសុខវត្តស្រង៉ែ ....................................១០៥

១-១៣- មន្ទីរសន្តិសុខវត្តអង្គញជី ....................................១០៨

១-១៤- ទីកន្លែងសម្លាប់មនុស្សនៅទួលបេង ....................................១០៩

១-១៥- អាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់៤១
(ស្រុកកំពង់សៀមនិងព្រៃឈរ)......១១០
១-១៦- អំពើប្រល័យពូជសាសន៍ជនជាតិចាមនៅខេត្តកំពង់ចាម ......១១៣
២. ចំនួនជនរងគ្រោះ ......១១៦

IV. **ច្បាប់ជាធរមាន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក** ..១១៧
ក. ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និងយុត្តាធិការបទល្មើស ......១២១
ខ. គោលការណ៍ច្បាប់ព្រហ្មទណ្ឌ ៖ ការបកស្រាយចង្អៀត យុត្តាធិការបែបជ្រើសរើស ......១២៦
គ. លក្ខណៈវិនិច្ឆ័យក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិ៖ការធ្វើសេចក្ដីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ ......១៣០
ឃ. សារៈសំខាន់នៃដំណើរការស្វែងរកយុត្តិធម៌ ......១៣២

V. **ការពិចារណាទៅលើភ័ស្តុតាង** ......១៣៩
ក. ការធ្វើសម្ភាសន៍ដែលមិនមែនជា កំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយ សហចៅក្រមស៊ើបអង្កេត ......១៣៩
ខ. ភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម ......១៤១

VI. **សំអាងហេតុ និងសេចក្តីសន្និដ្ឋាន បញ្ហាយុត្តាធិការបុគ្គលលើ អោ អាន** ......១៤១

VII. **ឯកសារឧបសម្ព័ន្ធ** ......៤៦២
ក. បញ្ជីពាក្យបំព្រួញ
ខ. បញ្ជីប្រភេទឯកសារផ្សេងៗ ដែលត្រូវបានប្រើដើម្បីសរសេរដីកាដំណោះស្រាយ

* ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581319



# យើង យូ ប៊ុនឡេង សហចៅក្រមស៊ើបអង្កេតជាតិនៃ អ.វ.ត.ក

- **បានឃើញ** ច្បាប់ស្ដីពី "ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (ច្បាប់ស្ដីពី "ការបង្កើត អ.វ.ត.ក") ។

- **បានឃើញ** វិធាន ៥៥, ៦៦, និង ៦៧ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ( វិសោធនកម្មលើកទី ៩ នៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ) ("វិធានផ្ទៃក្នុង") ។

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ។[1]

- **បានឃើញ** ការបើកកិច្ចស៊ើបសួរទាក់ទងការចោទប្រកាន់ **អោ អាន** ដូចខាងក្រោម[2]៖
  - ក. មនុស្សឃាតទារុណកម្ម និង ការធ្វើទុក្ខបុកម្នេញ ដោយហេតុផលសាសនាមកលើជនជាតិចាម។ ឧក្រិដ្ឋកម្មនេះជាការរំលោភក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ (មាត្រា៥០១ ៥០៣ ៥០៤ ៥០៥ ៥០៦ ៥០៧ និង ៥០៨), មាត្រា ៥០០ និងមាត្រា ២០៩ និងមាត្រា ២១០ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៣ (ថ្មី) ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ។
  - ខ. អំពើប្រល័យពូជសាសន៍ចាម (កថាខណ្ឌទី ៣៧ ដល់កថាខណ្ឌទី ៤៨) ។ ឧក្រិដ្ឋកម្មនេះជាការរំលោភលើអនុសញ្ញាឆ្នាំ១៩៤៨ ស្តីពីការបង្ការនិងផ្តន្ទាទោស ចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៤ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ។
  - គ. ការធ្វើឃាតកម្ម ការសម្លាប់រង្គាល ការធ្វើទៅជាទាសករ ការដាក់ក្នុងមន្ទីរឃុំឃាំង ការធ្វើទារុណកម្ម ការរំលោភលើផ្លូវភេទនិងធ្វើទុក្ខបុកម្នេញ ដោយមូលហេតុ នយោបាយ ពូជសាសន៍ និងសាសនា ទៅលើអតីតមន្ត្រីសាធារណៈរដ្ឋខ្មែរ វណ្ណៈសក្តិភូមិនាយទុន និង គហបតី "ប្រជាជនថ្មី" អ្នកជាប់សង្ស័យជា "សមាសភាពអាក្រក់" ជនជាតិចាម និងជនជាតិភាគតិចវៀតណាម និងអំពើអមនុស្សធម៌ដទៃទៀត ដែលបទឧក្រិដ្ឋទាំងនេះជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ដែលត្រូវផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ អ.វ.ត.ក ។



ECCC * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

- **បានឃើញ** សេចក្តីដកស្រង់របស់អង្គបុរេជំនុំជម្រះ (អ.ប.ជ) ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ លើការខ្វែងយោបល់រវាង សហព្រះរាជអាជ្ញា (ស.ព) ដោយអះអាងថា អ.ប.ជ មិនអាចឈានដល់ការធ្វើសេចក្តីសម្រេចលើការខ្វែងយោបល់ នោះកិច្ចរបស់សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) ត្រូវតែយកទៅអនុវត្ត ។[3]

- **បានឃើញ** ការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣ ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ដោយ ស.ព.អ ស្នើដល់សហចៅក្រមស៊ើបអង្កេត (ស.ច.ស) សុំឱ្យចាប់ផ្តើមបើកកិច្ចស៊ើបសួរ ។[4]

- **បានឃើញ** សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែមរបស់ ស.ព.អ ទាក់ទិនទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ ០០៤ នៅភូមិភាគកណ្តាល និង ការទទួលខុសត្រូវរបស់ជនសង្ស័យឈ្មោះ **អោ អាន** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ។[5]

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ។[6]

- **បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ ស.ព.អ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ។[7]

- **បានឃើញ** ការជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន** ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ យោងតាមវិធានផ្ទៃក្នុង ៦៦ (១) ស.ច.ស បានជូនដំណឹងដល់ភាគីនិងមេធាវីរបស់ភាគីទាំងអស់ថា កិច្ចស៊ើបសួរប្រឆាំង **អោ អាន** បានបញ្ចប់ហើយ ។[8]

- **បានឃើញ** ដីកាសម្រេចបំបែកនីតិវិធី **អោ អាន** ចេញពីសំណុំរឿង ០០៤ ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ដោយបង្គាប់ឱ្យបង្កើតសំណុំរឿងថ្មីជា "**សំណុំរឿង០០៤/២**" ។[9]



អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១ ។

- **បានឃើញ** ការសុំពន្យារពេលកំណត់ សម្រាប់ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានការជូនដំណឹង អនុលោមតាមវិធាន ៦៦ ដោយបន្ថែមរយៈពេល ៣០ (សាមសិប) ថ្ងៃនៃប្រក្រតិទិន ។[10]

- **បានឃើញ** ដីកាសម្រេចលើសំណើរបស់ **អោ អាន** សុំពន្យាររយៈពេលកំណត់ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែមដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ស.ច.ស.អ) បានសម្រេចផ្តល់ជូនរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃបន្ថែមដោយកាលបរិច្ឆេទកំណត់ថ្មីត្រឹមថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៧ ។[11]

- **បានឃើញ** ការជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន** ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ដោយ ស.ច.ស បានបញ្ចប់ ហេតុនេះ មិនផ្តល់ជូនពេលវេលាបន្ថែមទៀតទេ ។[12]

- **បានឃើញ** ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ស.ព មានវេលា ៣ (បី) ខែ ចាប់ពីពេលជូនដំណឹងពីដីកាសម្រេចនេះ ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ។[13]

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិ (ស.ព.ជ) ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០១៧ ។[14]

- **បានឃើញ** ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។[15]

- **បានឃើញ** ចម្លើយតបរបស់ **អោ អាន** ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ។[16]

- **យល់ឃើញថា** ការស៊ើបសួរលើយុត្តាធិការបុគ្គល បានបង្ហាញលទ្ធផលដូចតទៅ៖

01581322



# I. សេចក្តីផ្តើម

## ក. ការកត់សម្គាល់អំពីដីកាដំណោះស្រាយ

១ ដូចដែលនឹងបង្ហាញបន្ថែមក្នុងផ្នែកខាងក្រោម ក្រោយពីអង្គបុរេជំនុំជម្រះសម្រេចសហចៅក្រមស៊ើបអង្កេតជាតិ បានចាប់ផ្តើមធ្វើការងារស៊ើបអង្កេត ទៅលើឯកសារក្នុងសំណុំរឿងបន្ថែមពីលើឯកសារដទៃទៀត ដែលត្រូវបានផ្ទេរពីសំណុំរឿងលេខ០០១ និងលេខ០០២ ។ ជាមួយនឹងមន្ទិលថា តើ **អោ អាន** ជាមេដឹកនាំជាន់ខ្ពស់ ឬ ជាជនទទួលខុសត្រូវខ្ពស់បំផុត បន្ទាប់ពីពិនិត្យឯកសារ សហចៅក្រមស៊ើបអង្កេតជាតិ មិនបានឯកភាពដាក់ **អោ អាន** ឲ្យស្ថិតនៅក្រោមការពិនិត្យទេ ។

២ ដីកាដំណោះស្រាយនេះ ពិចារណាផ្តោតទៅលើថា តើ **អោ អាន** ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ដែរឬទេ?លក្ខណៈពិសេសនៃកិច្ចព្រមព្រៀងនិងច្បាប់ស្តីពី អ.វ.ត.ក ឆ្លុះបញ្ចាំងពីយុត្តាធិការជ្រើសរើស ។ អង្គហេតុដែលត្រូវបានប្តឹងដោយសហព្រះរាជអាជ្ញាអន្តរជាតិ ជាសត្យានុម័តពិតជាមាន ទោះបីជាយ៉ាងនេះក្តី ដីកាដំណោះស្រាយនេះត្រូវបានចេញដោយផ្អែកលើភ័ស្តុតាង ដែលបានមកពីលទ្ធផលនៃការស៊ើបអង្កេតស្របច្បាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតលើអង្គហេតុទាំងអស់ ។ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាជាសំខាន់លើការចូលរួមប្រព្រឹត្ត និង លក្ខខណ្ឌផ្សេងៗទៀតរបស់ជនត្រូវចោទពាក់ព័ន្ធអង្គហេតុទាំងនោះ ដែលជាកត្តាសំខាន់ដើម្បីកំណត់ថា "ជនត្រូវចោទ" ជាមេដឹកនាំជាន់ខ្ពស់ ឬ ជនទទួលខុសត្រូវខ្ពស់បំផុត ។ ក្នុងន័យនេះ ដីកាដំណោះស្រាយនឹងមិនមានភាពចាំបាច់ ក្នុងការចាត់បទល្មើសទៅតាមអង្គហេតុ និង សរសេរបញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវនោះទេ ។

៣ ឯកសារដែលនឹងត្រូវប្រើក្នុង ដីកាដំណោះស្រាយនេះរួមមាន៖ ឯកសារទាំងឡាយដែលមានក្នុងសំណុំរឿងលេខ០០៤/២ ដែលទទួលបានមកពីការស៊ើបអង្កេត និង ការផ្ទេរបញ្ចូលពីសំណុំរឿងដទៃទៀតរួមមាន៖ សំណុំរឿងលេខ០០១ លេខ០០២ និងលេខ០០៣ ផងដែរ ។ ឯកសាររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet នឹងមិនត្រូវបានប្រើទេ ។ ទោះបីជាយ៉ាងនេះក្តី បន្ទាប់ពីការចាកចេញរបស់ចៅក្រម



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

Laurent Kasper-Ansermet នៅមានឯកសារមួយចំនួន ដែលត្រូវបានដាក់បញ្ចូលជាផ្នែកមួយ និង ក្នុងក្របខ័ណ្ឌនៃដីកាបង្គាប់ឱ្យស៊ើបសួរជំនួស ចេញដោយចៅក្រមរូបនេះ ។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតជាតិ បានពិចារណាថា ដីកាដំណោះស្រាយនេះ អាចនឹងប្រើប្រាស់ឯកសារមួយចំនួនដោយច្រលំជាយថាហេតុ ។

៤ ដីកាដំណោះស្រាយនេះប្រើឯកសារចំនួនប្រហែល ១៣០១ (មួយពាន់បីរយមួយ) ឯកសារចែកចេញជា ២១ (ម្ភៃមួយ) ប្រភេទដូចជា៖ កំណត់ត្រាប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មការមជ្ឈិមបក្សក្នុងរបបកម្ពុជាប្រជាធិបតេយ្យ សារទូរលេខ ចម្លើយសារភាពនៃអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា និង កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលមានចំនួនច្រើនជាងគេរហូតដល់ ៥៦១ (ប្រាំរយហុកសិបប្រាំមួយ) (ឧបសម្ព័ន្ធខ) ជាអាទិ៍ ។ ក្នុងប្រភេទឯកសារចុងក្រោយនេះ មានចម្លើយរបស់សាក្សីសំខាន់ (insider witness) ដូចជា កម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យមានចំនួន ១៨៣ (មួយរយប៉ែតបី) កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីដែលត្រូវបានបង្កើតឡើងក្នុងក្របខ័ណ្ឌនៃសំណុំរឿង០០៤/២ នេះ ។

៥ យើងចង់បង្ហាញថា តាមទ្រឹស្តីជនដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាត្រូវបានហៅថា "ជនត្រូវចោទ" រួចទៅហើយ ។ យើងបានចុះកំណត់ត្រាខ្វែងយោបល់ ពាក់ព័ន្ធនឹងការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និង មិនបានប្ដឹងទៅអង្គបុរេជំនុំជម្រះ ។ ដូចនេះ ការប្រើប្រាស់ឯកសារទទួលបាន ក្រោយពីការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យមិនខុសទេ ហើយការប្រើពាក្យជនត្រូវចោទក្នុងដីកាដំណោះស្រាយនេះក៏មិនមានអ្វីខុសឆ្គងដែរ ។ ជនត្រូវចោទ គឺមានឋានៈចាប់ពីមានដីកាបញ្ជូនរឿងឱ្យស៊ើបសួររបស់សហព្រះរាជអាជ្ញា ដោយឡែក ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ គឺជានីតិវិធីដើម្បីជនត្រូវចោទមានសិទ្ធិដឹងនិងពឹងពាក់មេធាវី ការពារតទល់នឹងអង្គហេតុដែល សហព្រះរាជអាជ្ញាបានប្ដឹង និងជូនដំណឹងដោយ សហចៅក្រមស៊ើបអង្កេត ។

៦ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ សហចៅក្រមស៊ើបអង្កេត បានប្រកាសបិទការស៊ើបអង្កេត ហើយក្នុង *បំណងពន្លឿននីតិវិធី* នៅថ្ងៃតែមួយបានសម្រេចបំបែកនីតិវិធី និងបង្កើតសំណុំរឿងថ្មីសម្រាប់ **អោ អាន** ជា"សំណុំរឿងលេខ០០៤/២" ។ ដោយយោងលើ ភាពស្មុគ



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

ស្មាញនៃសំណុំរឿង សហចៅក្រមស៊ើបអង្កេត បានសម្រេចទុកពេលឱ្យមានការស្នើសុំស៊ើបអង្កេតរហូតដល់ ៤៥ (សែសិបប្រាំ) ថ្ងៃ រហូតដល់ការប្រកាសបិទស៊ើបអង្កេតជាលើកទី ២ ក្នុងថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ។ បន្ទាប់មក នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត បានបញ្ជូនសំណុំរឿងទៅឱ្យសហព្រះរាជអាជ្ញាពិនិត្យ ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរក្នុងអំឡុងពេល ៣ (បី) ខែ គិតចាប់ពីថ្ងៃទទួលដីកាបញ្ជូនពីសហ-ចៅក្រមស៊ើបអង្កេត ។ សហព្រះរាជអាជ្ញាជាតិ និងអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានស្ថាពរនៅថ្ងៃទី១៨ ខែសីហា និងថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ រៀង១ខ្លួន ។ ដើម្បីធានានូវគោលការណ៍សមភាពរវាងភាគី (equality of arms) ភាពស្មុគស្មាញនៃសំណុំរឿង បញ្ហានៃការបកប្រែភាសា សហចៅក្រមស៊ើបអង្កេត បានទុកពេលវេលាសមស្របសម្រាប់ **អោ អាន** ឆ្លើយតបនឹង ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជាអាជ្ញា ហើយក្នុងថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ **អោ អាន** បានដាក់ឯកសារឆ្លើយតប ។

៧ គិតពីថ្ងៃបិទការស៊ើបអង្កេត មកដល់ថ្ងៃចេញដីកាដំណោះស្រាយ មានរយៈពេលយូរជាងប្រសិនបើធៀបនឹងសំណុំរឿង០០១ សំណុំរឿង០០២ និង សំណុំរឿង០០៤/១ ។ តែទោះបីជាយ៉ាងនេះក្តី ការសម្រេចថាមានការរំលោភលើសិទ្ធិសេរីភាព **អោ អាន** ក្នុងការទទួលបានការកាត់សេចក្តី ក្នុងពេលសមស្រប ដោយពិចារណាលើតែរយៈពេលតែមួយមុខពិតជាមិនសមស្របទេ ។ បុគ្គលិករបស់សហចៅក្រមស៊ើបអង្កេតជាតិ មានតែម្នាក់គត់ទទួលបន្ទុកសំណុំរឿង **អោ អាន** ប្រសិនបើធៀបនឹងសំណុំរឿងលេខ០០១ ទាក់ទិននឹង កាំង ហ្កេកអ៊ាវ ហៅ ឌុច ដែលមានមន្ត្រីទទួលបន្ទុកស្ទើរមួយការិយាល័យ ។ សំណុំរឿងលេខ០០៤/២ ជាសំណុំរឿងធំមានទីតាំងបទឧក្រិដ្ឋច្រើន ដែលត្រូវបានចោទ បើធៀបនឹងសំណុំរឿងលេខ០០៤/១ ។ បន្ថែមពីលើនេះ ក្នុងដំណាក់កាលនៃនីតិវិធី មានបណ្តឹង ឬញត្តិជាច្រើនរបស់ភាគីទៅអង្គបុរេជំនុំជម្រះ ដែលការវិនិច្ឆ័យទាំងនោះ ត្រូវបានធ្វើឡើងតាមកាលបរិច្ឆេទ កំណត់ទុកពេលវេលាជូនភាគីដើម្បីអាចតបឆ្លើយ និងធានានូវសមភាពតម្លាភាពនៃនីតិវិធី ។ ការកំណត់ពេលវេលាចែងក្នុងវិធានផ្ទៃក្នុង ការរង់ចាំលទ្ធផលសម្រេចរបស់ផ្នែកផ្សេងៗរាប់ទាំងការបកប្រែ បានប៉ះពាល់ដល់ដំណើរការ ឬ នីតិវិធីបន្ទាប់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេត ។ ជាការឆ្លើយតបសហចៅក្រម-ស៊ើបអង្កេត (*Motu proprio*) បានបន្តសកម្មភាពដោយគ្មានការរង់ចាំ ហើយលទ្ធផលយ៉ាងណា នឹងពិនិត្យកែតម្រូវខ្លឹមសារឯកសាររបស់ខ្លួនតាមជាក្រោយ ។ ជាក់ស្តែង

01581325



ក្នុងការរង់ចាំសេចក្តីសម្រេច របស់អង្គបុរេជំនុំជម្រះស្តីពីបណ្តឹងសុំមោឃភាព ភ័ស្តុតាង ទទួលបានតាមរយៈអំពើទារុណកម្ម សហចៅក្រមស៊ើបអង្កេត បានសម្រេចបន្តការងារសរសេរ ដីកាដំណោះស្រាយដោយមិនចាំបាច់រង់ចាំសេចក្តីសម្រេចទេ ។[17]

៨ សហចៅក្រមស៊ើបអង្កេត នឹងមិនឆ្លើយតបដល់ការរិះគន់ អំពីការយឺតយ៉ាវនៃនីតិវិធីទេ ប៉ុន្តែ ការវាយតម្លៃការយឺតយ៉ាវត្រូវធ្វើឡើង ប្រកបដោយវិជ្ជាជីវៈ សុចរិត និងស្មោះត្រង់ លុះត្រាណា ការពិនិត្យវាយតម្លៃលើគ្រប់ទិដ្ឋភាពទាំងអស់នៃនីតិវិធី រាប់តាំងពីដំណាក់កាលដើមដំបូងនៃការងាររបស់ការិយាល័យសហព្រះរាជអាជ្ញា មេធាវី ប្រព័ន្ធរដ្ឋបាល រួមទាំងការងាររបស់អង្គបុរេជំនុំជម្រះផងដែរ ទើបជាការវាយតម្លៃត្រឹមត្រូវសត្យានុម័ត ។

៩ ដូចដែលមាន បង្ហាញជូនខាងក្រោមផ្នែក V សហចៅក្រមស៊ើបអង្កេតជាតិ ពិចារណាថា មិនមានការខុសឆ្គងអ្វីទេ ក្នុងការបរិយាយអំពីប្រភេទនៃភ័ស្តុតាង និងតម្លៃនៃភ័ស្តុតាងនៅក្នុងដីកាដំណោះស្រាយនេះ ។ មាត្រា ៣២១ (ការវាយតំលៃលើភ័ស្តុតាងដោយតុលាការ) នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ និង គោលការណ៍ទទួលភ័ស្តុតាងដោយសេរីនៃប្រព័ន្ធច្បាប់ស៊ីវិលឡូមិនហាមឃាត់ទេ ។ ជាការអនុវត្តន៍ជាក់ស្តែង និង សមហេតុផល វាពិតជាមានភាពខុសគ្នារវាងប្រភេទនៃភ័ស្តុតាង (ភ័ស្តុតាងផ្ទាល់ និង ភ័ស្តុតាងមិនផ្ទាល់) ឧទាហរណ៍ រវាងភ័ស្តុតាងឮតាមគ្នា (Hearsay evidence) និង សក្ខីកម្មសាក្សីដែលបានឃើញព្រឹត្តិការណ៍ផ្ទាល់ ។ អ្វីជាសំខាន់គឺការពិចារណានូវភ័ស្តុតាងជាក់ស្តែង តាមវិធានកំណត់គឺភាពជាប់ពាក់ព័ន្ធ ភាពស្របច្បាប់ និង ភាពសត្យានុម័តនៃភ័ស្តុតាង ។

១០ ពាក់ព័ន្ធនឹងភ័ស្តុតាងត្រូវបានចោទថា ទទួលបានតាមរយៈអំពើទារុណកម្ម សហចៅក្រមស៊ើបអង្កេតជាតិ មានឆន្ទានុសិទ្ធិក្នុងការកំណត់វាយតម្លៃភ័ស្តុតាង ដែលប្រមូលបានដោយផ្អែកលើលក្ខណៈសម្បត្តិភ័ស្តុតាង ភាពជាប់ពាក់ព័ន្ធ ភាពស្របច្បាប់ និង ភាពសត្យានុម័ត ដោយពិចារណាលើ សេចក្តីសម្រេចកន្លងមករបស់អង្គជំនុំជម្រះសាលាដំបូង[18] អង្គជំនុំជម្រះតុលាការកំពូល[19] ដើម្បីដំណើរការនេះអាចប្រព្រឹត្តិទៅលឿនដោយមិនចាំបាច់ប្តឹងទៅអង្គបុរេជំនុំជម្រះទេ ។ ទោះបីជាយ៉ាងនេះក្តី ការខិតខំបែបនេះ ក៏អង្គបុរេជំនុំជម្រះនៅមានយោបល់ថា សហចៅក្រមស៊ើបអង្កេត មានភាពយឺតយ៉ាវទៀតផង ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(០)២៣ ២១៩៨៤១ ។

01581326



## ខ. ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

១១ បន្ទាប់ពីមាន សំណើសុំជំនួយជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជា នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧[20] កិច្ចព្រមព្រៀងមួយត្រូវបានចុះហត្ថលេខានាថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជានិងច្បាប់អន្តរជាតិ ដែលប្រព្រឹត្តឡើងក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ (“កិច្ចព្រមព្រៀងស្តីពី “ការបង្កើត អ.វ.ត.ក”)[21] ។

១២ ជាក់ស្តែង អ.វ.ត.ក ត្រូវបានបង្កើតឡើងជាផ្លូវការ នាថ្ងៃទី០៣ ខែកក្កដា ឆ្នាំ២០០៦ ក្នុងប្រព័ន្ធច្បាប់កម្ពុជា បន្ទាប់ពីមានការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ ។[22]

## គ. អនិយ័តភាពនៃនីតិវិធីលើការស៊ើបអង្កេតបឋម

១៣ ទោះបីជា បញ្ហាខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាទាំងពីរ ត្រូវបានដោះស្រាយដោយ អ.ប.ជ ហើយ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ មានសុពលភាពរួចហើយក្តី ស.ច.ស.ជ ពិចារណាថា វាជាការចាំបាច់ក្នុងការបង្ហាញ ដោយសង្ខេបនូវសារៈសំខាន់នៃបញ្ហានេះ ។

១៤ ស.ព.អ បានបើកការស៊ើបអង្កេតបឋមដោយឯកឯង ខណៈបរិបទច្បាប់នៅ អ.វ.ត.ក គោលការណ៍ “សហ” ត្រូវបានក្លាយជាចំណងតាមផ្លូវច្បាប់ជាល័ក្ខខ័ណ្ឌកំណត់ ទោះបីជាស្ថិតក្នុងដំណាក់កាល ស.ព ក៏ដោយ ស.ព ត្រូវតែធ្វើការរួមគ្នា ។ គោលការណ៍នេះតម្រូវជាចាំបាច់ ឱ្យគោរពនូវវិធានបញ្ញត្តិតាមច្បាប់ជាធរមានទាំងឡាយ ដូចមានក្នុងកិច្ចព្រមព្រៀង និងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ជាអាទិ៍ ។ ផ្ទុយទៅវិញ ស.ព.អ បានធ្វើការស៊ើបអង្កេតបឋមតែម្នាក់ឯង ដោយប្រមែប្រមូលនូវឯកសារ និងធ្វើការសម្ភាសន៍



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

01581327



ផ្សេងៗដោយគ្មានការចូលរួមពី ស.ព.ជ និង មិនឆ្លងកាត់តាមនីតិវិធីនៃការខ្វែងយោបល់ឡើយ ។ មូលហេតុទាំងនេះ មិនទាន់ពិចារណាដល់ កំណត់ហេតុនៃការសួរយកចម្លើយទាំងនោះ ដោយគ្មានហត្ថលេខារបស់សហព្រះរាជអាជ្ញា និងជនដែលត្រូវបានសួរយកចម្លើយថែមទៀត ។

១៥ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរជាអត្តនោម័តតែម្នាក់ឯង ក្នុងក្របខ័ណ្ឌនៃសំណុំរឿងនេះដោយបានចោទ **អោ អាន** ឲ្យទទួលខុសត្រូវ ចំពោះឧក្រិដ្ឋកម្មដែលស្ថិតក្រោមយុត្តាធិការ អ.វ.ត.ក ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរនេះ មិនត្រូវបានចាត់ការដោយ ស.ច.ស ភ្លាមទេ ដោយហេតុថាទន្ទឹមគ្នានោះ ស.ព.ជ បានប្ដឹងជំទាស់ឲ្យពិចារណាលើបញ្ហានៃការខ្វែងយោបល់ ដែលជាកម្មវត្ថុនឹងត្រូវបានបញ្ជូនទៅ អ.ប.ជ ។ ជាលទ្ធផល អ.ប.ជ រកសម្លេងមិនបានដែលការណ៍នេះជាផល-វិបាកផ្នែកគតិយុត្តក្នុងបរិបទ អ.វ.ត.ក ដែលនាំឲ្យដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមានអានុភាពគតិយុត្តកើតឡើង ។ បន្ទាប់មក ស.ព.អ ស្ដីទី បានបញ្ជូនដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមក ស.ច.ស សុំឲ្យបំពេញកិច្ចស៊ើបសួរទៅលើអង្គហេតុក្នុងសំណុំរឿងលេខ០០៤ ហើយក្រោយមកត្រូវបានបំបែកជា សំណុំរឿងលេខ០០៤/២ ។

១៦ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ស.ច.ស.អ បានធ្វើនីតិវិធីនៃការបង្ហាញខ្លួនលើកដំបូងដោយដាក់ **អោ អាន** ឲ្យស្ថិតនៅក្រោមការពិនិត្យ ប៉ុន្តែ ចំណាត់ការនៃកិច្ចនីតិវិធីនេះត្រូវបានរងនូវការខ្វែងយោបល់ពីសំណាក់ ស.ច.ស.ជ ដោយផ្អែកលើវិធាន ៧២ ចំណុចទី ១ នៃវិធានផ្ទៃក្នុង ។[23]

១៧ ស.ច.ស.ជ មិនបានឯកភាពនូវការសម្រេចដាក់ **អោ អាន** ឲ្យស្ថិតនៅក្រោមការពិនិត្យទេ ពីព្រោះថា ស.ច.ស.ជ នៅតែយល់ឃើញថា បើតាមលទ្ធផលដែលទទួលបានពីការស៊ើបសួរនៅតែមានវិមតិសង្ស័យលើឈ្មោះ **អោ អាន** ពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គល ដើម្បីដាក់ឈ្មោះនេះឲ្យស្ថិតនៅក្រោមការពិនិត្យ ។ បញ្ហាយុត្តាធិការបុគ្គលលើ **អោ អាន** ជាបញ្ហាអាទិភាពបំផុតមួយ ដែលជាកម្មវត្ថុនៃការពិចារណាមុននឹងចំណាត់ការលើកិច្ចផ្សេងៗទៀត សម្រាប់បរិបទច្បាប់នៅ អ.វ.ត.ក ជាយុត្តាធិការជ្រើសរើស ។



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581328



## ឃ. ការរំលឹកឡើងវិញពីនីតិវិធី

១៨ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ស.ព.អ ស្តីទី បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ ។[24]

១៩ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៨ មានកំណត់ត្រាខ្វែងយោបល់រវាង ស.ព លើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ ហើយបញ្ហាខ្វែងយោបល់នេះ ត្រូវបានដាក់ប្តឹងទៅ អ.ប.ជ ។

២០ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ អ.ប.ជ បានប្រកាសថា ដោយមិនបានទទួលមតិភាគច្រើនដាច់ខាត ហេតុដូច្នេះ កិច្ចរបស់ ស.ព.អ ត្រូវតែយកទៅអនុវត្ត ។[25]

២១ នៅថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ស.ព.អ ស្តីទី បានជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣ និង ស្នើឲ្យ ស.ច.ស ចាប់ផ្តើមបើកកិច្ចស៊ើបសួរ ។[26]

២២ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ស.ច.ស បានចុះកំណត់ត្រាខ្វែងយោបល់អំពីរបៀបនិងវិធីសាស្ត្រនៃការស៊ើបអង្កេត ។ ស.ច.ស.ជ បានអះអាង អំពីភាពមិនចាំបាច់ក្នុងការចុះស៊ើបអង្កេត ហើយបានផ្តោតលើតែការពិនិត្យឯកសារដែលមានស្រាប់ក្នុងសំណុំរឿង ។[27]

២៣ នៅថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ស.ច.ស.អ Marcel LEMONDE បានចេញនូវដីកាចាត់ឲ្យស៊ើបសួរជំនួស ។[28]

២៤ នៅថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១០ ចៅក្រម Marcel LEMONDE បានលាលែងពីមុខតំណែងដោយមូលហេតុផ្ទាល់ខ្លួន ។

២៥ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ ស.ច.ស.អ Siegfried BLUNK បានចាប់ផ្តើមចូលបំពេញការងារជាផ្លូវការ ។[29]

២៦ នៅថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១ ក.ស.ច.ស ចេញសេចក្តីប្រកាសព័ត៌មាន ដោយបានបង្កើតឱ្យមានក្រុមការងាររួមជាច្រើនក្រុម ដើម្បីធ្វើការពិនិត្យ និងវិភាគលើឯកសារនានាក្នុងសំណុំរឿង ជាពិសេសឯកសារដែលមានក្នុងសំណុំរឿងលេខ០០១ និងសំណុំរឿងលេខ០០២ ។[30]

២៧ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ។[31]

២៨ នៅថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ស.ព.អ ដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ០០៤ នៅភូមិភាគកណ្តាល និង ការទទួលខុសត្រូវរបស់ជនសង្ស័យឈ្មោះ **តា អាន** ។[32]

២៩ នៅថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ស.ច.ស បានចេញដីកាសម្រេចស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹង ទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដោយបានសម្រេច បង្គាប់សហព្រះរាជអាជ្ញាឱ្យធ្វើការបង្ហាញក្នុងរយៈពេល ២ (ពីរ) ថ្ងៃ នៃថ្ងៃធ្វើការអំពីពេលវេលាដែលកំណត់ហេតុនៃការខ្វែងយោបល់ត្រូវបានធ្វើ ។[33]

៣០ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានដាក់ចម្លើយតបទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ទាក់ទងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយបានបញ្ជាក់ថា ការខ្វែងយោបល់ត្រូវបានចុះកំណត់ហេតុ នៅមុនការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ។[34]

៣១ នៅថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ស.ច.ស បានចេញសេចក្តីសម្រេចស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដោយសម្រេច បដិសេធដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ដោយហេតុថា ដីកានោះបានធ្វើឡើងដោយគ្មានសុពលភាព ។[35]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581330



៣២ នៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម ដោយបានបញ្ជាក់ថា កំណត់ហេតុនៃការខ្វែងយោបល់រវាងសហព្រះរាជអាជ្ញាត្រូវបានដាក់ក្នុងសំណុំឯកសារនៃការខ្វែងយោបល់ ដែលបានរក្សាទុកដោយក្រឡាបញ្ជីរបស់សហព្រះរាជអាជ្ញានៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ។[36]

៣៣ នៅថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១១ ស.ច.ស បានចេញសេចក្តីប្រកាសព័ត៌មានទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណីថា មិនធ្វើការជូនដំណឹងដល់សាធារណជន អំពីទីតាំងឧក្រិដ្ឋកម្មនៅក្នុងសំណុំរឿង០០៤ ទេ ។ ដោយហេតុថា មានវិមតិសង្ស័យថា តើជនសង្ស័យនៅក្នុងសំណុំរឿងនេះស្ថិតនៅក្នុងប្រភេទអ្នកទទួលខុសត្រូវខ្ពស់បំផុត ឬ យ៉ាងណា ? ។ [37]

៣៤ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ Siegfried BLUNK បានលាលែងចេញពីតំណែង ។ [38]

៣៥ នៅថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១១ ដដែល ក្រោយពីការលាឈប់របស់ចៅក្រម Siegfried BLUNK សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង (ស.ច.ស.អ.ប) Laurent Kasper-Ansermet ដែលមិនទាន់ត្រូវបានតែងតាំងជាផ្លូវការជា ស.ច.ស.អ បានចាប់ផ្តើមសកម្មភាពការងារពីចម្ងាយ ។

៣៦ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១១ ស.ច.ស.អ.ប Laurent Kasper-Ansermet បានមកដល់ អ.វ.ត.ក និង បានបំពេញកិច្ចមួយចំនួនតែម្នាក់ឯងលើការងារផ្សេងៗដូចជា ការស៊ើបសួរ ការសាកសួរសាក្សី ជាអាទិ៍ ។

៣៧ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ស.ច.ស.អ.ប Laurent Kasper-Ansermet ចេញសេចក្តីប្រកាសព័ត៌មានថា នឹងចាត់ចែងធ្វើកិច្ចស៊ើបសួរ ព្រមទាំងចាត់វាល់វិធានការចាំបាច់នានាដើម្បីគ្រប់គ្រងការិយាល័យរបស់ខ្លួន ហើយនឹងព្យាយាមផ្តល់ព័ត៌មានទៅសាធារណជនឱ្យគ្រប់គ្រាន់ អំពីការវិវឌ្ឍន៍សំខាន់ៗនៅក្នុងសំណុំរឿងលេខ០០៤ ។[39]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៣៨ នៅថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ដដែល ស.ច.ស.ជ បានចេញនូវសេចក្ដីប្រកាសព័ត៌មានថា ស.ច.ស.អ.ប មិនទាន់ត្រូវបានតែងតាំងជាផ្លូវការឡើយ ។ ហេតុដូច្នេះ ស.ច.ស.ជ មិនទទួលស្គាល់តាមផ្លូវច្បាប់ នូវរាល់កិច្ចទាំងឡាយណាដែលបានធ្វើឡើងដោយ ស.ច.ស.អ.ប Laurent Kasper-Ansermet ឡើយ ។[40]

៣៩ នៅថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ.ប Laurent Kasper-Ansermet បានចេញសេចក្ដីជូនដំណឹង អំពីសិទ្ធិរបស់ជនសង្ស័យ ឌឹម អាន ហៅ **តា អាន** ។[41]

៤០ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ ស.ច.ស.អ.ប Laurent Kasper-Ansermet បានផ្ដល់ព័ត៌មានដោយផ្ទាល់ដល់ជនសង្ស័យ **អោ អាន** ថា គាត់ជាជនសង្ស័យម្នាក់នៅក្នុងកិច្ចស៊ើបសួរ ហើយអនុញ្ញាតឱ្យ **អោ អាន** អាចចូលពិនិត្យមើលសំណុំរឿងបាន ។ ជាក់ស្ដែង ជនសង្ស័យមិនត្រូវបានអនុញ្ញាតឱ្យមើលសំណុំរឿងទេ ។

៤១ នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១២ អ.វ.ត.ក ចេញសេចក្ដីប្រកាសព័ត៌មានថា ស.ច.ស.អ.ប Laurent Kasper-Ansermet បានដាក់លិខិតលាលែង ដែលនឹងត្រូវមានសុពលភាពគិតចាប់តាំងពីថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ ។[42]

៤២ នៅថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១២ ស.ច.ស.អ.ប Laurent Kasper-Ansermet បានលាលែងជាផ្លូវការរបស់ពី អ.វ.ត.ក ។[43]

៤៣ នៅថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១២ ឧត្ដមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជា បានតែងតាំង លោកចៅក្រម Mark B. HARMON ជា ស.ច.ស.អ ។[44]

៤៤ នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១២ ចៅក្រម Mark B. HARMON បានចាប់ផ្ដើមបំពេញការងារ ។

៤៥ នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ ស.ច.ស បានធ្វើការខ្វែងយោបល់ ទាក់ទិនដីកាចាត់ឱ្យស៊ើបសួរជំនួស និង ការឆ្លើយតបទៅ ស.ព លើសំណើសុំការស៊ើបអង្កេត ។

៤៦ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ ចៅក្រម Mark B. HARMON បានចេញសេចក្តីប្រកាសព័ត៌មាន ដែលទាក់ទងទៅនឹង ទីតាំងឧក្រិដ្ឋកម្មបន្ថែម នៅក្នុងសំណុំរឿងលេខ០០៤ ។

៤៧ នៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៣ ស.ច.ស បានខ្វែងយោបល់ទាក់ទងការផ្តល់លេខក្នុងសំណុំរឿងនេះ ។ ស.ច.ស.ជ ប្រកាន់ជំហរថា ឯកសារដាក់ចូលដោយ ស.ច.ស.អ ត្រូវចុះលេខបន្តពីលេខឯកសារចុងក្រោយដាក់ក្នុងសំណុំរឿង មុនការលាលែងរបស់លោកចៅក្រម Siegfried BLUNK ។ ប៉ុន្តែ បានគូសបញ្ជាក់ផងដែរថា ការចុះលេខសំណុំរឿងនេះមិនមានអានុភាពគតិយុត្តអ្វីឡើយ ។ ខណៈ ស.ច.ស.អ ថា លេខឯកសារសំណុំរឿងត្រូវបន្តពីលេខឯកសារដាក់ចូលដោយ ស.ច.ស.អ.ប Laurent Kasper-Ansermet ។

៤៨ នៅថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ស.ព.អ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ អំពើហិង្សាយេនឌ័រ ។[45]

៤៩ នៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៤ ស.ច.ស ខ្វែងយោបល់លើការសួរតទល់គ្នារវាងសាក្សី ។ ស.ច.ស.ជ យល់ថា ការស៊ើបសួរក្នុងគោលបំណងកំណត់នូវយុត្តាធិការបុគ្គល ខណៈដែលដំណាក់កាលនៃនីតិវិធីបែបនេះ មិនមានភាពចាំបាច់សម្រាប់រៀបចំឱ្យមានការតទល់គ្នារវាងសាក្សី និង/ឬ ដើមបណ្តឹងរដ្ឋប្បវេណី ឡើយ ។

៥០ នៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០១៥ ស.ច.ស បានខ្វែងយោបល់ ពីការជូនដំណឹងពីបទចោទទៅ **អោ អាន** ដោយ ស.ច.ស.ជ យល់ថា ការស៊ើបសួរក្នុងគោលបំណងកំណត់នូវយុត្តាធិការបុគ្គល ហើយតាមរយៈបច្ចុប្បន្នភាពនៃការស៊ើបសួរ នៅមានវិមតិសង្ស័យថា **អោ អាន** នេះស្ថិត ឬមិនស្ថិតនៅក្នុងយុត្តាធិការបុគ្គលនៃ អ.វ.ត.ក ។

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១ ។

៥១ នៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ស.ច.ស.អ Mark B. Harmon បានចេញដីកាកោះហៅ **អោ អាន** ឱ្យចូលមកបង្ហាញខ្លួនជាលើកដំបូង ។

៥២ នៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ក្រោយពី ស.ច.ស បានខ្វែងយោបល់ពីការជូនដំណឹងអំពីបទចោទ ចៅក្រម Mark Harmon បានរៀបចំនីតិវិធីបង្ហាញខ្លួនលើកដំបូង និងបានជូនដំណឹងដល់ **អោ អាន** ថា គាត់ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យដោយ ស.ច.ស.អ ។

៥៣ នៅថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៥ ស.ច.ស.អ Mark Harmon បានដាក់សំណើសុំលាលែងពីតំណែងក្រោមហេតុផលផ្ទាល់ខ្លួន ។[46]

៥៤ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៥ លោកចៅក្រម Michael BOHLANDER ត្រូវបានតែងតាំងជា ស.ច.ស.អ ។

៥៥ នៅថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១៥ អ.វ.ត.ក ចេញសេចក្តីប្រកាសព័ត៌មានថា ចៅក្រម Michael BOHLANDER ត្រូវបានឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាបានតែងតាំងជា ស.ច.ស.អ ជំនួសចៅក្រម Mark Harmon ។[47]

៥៦ នៅថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៦ ចៅក្រម Michael BOHLANDER បានចេញដីកាកោះឱ្យ **អោ អាន** បង្ហាញខ្លួនម្តងទៀតនៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ វេលាម៉ោង ១០ ព្រឹក ។[48]

៥៧ នៅថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ ចៅក្រម Michael BOHLANDER បានធ្វើការជូនដំណឹងពីការចោទប្រកាន់បន្ថែម ទាក់ទិននឹងតំណែងគាត់ជាអនុលេខាភូមិភាគកណ្តាល(ឧត្តរចាស់) សមាជិកនៃគណៈភូមិភាគកណ្តាល (ឧត្តរចាស់) និងលេខាតំបន់ ៤១ នៅភូមិភាគកណ្តាល (ឧត្តរចាស់) ពីបទអំពើប្រល័យពូជសាសន៍ និង អំពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។[49]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO. JUGES D'INSTRUCTION

៥៨ នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ ស.ច.ស.អ បានចេញសេចក្ដីជូនដំណឹង យោងតាមវិធានផ្ទៃក្នុង ៦៦ ស្ទួន (២) ដោយបានបញ្ជាក់ពី គោលបំណងក្នុងការកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ ។[50]

៥៩ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស.ច.ស.អ បានចេញដីកាសម្រេចកាត់បន្ថយវិសាលភាពនៃកិច្ចស៊ើបសួរ៖ មន្ទីរសន្តិសុខទួលតាផ្លុង, មន្ទីរសន្តិសុខវត្តកណ្តាល, មន្ទីរសន្តិសុខចំការស្វាយចន្ទី, មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, មន្ទីរសន្តិសុខវត្តស្រងែ, ការចាប់ខ្លួននិងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា, ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញដី, និងការដាក់ក្នុងមន្ទីរឃុំឃាំង និង ការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស ។[51]

៦០ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស.ច.ស បានចេញសេចក្ដីជូនដំណឹង អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន** ។[52]

៦១ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ស.ច.ស បានចេញដីកាសម្រេចបំបែកនីតិវិធី **អោ អាន** ចេញពីសំណុំរឿងលេខ០០៤ ទៅជា "**សំណុំរឿងលេខ០០៤/២**" ។[53]

៦២ នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ស.ច.ស បានចេញសេចក្ដីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន** ដោយថា កិច្ចស៊ើបសួរប្រឆាំង **អោ អាន** បានបញ្ចប់ហើយតាមវិធានផ្ទៃក្នុង មិនតម្រូវឱ្យទុកពេលសម្រាប់កិច្ចស៊ើបសួរបន្ថែមទៀត ហេតុនេះមិនផ្តល់ជូនពេលវេលាបន្ថែមទៀតទេ ។[54]

៦៣ នៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ស.ច.ស បានចេញដីកាបញ្ជូនសំណុំរឿងទៅពិនិត្យអនុលោមតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង ដោយបញ្ជូនសំណុំរឿងលេខ០០៤/២ ដែលស្ថិតក្រោមការស៊ើបសួរជូនទៅ ស.ព ដើម្បីចេញដីកាសន្និដ្ឋានស្ថាពរ ដោយមានរយៈពេល ៣ (បី) ខែ ចាប់ពីពេលជូនដំណឹងនេះ ។[55]

01581335



៦៤ នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ស.ព.ជ បានចេញដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី **អោ អាន** អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ដោយស្នើឱ្យ ស.ច.ស សម្រេចលើកលែងចោទប្រកាន់ប្រឆាំង **អោ អាន** តាមវិធាន ៦៧ (៣) (ក) នៃវិធានផ្ទៃក្នុង ។[56]

៦៥ នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ស.ព.អ បានចេញដីកាសន្និដ្ឋានស្ថាពរ ដោយស្នើសុំ ស.ច.ស ចោទប្រកាន់ **អោ អាន** និងបញ្ជូនគាត់ទៅជំនុំជម្រះ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ។[57]

៦៦ នៅថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ សហមេធាវីការពារក្តីឱ្យ **អោ អាន** បានដាក់ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព ដោយស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតលើកលែងការចោទប្រកាន់លើ **អោ អាន** ។[58]

## ខ. អនិយ័តភាពនៃកិច្ចដែលបំពេញដោយ ស.ច.ស.អ.ប

៦៧ បន្ទាប់ពីមានការលាឈប់ជាផ្លូវការរបស់ចៅក្រម Siegfried BLUNK ស.ច.ស.អ.ប Laurent Kasper-Ansermet មិនទាន់ទាំងបានមកដល់ អ.វ.ត.ក ភ្លាមទេ ហើយបានចាប់ផ្តើមធ្វើការងារពីកន្លែងការងារចាស់របស់គាត់ តាមប្រព័ន្ធអ៊ីនធើណិតជាស្រេច ។ ពេលមកដល់ អ.វ.ត.ក គាត់ចាប់ផ្តើមការងារមួយចំនួន ដោយគ្មានពិភាក្សាជាមួយ ស.ច.ស.ជ ។ នេះខុសនឹងខ្លឹមសារកិច្ចព្រមព្រៀងដែលចែងអំពីកិច្ចសហការរវាង ស.ច.ស ។ ស.ច.ស.ជ បានស្នើឱ្យមានការរង់ចាំជាបណ្តោះអាសន្ននូវការតែងតាំងដោយ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនៃព្រះរាជាណាចក្រកម្ពុជាជូន ស.ច.ស.អ.ប ឱ្យក្លាយខ្លួនជា ស.ច.ស.អ ពេញសិទ្ធិសិន ។ [59]

៦៨ ទោះបីជាយ៉ាងនេះក្តី ស.ច.ស.អ.ប Laurent Kasper-Ansermet បានបន្តបំពេញកិច្ចស៊ើបសួរមួយចំនួនដូចជា ការជូនដំណឹងបទចោទដល់ជនសង្ស័យ ការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ និង ចំណាត់ការកិច្ចផ្សេងៗ ជាអាទិ៍ ។

01581336



៦៩ ជាការអនុវត្តន៍ ស.ច.ស.អ.ប គ្រប់រូបមុននឹងបំពេញការងារ ត្រូវទទួលការតែងតាំងជា ស.ច.ស.អ ពេញសិទ្ធិជាមុន ។ ស.ច.ស.ជ បានធ្វើសេចក្តីប្រកាសព័ត៌មានបដិសេធនូវសកម្មភាពការងាររបស់ ស.ច.ស.អ.ប និងអះអាងថា កិច្ចទាំងនោះគ្មានសុពលភាពតាមច្បាប់ទេ ដោយសារវាត្រូវបានធ្វើឡើងនៅខណៈពេលដែល ស.ច.ស.អ.ប មិនទាន់ក្លាយជាចៅក្រមស៊ើបអង្កេតពេញសិទ្ធិ ។ អាស្រ័យហេតុនេះ ស.ច.ស.ជ ទាំងផ្ទាល់មាត់ និងក្នុងកំណត់ត្រាខ្វែងយោបល់ពាក់ព័ន្ធនឹងឯកសារសំណុំរឿង មិនទទួលយកឯកសារបង្កើតដោយ ស.ច.ស.អ.ប ដាក់ក្នុងសំណុំរឿងទេ ហើយការចុះលេខឯកសារនៃសំណុំរឿងលេខ០០៤ ត្រូវរាប់បន្តពីឯកសារចុងក្រោយ មុនការលាលែងរបស់ចៅក្រម Siegfried BLUNK ។ ក្នុងន័យដីកាដំណោះស្រាយនេះ នឹងមិនចាត់ទុកឯកសារបង្កើតឡើងដោយ ស.ច.ស.អ.ប Laurent Kasper-Ansermet មានតម្លៃគតិយុត្តឡើយ ។

## ច. នីតិវិធីនៃការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ

៧០ ផ្អែកលើវិធានផ្ទៃក្នុង ការស៊ើបសួរត្រូវធ្វើឡើងតែលើ អង្គហេតុដែលមានក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ។ ទោះបីជាយ៉ាងនេះ ការសម្រេចបើកការស៊ើបអង្កេតលើបុគ្គលណាមួយជាឆន្ទានុសិទ្ធិរបស់ ស.ច.ស ។ វិធាន ៥៥ (៤) នៃវិធានផ្ទៃក្នុង បានចែងពាក់ព័ន្ធនឹងបញ្ហានេះ *"សហចៅក្រមស៊ើបអង្កេតមានអំណាច បើកការស៊ើបសួរប្រឆាំងនឹងជនទាំងឡាយ ដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ។ សហចៅក្រមស៊ើបអង្កេត អាចបើកកិច្ចស៊ើបសួរផងដែរ ចំពោះបុគ្គលគ្រប់រូប ដែលមានតម្រុយច្បាស់លាស់ និងស៊ីសង្វាក់ដែលបញ្ជាក់ថា បុគ្គលនោះអាចជាអ្នកទទួលខុសត្រូវក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម"* ។[60]

៧១ ក្រោយពីទទួលបាន ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ សហចៅក្រមស៊ើបអង្កេតអាចធ្វើការអង្កេតនិងមិនទាន់ដាក់ជនណាមួយក្រោមការពិនិត្យភ្លាមទេ ។ ជនត្រូវចោទអាចត្រូវបានហៅមកឆ្លើយ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត ។ ក្នុងដំណាក់កាលនេះ សហចៅក្រមស៊ើបអង្កេតអាច សម្រេចលើកលែងការចោទប្រកាន់ ។ ជាគោលការណ៍ ចៅក្រមស៊ើបអង្កេតនឹងមិនបញ្ជូនទៅជំនុំជម្រះទេ ប្រសិនបើមិនបានដាក់ឲ្យស្ថិតក្រោមការពិនិត្យជា



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

01581337



មុន ដោយសារ ជនត្រូវចោទមិនទាន់ត្រូវបានជូនដំណឹងជាមុន អំពីបទចោទប្រកាន់ ដែលនាំឱ្យសាមីជនត្រូវចោទមានពេលវេលា និង ពិចារណានូវមធ្យោបាយការពារខ្លួន ដើម្បីឆ្លើយតបចំពោះបទចោទ ។ ការបញ្ជូនទៅជម្រះក្នុងករណីនេះ នឹងនាំឱ្យមានការរំលោភសិទ្ធិទទួលការកាត់សេចក្តីដោយយុត្តិធម៌ ។

៧២ ទោះបីជាវិធាន ៥៥ នៃវិធានផ្ទៃក្នុង បានចែងតម្រូវកម្រិតភ័ស្តុតាង "តម្រុយច្បាស់លាស់និងស៊ីសង្វាក់" សម្រាប់ករណីដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ លើបុគ្គលដែលគ្មានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ក្តីក៏កន្លងមកសហចៅក្រមស៊ើបអង្កេត បានប្រើប្រាស់កម្រិតភ័ស្តុតាងនេះ ដើម្បីដាក់ជនត្រូវចោទដែលមានឈ្មោះក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ឱ្យស្ថិតនៅក្រោមការពិនិត្យ ។ កម្រិតភ័ស្តុតាងនេះ មិនខ្ពស់ដូចជាកម្រិតភ័ស្តុតាងសម្រាប់ដាក់ពិរុទ្ធភាព (ហួសពីវិមតិសង្ស័យ) ដែលសហព្រះរាជអាជ្ញាត្រូវបង្ហាញទេ ។[61] ក៏ប៉ុន្តែកម្រិតភ័ស្តុតាងនេះក៏មិនទាបដែរ ដោយវាតម្រូវឱ្យមានភ័ស្តុតាងច្រើនច្បាស់-លាស់និងគាំទ្រគ្នាទៅវិញទៅមក ដើម្បីបង្ហាញថា ជនត្រូវចោទជាជនទទួលខុសត្រូវក្នុងការប្រព្រឹត្តព្រមទាំងមានភាពប្រាកដប្រជាខ្ពស់ថា បុគ្គលណាមួយនោះទទួលខុសត្រូវហើយនឹងត្រូវបញ្ជូនទៅជំនុំជម្រះសេចក្តីនាពេលអនាគត ។[62]

៧៣ អ.វ.ត.ក ត្រូវបានបង្កើតឡើងតាមរយៈកិច្ចព្រមព្រៀងរវាង រាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ។ អ.វ.ត.ក ជាតុលាការពិសេសហើយអនុលោមតាមគោលបំណងរបស់ អ.វ.ត.ក មានតែបុគ្គលពីរប្រភេទដែលស្ថិតក្នុងយុត្តាធិការ ។ អាស្រ័យហេតុនេះខុសពីតុលាការជាតិ ស.ច.ស ត្រូវគិតជាបឋមសិនថា តើបុគ្គលមានឈ្មោះក្នុងដីកា សន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរជាជនស្ថិតក្នុងសមត្ថកិច្ចរបស់ អ.វ.ត.ក ដែរឬទេ? មុននឹងសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ។ ស.ច.ស ត្រូវពិចារណាឱ្យបានហ្មត់ចត់ និង ពេញលេញមុនសម្រេចដាក់បុគ្គលណាមួយស្ថិតនៅក្រោមការពិនិត្យ ។ ក្នុងន័យនេះ ស.ច.ស ដូចដែលបាននិយាយពីខាងដើមមានឆន្ទានុសិទ្ធិក្នុងការសម្រេច ដោយអនុលោមតាមគោលការណ៍ឯករាជ្យភាព[63] និង មិនតម្រូវឱ្យសម្រេចភ្លាមៗនោះទេ នូវការដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ។ ការសម្រេចយ៉ាងណា ត្រូវឈរលើកម្រិតនៃភ័ស្តុតាង ដូចមានចែងក្នុងវិធាន ៥៥ ។



*E.C.C.C* C.E.T.C* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581338



នៃវិធានផ្ទៃក្នុង ព្រមទាំងគោរពនូវសិទ្ធិសេរីភាព ផលប្រយោជន៍របស់ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី ផងដែរ ។

៧៤ ចៅក្រមស៊ើបសួរមិនអាចបញ្ជូនជនណាម្នាក់ទៅជំនុំជម្រះ ដោយមិនបានដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យជាមុនឡើយ ។ យុត្តិសាស្ត្ររបស់តុលាការកំពូលបារាំងធ្លាប់បានបញ្ជាក់ដែរថា "ចៅក្រមស៊ើបសួរ មុននឹងចេញដីកាដំណោះស្រាយ ជាការលើកលែងការចោទប្រកាន់ ចៅក្រមស៊ើបសួរពុំចាំបាច់ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ ឬការស្តាប់ចម្លើយជននោះឡើយ ប្រសិនបើចៅក្រមស៊ើបសួរយល់ថាពិរុទ្ធភាពនៃជននោះនឹងមិនត្រូវបានរកឃើញ" ។[64]

៧៥ ចំពោះការសម្រេចដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យ លើជនត្រូវចោទណាម្នាក់ មិនមែនជាកាតព្វកិច្ចចំណងដល់ ស.ច.ស ឱ្យត្រូវតែប្រតិបត្តិតាមជានិច្ចនោះទេ ។ អាស្រ័យហេតុនេះ ដោយឈរលើ គោលការណ៍ឯករាជ្យភាព និងមិនលំអៀង ជាពិសេសគោលការណ៍នៃការសន្មតជាមុនថាគ្មានទោស ដែលការពារដល់សិទ្ធិនិងផលប្រយោជន៍ជនសង្ស័យស្របតាមគោលការណ៍នៃការទទួលបានការជម្រះក្តីដោយយុត្តិធម៌[65] បើទោះបីជា ស.ច.ស បានដាក់ឱ្យស្ថិតក្រោមការពិនិត្យក្តី ស.ច.ស នៅតែអាចលើកលែងការចោទប្រកាន់បាន ប្រសិនបើល័ក្ខខ័ណ្ឌទាំងឡាយមិនត្រូវបានរកឃើញ ដើម្បីបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ។ ការលើកលែងចោទប្រកាន់ អាចធ្វើឡើងចំពោះគ្រប់អង្គហេតុទាំងអស់ ដែលត្រូវបានចោទប្រកាន់ប្រឆាំងនឹងជនត្រូវចោទ ។ បន្ថែមពីលើនេះ ការដាក់បុគ្គលណាមួយឱ្យស្ថិតនៅក្រោមការពិនិត្យក៏មិនតម្រូវឱ្យចៅក្រមឃុំខ្លួនដែរ ប្រសិនការឃុំខ្លួនមិនមែនជាការចាំបាច់ ។

៧៦ ជនត្រូវចោទមានសិទ្ធិចំបងមួយចំនួន ក្នុងដំណើរការសំណុំរឿងក្តីព្រហ្មទណ្ឌដូចជា សិទ្ធិមានមេធាវី ដូចមានចែងក្នុងសេចក្តីប្រកាសជាសកល កតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយមួយចំនួនទៀតដែលកម្ពុជាជាភាគី ។[66] ការមិនដាក់ក្រោមឱ្យស្ថិតនៅក្រោមការពិនិត្យលើបុគ្គលណាមួយ ហើយចុងបញ្ចប់បញ្ជូនគាត់ទៅទទួលជំនុំជម្រះក្តី អាចបំពារបំពានដល់សិទ្ធិទាំងនេះ ដោយសារជនត្រូវចោទមិនមានឱកាសអនុវត្តសិទ្ធិ ជាលទ្ធផលនាំឱ្យសវនាការមិនមានភាពយុត្តិធម៌ទេ ។ ការសម្រេចដាក់ជនត្រូវចោទណាមួយ ឱ្យស្ថិតនៅក្រោមការពិនិត្យ នឹងរុញកិច្ចនៃដំណើរការនីតិវិធីព្រហ្មទណ្ឌឱ្យដើរទៅមុខ ហើយតុលាការនឹងចំណាយ[illegible] ពេលវេលា ព្រមទាំងធនធាន ដើម្បីបំពេញតាមកិច្ចនីតិវិធីតម្រូវដោយច្បាប់ ។ ក្នុងករណីមិន[illegible]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បញ្ចប់ ទោះបីបុគ្គលនោះនឹងត្រូវបានលើកលែងចោទប្រកាន់ ដោយសារតុលាការមិនបានរកឃើញនូវការទទួលខុសត្រូវក្តីក៏តុលាការបានចំណាយពេលវេលា និងធនធានរួចទៅហើយ ។ នេះមិនមែនជាវិធីដ៏ប្រពៃឆ្លើយតបនឹងប្រសិទ្ធភាព និង ការសន្សំសំចៃនៃដំណើរការតុលាការ (*Judicial Economy*) ទេ ។

## II. ការកត់សម្គាល់ឃើញអំពីអង្គហេតុ

### ក. អំពីគោលនយោបាយទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ

៧៧ របបកម្ពុជាប្រជាធិបតេយ្យបានដឹកនាំប្រទេសចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[67] ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ មានគោលដៅកសាងសង្គមកម្ពុជាទាំងមូលទៅជាប្រទេសដើរតាមមាគ៌ាសង្គមនិយមពិតប្រាកដក្នុងលោក ។[68] ដើម្បីសម្រេចគោលដៅនេះ មានការដាក់ចេញនូវនយោបាយនៃការបណ្តេញប្រជាជនចេញពីទីក្រុង និងទីប្រជុំជន ឱ្យទៅនៅតាមទីជនបទ[69] ដើម្បីចូលរួមធ្វើមហាកសិកម្ម[70] ដែលជាវិស័យដ៏សំខាន់បំផុតក្នុងការជួយជម្រុញសេដ្ឋកិច្ចឱ្យរីកចំរើនជាអតិបរមាក្រោមការដឹកនាំ និងណែនាំពីបក្ស[71] តាមគោលជំហរ "**ឯករាជ្យ ម្ចាស់ការ ខ្លួនទីពឹងខ្លួន**" ។[72] ម្យ៉ាងវិញទៀត នៅមានគោលបំណង ដាក់វណ្ណៈជាន់ទាបដែលជាវណ្ណៈកម្មករ កសិករក្រីក្រ ឱ្យធ្វើការត្រួតត្រានៅតាមថ្នាក់មូលដ្ឋានដោយរាប់ចាប់ពីថ្នាក់ភូមិ ។[73]

៧៨ សៀវភៅក្រោមចំណងជើង "*ភូមិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ*" ដែលចេញផ្សាយដោយក្រសួងសិក្សាធិការនៃរបបកម្ពុជាប្រជាធិបតេយ្យនាឆ្នាំ១៩៧៧ បង្ហាញថា ប្រទេសកម្ពុជាមានប្រជាជនសរុបចំនួន ៧.៧០០.០០០ (ប្រាំពីរលានប្រាំពីរសែន) នាក់ ដោយក្នុងនោះ ៨០ ភាគរយ (ប៉ែតសិបភាគរយ) ជាកសិករនៅតាមសហករណ៍និង ២០ ភាគរយ (ម្ភៃភាគរយ) ជាកម្មករ សហជីព និង ជាយុទ្ធជន យុទ្ធនារីនៃកងទ័ពបដិវត្តន៍កម្ពុជា ។[74]

៧៩ ហេតុផលខាងលើ វាបានបង្កឱ្យមានកំហឹងវណ្ណៈ[75] កើតឡើងយ៉ាងសន្ធោសន្ធៅជាប់ជានិច្ចចំពោះវណ្ណៈសក្តិភូមិ[76] វណ្ណៈនាយទុន ដែលជាវណ្ណៈធ្លាប់កាន់អំណាចជិះជាន់ប្រជាជនជាង ២.០០០ (ពីរពាន់) ឆ្នាំ ហើយថែមទាំងរងនូវចោទថា នាពេលកន្លងមកការលក់ប្រទេស[illegible]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01581340



ចក្រពត្តិនិយមបរទេសជាបន្តបន្ទាប់ ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួននិងបក្សពួកយ៉ាងថោកទាបជាទីបំផុត ។[77] ការណ៍នេះបានធ្វើឱ្យក្រុមវណ្ណៈជាន់ទាបនេះ ចង់ក្លាយជាផ្នែកមួយដ៏សំខាន់ក្នុងការចូលរួមកាច់ចង្កូតជោគវាសនាកម្ពុជាទាំងមូល ។[78]

៨០ រចនាសម្ព័ន្ធរដ្ឋបាលក្នុងរបបកម្ពុជាប្រជាធិបតេយ្យចាប់ពី ថ្នាក់លើ ថ្នាក់ក្រោម និងថ្នាក់មូលដ្ឋាន ត្រូវបានបែងចែងយ៉ាងជាក់លាក់ លើការសម្រេចចាត់ចែង និង ការគ្រប់គ្រងការងារដែលមានលក្ខណៈជា "**សមូហភាព**" ។[79] ក្រោមហេតុផលថា ទាល់តែកសាងប្រទេសដោយឈរលើសមូហភាព ទើបអាចកសាងប្រទេសបានរហ័ស ។[80] ម្យ៉ាងវិញទៀតគោលនយោបាយត្រូវបានផ្សព្វផ្សាយយ៉ាងទូលំទូលាយ តាមរយៈការប្រជុំនូវកម្រិតភូមិភាគ តំបន់ ស្រុក ឃុំ ភូមិ និង សហករណ៍ ហើយត្រូវបានបញ្ជូនពីថ្នាក់លើទៅថ្នាក់ក្រោមតាមឋានានុក្រមនៃការដឹកនាំ ។[81]

៨១ ការដឹកនាំតាមបែបកុំម្មុយនីស្ត ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានយកបក្សជាអ្នកមានអំណាចខ្ពស់បំផុត តាមរយៈស្ថាប័នដ៏មានឥទ្ធិពលបំផុត ដែលត្រូវបានគេស្គាល់ឈ្មោះថា "**គណៈកម្មាធិការមជ្ឈិមបក្ស**" ។ គណៈកម្មាធិការនេះ មានសមាជិកប្រមាណ ៣០ (សាបសិប) រូប ត្រូវធ្វើការសម្រេចលើការងារចម្បងសំខាន់ៗ ពាក់ព័ន្ធនឹងជោគវាសនាប្រទេសជាតិ ។[82] ខណៈ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំម្មុយនីស្តកម្ពុជា មានសមាជិកចំនួន ៧ (ប្រាំពីរ) រូបមាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, វន វ៉េត, និង សុន សេន ។[83] ជាក់ស្តែង **អំណាចលើការសម្រេចស្ថិតនៅលើគណៈកម្មាធិការ-អចិន្ត្រៃយ៍**[84] បើទោះបីជា មានការលើកឡើងដោយ អតីតប្រធានគណៈប្រធានរដ្ឋ[85] ខៀវ សំផន ថា ជាគោលការណ៍អង្គការសំខាន់ជាងគេគឺ "គណៈកម្មាធិការមជ្ឈិម"[86] ។

៨២ នៅមុនឆ្នាំ១៩៧៥ បក្សបានតម្រូវឱ្យប្រជាជនរស់នៅជាសហករណ៍ក្នុងតំបន់រំដោះ ដោយឱ្យរស់នៅរួម ធ្វើស្រែរួម ប្រមូលផលរួម រោងបាយរួម ធ្វើការរួម ហើយបក្សជាអ្នកគ្រប់គ្រង និង ប្រមូលភោគផលដែលទទួលបាន ។[87] លើសពីនេះ បក្សនៅបានគ្រប់គ្រងរាល់សកម្មភាពការងារ ការរស់នៅរបស់ប្រជាជន រាប់តាំងពីការស្លៀកពាក់ របៀបនៃការប្រាស្រ័យទាក់ទង ទ្រព្យសម្បត្តិ ពេលវេលា ជំនឿ អាហារ និង ការធ្វើដំណើររបស់ប្រជាជន ជាអាទិ៍ ។[88]



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៨៣ លោក ម៉ាត់ លី បានលើកឡើងថា សហករណ៍ត្រូវបានបង្កើតដំបូងនៅថ្ងៃទី២០ ខែមីនា ឆ្នាំ ១៩៧៣ ហើយប្រជាជនពេញចិត្តណាស់ ។[89] ប៉ុន្តែ ជាក់ស្តែងបក្សបានសម្រេចចាត់តាំងជាសហករណ៍កសិករនៅថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៣ ។[90] ចំពោះការរៀបចំជាសហករណ៍នេះ កសិករដែលគ្មានដីធ្លីមានការពេញចិត្តជាខ្លាំងមែន ផ្ទុយទៅវិញ កសិករដែលមានដីធ្លីច្រើនហាក់ដូចជាមិនសូវពេញចិត្ត ហើយអារម្មណ៍នឿយណាយ ជាមួយនឹងភាពជាសមូហភាពនេះ ។[91]

៨៤ ក្រោយពីរំដោះបាន តាមមូលដ្ឋានមួយចំនួនភ្លាមៗភូមិខ្លះ ត្រូវបានរួមបញ្ចូលគ្នាទៅជា "សហករណ៍"[92] មានលក្ខណៈជាសមូហភាពទាំងលើការហូបចុក[93] និង ការរស់នៅក្រោមហេតុផលថា ភាពជាសមូហភាពជាទស្សនៈទានមនុស្សធម៌ ដោយមនុស្សគ្រប់រូបគួរតែទទួលបានបរិមាណម្ហូបអាហារដូចគ្នាៗ ។[94] ខណៈសហករណ៍ត្រូវគេចាត់ទុកថាជាមូលដ្ឋានបង្អែកបដិវត្តន៍ដ៏រឹងមាំនៅទូទាំងប្រទេស ។[95] ក្រោមការដឹកនាំនេះប្រជាជនទទួលបានអាហារ ២ (ពីរ) ពេលក្នុងមួយថ្ងៃ បបរមួយពេល និង បាយមួយពេល ។[96]

៨៥ មិនតែប៉ុណ្ណោះ នាពេលក្រោយមកបក្សបានកំណត់ទិសដៅបង្កើនទិន្នផលស្រូវ[97] ដោយបក្សជាអង្គការថ្នាក់លើបានបង្ខំឱ្យប្រជាជនធ្វើស្រូវឱ្យបាន **បីតោនក្នុងមួយហិចតា**[98] លើដីស្រែទំហំ ១ លាន ៥ សែន ហិចតា ។ អង្គការរំពឹងថានឹងទទួលបានស្រូវរហូតដល់ ៤ លាន ៥ សែន តោន ដែលជាភារកិច្ចស្នូលមួយនៅឆ្នាំ១៩៧៦ ។[99] សាក្សីជាអតីតអ្នកវាយអង្គុលីលេខបានអះអាងថា "*ឯកសារភាគច្រើននិយាយពីការធ្វើស្រែឱ្យបានបីតោនក្នុងមួយហិចតា*" ។[100] ចំពោះទិន្នផលដែលប្រមូលបានភាគច្រើនបំផុត ត្រូវតែប្រគល់ជូនបក្សជាដាច់ខាត សម្រាប់ធ្វើការនាំចេញក្រៅប្រទេស ។[101] ប្រធានសហករណ៍មួយចំនួនតាមមូលដ្ឋានបានបំប៉ោងតួលេខទិន្នផលដែលទទួលបាន ដើម្បីធ្វើឱ្យបក្សដែលជាអង្គការថ្នាក់លើ មើលឃើញថាខិតខំប្រឹងប្រែងដើម្បីបក្ស និងជាមនុស្សស្មោះត្រង់នឹងបក្ស ដោយបានបញ្ជូនផលស្រូវឱ្យថ្នាក់លើយ៉ាងច្រើន ខណៈប្រជាជននៅមូលដ្ឋានខ្លួន ខ្វះខាតអង្ករទុកបរិភោគ ។[102]



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៨៦ ម្យ៉ាងវិញទៀត នៅមានករណីប្រធានសហករណ៍ខ្លះ បានរាយការណ៍ភូតកុហកអង្គការថ្នាក់លើ ដើម្បីទុកស្រូវសម្រាប់ប្រជាជនមូលដ្ឋាន ។ ជាក់ស្តែង ទង្វើនេះបក្សនឹងធ្វើការចាប់ខ្លួនកម្មាភិបាលដើម្បីយកទៅសម្លាប់ប្រសិនបានដឹងនូវទង្វើភូតកុហក ។ កង្វះអង្ករបរិភោគជម្រុញឱ្យប្រជាជនជួបគ្រោះអត់ឃ្លាន ។ ការប្រឈមនេះប្រជាជនត្រូវបានទទួលរងនូវអំពើអមនុស្សធម៌ផ្សេងៗដូចទាសករ ។[103] បញ្ហានេះបានបង្កចេញជាផលវិបាកផ្សេងៗដូចជាប្រជាជនបានស្លាប់អស់ជាច្រើននាក់ដោយ ការអត់អាហារ និង ជំងឺឆ្លង ជាដើម ។

៨៧ កម្ពុជាប្រជាធិបតេយ្យ មានទម្រង់ដឹកនាំខុសប្លែកពីរបបដទៃទៀតក្នុងសកលលោក ។[104] សូម្បីតែ អៀង សារី អតីតឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស បានលើកឡើងដែរថា "**បដិវត្តន៍ខ្មែរគ្មានប្រើគំរូណាមួយពីមុនឡើយ ហើយអ្វីដែលយើងកំពុងសម្រេចទាំងនេះមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រពីមុននៅឡើយទេ**"។[105] បើនិយាយពីគោលជំហរគឺកម្ពុជាប្រជាធិបតេយ្យមានលក្ខណៈដាច់ខាតបំផុត[106] ហើយប្រជាជនត្រូវបង្ខំឱ្យធ្វើការងារតាមមូលដ្ឋាន ក្នុងស្ថានភាពលំបាកក្រៃលែង[107] គ្មានទេពេលសម្រាកគ្រប់គ្រាន់ ។ បន្ថែមពីលើនេះ នាពេលនោះប្រជាជន គ្មានទេសិទ្ធិសេរីភាព[108] គ្មានសិទ្ធិទទួលបានព័ត៌មាន[109] គ្មានសិទ្ធិធ្វើដំណើរ[110] គ្មានទីផ្សារ[111] គ្មានកម្មសិទ្ធិឯកជន[112] គ្មានមន្ទីរពេទ្យ គ្មានមណ្ឌលសុខភាព និង គ្មានថ្នាំព្យាបាលជំងឺឱ្យបានគ្រប់គ្រាន់[113] ជាអាទិ៍ ។

៨៨ សេដ្ឋកិច្ចជាតិទាំងមូលវិញ ត្រូវប្រឈមមុខនឹងការដាំក្បាលចុះដោយហេតុថា ប្រទេសមួយនេះត្រូវបានដឹកនាំដោយអង្គការ គ្មានការចរាចរណ៍រូបិយវត្ថុជាតិទាំងស្រុង[114] ក្រោមលេសថា ការចាយលុយនាំឱ្យមានការជិះជាន់ ហើយក៏អាចបង្កើតឱ្យមាន អំពើពុករលួយជាដើម ដែលជាប្រភពស្នូលបញ្ហាដ៏សំខាន់បំផុត ក្នុងការបង្កឱ្យរបបនេះ អាចប្រឈមមុខនឹងអស្ថិរភាពក្នុងការគ្រប់គ្រង និង ដឹកនាំប្រទេស ។[115] ខណៈដែលការមានរូបិយវត្ថុនេះត្រូវបានអ្នកសេដ្ឋកិច្ចវិទូចាត់ទុកថា ជាមូលដ្ឋានគ្រឹះចម្បង និងតែមួយគត់ សម្រាប់ដំណើរការសេដ្ឋកិច្ចរបស់ប្រទេសជាតិមួយ ។

៨៩ ពាក់ព័ន្ធបញ្ហាជំនឿសាសនា កម្ពុជាប្រជាធិបតេយ្យបានចាប់បង្ខំឱ្យព្រះសង្ឃផ្សឹក[116] បើមិនព្រមសម្លាប់ចោល[117] រីឯ វត្តអារាមត្រូវរងនូវការបំផ្លិចបំផ្លាញ[118] យ៉ាងគំហុក ។[119] ជាក់ស្តែង ប៉ុល ពត បានអនុវត្តលទ្ធិម៉ាកដាច់ខាតទៅលើសាសនាទាំងអស់នៅកម្ពុជា ។[120]



E.C.C.C * C.E.T.C. INVESTIGATING JUDGES CO-JUGES D'INSTRUCTION

01581343



សាក្សីជាច្រើនរូបអះអាងថា គ្រប់សាសនាទាំងអស់ត្រូវហាមឃាត់ ខណៈដែលវត្តអារាមក៏ត្រូវបានប្រើក្លាយជាកន្លែងរោងបាយ និង កន្លែងចិញ្ចឹមសត្វ ។[121] សាក្សីម្នាក់បាននិយាយថា "*ពេលនោះគ្រប់សាសនាទាំងអស់ ត្រូវបានបំបាត់ចោល គឺមានតែបក្សកុម្មុយនីស្តមួយទេដែលត្រូវគោរព ។ បក្សកុម្មុយនីស្តស្អប់ព្រះសង្ឃ ... ជាងគេ*" ។[122]

៩០ របបកម្ពុជាប្រជាធិបតេយ្យមានការបែងចែកមនុស្សតាមវ័យ តាមភេទ តាមប្រភេទការងារជាក្រុមៗ ហើយតម្រូវឱ្យប្រជាជនរស់នៅ និង ធ្វើការងារកន្លែងផ្សេងពីគ្នា ។[123] ចំពោះប្រជាជនមានវ័យចំណាស់មួយចំនួនតូច មិនត្រូវបានអង្គការឱ្យនៅទំនេរទេ ដោយតម្រូវឱ្យជួយមើលថែក្មេងតូចៗ ខណៈឪពុកម្តាយត្រូវទៅធ្វើការងារនៅតាមការដ្ឋាន ។[124] រីឯមនុស្សពេញវ័យ តម្រូវឱ្យចូលរួមធ្វើកសិកម្មតាមសហករណ៍មាន ធ្វើស្រែ[125] ធ្វើចំការ ដាំដំណាំនិងដាំបន្លែ ហើយខ្លះទៀតឱ្យជីកប្រឡាយ[126] លើកទំនប់[127] ជាដើម ។[128] ជាពិសេសពាក់ព័ន្ធការជម្រុញឱ្យលើកជាអាងទឹក មានការលើកឡើងដោយបក្សកុម្មុយនីស្តកម្ពុជាថា "**យើងមើលការប្រែប្រួលតែ ២ (ពីរ) ឆ្នាំនេះគឺលឿនណាស់ ប្រៀបធៀបនិង ១០០ (មួយរយ) ឆ្នាំមុន ១០០ (មួយរយ) ឆ្នាំមុនគ្មានអាងទឹកដូច្នេះឯណាទេ**" ។[129] កុមារៗក៏ត្រូវគេបង្ខំឱ្យធ្វើការងារឃ្វាលគោ[130] និងប្រមូលអាចម៍គោ សម្រាប់ធ្វើជីកសិកម្ម[131] ។

៩១ ជាទូទៅ ប្រជាជនពុំមានសិទ្ធិក្នុងការដើរហើរ មកលេងក្រុមគ្រួសារសាច់ញាតិ ឬធ្វើដំណើរទេ ប្រសិនបើគ្មានការអនុញ្ញាតពីអង្គការ ។[132] អវត្តមានពីកន្លែងរស់នៅ ឬកន្លែងការដ្ឋានធ្វើការជាការល្មើសនឹងវិន័យប្រឆាំងអង្គការ ។ ជាក់ស្តែង សមាជិកនីមួយៗតាមគ្រួសារមានពេលវេលាតិចតួចបំផុតដើម្បីបានជួបជុំគ្នា[133] ទោះបីក្នុងគ្រួសារ ឬពេលធ្វើការតាមការដ្ឋាន ។ ការនិយាយស្តីក៏ត្រូវបានអង្គការកម្រិតជាខ្លាំងផងដែរ ។ ប្រជាជនមានការភិតភ័យពាក់ព័ន្ធបញ្ហានេះជានិច្ច ដោយសារការនិយាយអាចនាំឱ្យមានការយកទៅអប់រំ ការចាប់ខ្លួន ឬយកទៅសម្លាប់ ក្នុងករណីមានការរិះគន់ ឬ/និង រអ៊ូរទាំទាក់ទិននឹងបញ្ហាការងារលំបាក ឬការផ្តល់អាហារឱ្យបរិភោគពុំគ្រប់គ្រាន់ ។[134] សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម បាននិយាយថា "*កាលពីគម្រោងធ្វើទំនប់នៅនិរតី ប្រជាជនមិនអាចប្រកែកនឹងបញ្ហាបានទេ បើប្រកែកនឹងយកទៅអប់រំណែនាំ*" ។[135]



E.C.C.C * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៩២ ដើម្បីសម្រេចតាមទិសដៅរបស់របបនេះ ក្នុងការកសាងប្រទេសនាពេលអនាគតឱ្យខ្លាំងក្លា និងឈានទៅរកការដឹកនាំតាមបែបសង្គមនិយម ដែលសំបូរសប្បាយថ្កុំថ្កើង រុងរឿងយ៉ាងឆាប់រហ័សក្រោមពាក្យស្លោក "មហាលោតផ្លោះមហាអស្ចារ្យ"[136] នោះកម្ពុជាប្រជាធិបតេយ្យបានអនុវត្ត និងប្រកាន់យកគោលនយោបាយចម្បងៗដូចជា ការសម្រេចឱ្យមានការជម្លៀសប្រជាជន ការប្រព្រឹត្តលើក្រុមពិសេស ការដ្ឋានការងារដោយបង្ខំ ការបង្ខំឱ្យរៀបការ និង ការបោសសម្អាតខ្មាំងផ្ទៃក្នុងនិងក្រៅបក្ស ជាអាទិ៍ ។ រហូតដល់ពាក្យថា "ខ្មាំង" ពេលខ្លះសំដៅតែលើអ្នកដែលគ្រាន់តែធ្វើឱ្យ បាក់ន័ង្គល[137] បាក់ចប បាក់ស្ពាបព្រា បែកចានឆ្នាំង[138] ស្ងួតស្រូវច្រឡំពូជ[139] លួចស្ករផែន[140] លួចពោតចេកនិងដំឡូងដែលដាំដោយខ្លួនឯង[141]បើកឡានជាន់ហ្វ្រាំងអូសកង់វែង[142] ទៅធ្វើការយឺតមិនទាន់ពេល[143] អនុវត្តបទបញ្ជាថ្នាក់លើលើស[144] រិះគន់អង្គការ[145] ឬ ក្រោមហេតុផលថា អ្នកទាំងនោះជាអ្នកចង់បំផ្លិចបំផ្លាញ ប.ក.ក ។[146]

៩៣ មុនឆ្នាំ១៩៧៥ បក្សធ្វើការជម្លៀសប្រជាជនចេញពីតំបន់ក្រោមការត្រួតត្រារបស់ខ្លួន ។[147] នៅខែកុម្ភៈ ឆ្នាំ១៩៧៥ គណៈកម្មាធិការមជ្ឈិមបក្ស បានប្រជុំសម្រេចផែនការជម្លៀសជាការត្រៀមទុកជាមុន ក្រោយពេលទទួលបានជ័យជម្នះ ។[148] នាពេលនោះមេដឹកនាំជាន់ខ្ពស់មាន ប៉ុល ពត, នួន ជា, អៀង សារី, និង ខៀវសំផន ក៏បានចូលរួមកិច្ចប្រជុំ[149] ដោយបានសម្រេចធ្វើការជម្លៀសដែលក្រោយមកមាន ៣ (បី) ដំណាក់កាល ។[150] សក្ខីកម្មសាក្សីបានដកស្រង់សំដីរបស់កម្មាភិបាលជាន់ខ្ពស់ឈ្មោះ តា ម៉ុក ថា "*ប្រជាជនទាំងអស់ត្រូវតែជម្លៀសទៅកាន់ទីជនបទ ដើម្បីកសាងសេដ្ឋកិច្ចជនបទ ។ ... ការជម្លៀសប្រជាជនចេញពីទីក្រុងត្រូវបានធ្វើឡើងនៅទូទាំងប្រទេស ដោយការជម្លៀសត្រូវតែឱ្យហើយក្នុងរយៈពេល ២ (ពីរ) ថ្ងៃ*" ។[151] បក្សកុំម្មុយនីស្តកម្ពុជា បានធ្វើការប៉ាន់ប្រមាណនូវចំនួនអ្នកដែលត្រូវបានជម្លៀសសរុបជាផ្លូវការមានចំនួន ២.០០០.០០០ (ពីរលាន) នាក់ ។[152]

៩៤ ការជម្លៀសនៅដំណាក់កាលទីមួយ បន្ទាប់រំដោះបាននាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[153] ដោយមានអង្គភាពយោធា ជាអ្នកទទួលខុសត្រូវអនុវត្តផែនការ ដោយបង្ខំឱ្យប្រជាជនចាកចេញពីផ្ទះទៅតាមផ្លូវជាតិគ្រប់ទិសជុំវិញរាប់ទាំងប៉ែកខាងលិច ខាងកើត ខាងជើង និងខាងត្បូងក្រុងភ្នំពេញ ពីទីរួមខេត្ត និងស្រុកផ្សេងទៀតឱ្យទៅតាមជនបទ ។[154] ក្នុងទិសដៅ ជម្រុញសេដ្ឋកិច្ច ដើម្បីកសាងរបបនេះលើមាគ៌ាសង្គមនិយម បែបសមូហភាពតាមជនបទ

ដោយមានការកសាងប្រព័ន្ធធារាសាស្ត្រ[155] ជីកព្រែក[156]លើកទំនប់[157]ជីកប្រឡាយ[158]អាងស្តុកទឹកដើម្បីឱ្យត្រូវតាមពាក្យថា "**បើមានទឹកគឺមានត្រី និងបើមានត្រីគឺមានអ្វីៗទាំងអស់**" ។[159]

៩៥ លើសពីនេះ នៅមានការជម្រុញឱ្យមានការធ្វើស្រែ និង ការបង្កបង្កើតផលតាមសហករណ៍ [160] ហើយក៏ជាចំណែកមួយដ៏សំខាន់ ក្នុងការជួយពង្រឹងបញ្ហាសន្តិសុខរបស់កម្ពុជាប្រជាធិបតេយ្យ ដែលអាចឈានទៅកំណត់បាននូវអត្តសញ្ញាណខ្មាំងមាន អតីតកងទ័ព[161] អតីតមន្ត្រីរដ្ឋការរបបមុនៗ[162] សេអ៊ីអា[163] កាហ្សេបេ[164] ខ្មាំងយួនបង្កប់[165] ដើម្បីការពារប្រទេសពីការប្រឈមមុខនឹងប្រទេសវៀតណាម ជាដើម ។[166]

៩៦ ការជម្លៀសដំណាក់កាលទីពីរ បានចាប់ផ្តើមពីខែកញ្ញា ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៧ ។ ប្រជាជន និងកម្មាភិបាលភូមិភាគនិរតី (ខេត្តកណ្តាល និងខេត្តតាកែវ) ត្រូវបានជម្លៀសទៅកាន់ភូមិភាគពាយ័ព្យ (ខេត្តបាត់ដំបងនិងខេត្តពោធិ៍សាត់)។[167] ផែនការនេះធ្វើឡើងក្រោយពីមានដំណើរទស្សនកិច្ចទៅកាន់នៅភូមិភាគពាយ័ព្យ របស់គណៈកម្មាធិការអចិន្ត្រៃយ៍នាខែសីហា-កញ្ញា ឆ្នាំ១៩៧៥ ដែលបានដឹងពីតម្រូវការ និងផែនការបន្ថែមប្រជាជន ៥០០.០០០ (ហាសិបម៉ឺន) នាក់ ទៅលើចំនួនប្រជាជនដែលមានស្រាប់ក្នុងភូមិភាគ[168] ក្នុងគោលដៅបង្កើនសេដ្ឋកិច្ចសង្គមនិយម សហករណ៍បង្កបង្កើតផល ដោយសារភូមិភាគនេះដីមានជីជាតិ ហើយអាចទទួលរ៉ាប់រងចិញ្ចឹមប្រជាជនថ្មីបានបន្ថែមទៀត ។[169] ជាក់ស្តែង ប្រជាជនរាប់សិបពាន់នាក់ត្រូវបានបញ្ជូនតាមមធ្យោបាយផ្សេងៗដូចជា តាមរថភ្លើង និង រថយន្ត ជាអាទិ៍ ដោយចេញពីភ្នំពេញឆ្ពោះទៅគោលដៅនានា ក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង ។[170] រហូតដល់ឆ្នាំ១៩៧៧ ប.ក.ក បានប៉ាន់ប្រមាណចំនួនប្រជាជនសរុប ដែលត្រូវបានជម្លៀសថា មានចំនួនដល់ ៤.០០០.០០០ (បួនលាន) នាក់ ។[171]

៩៧ ការជម្លៀសចុងក្រោយនៅដំណាក់កាលទីបី កើតមានពីចុងឆ្នាំ១៩៧៧-១៩៧៨ ។[172] ប្រជាជនដែលរស់នៅខេត្តព្រៃវែង និងស្វាយរៀង ក្នុងភូមិភាគបូព៌ា ក៏ត្រូវបានអង្គការបង្ខំទៅកាន់ភូមិភាគពាយ័ព្យ ។[173] ក្រៅពីប្រជាជនធម្មតានៅមានទាំងខ្មាំងនិងមុខសញ្ញាខ្មាំងដែលរួមមានអ្នកពាក់ព័ន្ធរបបមុនៗ ជាខ្សែរយៈវៀតណាម ប្រជាជន១៧មេសា ព្រះសង្ឃ ជនជាតិចាម កូនកាត់ចិន និង កូនកាត់វៀតណាម ជាដើម ។[174] អ្នកដែលមកដល់ភូមិភាគនេះត្រូវធ្វើប្រវត្តិរូប ហើយត្រូវបានបែងចែកទៅតាមសហករណ៍ និង ការដ្ឋានធ្វើការងារផ្សេងៗ

។ ខណៈដែលអ្នកខ្លះក៏ត្រូវបានបញ្ជូនទៅមន្ទីរសន្តិសុខសិន ហើយអ្នកខ្លះក៏ត្រូវបានយកទៅសម្លាប់ភ្លាមៗតែម្តង ។[175]

៩៨ លើសពីនេះទៀត ក្រោមហេតុផលនៃការជម្លៀសប្រជាជន ថ្នាក់ដឹកនាំបក្សបានសម្រេចដកប្រជាជន និង កងទ័ព ចេញពីសមរភូមិដែលកំពុងប្រយុទ្ធជាមួយវៀតណាម ខណៈមានការសង្ស័យថាជាជនក្បត់ ឬ ខ្សែរបស់ សោ ភឹម ។[176] តា ម៉ុក (គណៈកម្មាធិការភូមិភាគ-ពាយ័ព្យ) ជាមួយវត្តមានរបស់ សារុន (គណៈកម្មាធិការតំបន់ ១០៥) និង រឹម (គណៈកម្មា-ធិការស្រុក) បានដឹកនាំការប្រជុំនៅខេត្តពោធិ៍សាត់ ដើម្បីចាត់ចែងអ្នកមកដល់ភូមិភាគពាយ័ព្យហើយបានណែនាំឲ្យមានការប្រុងប្រយ័ត្ន ចំពោះអ្នកដែលមកពីភូមិភាគបូព៌ាពីព្រោះនៅពេលមកដល់ភ្នំពេញមានខ្លះឆែកឃើញមានអាវុធ ហើយខ្លះទៀតជាខ្សែវៀតណាម ។[177]

៩៩ របបកម្ពុជាប្រជាធិបតេយ្យ បានធ្វើបំណែកចែកប្រជាជនតាមប្រវត្តិរូប[178] រវាងអ្នករស់ក្នុងតំបន់រំដោះ និងអ្នកក្រោយឆ្នាំ១៩៧៥ ។ ភ្លាមៗក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការបែងចែកប្រជាជនជាក្រុមជីវភាពជា អ្នកមាន អ្នកក្រីក្រ ឬ អ្នកចេះដឹង ។ អ្នកណាមានឋានៈផ្ទាល់ ឬ សាច់ញាតិជាអ្នករដ្ឋការរបបលន់នល់ របបសង្គមរាស្ត្រនិយមត្រូវបានចាត់ថាជាអ្នកជាប់និន្នាការមិនល្អ ។[179] ចំណែកអ្នកដែលត្រូវជម្លៀសមកដល់កន្លែងថ្មីត្រូវបានអង្គការហៅថា ប្រជាជនថ្មី[180] ឬ ប្រជាជន១៧មេសា[181]។ រីឯ អ្នកនៅទីតាំងដដែលហៅថាប្រជាជនចាស់[182]ឬប្រជាជន១៨មេសា[183] ជារួមសំដៅលើប្រជាជនអ្នកមូលដ្ឋាន[184] ។ ប្រជាជនថ្មីត្រូវគេផ្តល់ឋានៈជា “ជនបញ្ញើ” ហើយមិនអាចកាន់តំណែងតួនាទីក្នុងរចនា-សម្ព័ន្ធក្នុងកម្រិតណាមួយបានឡើយ ។[185]ផ្ទុយទៅវិញ ចំពោះប្រជាជនចាស់ ឬ អ្នកមូលដ្ឋានអាចទទួលបានឋានៈជាប្រជាជនពេញសិទ្ធិតែម្តង ឬ ត្រៀម ប្រសិនមានសាច់ញាតិមានទំនាក់ទំនងជាមួយខ្មាំង ។[186]

១០០ ជាទូទៅ ប្រជាជនត្រូវបង្ខំឲ្យស្លៀកពាក់ដែលកំណត់ដោយអង្គការ ជាខោអាវពណ៌ខ្មៅដោយក្នុងមួយឆ្នាំប្រជាជនអាចទទួលបានពីរសម្រាប់ ។[187] នៅតាមគ្រួសារនីមួយៗ គ្មានទេទ្រព្យសម្បត្តិឯកជន ផ្អែកលើគោលនយោបាយដែលត្រូវបានដាក់ឲ្យអនុវត្តចាប់តាំងពីមុនថ្ងៃរំដោះទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកម្លេះ ។[188] ដោយមានហេតុផលថា របបកម្ពុជា

ប្រជាធិបតេយ្យយល់ថា ទ្រព្យសម្បត្តិឯកជន[189] ជារបបនាយទុននិយមនាំឱ្យមានអំពើពុករលួយ[190] ឬ ការកេងប្រវ័ញ្ចពីសំណាក់អ្នកមានទ្រព្យធនមកលើប្រជាជន ។[191]

១០១ អង្គប្រជុំនាថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៧៥ នាពហុកីឡាដ្ឋានជាតិអូឡាំពិកបានសម្រេចមិនឱ្យមានទីផ្សារ និងរូបិយវត្ថុជាតិ ។[192] ជាក់ស្តែង សាក្សីជាអតីតកម្មាភិបាលដែលបានចូលរួមប្រជុំទាក់ទិនគោលនយោបាយបក្សដែលមាន ប៉ុល ពត និង នួន ជា ជាអ្នកឧទ្ទេសនាមបើកវគ្គបានអះអាងថា *"អ្នកទាំងពីរនេះនិយាយពីនយោបាយរៀបចំសហករណ៍ ហាមមិនឱ្យចាយលុយ បិទទីផ្សារ និងវត្តអារាម ហើយថ្ងៃក្រោយអាចនឹងបើកឱ្យមានវិញ"*។[193] នៅចុងឆ្នាំ១៩៧៨ មានសេចក្តីសម្រេចឱ្យមានរូបិយវត្ថុ និងទីផ្សារ ដែលមិនទាន់ត្រូវបានអនុវត្តចេញជារូបរាងផង របបក៏បានដួលរលំ ។ [194]

១០២ របបកម្ពុជាប្រជាធិបតេយ្យ បានដាក់កំហិតឱ្យមានការរៀបការដោយបង្ខំ ដើម្បីសម្រេចឱ្យបាននូវការការពារបដិវត្តន៍សង្គមនិយម តាមរយៈយកអង្គការថ្នាក់លើរបស់ខ្លួនជាមេបាជំនួសឱ្យឪពុកម្តាយ ។[195] មានសាក្សីបង្ហាញដោយយោងដល់ សារគោលនយោបាយពីកម្មាភិបាលថា *"គេគ្រោងនឹងបង្កើនកម្លាំងថ្មី ឬ ក៏ប្រជាជនថ្មីឱ្យដល់ ១៥ (ដប់ប្រាំ) ទៅ ២០ (ម្ភៃ) លាននាក់នៅក្នុងរយៈពេលពី ១៥ (ដប់ប្រាំ) ទៅ ២០ (ម្ភៃ) ឆ្នាំទៀត"*។[196] មិនតែប៉ុណ្ណោះការណ៍នេះ ដើម្បីចំណេញនយោបាយគ្រប់គ្រងលើបុគ្គល និងសេដ្ឋកិច្ច ដោយទុកឱ្យឪពុកម្តាយ នៅធ្វើការតាមសហករណ៍ និងការដ្ឋានការងារ ។[197]

១០៣ ចំពោះការរៀបការអង្គការបានប្រមូលចងក្រង អ្នកដែលមានឋានៈនយោបាយដូចគ្នាដោយផ្តល់ការលើកទឹកចិត្តដល់កងទ័ព[198] តាមការប្រកាសរបស់ ប៉ុល ពត ក្នុងសន្និសីទ ការបោះពុម្ពផ្សាយជាផ្លូវការ តាមសារទូរលេខ រួមផ្សំជាមួយនឹងការភ័យខ្លាចនូវអំពើហិង្សា ឬការស្លាប់ ។[199] មានសាក្សីជាច្រើនផ្តល់សក្ខីកម្មថា អ្នកត្រូវគេបង្ខំឱ្យរៀបការមិនហ៊ានតវ៉ាឡើយ ។ [200]

១០៤ គោលនយោបាយធ្វើវិសុទ្ធកម្មក្នុងនិងក្រៅបក្ស ត្រូវបានបង្កើតតាំងពីមុនឆ្នាំ១៩៧៥ ក្នុងគោលបំណងបំផ្លាញនូវរចនាសម្ព័ន្ធរបបចាស់ វណ្ណៈសក្តិភូមិ នាយទុន សាសនា ពូជសាសន៍ជាដើម ។[201] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រង់មាត្រា ១០ បានបញ្ជាក់ថា *"ចំពោះ*

*ប្រភេទសកម្មភាពប្រឆាំង និង បំផ្លិចបំផ្លាញជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជនត្រូវផ្តន្ទាទោសកម្រិតខ្ពស់បំផុត ។ ចំពោះបទល្មើសក្រៅពីប្រភេទខាងលើត្រូវអប់រំកសាងក្នុងក្របខ័ណ្ឌអង្គការរដ្ឋ ឬ ក្នុងក្របខ័ណ្ឌអង្គការប្រជាជន*” ។[202]

១០៥ នៅក្រោយឆ្នាំ១៩៧៥ អ្វីៗមានភាពស្មុគស្មាញ ពិបាកយល់បញ្ហានៅគ្រប់ជាន់ថ្នាក់ រីឯគោលនយោបាយទូទៅមានលក្ខណៈឆ្វេងនិយមជ្រុល តាមមាគ៌ាឯករាជ្យម្ចាស់ការ ខ្លួនទីពឹងខ្លួនដែលត្រូវបានយកមកអនុវត្តតឹងរ៉ឹងហួសហេតុ ។[203] គោលនយោបាយសម្រិតសម្រាំងត្រូវបានស្តែងឡើង តាមរយៈសេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្សនាឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធ សិទ្ធិសម្រេចកម្ទេចក្នុងនិងក្រៅជួរបក្ស ដោយបានថែងយ៉ាងច្បាស់ថា “*បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច ជុំវិញមន្ទីរមជ្ឈិម ត្រូវគណៈមន្ទីរមជ្ឈិមសម្រេច តំបន់ឯករាជ្យត្រូវអចិន្ត្រៃយ៍សម្រេច កងទ័ពមជ្ឈិមត្រូវសេនាធិការសម្រេច*” ។[204]

១០៦ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច កន្លងមកបានបកស្រាយទាក់ទិននឹងសេចក្តីសម្រេចនាឆ្នាំ១៩៧៦ ថា “*អ្នកដែលមានសិទ្ធិនៅមូលដ្ឋានមិនមែនអចិន្ត្រៃយ៍ភាគទាំងមូលនោះទេ ... លេខាភាគមានសិទ្ធិសម្រេចអ្នកណាត្រូវកម្ទេចអ្នកនោះ លេខាភូមិភាគទុកឱ្យអ្នកណារស់គឺ អ្នកនោះរស់ ដូច្នេះអំណាចនៅលើលេខាភាគ*” ។[205] ដូចគ្នាដែរ លេខាភូមិភាគជាអ្នកគ្រប់គ្រងទាំងកងទ័ព និង កងឈ្លបដែលស្ថិតនៅក្រោមភូមិភាគ ។[206]

១០៧ នៅក្រោមការដឹកនាំរបស់ ប.ក.ក របបនេះបានបង្កើតឱ្យមានមន្ទីរសន្តិសុខជាច្រើនកន្លែងសម្រាប់ចាប់ឃុំ និង សម្លាប់មនុស្សដែលសរុបប្រហែល ១៩៦ (មួយរយកៅសិបប្រាំមួយ) មន្ទីរសន្តិសុខនៅទូទាំងប្រទេស ។ មន្ទីរសន្តិសុខជាកន្លែងសម្រាប់ធ្វើការឃុំខ្លួន ធ្វើការលត់ដំអប់រំ កែប្រែ ធ្វើទារុណកម្ម ដើម្បីរកខ្សែក្បត់ ឬ សម្លាប់ទាំងគ្រួសារ ។[207] កម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែអនុវត្តតាមមាគ៌ារបស់បក្ស តាមរយៈការផ្សព្វផ្សាយ គោលនយោបាយបក្ស ការសម្របសម្រួលលើការចាប់ខ្លួន ការបញ្ជូនខ្លួនតាមបញ្ជាថ្នាក់លើ ដែលត្រូវគេស្គាល់ជាទូទៅថា “**អង្គការ**” ។[208] ប្រយោគមួយឃ្លាដែលត្រូវបានគេប្រើប្រាស់ជាញឹកញាប់ថា “**កុំធ្វើអីដែលនាំឱ្យខ្មាស់នឹងអង្គការ ខ្មាស់នឹងកង់ប្រវត្តិសាស្ត្រ**” ។[209]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES

១០៨ អ្វីៗទាំងអស់ សុទ្ធតែជាបញ្ហាពី **"ថ្នាក់លើ"**[210] ខណៈថ្នាក់ក្រោមពុំបានយល់ពីផែនការ ឬ កម្មវិធីនយោបាយបន្តិចផង ។[211] ប៉ុន្តែ ប្រសិនបើមិនធ្វើតាមគោលនយោបាយថ្នាក់លើ ពួកគេត្រូវចាត់ទុកជា **"ខ្មាំង"**[212] ហើយត្រូវយកសម្លាប់ចោល ។[213] ក្នុងបរិបទកម្ពុជាប្រជាធិបតេយ្យ បញ្ជាថ្នាក់លើត្រូវតែគោរពដាច់ខាត ហ៊ានតែបដិសេធអ្នកនឹងត្រូវបានចាប់ខ្លួន និង សម្លាប់ ។[214] ជាក់ស្តែង កម្មាភិបាលដែលហ៊ានរិះគន់មាគ៌ារបស់បក្សត្រូវបានអង្គការចាត់ទុកជា **"ជនក្បត់ជាតិ"** ។[215]

១០៩ ក្នុងរបបនោះមាន **"ការប្រជុំស្វ័យទិតៀន"** ដែលតម្រូវឱ្យអ្នកប្រព្រឹត្តខុស ត្រូវនិយាយពីកំហុសខ្លួនចេញមកក្រៅ ដើម្បីឱ្យអង្គប្រជុំជួយឱ្យយោបល់ ដើម្បីកុំឱ្យធ្វើកំហុសដដែលៗ ។[216] ប.ក.ក បានកំណត់ឱ្យមានប្រជុំជីវភាពបក្សជាទៀងទាត់ ដោយលើកហេតុផលថា *"បើប្រជុំទៀងទាត់គឺចំរើន ចំរើនលឿន ចំរើនយឺតគឺ ចំរើន"*។[217] តាមរយៈការប្រជុំទាំងនោះ អង្គការបានឃោសនាពង្រឹងស្មារតីប្រជាជន ឱ្យខិតខំធ្វើការហើយកុំឱ្យក្បត់បក្សនិងអង្គការ បើមិនដូច្នេះទេអ្នកទាំងនោះនឹងត្រូវ **"ប្រវត្តិសាស្ត្រផ្តោលទោស"** ។[218]

១១០ នៅពេលអង្គការសម្រេចយកអ្នកណាទៅអប់រំ ឬ កសាងមិនបាន អ្នកនោះនឹងត្រូវយកទៅសម្លាប់ចោលដោយប្រាប់ថា **"ទុកក៏មិនចំណេញ ដកចេញក៏មិនខាត"**។[219] នាឆ្នាំ១៩៧៦ ហ៊ូ នឹម ត្រូវចាប់យកទៅសម្លាប់ ដោយសារគាត់មានយោបល់លើការស្នើឱ្យចាយលុយ និង បើកឱ្យមានទីផ្សារឡើងវិញ ដែលផ្ទុយការសម្រេចកន្លងមករបស់ ប៉ុល ពត នួន ជា និង តា ម៉ុក ។[220]

១១១ ការអនុវត្តន៍នូវគោលនយោបាយ ប.ក.ក ខាងលើបង្ហាញឱ្យឃើញថា ប្រជាជនបានប្រឈមមុខនឹងផលវិបាកជាច្រើនឥតគណនា ពិសេសបណ្តាលឱ្យប្រជាជន ខ្វះអាហារូបត្ថម្ភ និង មានជំងឺ ។[221] នៅពេលឈឺមិនមានទេ ការផ្តល់សេវាពីខាងមណ្ឌលសុខភាព មន្ទីរពេទ្យ ខណៈដែលថ្នាំព្យាបាលវិញក៏មិនមានឱ្យបានគ្រប់គ្រាន់ ហើយពេលខ្លះក៏បណ្តាលឱ្យអ្នកជំងឺឈឺកាន់តែធ្ងន់ធ្ងរ និង ភាគច្រើនមែនទែនឈានទៅស្លាប់តែម្តង ។[222]

១១២ លើសពីនេះ នៅមានការស្លាប់របស់ប្រជាជន ដែលកើតចេញពីការបង្ក្រាប តាមរយៈការអនុវត្តន៍នូវគោលនយោបាយវិសុទ្ធកម្ម ។ ប្រជាជននិងកម្មាភិបាលដែលត្រូវបានចោទថាជា

ខ្មាំង ឬ មិនគោរពតាមបទបញ្ជាអង្គការក៏ត្រូវបានសម្លាប់ ។[223] នាពេលនោះ គ្មានទេការបន្ធូរបន្ថយវិធានការវិន័យ ឱ្យតែមិនតាមគោលនយោបាយ បើទោះបីជាកម្មាភិបាលថ្នាក់ណាក៏ត្រូវទទួលទោសកំចាត់ចោលដូចជា៖ ហ៊ូ យន់[224] ហ៊ូ នឹម[225] វន វ៉េត[226] កុយ ធួន[227] វស់ ញឹម[228] និង សោ ភឹម[229] ជាដើម ។

១១៣ ជាក់ស្តែង ក្នុងអំឡុងពេលគ្រប់គ្រងអំណាចរយៈពេល ៣ (បី) ឆ្នាំ ៨ (ប្រាំបី) ខែ ២០ (ម្ភៃ) ថ្ងៃ កម្មាភិបាលជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យយ៉ាងតិចចំនួន ៦០ (ហុកសិប) រូប ត្រូវបានចាប់ខ្លួន និងសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ។[230] រីឯប្រជាជនទូទៅជាសរុបប្រមាណជាង ១.៧០០.០០០[231] (មួយលានប្រាំពីរសែន) នាក់ ត្រូវបានសម្លាប់ និងស្លាប់ដោយសារការអត់ឃ្លាន[232] ជំងឺ[233] និង ធ្វើការងារហួសកម្លាំង[234] ។

១១៤ នយោបាយដែលត្រូវបានដាក់ចេញដោយ ប.ក.ក ដូចបានរៀបរាប់ខាងលើ បានបង្ហាញថានៅទូទាំងប្រទេសកម្ពុជា មានបង្កើតឱ្យមាននូវប្រព័ន្ធតាមដានគ្រប់រូបភាព និងពេលវេលា ។ ហេតុដូច្នេះហើយទើបមានពាក្យថា **"អង្គការភ្នែកម្នាស់"** មានមធ្យោបាយរិតត្បិតគ្រប់សព្វមិនត្រឹមតែលើប្រជាជនទេ រួមទាំងកម្មាភិបាលផងដែរ ។[235] មិនតែប៉ុណ្ណោះ ប្រសិនបើមានការដើរខុសគន្លង បន្ទាត់គោលនយោបាយរបស់ ប.ក.ក នឹងក្លាយជាខ្មាំងរបស់អង្គការ និងពេលខ្លះគេថាជាខ្មាំងបដិវត្តន៍ ។ អ្វីដែលចម្លែកត្រង់ថា ការបំបាត់នូវរបបកម្មសិទ្ធិឯកជន បើសូម្បីតែដំណាំដាំជុំវិញផ្ទះបន្តិចបន្តួច ម្ចាស់មិនអាចបេះយកមកហូបចុកបានទេ ដោយសារដំណាំទាំងនោះជាកម្មសិទ្ធិផ្តាច់មុខរបស់សហករណ៍ ។[236] នេះជាដើមចមនៃបញ្ហារហូតដល់មានពាក្យស្លោកថា **"ជាកម្មសិទ្ធិសមរម្យគឺស្លាបព្រាមួយតួច"** ។

១១៥ អង្គហេតុទាំងអស់នេះ មានលក្ខណៈជាសត្យានុម័ត ដែលដឹងឮជាសាធារណៈពោលគឺប្រជាជនកម្ពុជាដែលនាពេលនេះមានអាយុចាប់ពី ៥០ (ហាសិប) ឆ្នាំ **(គិតត្រឹមឆ្នាំ២០១៨)** ឡើងទៅ កាលបើរស់នៅក្នុងរបបនោះសុទ្ធតែបានដឹងឮ និងឃើញទាំងអស់ដោយមិនចាំបាច់មានភស្តុតាងបញ្ជាក់ ។

១១៦ បរិបទនៃការប្រព្រឹត្តនិងទម្រង់នៃការគ្រប់គ្រង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺខុសពីអ្វីដែលកើតមាននៅប្រទេស យូហ្គោស្លាវី រ្វ៉ាន់ដា និង សេរ៉ាឡេអូន ដែលនាំឲ្យបង្កើតមាននូវតុលាការព្រហ្មទណ្ឌអន្តរជាតិស្រដៀងគ្នានឹង អ.វ.ត.ក ដែរ ។ របបកម្ពុជាប្រជាធិបតេយ្យជារបបប្រកាន់និន្នាការដឹកនាំរដ្ឋមួយជាក់លាក់ ផ្ទុះបញ្ចាំងក្នុងគោលនយោបាយ ធ្វើទុក្ខបុកម្នេញកម្រិតជាតិអនុវត្តជារូបរាងទូទៅ ប្រទេសក្នុងរចនាសម្ព័ន្ធដឹកនាំសមូហភាព ដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវតែគោរព និងធ្វើតាមបញ្ជា ។

១១៧ ជាក់ស្តែង ពាក្យថា "សត្រូវ" ឬ "ខ្មាំងបដិវត្តន៍" មានវិសាលភាពធំធេងនិងគ្របដណ្តប់លើប្រជាពលរដ្ឋស្លូតត្រង់ខ្លួនឯងតែម្តង ។ នេះខុសគ្នានឹងជម្លោះពូជសាសន៍រវាង ហ៊ូទូ (Hutus) និង ទុតស៊ី (Tutsi) ដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍នៅប្រទេសរ្វ៉ាន់ដា (Rwanda) ។[237] អ្វីបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យនេះ ក៏ខុសគ្នានឹងអំពើប្រល័យពូជសាសន៍ដោយពួកជាតិនិយមស៊ែប(Serb) ដែលដឹកនាំដោយអតីតប្រធានាធិបតីលោក ស្លូបូដាន ម៉េឡូសូវិច (Slobodan Milosevic) ទៅលើប្រជាជនក្រូអាត (Croat) និង បូស្នៀ (Bosnia) ។[238]

## ខ. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មជ្ឈិមបក្ស

### ១. គណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា

១១៨ បក្សកុំម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតឡើងតាំងពីមុនការកាន់អំណាចនៃរបបកម្ពុជាប្រជាធិបតេយ្យពីឆ្នាំ១៩៧៥-១៩៧៩ មកម្លេះ ។[239] របបកម្ពុជាប្រជាធិបតេយ្យជារបបដឹកនាំតាមបែបកុំម្មុយនីស្តដោយមានបក្សជាអ្នកដឹកនាំរដ្ឋ ។[240] គោលនយោបាយរបស់ ប.ក.ក មានគោលដៅធ្វើការបោសសម្អាតលើ វណ្ណៈសក្តិភូមិ និង បញ្ញាវន្ត ជាអាទិ៍ ដែលត្រូវចាត់ទុកជាខ្មាំង ដែលអ្នកទាំងនេះត្រូវបានគេចោទថា ធ្លាប់កេងប្រវ័ញ្ច និងជិះជាន់លើប្រជាជននាពេលកន្លងមក ។[241] ដូច្នេះ ប.ក.ក បានដាក់ចេញនូវគោលនយោបាយជាការសងសឹកចំពោះអ្នកទាំងនោះ ។[242]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

១១៩ គណៈកម្មាធិការមជ្ឈិមបក្ស ជាថ្នាក់ដឹកនាំកំពូលរបស់ ប.ក.ក ។[243] ពាក្យថា "បក្ស" សំដៅលើថ្នាក់ដឹកនាំនៃគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា ។[244] គណៈកម្មាធិការនេះមានសមាជិកប្រមាណ ៣០[245] (សាមសិប) រូប មានការកំណត់ការប្រជុំជាទៀងទាត់នៅរៀងរាល់ ៦ (ប្រាំមួយ)[246] ខែ ម្តង ។ ការអនុវត្តន៍ជាក់ស្តែង គណៈកម្មាធិការនេះតែងធ្វើការកោះហៅប្រជុំ ថ្នាក់ដឹកនាំគណៈភូមិភាគ និងគណៈតំបន់ ឱ្យមកចូលរួមប្រជុំនៅភ្នំពេញ ជាពិសេស ពេលត្រូវធ្វើការប្រកាសផ្សព្វផ្សាយនូវផែនការនៃការអនុវត្តន៍គោលនយោបាយផ្សេងៗរបស់ ប.ក.ក ។[247]

១២០ ការអនុវត្តន៍នូវការសម្រេចចាប់ខ្លួនថ្នាក់ភូមិភាគ ឬ តំបន់ ត្រូវចេញពីគណៈកម្មាធិការមជ្ឈិមបក្ស ។[248] សាក្សីឈ្មោះ សែម ហឿន បាននិយាយថា "*អ្នកទោសថ្នាក់ប្រធានតំបន់គឺធំដូច្នេះថ្នាក់ស្រុកមិនអាចទៅចាប់បានទេ ។ ដូច្នេះ បញ្ជាត្រូវចេញមកពីថ្នាក់មជ្ឈិមដែលជាថ្នាក់កំពូល*"។[249] ការសម្រេចចាប់ខ្លួនថ្នាក់តំបន់ ជាគោលការណ៍ក្នុងការអនុវត្តន៍ ពេលខ្លះខាងភូមិភាគ ក៏មិនមានសិទ្ធិក្នុងសម្រេចឱ្យមានការចាប់ខ្លួនទេ មានតែគណៈកម្មាធិការមជ្ឈិមបក្ស ដែលមានសិទ្ធិចេញបញ្ជាឱ្យចាប់ ។[250] ខណៈសក្ខីកម្មរបស់សាក្សីឈ្មោះ សួន កានិល បង្ហាញថា "*បើមិនមានឯកសារចាប់ខ្លួន គាត់ (កែ ពក) មិនហ៊ានចាប់ខ្លួនទេគឺត្រូវទទួលបញ្ជាពីថ្នាក់លើ*" ។[251]

១២១ មានការចោទប្រកាន់ **អោ អាន** ថា "ក្នុងនាមជាអនុលេខាភូមិភាគ **តា អាន** ប្រហែលជាធ្លាប់ជាសមាជិកគណៈមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជា នៅក្នុងមហាសន្និបាតបក្សលើកទី ៥ ដែលគណៈកម្មាធិការនេះរួមមាន លេខា និងអនុលេខាតំបន់ លេខា និងអនុលេខាភូមិភាគ" ។[252] ជាក់ស្តែង ប.ក.ក មានសមាជិកគណៈកម្មាធិការមជ្ឈិមប្រមាណ ៣០ (សាមសិប) រូប ក្នុងនោះរួមទាំងសមាជិកពេញសិទ្ធិ និង សមាជិកត្រៀមចូលបក្ស ដែលភាគច្រើនជាលេខាភូមិភាគ អនុលេខាភូមិភាគ សមាជិកគណៈភូមិភាគនិងលេខាតំបន់ ប៉ុន្តែ ពុំមែនអ្នកដែលមានតួនាទីទាំងនេះ ជាស្វ័យប្រវត្តិមានតួនាទីជាសមាជិកគណៈកម្មាធិការមជ្ឈិមទេ ។[253] តាមការឆ្លើយកន្លងមក **អោ អាន** បញ្ជាក់ថា គាត់ពុំមែនជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុនីស្តកម្ពុជាទេ ។[254] **អោ អាន** បានបន្ថែមថា លេខាតំបន់ដែលអាចជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សបាន លុះណាតែតំបន់នោះជាតំបន់ស្វយ័ត ។[255]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * C.C.C. * C.E.T.C.

## ២. គណៈកម្មាធិការអចិន្ត្រៃយ៍បក្សកុម្មុយនីស្តកម្ពុជា

១២២ គណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ជាអ្នកដើរតួនាទីសំខាន់ក្នុងការដឹកនាំការងារប្រចាំថ្ងៃជំនួស គណៈកម្មាធិការមជ្ឈិមបក្ស ជាមេដឹកនាំជាន់ខ្ពស់របស់បក្ស ។[256] សមាសភាពគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ៧ (ប្រាំពីរ) រូបរួមមាន៖ ប៉ុល ពត, នួន ជា, សោ ភឹម, តា ម៉ុក, អៀង សារី, វន វ៉េត, និង សុន សេន ។[257] ខណៈដែល ប៉ុល ពត មានតួនាទីជាលេខាបក្ស[258] រីឯ នួន ជា ជាអនុលេខាបក្ស[259] ។

១២៣ ក្នុងចំណោមសមាជិកនោះមានសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍រហូតដល់ទៅ ៥ (ប្រាំ) រូបមាន៖ ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត និង សុន សេន ដែលនៅធ្វើការជាប្រចាំនៅភ្នំពេញតែម្តង ។[260] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថាថ្នាក់ខ្ពស់ទាំង ៤ (បួន) នៃបក្សគឺ៖ ទី១. គណៈកម្មាធិការអចិន្ត្រៃយ៍ ទី២. សមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិម ទី៣.សមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិម និង ទី៤. គណៈកម្មាធិការជំនួយការនៃគណៈកម្មាធិការមជ្ឈិម ។[261]

១២៤ តួនាទី និង អំណាចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស ត្រូវបានចែងក្នុងលក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជា ដោយផ្តល់ការទទួលបន្ទុក និង ធ្វើការតាមដានក្នុងការអនុវត្តន៍នូវគោលនយោបាយរបស់ ប.ក.ក ។[262] គណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្សមានការទទួលបន្ទុកលើការមើលខុសត្រូវលើមាគ៌ានយោបាយគ្រប់ខទាំងអស់ នៅចន្លោះពេលពីមហាសន្និបាតមួយទៅមហាសន្និបាតមួយ ។[263] កន្លងមក មហាសន្និបាតបក្សលើកទី ១ ធ្វើនៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៦០ ។[264] នៅឆ្នាំ១៩៧៧ បក្សកុម្មុយនីស្តកម្ពុជាបានធ្វើមហាសន្និបាតជាតិប្រចាំឆ្នាំរបស់បក្ស ។[265] មហាសន្និបាតបក្សទូទាំងប្រទេស ជាអង្គការខ្ពស់បំផុតរបស់បក្ស ។[266] មហាសន្និបាតលើកទី ៥ របស់មជ្ឈិមបក្សត្រូវបានប្រារព្ធធ្វើជាចុងក្រោយមុនការដួលរលំក្នុងនៅថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ ។[267]

១២៥ ជាក់ស្តែង ភារកិច្ចត្រូវបានអនុវត្តដោយ ការិយាល័យនយោបាយមជ្ឈិមបក្ស ដែលធ្វើការប្រជុំគ្នាជាទៀងទាត់នៅរៀងរាល់ថ្ងៃអាទិត្យ ដើម្បីធ្វើការដោះស្រាយបញ្ហា ដែលកើតមានទាំងនៅក្នុង និង ក្រៅប្រទេស ។[268] ចំពោះសមាសភាពសមាជិកការិយាល័យនយោបាយ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581354



មជ្ឈិមបក្សមាន ៦ (ប្រាំមួយ) រូបមានៈ ប៉ុល ពត, នួន ជា, អៀង សារី, វន វ៉េត, សុន សេន និង ខៀវ សំផន ។[269] ក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ គណៈកម្មាធិការអចិន្ត្រៃយ៍ប្រជុំយ៉ាងតិច ១៩ (ដប់ប្រាំបួន) លើក ។[270]

១២៦ កិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នេះភាគច្រើនត្រូវបានធ្វើនៅ ក-១ ហើយពេលខ្លះនៅ ក-៣ ។[271] សេចក្តីសម្រេចឲ្យមានកិច្ចប្រជុំ របស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្សត្រូវសម្រេចដោយលេខាបក្ស ប៉ុល ពត ។[272] ទីស្នាក់ការកណ្តាលរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស ត្រូវបានគេស្គាល់ជាទូទៅ ដោយមានឈ្មោះថា **“មន្ទីរ៨៧០”** ។[273]

១២៧ អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានលើកឡើងដែរថា គណៈកម្មាធិការអចិន្ត្រៃយ៍ ជាស្ថាប័នដ៏សំខាន់បំផុតនៅក្នុងបក្ស ។[274] មិនតែប៉ុណ្ណោះ គណៈកម្មាធិការនេះមានការត្រួតត្រា ទៅលើគោលនយោបាយទាំងអស់របស់បក្ស និងរដ្ឋាភិបាលដោយរាប់ទាំងកិច្ចការសន្តិសុខក្នុង និងក្រៅប្រទេស[275] ដោយបូករួមទាំងវិស័យសំខាន់ៗមានៈ កសិកម្ម សុខាភិបាល និង សង្គមកិច្ច ជាអាទិ៍ ។[276] គណៈកម្មាធិការ-អចិន្ត្រៃយ៍បក្ស ជាអ្នកផ្តល់ការពិភាក្សាលើបញ្ហា ធ្វើការនៅតាមការដ្ឋាន ការសួរចម្លើយ និងការចាប់ខ្លួន ព្រមទាំងពិនិត្យមើលល័ក្ខខ័ណ្ឌរស់នៅទូទាំងប្រទេស និងមានសិទ្ធិអំណាចដើម្បីបញ្ជាឲ្យសម្លាប់មនុស្សបានភ្លាមៗ ។[277]

## ៣. ស្ថាប័នដទៃទៀត

១២៨ តាមរយៈមហាសន្និបាតជាតិលើកទី ៣ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យត្រូវបានអនុម័តនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៥ និង ប្រកាសជាផ្លូវការ នាថ្ងៃទី០៥ ខែមករា ឆ្នាំ១៩៧៦ ។[278] រដ្ឋធម្មនុញ្ញក៏មានចែង អំពីបញ្ហាតុលាការដោយត្រូវបានគេហៅឈ្មោះថា **“គណៈកម្មាធិការតុលាការ”**ដែលត្រូវបានជ្រើសតាំងដោយសភាតំណាងប្រជាជនកម្ពុជា។[279]គណៈកម្មាធិការនេះជាអង្គការតុលាការរបស់ប្រជាជន ដែលតំណាងយុត្តិធម៌របស់ប្រជាជនការពារយុត្តិធម៌របស់ប្រជាជន ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន ហើយផ្តន្ទាទោសធ្ងន់ដល់គ្រប់សកម្មភាព ដែលប្រឆាំងនឹងរដ្ឋរបស់ប្រជាជន ឬ ដែលល្មើសនឹងច្បាប់រដ្ឋរបស់



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES

01581355



ប្រជាជន កម្មករ កសិករ និងកងទ័ពបដិវត្តន៍កម្ពុជា ។[280] ជាក់ស្តែង គណៈកម្មាធិការតុលាការពុំត្រូវបានដាក់ឱ្យដំណើរការទេ ។[281]

១២៩ ស្ថាប័នកំពូលពីរផ្សេងទៀតរួមមាន សភាតំណាងប្រជាជនកម្ពុជា[282] និង រដ្ឋាភិបាល[283] ។ រដ្ឋាភិបាលជាអង្គការអនុវត្តច្បាប់ និង មាគ៌ានយោបាយរបស់សភាតំណាងប្រជាជនកម្ពុជា ហើយ ទទួលខុសត្រូវចំពោះសភាតំណាងប្រជាជនកម្ពុជា ក្រោមហេតុផលថា រដ្ឋាភិបាលត្រូវបានជ្រើសតាំងឡើងដោយសភាតំណាងប្រជាជន ។[284] សភាតំណាងប្រជាជនកម្ពុជាមានសមាជិកសរុប ២៥០ (ពីររយហាសិប) រូប ដែលជ្រើសតាំងឡើងដោយប្រជាជនកម្ពុជា និងកងទ័ពបដិវត្តន៍កម្ពុជា តាមរយៈការបោះឆ្នោតដោយផ្ទាល់និងសម្ងាត់ដោយមានអាណត្តិ ៥ (ប្រាំ) ឆ្នាំ។[285] តំណាងមកពីកសិករមាន ១៥០ (មួយរយហាសិប) រូប តំណាងកម្មករមាន ៥០ (ហាសិប) រូប និង តំណាងកងទ័ពបដិវត្តន៍មាន ៥០ (ហាសិប) រូប ។[286]

១៣០ សភាតំណាងប្រជាជនកម្ពុជា មានភារកិច្ចបង្កើតច្បាប់ អនុម័តច្បាប់ ពិនិត្យនិងតាមដានការអនុវត្តន៍ច្បាប់ និង កំណត់មាគ៌ានយោបាយកម្ពុជាប្រជាធិបតេយ្យ ។[287] សភាតំណាងប្រជាជនកម្ពុជានេះ មានគណៈកម្មាធិការអចិន្ត្រៃយ៍មួយ និង គណៈកម្មាធិការផ្សេងទៀត ដូចជា គណៈកម្មាធិការសេដ្ឋកិច្ច គណៈកម្មាធិការការពារប្រទេស គណៈកម្មាធិការការបរទេស និង គណៈកម្មាធិការវប្បធម៌សង្គមនិងសុខាភិបាល ជាដើម ។[288]

១៣១ ក្រមកំណត់របៀបរបបធ្វើការងារ របស់សភាតំណាងប្រជាជនកម្ពុជាត្រង់មាត្រា ១ បានចែងថា *"សមាជិករបស់សភាតំណាងប្រជាជនកម្ពុជាមួយរូបៗ ត្រូវស្ថិតនៅជិតស្និទ្ធក្នុងមូលដ្ឋានរបស់ខ្លួនតទៅទៀត ត្រូវរួមសុខរួមទុក្ខជាមួយប្រជាជន ស្គាល់ចិត្តស្គាល់ថ្លើមប្រជាជន ស្តាប់សំណូមពរប្រជាជន ពោលគឺនៅជាប់នឹងសហជីព នឹងរោងចក្រ នៅជាប់នឹងសហករណ៍ ការដ្ឋានប្រព័ន្ធភ្លឺ និងប្រឡាយទឹក នៅជាប់នឹងអង្គភាពរបស់ខ្លួន រួមសកម្មភាពកសាងប្រទេស និងការពារប្រទេសជាមួយប្រជាជនកម្មករ និងកសិករពលករផ្សេងៗ យុទ្ធជនយុទ្ធនារី និង កម្មាភិបាលនៃកងទ័ពបដិវត្តន៍កម្ពុជាតទៅទៀត ដើម្បីឱ្យសមស្របនឹងឋានៈរបស់ខ្លួន ជាតំណាងពិតប្រាកដរបស់ប្រជាជនកម្ពុជានិងកសិករ ពលករផ្សេងៗ និងកងទ័ពបដិវត្តន៍កម្ពុជា"* ។[289]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES

១៣២ សេចក្តីសម្រេចរបស់គណៈកម្មាធិការមជ្ឈិមបក្ស នាថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បានសម្រេចតែងតាំង នួន ជា ជាប្រធានគណៈអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជន ។[290] នៅឆ្នាំ១៩៧៦ ក្រោយពីរដ្ឋធម្មនុញ្ញត្រូវបានអនុម័ត កិច្ចប្រជុំប្រកាសបង្កើតរដ្ឋសភាត្រូវបានធ្វើឡើងបានតែម្តងគត់ ដើម្បីបង្ហាញពិភពលោកថា ការដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យមានរដ្ឋសភា ។[291] សាក្សីមួយរូបបានលើកឡើងថា *"ក្នុងនាមខ្លួនជាតំណាងរាស្ត្រ តែខ្លួនមិនដឹងពីការងារនោះទេ ហើយខ្លួនមិនទាំងស្គាល់ប្រធានសភាជាអ្នកណាទេ ហើយថែមទាំងឆ្ងល់ថា សភាហ្នឹងធ្វើការអី?"* ។[292]

១៣៣ សភាតំណាងប្រជាជនកម្ពុជាហាក់ដូចជា សភាគ្មានសិទ្ធិអំណាច ពីព្រោះថា អ្វីៗទាំងអស់ត្រូវស្ថិតនៅក្រោមអំណាចនៃការដឹកនាំរបស់បក្ស ។[293] សភាតំណាងប្រជាជនកម្ពុជា បែរជាបានធ្វើការងារជាទៀងទាត់ លើការផ្ញើសារអបអរសាទរទៅប្រទេសជាមិត្ត ទទួលគណៈប្រតិភូសភាបរទេសមកទស្សនកិច្ចនៅកម្ពុជា ។[294] សាក្សី ចាន់ យូរ៉ាន់ លើកឡើងថា *"ចំពោះ លោក នួន ជា ក្រោយមកមានគណៈប្រតិភូសភាប្រទេសអាល់ហ្សេរីមកទស្សនកិច្ចនៅភ្នំពេញលោក នួន ជា ជាអ្នកទទួលគណៈប្រតិភូ ... ឆ្នាំ១៩៧៧"* ។[295]

១៣៤ សភាមិនដែលបានធ្វើការងារទេ ទាក់ទិនសេចក្តីស្នើច្បាប់ ឬ/និង ការពិភាក្សាលើការអនុម័តច្បាប់ណាមួយ[296] បើទោះបីជារដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ បានចែងយ៉ាងច្បាស់ថា សភាតំណាងប្រជាជនកម្ពុជាមានភារកិច្ចធ្វើច្បាប់[297] អនុម័តច្បាប់[298] ពិនិត្យតាមដានការអនុវត្តន៍ច្បាប់ និង កំណត់មាគ៌ានយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ។[299] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថា *"កម្ពុជាជាប្រទេសមួយដែលសភាតំណាងប្រជាជនមានត្រឹមតែជានិមិត្តរូប"* ។[300]

១៣៥ ស.ព.អ បានចោទប្រកាន់ថា **អៀ អាន** នៅខែមីនា ឆ្នាំ១៩៧៦ ត្រូវបានជ្រើសតាំងដោយប្រើឈ្មោះ ថូ អាន ឱ្យធ្វើជាតំណាងកសិករភូមិភាគនិរតីក្នុងសភាតំណាងប្រជាជន ។[301] ឆ្លើយតបនឹងបញ្ហានេះ មានតែឯកសារមិនផ្លូវការដែលថតចម្លងពុំសូវច្បាស់តែមួយ បានបញ្ជាក់ពីបញ្ជីរាយនាមតំណាងរាស្ត្រនៃសភាតំណាងប្រជាជនកម្ពុជា ។[302] យោងលើបញ្ជីនោះត្រង់ផ្នែកតំណាងកសិករភូមិភាគនិរតីត្រង់លេខរៀងទី ១៦ មានឃើញឈ្មោះ ថូ អាន ឬ ថូ អាន់ ។ មានការសន្និដ្ឋានថា ថូ អាន គឺជា **អៀ អាន** ឬ ថូ អាន និង **អៀ អាន** ជាបុគ្គលតែ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មួយ ។[303] មិនមានឯកសារណាមួយដែលបញ្ជាក់ថា បុគ្គលឈ្មោះ ថូ អាន ជានរណានោះទេ ? ប៉ុន្តែ អ្វីដែលច្បាស់នោះគ្រង់ថា គ្មានឯកសារ ឬ/និង ជាភ័ស្តុតាងណាមួយដែលត្រូវបានបញ្ជាក់ថា ថូ អាន គឺជា **អោ អាន** នោះទេ ។

## គ. គោលនយោបាយរបស់ ប.ក.ក ចំពោះជនជាតិចាម

### ១. ការប្រព្រឹត្តជាទូទៅលើជនជាតិចាម

១៣៦ សាក្សី ម៉ាត់ លី បានលើកឡើងថា *"ដល់ឆ្នាំ៧៦ ចេញរដ្ឋធម្មនុញ្ញរបស់សភាគេអានថា ចំពោះសាសនាជឿក៏បានមិនជឿក៏បាន ហើយហាមដាច់ខាតសាសនាណាដែលប្រតិកិរិយា ។ ប៉ុន្តែរំដោះហើយ ៧៥ គឺថាសាសនាហ្នឹងប្រតិកិរិយាទាំងអស់"* ។[304] សាក្សីឈ្មោះ ឈូក រីន បានផ្តល់សក្ខីកម្មថា *"ខ្ញុំមិនយល់ទេព្រោះមិនថាចាម ឬ ខ្មែរទេគឺត្រូវបានធ្វើបាបដូចគ្នា។ រាល់សាសនាទាំងអស់ត្រូវបានហាមឃាត់"*។[305] សាក្សីឈ្មោះ ម៉ាត់ អ៊ីសា លើកឡើងថា *"ពួកគេ (ខ្មែរក្រហម) ចង់បំបាត់សាសនាទាំងអស់ រួមទាំងសាសនាអ៊ីស្លាម"*។[306] នៅមានសាក្សីឈ្មោះ ហ្វ្រង់ស័រ ប៉ុងសូរ (Mr.FRANÇOIS Ponchaud) បាននិយាយថា *"ពួកអ្នកដែលត្រូវបានគេសម្លាប់ ហើយដែលមានពិតប្រាកដ មិនមែនសាសនាជាមូលហេតុទេ ប៉ុន្តែពីព្រោះពួកគេបានត្រូវចាត់ទុកថាជាសត្រូវនយោបាយ"* ។[307]

១៣៧ ការប្រព្រឹត្តទៅលើជនជាតិចាម មានចរិតខ្លាំងក្លាជាលក្ខណៈប្រព័ន្ធប្លែកខុសពីការប្រព្រឹត្តទៅលើសាសនាដទៃ បើទោះបីជា ក្នុងរបបនោះទាំងប្រជាជនខ្មែរ និងជនជាតិចាម ស្លៀកពាក់ខ្មៅដូចគ្នា ។[308] ជនជាតិចាម មិនត្រូវអនុញ្ញាតឲ្យទទួរកន្សែង និងបង្ខំឲ្យហូបបាយនៅរោងបាយជាមួយគ្នា ។[309] សាក្សីឈ្មោះ ឡឹប ស្រ៊ុល បង្ហាញថា *"តឹងទាំងអស់គ្នា តែចាមតឹងជាងគេ គេឲ្យហូបសាច់ជ្រូក ។ បើមិនហូបទេ គេយកទៅវៃចោល"*។[310]

១៣៨ មតិខ្លះលើកឡើងថា ប្រជាជនខ្មែរមានការលំបាកខ្លាំងជាងជនជាតិចាម ។[311]ប៉ុន្តែ ជនជាតិចាមទេដែលត្រូវទទួលរងទុក្ខវេទនាខ្លាំងជាងបងប្អូនប្រជាជនខ្មែរ ដោយហេតុថា ជនជាតិចាមត្រូវបានអង្គការ មិនអនុញ្ញាតឲ្យប្រតិបត្តិប្រពៃណីទំនៀមទម្លាប់ និងវប្បធម៌របស់ខ្លួនទាំងស្រុង ។[312] លើសពីនេះ ជនជាតិចាមត្រូវបានអង្គការ ធ្វើការបំបែកមិនឲ្យ រួមរស់នៅជុំ

គ្នាជាលក្ខណៈសហគមន៍ដូចសម័យមុនៗទេ[313] ដោយត្រូវឱ្យរស់នៅតាម សហករណ៍ កងចល័ត ហើយឱ្យធ្វើការងារដូចប្រជាជនខ្មែរដែរ [314] ។

១៣៩ ជនជាតិចាមត្រូវបានអង្គការចាត់ទុកដូចជា ប្រជាជន១៧មេសា ដោយត្រូវបង្ខំឱ្យធ្វើការផ្សេងៗដូចជា៖ ធ្វើស្រែ លើកទំនប់ ជីកប្រឡាយ កាប់អុស ដឹកជញ្ជូនអុស នេសាទ ជាអាទិ៍ ។[315] រីឯ ការហូបចុកមិនបានគ្រប់គ្រាន់ទេ ខណៈដែលជំនឿសាសនារបស់ជនជាតិចាម ហាមឃាត់មិនឱ្យហូបសាច់ជ្រូក និងសាច់ឆ្កែ ប៉ុន្តែ បែរជាត្រូវអង្គការគេបង្ខំឱ្យជនជាតិចាមខ្លះឱ្យហូបសាច់ជ្រូក និងសាច់ឆ្កែ ។[316]

១៤០ ជាទូទៅ ជនជាតិចាមមិនត្រូវបាន អង្គការអនុញ្ញាតឱ្យគោរពបូជាលើជំនឿសាសនា [317] បើសូម្បីតែព្រះគម្ពីរកូអាន (The Koran) ក៏ត្រូវប្រមូលដុតចោល[318] លើសពីនេះ ថែមទាំងមិនឱ្យជនជាតិចាមបានរៀនសូត្រ និងនិយាយភាសាចាមទេ ។[319] ប្រសិនបើអង្គការតាមទាន់ អ្នកណាម្នាក់និយាយភាសាចាម ជាដំបូងអង្គការធ្វើការព្រមានសិន បើនៅតែមិនរាងលើកក្រោយចាប់ដាក់គុក ។[320]

១៤១ ជនជាតិចាមក៏ត្រូវបង្ខំឱ្យរៀបការ ជាមួយអ្នកដែលមិនមែនជាជនជាតិចាម ។[321] មានការរើសអើងមែនទែនទៅលើជនជាតិចាម ហើយស្ថានភាពនេះ មានការកើនឡើងខ្លាំងតាំងពីក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។[322] នៅឆ្នាំ១៩៧៧ កម្ពុជាប្រជាធិបតេយ្យបានចាប់ផ្ដើមអនុវត្តនូវគោលនយោបាយលុបបំបាត់ជាតិសាសន៍ជនជាតិចាម យ៉ាងសកម្មនៅទូទាំងប្រទេស ។[323]

១៤២ សាក្សីឈ្មោះ សុះ កំរី ហៅ ហាជីកាម៉ារុទ្ទីន យូសុះ បាននិយាយថា *"ខ្ញុំបានប្រទះឃើញសៀវភៅមួយដែលមានក្របពណ៌លឿងខ្ចីមាន ១៦ (ដប់ប្រាំមួយ) ទំព័រ មានចំណងជើងថា ផែនការសម្រាប់សហករណ៍ជឿនលឿន ... សៀវភៅនោះសរសេរយ៉ាងច្បាស់ថា **ចាមគឺជាខ្មាំងធំជាងគេ ហើយត្រូវកម្ទេចឱ្យអស់មុនឆ្នាំ១៩៨០**"* ។[324] ទន្ទឹមនឹងនោះដែរសាក្សីនេះក៏បានឆ្លើយប្រាប់ថា *"នៅក្នុងឆ្នាំ១៩៧៧ កម្មាភិបាលសន្តិសុខថ្នាក់តំបន់មកពីតំបន់ ២១ ភូមិភាគបូព៌ាបាននិយាយជាមួយខ្ញុំ ដោយមិនបានដឹងថាខ្ញុំជាចាមថា **ទៅថ្ងៃមុខពួកចាមដែលនៅសេសសល់នឹងត្រូវសម្លាប់ទាំងអស់**"* ។[325] សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់

សៀមបាននិយាយថា *"ខ្ញុំធ្លាប់ចូលប្រជុំនៅថ្នាក់តំបន់ដែល នៅក្នុងកិច្ចប្រជុំនោះមានការសម្រេចឲ្យចាប់ខ្លួនជនជាតិចាម"* ។[326] សាក្សីម្នាក់ទៀតឈ្មោះ ពៅ សារ៉ុម បាននិយាយដែរថា *"ជនជាតិចាមត្រូវបានគេធ្វើបាបធ្ងន់ធ្ងរកាលពីសម័យនោះ"* ។[327]

១៤៣ សាក្សីឈ្មោះ ញឹម កុល ដែលជាអ្នករស់នៅស្រុកកំពង់សៀមបាននិយាយថា *"ខ្ញុំដឹងថាមេឃុំបានឲ្យមេភូមិសរសេរឈ្មោះប្រជាជនទាំងអស់ នៅក្នុងភូមិចូលទៅក្នុងសៀវភៅចំនួនពីរក្បាល ។ ក្នុងសៀវភៅនោះ មេភូមិត្រូវផ្តល់ព័ត៌មានលម្អិតដូចជា ជាតិសាសន៍ និងប្រវត្តិរូបរបស់អ្នកភូមិ ... ខ្ញុំដឹងថាអ្នកដែលគេយកទៅនោះត្រូវបានគេកុហកថា ពួកគេត្រូវយកទៅឲ្យធ្វើការនៅសហជីពចំការកៅស៊ូ តាមពិតទៅពួកគាត់ត្រូវបានគេយកទៅសម្លាប់"* ។[328] ចំពោះការធ្វើបញ្ជីបែបនេះ ជាបញ្ជាចេញពីថ្នាក់លើឲ្យមកមូលដ្ឋានដើម្បីធ្វើបញ្ជី ។[329]

១៤៤ សាក្សីឈ្មោះ ពៅ សារ៉ុម ជាអ្នកធ្លាប់ចូលរួមធ្វើបញ្ជីផ្ទាល់បានប្រាប់ថា *"គាត់បានបញ្ជាឲ្យធ្វើបញ្ជីលម្អិត អំពីចំនួនប្រជាជននៅក្នុងឃុំក្រឡាដូចជា ភេទប្រុស ភេទស្រី ក្មេង ចាស់ ជាតិសាសន៍ ប្រជាជនថ្មី ឬ ក៏អតីតទាហានលន់នល់"* ។[330] សាក្សីឈ្មោះ លាវ លាស់ បានលើកឡើងថា *"មានប្រជាជនចាមនៅឃុំរបស់ខ្ញុំ ប្រជាជនចាមមិនសូវនៅរស់ទេ ព្រោះទាំងមានកំហុស និងគ្មានកំហុស គឺជនជាតិចាមត្រូវគេសម្លាប់ ។ ខ្ញុំមិនបានឃើញគេសម្លាប់ទេ គ្រាន់តែឃើញខ្មែរក្រហមចូលមកហៅមួយគ្រួសារម្តងៗចេញទៅ ហើយប្រជាជនចាមកាន់តែតិចទៅៗក្រោយមកគេប្រមូលទាំងអស់ ។ គេចាប់ប្រជាជនចាមនៅឆ្នាំ១៩៧៨"* ។[331]

១៤៥ ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ មួក សេងលី បានឆ្លើយដោយបានលើកសម្តី យាយ យុត បាននិយាយថា *"ពួកចាមជាសត្រូវរបស់អង្គការ ព្រោះគេមានផែនការក្បត់ ដូច្នេះអង្គការត្រូវតែកម្ទេចពួកគេ បើមានចាមនៅសេសសល់ត្រូវរាយការណ៍ ដើម្បីបោសសម្អាត ព្រោះនេះជាផែនការរបស់អង្គការថ្នាក់លើ"* ។[332]

១៤៦ សក្ខីកម្មសាក្សីផ្ទាល់ភ្នែកឈ្មោះ សឡេះ អះម៉ាត់ ដែលរស់នៅក្នុងភូមិជំនីកស្រុកក្រូចឆ្មារ បានបង្ហាញថា នៅចុងឆ្នាំ១៩៧៨ គាត់ជាអ្នកបើកម៉ូតូឲ្យលេខាស្រុកដែលជាអ្នកមិនចេះជិះម៉ូតូទៅកាន់អង្គប្រជុំមួយនៅស្រុកសណ្តាន់ខេត្តកំពង់ធំ ដោយហេតុថា សឡេះ មិនអាចចូលរួមក្នុងអង្គប្រជុំបាន គាត់ត្រូវអង្គុយចាំនៅខាងក្រៅ គាត់បាននិយាយថា *"ក្នុងពេលដែលគាត់*



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581360



*កំពុងរង់ចាំ គាត់បានឃើញលេខាស្រុកនៅភូមិភាគខាងកើត និងភូមិភាគកណ្ដាលមួយចំនួនទៀត នៅក្នុងកិច្ចប្រជុំនោះដែរ គាត់ក៏បានឮផងដែរពីការពិភាក្សា ក្នុងកិច្ចប្រជុំដោយក្នុងអំឡុងពេលប្រជុំនោះ កែ ពក ដែលជាលេខាភូមិភាគកណ្ដាល បានសួរទៅលេខាស្រុកក្រូចឆ្មារថា "គម្រោងដែលបានដាក់ជូនដោយបក្ស តើបានបញ្ចប់ប៉ុន្មានភាគរយហើយ?" សឡេះ បាននិយាយថា* កែ ពក ក៏បានបញ្ជាក់បន្ថែមទៀតថា "សមមិត្តត្រូវតែកម្ទេចពួកចាមដែលស្ថិតក្នុងកងចល័តមុន ព្រោះពួកគេទាំងនោះសុទ្ធតែជាជនក្បត់ជាតិ"។[333]

## ២. ការជម្លៀសជនជាតិចាម

១៤៧ ជនជាតិចាមក៏ត្រូវបានទទួលរងនូវការជម្លៀស ឲ្យចាកឆ្ងាយពីទីកន្លែងធ្លាប់រស់នៅផងដែរ។ សាក្សីឈ្មោះ សឡេះ អះម៉ាត់ បាននិយាយថា "*គេបានចាប់ជម្លៀស និងយកប្រជាជនចាមទៅសម្លាប់ចោល ។ ហេតុការណ៍បានកើតឡើងចាប់ពីឆ្នាំ១៩៧៦ មិនមានកិច្ចប្រជុំអ្វីដែលប្រកាសពី គោលនយោបាយប្រឆាំងនឹងពួកយើងទេ ប៉ុន្តែ គេបានប្រាប់យើងថាការជឿសាសនាមូស្លីមគឺជាអបិយជំនឿ*"។[334]

១៤៨ នាសម័យកាលនោះ ប្រជាជនទូទៅត្រូវបានទទួលរងការឈឺចាប់មិនថា ជនជាតិចាម ឬ ប្រជាជនខ្មែរទេ ។ ប៉ុន្តែ អត្រាបងប្អូនគ្រួសារជាជនជាតិចាម មានរហូតដល់ប្រហែលជា ៧៥ ភាគរយ (ចិតសិបប្រាំភាគរយ) ។ អង្គការធ្វើការជម្លៀសចេញពីភូមិកំណើតទៅកាន់កន្លែងផ្សេងៗគ្នានៅទូទាំងប្រទេស ។[335] ជាក់ស្ដែង ជនជាតិចាមត្រូវបានជម្លៀសឲ្យទៅរស់នៅតាមស្រុកមួយចំនួនក្នុងខេត្តកំពង់ធំ និង ខេត្តកំពង់ចាមរួមមាន៖ ស្រុកសន្ទុក និង ស្រុកចំការលើ ជាអាទិ៍ ។[336]

១៤៩ នៅពេលជម្លៀសជនជាតិចាម អង្គការបានតម្រូវឲ្យជនជាតិចាមទាំងប្រុស ស្រី និងកុមារត្រូវតែចាកចេញ បើតវ៉ាសម្លាប់ចោល ។[337] ការជម្លៀសចាប់ផ្ដើមតាំងពីឆ្នាំ១៩៧៦ ហើយបានបន្តរហូតដល់ចុងឆ្នាំ១៩៧៨ ។[338] ប៉ុន្តែ សាក្សីតែមួយរូបឈ្មោះ យ៉ា ម៉ាត់លី បាននិយាយថា "*នៅក្នុងឆ្នាំ៧៥ រហូតដល់ពាក់កណ្ដាលឆ្នាំ៧៧គឺមិនទាន់មានជម្លៀសខ្មែរអ៊ីស្លាមទៅណាទេ ។ រហូតដល់ពាក់កណ្ដាលឆ្នាំ៧៧ ទើបគេជម្លៀសរហូតដល់៧៨ ទើបគេឈប់ជម្លៀស*"។[339]

១៥០ សាក្សីឈ្មោះ សឡោះ អះម៉ាត់ បានបន្តរៀបរាប់ថា *"ការជម្លៀសបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៦ ហើយបន្តរហូតដល់ឆ្នាំ១៩៧៨ មុនពេលរំដោះ ។ ការប្រជុំនោះធ្វើឡើង ដើម្បីវាយតម្លៃ ពីការអនុវត្តន៍ផែនការបោសសម្អាតជនជាតិចាម ដើម្បីឱ្យដឹងថាសម្រេចបានប៉ុណ្ណាហើយ"* ។[340] សាក្សីរូបនេះបានបន្ថែមថា *"នៅចុងឆ្នាំ១៩៧៨ មានការប្រជុំមួយដែលមានការចូលរួមពីថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់ និងវត្តមានរបស់ កែ ពក ដោយគេបានសួរថា តើផែនការបក្សត្រូវបានអនុវត្តបានប៉ុន្មានភាគរយហើយ"* ។[341] អត្រាជាភាគរយនៃការជម្លៀសប្រជាជនចាមនេះ មានចំនួនច្រើនជាងប្រជាជនខ្មែរ ដែលត្រូវរងនូវការជម្លៀសចេញពីទីក្រុងភ្នំពេញ និង ទីប្រជុំជនឱ្យទៅតាមទីជនបទផ្សេងៗទូទាំងប្រទេស ។[342]

## ឃ. គោលនយោបាយនៃការបោសសម្អាតនៅភូមិភាគកណ្តាល

១៥១ គោលនយោបាយនៃ ការបោសសម្អាត ការសម្រិតសម្រាំង[343] ឬ វិសុទ្ធកម្ម[344] របស់ ប.ក.ក ត្រូវបានបក្សអនុវត្តចាប់តាំងពីដើមឆ្នាំ១៩៧៧[345] ខណៈកន្លែងខ្លះតាំងពីឆ្នាំ១៩៧៥ នៅតាមបណ្តាភូមិភាគ និង តំបន់ស្វយ័ត[346] ពេញផ្ទៃប្រទេសទាំងមូល ។[347] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថា *"ផ្អែកលើសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គឺជាការប្រគល់តួនាទីកម្ទេចអោយកម្មាភិបាល ពោលគឺជាឯកសារខាងចាត់តាំងដែលគេរក្សាជាសម្ងាត់ប្រហែលជាសម្រាប់តែ**អចិន្ត្រៃយ៍**"* ។[348]

១៥២ រលកនៃការចាប់ខ្លួន ត្រូវបានកើតស្របពេលគ្នា នឹងការកើនឡើងនៃអ្នកឆ្វេងនិយមក្នុងជួរគណៈកម្មាធិការមជ្ឈិមបក្ស ។ ជាក់ស្តែង ការចាប់ខ្លួន **"វន វេត"** ដែលពេលនោះ គាត់មានតួនាទីក្នុងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យ និង ជាឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច ។[349]

១៥៣ អតីតប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន ហៅ ហែម បាននិយាយថា *"គាត់ (វន វេត) ត្រូវគេចាប់ខ្លួន ព្រោះគាត់គឺជាស្ថាប័នរបស់ឃួនបង្កប់ នៅក្នុងបក្សកុំម្មុយនីស្តកម្ពុជា ។ ស្រដៀងគ្នានេះដែរ សោ ភឹម ក៏ត្រូវចាប់ខ្លួនដោយសារមូលហេតុដូចគ្នានេះ"* ។[350] ការអនុវត្តន៍នូវគោលនយោបាយនៃការបោសសម្អាតនេះ ប.ក.ក មានការរំពឹងទុកជាមុនខ្លះនិង



E.C.C.C * C.E.T.C

01581362



មហិច្ឆតាប្រកបដោយភាពជឿជាក់ថា ការបោសសម្អាតសត្រូវផ្ទៃក្នុង មុខជានឹងជួយទប់ស្កាត់នូវការឈ្លានពានណាមួយ ពីសំណាក់បរទេសខាងក្រៅជាក់ជាពុំខាន ។[351]

១៥៤ នៅពាក់កណ្តាលឆ្នាំ១៩៧៧ ការបោសសម្អាត ត្រូវបានចាប់ផ្តើមឡើងជាដំបូងនៅខេត្តសៀមរាប បន្ទាប់មកខេត្តកំពង់ធំ និងជាបន្តបន្ទាប់នៅទូទាំងភូមិភាគកណ្តាលតែម្តង[352] ហើយ បានកើនឡើងខ្លាំងនាឆ្នាំ១៩៧៨ ។[353] ប៉ុន្តែ ភូមិភាគពាយ័ព្យទំនងជាអាចបានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៦ ដោយហេតុថា នៅភូមិភាគនេះបានប្រជុំលើបញ្ហានេះដើម្បីរៀបចំការបោសសម្អាតដោយមានការចូលរួមប្រជុំពីខាងគណៈភូមិភាគ តំបន់ ស្រុក មេឃុំ ប្រធានសហករណ៍ និង មេកង ។[354]

១៥៥ នៅឆ្នាំ១៩៧៧ ការបោសសម្អាតក្នុងភូមិភាគពាយ័ព្យបានអនុវត្តយ៉ាងសកម្ម និងប្រសិទ្ធភាពគួរឱ្យកត់សម្គាល់ ។ សាក្សីឈ្មោះ ប៉ុល សឺន បាននិយាយថា *"នៅដើមឆ្នាំ១៩៧៧ កម្មាភិបាលនិរតី បានមកធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រង នៅភូមិភាគពាយ័ព្យទាំងមូល ដោយដកចេញគណៈភូមិភាគ គណៈតំបន់ គណៈស្រុក និង គណៈឃុំទាំងអស់ ហើយជំនួសដោយមនុស្សមកពីនិរតីទាំងអស់ ។ មនុស្សនិរតីបាននិយាយដែលខ្ញុំបានឮផ្ទាល់ថា កម្មាភិបាលភូមិភាគពាយ័ព្យទាំងអស់ក្បត់"* ។[355] លេខាភូមិភាគពាយ័ព្យឈ្មោះ មូល សម្បត្តិ ហៅ រស់ ញឹម ត្រូវបានចាប់ខ្លួន និង សម្លាប់នៅចុងឆ្នាំ១៩៧៧ ។ [356]

១៥៦ គោលនយោបាយបោសសម្អាតរបស់បក្សកុំម្មុយនីស្តកម្ពុជា ត្រូវបានអនុវត្តចាប់ពីថ្នាក់លើរហូតដល់ក្រោម[357] ដោយអង្គការថ្នាក់លើថា **"ធ្វើម៉េចឱ្យតែបានស្អាត កុំឱ្យមានជនក្បត់នៅក្នុងជួរ"** ។[358] សក្ខីកម្មសាក្សីឈ្មោះ ខៀវ អេន បានបង្ហាញថា *"បើអ្នកណាជាបក្ខជនជាយុវកក បើមកតាមខ្សែមួយណា ហើយខ្សែនោះត្រូវបានចាប់ខ្លួន ពួកគេក៏ត្រូវបានចាប់ខ្លួនដែរ"* ។[359] កន្លងមក អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើការបកស្រាយពាក្យ "សម្រិតសម្រាំង" មានន័យថា ***"ដកសមាសភាពខ្មាំងចេញ ពីក្នុងជួរ ពីក្នុងកងទ័ព ពីក្នុងប្រជាជន ដើម្បីឱ្យជួរឱ្យកងទ័ពឱ្យប្រជាជនស្អាត"*** ។[360] ឌុច បានបញ្ជាក់បន្ថែមថា *ការងារសម្រិតសម្រាំងផ្ទៃក្នុងបក្ស និងផ្ទៃក្នុងប្រជាជន ដែលឥឡូវនេះយើងហៅថា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ វាជាការងាររបស់ទាំងអស់គ្នា ដែលម្នាក់ៗត្រូវបំពេញទៅតាមតួនាទីរបស់ខ្លួនខានមិនបាន* ។[361]

១៥៧ គោលនយោបាយបោសសម្អាតនៅភូមិភាគកណ្ដាល ហាក់ដូចជាបានចាប់ផ្ដើមកើតតាំងពីចុងឆ្នាំ១៩៧៦ ក្រោយពីអង្គការសម្រេចឲ្យមានការចាប់ខ្លួនឈ្មោះ កុយ ធួន ហៅ ធុច ដែលជាអតីតលេខាភូមិភាគឧត្តរ (ក្រោយមកប្ដូរជាភូមិភាគកណ្ដាល) ។[362] កុយ ធួន ត្រូវថ្នាក់លើសម្រេចធ្វើការចាប់ឃុំខ្លួនឲ្យនៅក្នុងផ្ទះតាំងពីថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៧៦ ។[363] ក្រោយមកការចាប់ខ្លួនកម្មាភិបាលភូមិភាគកណ្ដាលផ្សេងៗទៀត បានចាប់ផ្ដើមយ៉ាងខ្លាំងចាប់ពីថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៧ ដោយកម្មាភិបាលជាច្រើនរូប ចាប់ពីថ្នាក់មូលដ្ឋាន សហករណ៍ ឃុំ ស្រុក តំបន់ និងភូមិភាគ បានរងការអនុវត្តន៍គោលនយោបាយនៃការបោសសម្អាតរបស់ ប.ក.ក ។[364] ឌុច បានលើកឡើងថា*"ការចាប់កម្មាភិបាលឧត្តរចាស់ចាប់ផ្ដើមគំហុកតាំងពីដំបូងនៅថ្ងៃ៣១.១.៧៧ ដោយមានកិច្ចសហការពី កែ ពក"* ។[365] នាពេលនោះជាទូទៅប្រសិនបើកម្មាភិបាលណាម្នាក់ត្រូវបានចាប់ខ្លួននោះខ្សែបណ្ដាញ និងសាច់ញាតិនឹងត្រូវរងការចាប់ខ្លួនជាបន្តបន្ទាប់គ្មានសេសសល់ ។[366]

១៥៨ សាក្សីឈ្មោះ ស៊ូ សឿ បាននិយាយថា *"ខ្ញុំឮអំពីការបោសសម្អាត អ្នកដែលជា CIA និង KGB ដែរ ។ នៅពេលដែលមានការចាប់ខ្លួនមនុស្ស គេមិនបានប្រាប់យើងនោះទេ"* ។[367] នៅតាមសហករណ៍ក្នុងស្រុកចំការលើនៃតំបន់ ៤២ ក៏មានការបាត់ខ្លួនមនុស្សជាបន្តបន្ទាប់ ភាគច្រើនជាប្រជាជន១៧មេសា ហើយប្រជាជនមូលដ្ឋាន មានអ្នកខ្លះបាត់ខ្លួនដែរ ។[368] ការបាត់ខ្លួនប្រជាជនពីតាមសហករណ៍ តែងកើតមានជាបន្តបន្ទាប់ ក្រោមហេតុផលថា "**ហៅយកទៅរៀនសូត្រ**" ។[369]

១៥៩ សាក្សីឈ្មោះ បាន សៀក អតីតអនុលេខាស្រុកចំការលើនិងជាអតីតលេខាស្រុកក្រូចឆ្មារ បានផ្ដល់សក្ខីកម្មថា *"ភូមិភាគគ្រប់គ្រងដោយ កែ ពក ជាលេខា ។ កែ ពក គឺជាប្រធានគណៈអចិន្ត្រៃយ៍របស់ភូមិភាគ ... តាមដែលខ្ញុំដឹង ការសម្រេចសំខាន់ៗដូចជា ការបោសសម្អាតជាដើម ត្រូវបានសម្រេចដោយគណៈអចិន្ត្រៃយ៍"* ។[370] គោលនយោបាយបោសសម្អាតត្រូវបានស្ដែងឡើង តាមរយៈសេចក្ដីសម្រេចគណៈកម្មាធិការមជ្ឈិមបក្ស ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ ដែលពាក់ព័ន្ធសិទ្ធិសម្រេចកម្ទេចក្នុងជួរ និងក្រៅជួរ ។

១៦០ ខ្លឹមសារនៃសេចក្ដីសម្រេចក៏បានចែងយ៉ាងច្បាស់ ទាក់ទងការបោសសម្អាត នៅក្នុងភូមិភាគថា បើនៅក្នុងក្របខ័ណ្ឌមូលដ្ឋានត្រូវ "**អចិន្ត្រៃយ៍ភាគសំរេច**" ។[371] ឌុច បានរៀបរាប់ថា

*"ឯកសារនេះមានលក្ខណៈជាប្រវត្តិសាស្ត្រវាបញ្ជាក់ពីរបត់មួយ ពីព្រោះវាបញ្ជាក់ពីការចាប់ផ្តើមនៃការសម្រិតសម្រាំងផ្ទៃក្នុង"* ។[372]

១៦១ សាក្សី ញ៉ែម ចេន និយាយថា *"អ្នកដឹកនាំប្រជុំខ្ញុំឃើញ កែ ពក ហ្នឹងឯងដឹកនាំ ។ កែ ពក ក៏និយាយថា ផែនការមកពីលើដែរ ធ្វើម៉េចចាប់ឱ្យអស់"* ។[373] ក្នុងនាមជាលេខាភូមិភាគ កែ ពក តែងធ្វើការដឹកនាំការប្រជុំណែនាំជានិច្ច អំពីរបៀបចាប់ខ្លួនខ្មាំង ដល់អ្នកនៅក្រោមបង្គាប់ដើម្បីសម្រេចតាមផែនការរបស់ ប.ក.ក ។ សាក្សីឈ្មោះ ញ៉ែម ចេន បន្ថែមទៀតថា *"គាត់ (កែ ពក) និយាយដែរ និយាយរួមខ្មាំង រយៈពេលហ្នឹងឱ្យចុះតាមស្រុក ចាត់ផែនការហ្នឹងទៅស្រុក ទៅដល់អត់ឱ្យឈប់ទេ ចុះតាមស្រុកចាប់ឱ្យរហ័ស ព្រោះផែនការគេជិតដល់ហើយ"* ។[374]

១៦២ ពាក់ព័ន្ធនឹងសិទ្ធិអំណាចនៃការចាប់ខ្លួន សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្តាល បង្ហាញថា *"កែ ពក មិនដែលប្រើសិទ្ធិអំណាចចាប់ខ្លួនមនុស្ស ដោយខ្លួនគាត់ផ្ទាល់ឡើយ គឺរាល់ការចាប់ខ្លួនមនុស្សនៅភូមិភាគកណ្តាល គឺជាការសម្រេចមកពីមជ្ឈិមទាំងអស់"* ។[375] សាក្សីរូបនេះបានបន្ថែមទៀតថា លេខាភូមិភាគ កែ ពក មិនមានសិទ្ធិចាប់ខ្លួនមនុស្សនៅក្នុងភូមិភាគរបស់គាត់ទេ ប៉ុន្តែ កែ ពក មានសិទ្ធិសុំលើកលែងទោសបាន ។[376]

១៦៣ សាក្សីឈ្មោះ ស៊ូ សឿន អតីតលេខាស្រុកចំការលើ បានលើកឡើងដែរថា *"នៅពេលដែលខ្ញុំសួរគេអំពីការបាត់ខ្លួននេះ គេបានប្រាប់ខ្ញុំថា កិច្ចការគេ គេដឹង កិច្ចការខ្ញុំ ខ្ញុំដឹង ។ ខ្ញុំមិនហ៊ានសួរគេទេ ខ្លាចជាប់ដោយទាំងខ្ញុំទៀត"* ។[377] ស្របគ្នាដែរ សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្តាល បានលើកឡើងបញ្ហានេះដែរថា *"បញ្ហាបោសសម្អាត ខ្ញុំមិនសូវដឹងទេ ព្រោះយើងត្រូវធ្វើតាមពាក្យស្លោកបួនយ៉ាងគឺ **មិនដឹង មិនឃើញ មិនឮ និង មិននិយាយ**"* ។[378]

១៦៤ ផលវិបាកជាច្រើនកើតចេញពី គោលនយោបាយបោសសម្អាត ។ សាក្សី ឈួក រីន ជាអតីតកម្មាភិបាលបាននិយាយថា *"រឿងដែលបែកបាក់គ្នាដោយសារនយោបាយរបស់ [illegible] ពិត ដោយសារតែគោលការណ៍បក្សកុំម្មុយនីស្តកម្ពុជាហ្នឹង វាមហាលោតផ្លោះពេក ដែលធ្វើឱ្យ*

*មានការបែកបាក់គ្នា*"។[379] ការបោសសម្អាតបានបណ្តាលឱ្យមាន ការបែកបាក់ផ្ទៃក្នុងរបស់ ប.ក.ក ដោយអតីតខ្មែរក្រហមខ្លះបានរត់ទៅវៀតណាម ហើយអ្នកខ្លះទៀតបានរត់ចូលព្រៃ ។[380]ប្រឈមមុខនឹងផលវិបាកជាច្រើន ដែលកើតចេញពីនយោបាយនៃការបោសសម្អាតនេះ កម្មាភិបាលខ្មែរក្រហមបានដាក់កំហុសលើ ប៉ុល ពត ។[381]

## ខ. ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ

១៦៥ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាក់ទិននឹងការរៀបការ ប្រជាជនអ្នកខ្លះមិនត្រូវគេបង្ខំឱ្យរៀបការទេ[382] ប៉ុន្តែ ភាគច្រើនត្រូវគេបង្ខំឱ្យរៀបការ[383] ហើយបើមិនព្រមអង្គការនឹងយកទៅកសាង[384] ក្រោយមកបើនៅតែមិនព្រមគេនឹងយកទៅសម្លាប់ចោល[385]។ ប៉ុន្តែ ចំពោះកម្មាភិបាលខ្លះ មានការលើកលែង កាលបើកម្មាភិបាលរូបនោះមិនចង់រៀបការ។[386] ការរៀបការដោយបង្ខំ ពុំមែនកើតមានឡើងតែនៅភូមិភាគកណ្តាលទេ ប៉ុន្តែ បញ្ហានេះបានកើតមានស្ទើរតែគ្រប់ភូមិភាគ និងតំបន់ស្វយ័ត ។[387]សក្ខីកម្មសាក្សីឈ្មោះ ឈូក រីន បានបង្ហាញថា "*ខ្ញុំមិនដឹងមូលហេតុទេ ។ យើងនៅជាមួយកុំម្មុយនីស្តគឺត្រូវតែធ្វើតាមបក្ស*"។[388] នៅក្នុងរបបនោះមិនមាននរណាហ៊ានលែងលះគ្នាទេ ។[389]

១៦៦ ឌុច បានលើកឡើងថា "*ខ្ញុំផងដែរបានឮថា តា ម៉ុក ប្រមូលអនាគតប្តីប្រពន្ធជាច្រើនរយគូ ហើយបង្ខំឱ្យរៀបការរួមគ្នា*"។[390] សាក្សីឈ្មោះ ឈឿន សែម បាននិយាយថា "*ខ្ញុំរៀបការនៅឆ្នាំ១៩៧៥ គឺក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ។ ការរៀបការនេះ គឺធ្វើឡើងដោយបង្ខំពីសំណាក់អង្គការ ដោយប្រាប់ថា មិត្តឯងត្រូវរៀបការ*"។[391] អតីតកម្មាភិបាលយោធាមួយរូបនិយាយថា "*ខ្ញុំស្ទុះរៀបការដូចតែគ្នាអីចឹង ខ្ញុំត្រូវគេដាក់រៀបការឱ្យដោយមិនដឹង ។ ខ្ញុំមិនស្គាល់ខាងស្រីទេ ស្រីក៏មិនដឹងថាខ្ញុំប្តីគេដែរ ។ ខ្ញុំរៀបការដោយបង្ខំជាមួយនឹងគូគេច្រើនគូដែរ*" ។[392]

១៦៧ បើទោះបីជា មិនបានដឹងជាមុនអំពីការរៀបការ ហើយអ្នកខ្លះមានគូដណ្តឹងហើយក៏ដោយ ក៏គ្មានអ្នកណាម្នាក់ហ៊ានបដិសេធ ការស្នើឱ្យរៀបការនោះទេ ។[393] មានករណីជាក់ស្តែងមួយបានកើតឡើង ដោយអង្គការបានបង្ខំឱ្យនារីម្នាក់រៀបការ តែត្រូវបាននារីនោះបដិសេធមិនព្រមរៀបការជាមួយបុរសជាជនពិការ ។[394] ក្រោយមកនារីនោះបានសម្លាប់ខ្លួនឯង អ្វីដែល

01581366



ជាផលវិបាកសពនារីនោះ ត្រូវគេយកទៅកប់និងដាក់ច្រវ៉ាក់ពីលើផ្នូរ ហើយមានសរសេរលើផ្នូរថា "**នារីនេះជាមនុស្សក្បាលរឹងក្បត់អង្គការ**" ។[395]

១៦៨ ការរៀបការមិនត្រូវបានអនុញ្ញាត ឱ្យធ្វើតាមប្រពៃណីទំនៀមទម្លាប់ឡើយ ។[396] គេអាចនិយាយបានថា ជាអាពាហ៍ពិពាហ៍ដែលគ្មានភ្លេងខ្មែរ និង គ្មានពិធីជប់លៀង ។[397] ជាធម្មតាក្នុងសង្គមខ្មែរ ការរៀបការធ្វើឡើងម្តងតែមួយគូ ។ ផ្ទុយទៅវិញ របបកម្ពុជា-ប្រជាធិបតេយ្យការរៀបការ អាចមានចាប់តាំងពីមួយគូ[398] ពីរគូ[399] បីគូ[400] បួនគូ[401] លើសពីបួនគូ[402] ឬ ពេលខ្លះដល់លើសពីមួយរយគូក៏មាន[403] ដែលបញ្ហានេះត្រូវបានកើតមានស្ទើរពេញផ្ទៃប្រទេស ។

១៦៩ ជាទូទៅ ក្នុងពិធីរៀបការភាគច្រើនគេសង្កេតឃើញមាន ប្រធានកងជាអ្នករៀបចំដឹកនាំ ។ ជាដំបូងប្រធានកងឡើងចាប់អារម្មណ៍[404] ហើយបុរសនារីដែលត្រូវរៀបការ ត្រូវអង្គការឱ្យអង្គុយទល់មុខគ្នា ដោយបុរសអង្គុយមួយជួរ[405] នារីអង្គុយមួយជួរ[406] ហើយបន្ទាប់មកគូនីមួយៗឡើងធ្វើការប្តេជ្ញាចិត្ត[407]។ ចុងក្រោយ ប្រធានកងតែងធ្វើការប្រកាសថា "**អបអរសាទរមិត្តៗដែលបានរៀបការមានគូស្រករ**" ។[408]

១៧០ នៅតាមមូលដ្ឋានខ្លះ ការរៀបការត្រូវធ្វើឡើងនៅកណ្តាលវាល ដោយបុរសនារីត្រូវរៀបការគេឱ្យអង្គុយផ្ទាល់លើសំបកបាវ ។[409] សំលៀកបំពាក់ របស់បុរសនារីដែលត្រូវរៀបការជាខោអាវពណ៌ខ្មៅ ។ ពេលខ្លះអង្គការឱ្យស្លៀកពាក់ខោអាវរាងថ្មីបន្តិច តែនៅតែខ្មៅដដែល ។[410] ជារួមការរៀបការរបស់កម្មាភិបាល មានភាពប្រសើរជាងប្រជាជនតាមមូលដ្ឋាន។[411]

១៧១ ក្រោយពេលរៀបការរួច ប្តីប្រពន្ធនោះនឹងត្រូវអង្គការអនុញ្ញាត ឱ្យឈប់សម្រាក ខណៈដែលចំនួនថ្ងៃឈប់សម្រាក អាស្រ័យទៅតាមមូលដ្ឋាននីមួយៗដោយខ្លះឱ្យ មួយថ្ងៃ[412] ពីរថ្ងៃ[413] បីថ្ងៃ[414] ឬរហូតដល់កន្លះខែ[415] ។ បន្ទាប់មកពីឈប់សម្រាក អង្គការបញ្ជូនអ្នកទាំងនោះឱ្យទៅធ្វើការតាមភូមិ ហើយជាទូទៅដំបូងហាក់ដូចការងារធូរស្រាលសិន[416] ប៉ុន្តែ អ្នកខ្លះក៏ត្រូវបញ្ជូនទៅធ្វើការនៅកន្លែងផ្សេងតែម្តង[417] ។ ទោះជាយ៉ាងណា ប្តីប្រពន្ធទាំងនោះនឹងត្រូវគេបំបែក មិនឱ្យនៅជួបជុំគ្នាទេ[418] ដោយអង្គការអាចអនុញ្ញាតឱ្យជួបគ្នាបានតែមួយសប្តាហ៍[419] មួយខែ[420] ឬ ពីរខែម្តង[421] ។

១៧២ ឆ្លើយនឹងសំណួរអ្នកស៊ើបអង្កេតសួរថា *"តើគូដែលគេចាប់ដៃគ្នាហ្នឹង គេរីករាយគេទទួលគ្នាជាគូ ឬ ក៏មិនសប្បាយចិត្ត ?"* សាក្សីឈ្មោះ ខិម យ៉ាត បានតបថា *"ឃើញដូចត្រឹមត្រូវមិនអីដែរ ឃើញតែគេពេញចិត្តដែរ"*។[422] ក៏ប៉ុន្តែ មានអត្រាប្តីប្រពន្ធតិចតួចប៉ុណ្ណោះ ដែលអាចរស់ជាមួយគ្នាបានរហូត[423] ខណៈមានគូមួយចំនួន ក៏ត្រូវបានគេយកទៅសម្លាប់ម្នាក់ក៏មាន[424] អ្នកខ្លះទៀតត្រូវបានគេយកទៅសម្លាប់ទាំងពីរនាក់តែម្តងក៏មានដែរ[425] ។

១៧៣ មូលហេតុនៃការរៀបការដោយបង្ខំ ហាក់ដូចជាពុំមានភាពច្បាស់លាស់ទេ ។[426] តាមការយល់ឃើញរបស់អតីតកម្មាភិបាលមួយចំនួន ការរៀបការដែលធ្វើឡើងជាច្រើនគូទំនងជាអង្គការមិនចង់ឲ្យខាតបង់ធនធាន ។[427] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ ឌុច បានលើកឡើងថា *"តាមខ្ញុំការរៀបការជាក្រុមត្រូវបានសម្រេចដោយ គណៈកម្មាធិការអចិន្ត្រៃយ៍មានន័យថាដោយ ប៉ុល ពត ប៉ុន្តែ ជាថ្មីម្តងទៀត ខ្ញុំមិនមានភស្តុតាងនៃនយោបាយសម្រេចថ្នាក់ជាតិទាក់ទងនឹងបញ្ហានេះទេ"* ។[428]

១៧៤ សាក្សីឈ្មោះ សេក សំអាត ហៅ យាយ រឹម ជាអតីតលេខាស្រុកបាកាន បាននិយាយដែរថា *"ខ្ញុំមិនមានគោលការណ៍អីណែនាំថា ត្រូវរៀបការដោយបង្ខំ ជាច្បាប់ជាគោលការណ៍អីមិនមានទេ តែខ្ញុំឃើញរបបហ្នឹង តាំងពីខ្ញុំដឹងមកឃើញតែធ្វើអីចឹង ។ ឃើញតែការរៀបការអត់មានដូចស្រុកពីដើម ចូលស្តីដណ្តឹងអីត្រឹមត្រូវ ។ ដល់សម័យហ្នឹងគឺការច្រើនគូអីចឹង ។ ខ្ញុំអត់មានគោលការណ៍អីទេ អត់ក្តាប់បានគោលការណ៍អីទេ"*។[429]

១៧៥ សាក្សីឈ្មោះ សៅ សារុន ជាអតីតលេខាតំបន់ ១០៥ (ខេត្តមណ្ឌលគិរី) បាននិយាយថា *"ខ្ញុំធ្លាប់ទៅប្រជុំជាមួយ ប៉ុល ពត (មិនចាំពេល) ហើយគាត់និយាយថា ឲ្យរៀបការជាគូៗពីរបីគូក៏រៀបការបានដែរកុំឲ្យលំបាកពេក តែតាមជាក់ស្តែងមួយគូ ក៏ខ្ញុំរៀបការឲ្យដែរ ។ ឪពុកម្តាយ ឬ បងប្អូនដែលរស់នៅសហករណ៍ផ្សេង ឬ នៅតំបន់ផ្សេងក៏អាចចូលរួមបានដែរ ហើយគូស្វាមីភរិយាត្រូវឡើងប្តេជ្ញាចិត្ត ប្រកាសប្រវត្តិរូប និង ស្មោះត្រង់ ចំពោះគ្នាទៅវិញទៅមក"*។[430]

១៧៦ ឌុច បានលើកឡើងដែរថា *"នៅឆ្នាំ១៩៧៦ ខ្ញុំបានចូលវគ្គរៀនសូត្រសម្ងាត់មួយនៅផ្ទះ... ហើយនាពេលនោះ ខ្ញុំបានអានឯកសារមួយ ដែលចេញពីសាខាបក្សដែលខ្ញុំជា...* ។



ECCC * CETC * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*នៅក្នុងឯកសារនោះមានការពន្យល់ថា ការរៀបការត្រូវតែជា មួយប្តូកមួយស្មើពីរគឺ មិនមែនស្មើមួយ ឬ ស្មើសូន្យនោះទេ ។ ខ្ញុំបានបកស្រាយពាក្យស្លោកនេះ តាមរបៀបខាងក្រោម សមាជិកបក្សម្នាក់ ត្រូវស្រឡាញ់តែសមាជិកបក្សដូចគ្នា ។ គឺនៅក្នុងស្មារតីនេះហើយដែលខ្ញុំបានរៀបចំខ្លួនដើម្បីរៀបការ ខ្ញុំមិនអាចរៀបការជាមួយនរណាម្នាក់ ដែលមិនមែនជាសមាជិកបក្សទេ និង ជាពិសេសគឺពួកប្រជាជនថ្មី ។ ខ្ញុំសុំបញ្ជាក់ថា ប្រពន្ធរបស់ខ្ញុំមិនមែនត្រឹមតែជាសមាជិកបក្សប៉ុណ្ណោះទេ គឺជាកសិករកណ្តាលស្រទាប់ក្រោម ហើយមានប្រភពចេញពីមូលដ្ឋានបដិវត្តន៍*” ។[431]

១៧៧ រីឯ កងទ័ពក៏ត្រូវគេបង្ខំឲ្យរៀបការដែរ ក្រោមការចាត់ចែងរបស់សាមីប្រធានអង្គភាព ។[432] សាក្សី ឈ្មោះ រីន ជាអតីតកងទ័ពលើកឡើងថា “*ការបង្ខំឲ្យរៀបការហ្នឹង គឺកើតមានមែនពីព្រោះថា បើគេកំណត់ឲ្យរៀបការគឺត្រូវតែរៀបការ*” ។[433] ជាទូទៅ ចំពោះនារីត្រូវអង្គការបង្ខំឲ្យរៀបការជាមួយកងទ័ព ពេលខ្លះជាមួយកងទ័ពដែលពិការ ដោយពួកគាត់មានសិទ្ធិស្នើសុំជាអាទិភាព ។[434] អ្នកដែលមិនពេញចិត្តនឹងគូរបស់ខ្លួនមិនហ៊ានតវ៉ាទេ ដោយខ្លាចអង្គការយកទៅសម្លាប់ ។[435]

១៧៨ មានការតាមដានគូស្រករជាប្តីប្រពន្ធទើបរៀបការថ្មីថ្មោង កើតឡើងមែនដោយឈ្លបតាមដានលួចស្តាប់ពីក្រោមផ្ទះពីរទៅបីថ្ងៃ ហើយប្រសិនបើមានប្តីប្រពន្ធណាមិនព្រម ឬឈ្លោះប្រកែកគ្នា អង្គការនឹងនាំយកទៅអប់រំ ហើយពេលខ្លះក៏ត្រូវបាត់ខ្លួន ។[436] ជាក់ស្តែង ការរួមដំណេករបស់ប្តីប្រពន្ធថ្មីថ្មោងមួយចំនួន អាចត្រូវធ្វើឡើងទាំងបង្ខំចិត្ត ដោយសារព្រួយបារម្ភណ៍ដល់សុវត្ថិភាពអាយុជីវិត[437] ដោយហេតុថា អ្នកបដិសេធមិនព្រមរួមដំណេកត្រូវគេចាត់ទុកជាខ្មាំង ដោយត្រូវរងការព្រមាន ឬ ចាប់យកសម្លាប់ចោលក៏មាន ។[438] ករណីប្តីប្រពន្ធចុះសម្រុងដំណេកគ្នា ការតាមដានខាងក្រោមផ្ទះក៏លែងមានទៀតដែរ ។[439] ប៉ុន្តែ ការលួចតាមដានរបស់ឈ្លប ចំពោះប្តីប្រពន្ធលើបញ្ហារួមដំណេក ពុំឃើញមានឯកសារណែនាំឲ្យបានប្រាកដប្រជាចេញមកពីបក្សលើបញ្ហានេះទេ ។

១៧៩ ឌុច ក៏បានលើកឡើងត្រង់បញ្ហានេះដែរថា “*តាមខ្ញុំដឹងមិនមានវិធានការជាក់លាក់ ដើម្បីតាមដាននោះទេ ប៉ុន្តែ មានកម្មាភិបាលខូចមួយចំនួន បានបញ្ជាឲ្យគេតាមដានមើលថា ប្តីប្រពន្ធមានបានរួមដំណេកជាមួយគ្នាដែរឬទេ ។ ចំណុចនេះ គឺមិនទាក់ទងនឹងបញ្ហារៀបការ*

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅផ្លូវជាតិលេខ៤ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ប្រអប់សំបុត្រលេខ ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៩៨១៤ ទូរសារលេខ +៨៥៥(0)២៣ ២១៩៨៤១ ។

01581369



*រៀបការដោយបង្ខំនោះទេ"* ។[440] ឌុច នៅបានបន្ថែមទៀតថា "*ប្រធានគណៈកម្មាធិការមន្ទីរពេទ្យយោធា៩៨ ដែលបានបញ្ជាឱ្យកូនចៅគាត់ទៅតាមដានប្ដីប្រពន្ធថា តើពួកគេមានបានរួមដំណេកជាមួយគ្នាឬអត់ ។ គាត់ត្រូវបានដាក់ទណ្ឌកម្មដោយសារបានធ្វើបែបនេះ ។ ជាដំបូងគាត់ត្រូវសុំទោសប្ដីប្រពន្ធនោះ បន្ទាប់មកដោយសារ មានចំនុចផ្សេងទៀត ដែលត្រូវស្ដីបន្ទោសគាត់ គាត់ត្រូវបានចាប់ខ្លួន បញ្ជូនទៅ ស-២១ និង សម្លាប់ចោល"* ។[441]

## ច. រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់មូលដ្ឋាន

### ១. ភូមិភាគ

១៨០ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានភូមិភាគចំនួន ៦ (ប្រាំមួយ) រួមមាន[442] ភូមិភាគនិរតី[443] ភូមិភាគបស្ចិម[444] ភូមិភាគពាយ័ព្យ[445] ភូមិភាគកណ្ដាល[446] (អតីតភូមិភាគឧត្ដរ[447]) ភូមិភាគឦសាន[448] និង ភូមិភាគបូព៌ា[449] ។ ក្រៅពីនេះក៏មានតំបន់ស្វយ័តមួយចំនួន[450]មាន៖ កំពង់សោម[451]មណ្ឌលគីរី(តំបន់១០៥)[452]ព្រះវិហារ(តំបន់១០៣)[453]ក្រចេះ(តំបន់៥០៥)[454] ជាអាទិ៍ ។ រចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាល មានតាមឋានានុក្រមពីលើទៅក្រោមដូចជា៖[455] ភូមិភាគ[456] តំបន់[457] ស្រុក[458] ឃុំ[459] ភូមិ[460] សហករណ៍[461] ក្រុម[462] កង[463] កងចល័ត[464] និង កងកុមារ[465] ។

១៨១ នៅថ្នាក់ភូមិភាគ សន្និបាតភូមិភាគជាអង្គការដែលមានឋានានុក្រមខ្ពស់បំផុត ។[466] ភូមិភាគនីមួយៗត្រូវបានដឹកនាំដោយ លេខាភូមិភាគមួយរូប[467] អនុលេខាភូមិភាគមួយរូប[468] ព្រមទាំងសមាជិកគណៈភូមិភាគ[469] ។ ដូចគ្នាដែរចំពោះការដឹកនាំរបស់តំបន់ស្វយ័ត ។[470] ចាប់ពីលេខាភូមិភាគឡើងទៅភាគច្រើន ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស[471] ហើយសមាជិកគណៈភូមិភាគមួយចំនួនតូចប៉ុណ្ណោះ អាចជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស ។[472]

១៨២ ភូមិភាគមានឋានានុក្រមរដ្ឋបាលត្រួតលើ តំបន់ ស្រុក ឃុំ ភូមិ និង សហករណ៍ ។[473] ហេតុនេះបណ្ដាភូមិភាគក៏ត្រូវបានបែងចែកជាតំបន់ ខណៈតំបន់ត្រូវបានបែងចែកការគ្រប់គ្រងបន្តទៅថ្នាក់ស្រុក រីឯ ស្រុកក៏ត្រូវគ្រប់គ្រងបន្តលើភូមិ សហករណ៍ជាបន្តនៅតាមមូលដ្ឋាន



E.C.C.C * C.E.T.C

ដ្ឋានផ្ទាល់តាមកងចល័ត ។[474] ជាក់ស្តែង កងចល័តតាមស្រុកនីមួយៗ មានសមាជិកប្រហែល ៣.០០០ (បីពាន់) នាក់ ។[475]

## ២. ខ្សែបញ្ជា

១៨៣ នៅពេលមានសេចក្តីសម្រេចពី គណៈកម្មាធិការមជ្ឈិមបក្ស ឬ គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស យន្តការនៃការផ្សព្វផ្សាយត្រូវបានអនុវត្តដល់ លេខាភូមិភាគ និង លេខាតំបន់ស្វយ័ត ដែលនឹងត្រូវមានកាតព្វកិច្ចធ្វើការ ផ្សព្វផ្សាយនូវគោលនយោបាយ និងសេចក្តីណែនាំជាបន្តទៅឱ្យលេខាតំបន់ និង លេខាស្រុក ដើម្បីអនុវត្តតាមគោលនយោបាយដែលអង្គការថ្នាក់លើដែលបានដាក់ចុះ ។[476]

១៨៤ រីឯ យន្តការនៃការរាយការណ៍ត្រលប់មកវិញ ឃុំនានាត្រូវរាយការណ៍ត្រឡប់ទៅគណៈស្រុក គណៈស្រុកត្រូវរាយការណ៍ជាបន្តទៅគណៈតំបន់ ។ គណៈតំបន់មានកាតព្វកិច្ចត្រូវរាយការណ៍ជាបន្តទៅគណៈភូមិភាគ ។ លក្ខន្តិកៈបក្សកុំម្មុយនីស្តកម្ពុជា ក៏បានចែងដែរថា "*អង្គការដែលមានសិទ្ធិ និង អំណាចខ្ពស់ជាងគេបំផុត សម្រាប់ភូមិភាគនីមួយៗនោះគណៈកម្មាធិការភូមិភាគ*" ។[477]

## ៣. ភូមិភាគនិរតី

១៨៥ ភូមិភាគនិរតីត្រូវបានបែងចែកជា ៤ (បួន) តំបន់រួមមាន៖ តំបន់ ៣៥[478](ខេត្តកំពត)[479] តំបន់ ១៣[480](ខេត្តតាកែវ)[481] តំបន់ ៣៣ (ស្រុកសំរោងទង ស្រុកគងពិសីខេត្តកំពង់ស្ពឺ)[482] និង តំបន់ ២៥ (មួយផ្នែកនៃខេត្តកណ្តាល) ។[483] ភូមិភាគនិរតីមានឈ្មោះ អ៊ុង ជឿន ឬ ឈិត ជឿន ហៅ តា ម៉ុក ត្រូវបានតែងតាំងជាលេខាភូមិភាគនេះ ចាប់តាំងពីកកើតរហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។[484]

## ៣.១. តំបន់ ១៣

១៨៦ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា **អោ អាន** ជាស្ថាបនិកមន្ទីរសន្តិសុខ និងកន្លែងសម្លាប់មនុស្សក្រាំងតាចាន់ ។[485] ទីតាំងនេះជាកម្មវត្ថុនៃការចោទប្រកាន់ផងដែរ ក្នុងសំណុំរឿង០០២ ហើយ ដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០២ បានរៀបរាប់លម្អិតរួចរាល់ហើយ ។[486]

១៨៧ សាក្សីបានអះអាងថា ឡេង អាន់ ជាអនុប្រធាន ក្នុងឆ្នាំ១៩៧៤ ហើយក្រោយមកក្លាយជាប្រធានមន្ទីរសន្តិសុខ រហូតដល់ឆ្នាំ១៩៧៨[487] ជាឆ្នាំដែលគាត់ត្រូវបានគេចាប់យកទៅសម្លាប់ ។[488] វាអាចមានការភាន់ច្រឡំថា អាន់ ថាជា អាន ដែលនាំឲ្យសន្និដ្ឋានថា **អោ អាន** ជាស្ថាបនិកនៃមន្ទីរសន្តិសុខនេះ ។ សាក្សីជាច្រើនបានអះអាងផ្ទុយពីនេះថា **អោ អាន** មិនធ្លាប់មានប្រវត្តិធ្វើការក្នុងស្រុកត្រាំកក់ ខេត្តតាកែវ តំបន់ ១៣ ភូមិភាគនិរតីទេ[489] ដែលជាកន្លែងដែលមន្ទីរសន្តិសុខតាំងនៅ ។ លើសពីនេះទៀត សាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) បាននិយាយកាន់តែយ៉ាងច្បាស់ទៀតថា *"**អាន** ដែលជាអនុរបស់ កែពក ។ **អាន** នេះមិនធ្លាប់ធ្វើការនៅមន្ទីរសន្តិសុខក្រាំងតាចាន់ទេ"* ។[490] ជាសរុប លទ្ធផលនៃការស៊ើបអង្កេត មិនបានបង្ហាញថា **អោ អាន** ជាស្ថាបនិកនៃមន្ទីរសន្តិសុខទេ ។

## ៣.២. តំបន់ ២៥

១៨៨ នៅមុនឆ្នាំ១៩៧៥ តំបន់ ២៥ ស្ថិតនៅក្នុងភូមិភាគពិសេស ។[491] ប៉ុន្តែ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ តំបន់ ២៥ ត្រូវបានអង្គការថ្នាក់លើសម្រេចដាក់ចូលជាផ្នែកមួយនៃភូមិភាគនិរតី ។[492] តំបន់ ២៥ មានវិសាលភាពគ្របដណ្តប់មួយផ្នែកនៃខេត្តកណ្តាលដែលមាន ៥ (ប្រាំ)[493] ស្រុកដូចជា៖ ស្រុកកណ្តាលស្ទឹង[494] ស្រុកស្អាង[495] ស្រុកកោះធំ[496] ស្រុកកៀនស្វាយ[497] និង ស្រុកខ្សាច់កណ្តាល[498] ។

១៨៩ គណៈកម្មាធិការតំបន់ ២៥ មាន៖ លេខាតំបន់ អនុលេខា និងសមាជិកគណៈតំបន់ត្រូវបានធ្វើការផ្លាស់ប្តូរជារឿយៗ និងពុំមានភាពច្បាស់លាស់លើពេលវេលាទេ ។[499] ចាប់តាំងពីមុន និងក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មានឈ្មោះ ជ័យ ជាលេខាតំបន់ សុខ ប៊ុតចំរើន

01581372



ជាអនុលេខាតំបន់ ហើយឈ្មោះ ហួត សី ជាសមាជិកគណៈតំបន់ ។[500] បន្ទាប់មក ចាប ចៀល បានក្លាយជាលេខាតំបន់ វីង ប្រាក់ ជាអនុលេខាតំបន់ ។[501] ក្រោយមកទៀត គណៈតំបន់ ២៥ មានសមាជិក ៤ (បួន) រូប៖ ជា[502] លេខាតំបន់, ប្រាក់[503] អនុលេខា, ស៊ាន[504] និង **អាន**[505] ជាសមាជិក ។[506] លេខាតំបន់ ជា ត្រូវបានចាប់ខ្លួននៅខែសីហា ឬ ខែកញ្ញា ឆ្នាំ១៩៧៧ [507] បន្ទាប់មក ប្រាក់ ឡើងជាលេខាតំបន់ជំនួស ជា ។[508]

១៩០ សាក្សីបាននិយាយថា នាអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៧០ **អោ អាន** ក៏ធ្លាប់មានតួនាទីជាមេបញ្ជាការកងទ័ពនៅថ្នាក់តំបន់ ដោយទទួលបន្ទុកក្នុងស្រុកកណ្តាលស្ទឹង ។[509] ឆ្នាំ១៩៧២-១៩៧៣ **អោ អាន** ត្រូវបានផ្លាស់ឲ្យទៅបំរើការងារ នៅខាងត្បូងក្រុងភ្នំពេញស្ថិតនៅក្នុងស្រុកកណ្តាលស្ទឹង ។[510] **អោ អាន** ក៏ធ្លាប់ជាលេខាស្រុកស្អាងក្នុងរយៈពេលមួយដ៏ខ្លី ។[511] នៅខែកុម្ភៈ ឆ្នាំ១៩៧៦ **អោ អាន** ត្រូវបានផ្ទេរពីតំបន់ ២៥ ទៅធ្វើការនៅតំបន់ ៣៥ ភូមិភាគនិរតី ។[512]

## ៣.៣. តំបន់ ៣៥

១៩១ តំបន់ ៣៥ ជាតំបន់មួយស្ថិតនៅក្នុងភូមិភាគនិរតី ក្រោមការគ្រប់គ្រងលេខាភូមិភាគនិរតី ឈ្មោះ តា ម៉ុក ។[513]តំបន់ ៣៥ នៃភូមិភាគនិរតីមាន ៥ (ប្រាំ) ស្រុករួមមាន៖ ស្រុកកោះស្លា ស្រុកកំពត ស្រុកទូកមាស ស្រុកកំពង់ត្រាច និង ស្រុកឈូក ។[514] គណៈកម្មាធិការតំបន់ ៣៥ ភូមិភាគនិរតីមានសមាសភាព៖ កង ចាប[515] ជាលេខាតំបន់ **អាន**[516] អនុលេខា, សោម ផន[517], សៀន[518], តាទី[519], យុត[520], និង តា មុត ជាសមាជិកតំបន់ ។[521]

១៩២ ក្នុងតួនាទីក្នុងជួរគណៈតំបន់ **អោ អាន** ត្រូវបានថ្នាក់លើឲ្យទទួលបន្ទុកលើការងារជីកទំនប់ និង លើកប្រឡាយ ។[522] ក្រៅពីនេះ **អោ អាន** ក៏អាចធ្លាប់ធ្វើជាប្រធានមន្ទីរតំបន់ ៣៥ បានមួយរយៈដែរ ។ សាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) បញ្ជាក់ថា *"ខ្ញុំលួចសួរគេហើយគេប្រាប់ថា គាត់(**អោ អាន**) ធ្លាប់ជាប្រធានមន្ទីរតំបន់ ៣៥ ក្នុងខេត្តកំពត"* ។[523] **អោ អាន** អាចនៅមានតួនាទីមួយទៀត នេះបើតាមសាក្សីមួយរូប បាននិយាយថា *"គាត់ (**អោ អាន**) គឺជាគណៈស្រុកកោះស្លា"* ។[524]



E.C.C.C * C.E.T.C

១៩៣ អោ អាន ក្រោយពីផ្លាស់មកធ្វើការនៅតំបន់ ៣៥ បានប្រហែល ១ (មួយ) ឆ្នាំ ត្រូវអង្គការថ្នាក់លើសម្រេច ធ្វើការចាត់តាំងឲ្យទៅបំរើការងារនៅភូមិភាគកណ្តាល ។[525] នាពេលនោះ កង ចាប ដែលជាលេខាតំបន់ ៣៥ នៃភូមិភាគនិរតីក៏ត្រូវផ្ទេរទៅភូមិភាគកណ្តាលដែរ ហើយឈ្មោះ សំ ប៊ិត ក៏ត្រូវបានថ្នាក់លើតែងតាំងឲ្យធ្វើជាលេខាតំបន់ ៣៥ ជំនួសវិញ ។[526]

## ៤. ភូមិភាគកណ្តាល

១៩៤ ក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ភូមិភាគឧត្តរត្រូវបានបញ្ចប់ដោយសារវិសាលភាពភូមិភាគមានទំហំធំពេក ។[527] ភូមិភាគឧត្តរត្រូវបានបែងចែកជា ២ (ពីរ) [528]មាន៖ ភូមិភាគកណ្តាល[529] និងភូមិភាគឧត្តរថ្មី[530]។ សាក្សី សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្តាល បានលើកឡើងថា "*ភូមិភាគឧត្តរថ្មី និង ភូមិភាគកណ្តាល បង្កើតឡើងក្នុងឆ្នាំ១៩៧៥ ប្រហែលជា ពីរ ឬ បី ខែក្រោយថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥*"។ [531] ចំណែកឯភូមិភាគឧត្តរចាស់[532] ត្រូវបានអង្គការថ្នាក់លើប្តូរឈ្មោះទៅជា ភូមិភាគ-កណ្តាល ជំនួសវិញ ។[533] ចំពោះភូមិភាគកណ្តាលដែលជាអតីតភូមិភាគឧត្តរចាស់ ក៏ត្រូវបានបែងចែកជា ៣ (បី)[534]តំបន់រួមមាន តំបន់៤១[535] តំបន់ ៤២[536] និង តំបន់ ៤៣[537] ។

១៩៥ ដំបូងភូមិភាគឧត្តរមានឈ្មោះ កុយ ធួន[538]ហៅ ធុច[539]ហៅ ឃួន[540] ជាលេខាភូមិភាគ[541] ហើយ កែ ពក ជាអនុលេខាភូមិភាគ[542] និងជាសេនាធិការភូមិភាគដែលមានតួនាទីគ្រប់គ្រងរួម ។[543] បន្ទាប់ពីរំដោះនាខែមេសា ឆ្នាំ១៩៧៥ កែ ពក បានក្លាយជាលេខាភូមិភាគឧត្តរ ខណៈដែលលេខាភូមិភាគ កុយ ធួន ត្រូវបានអង្គការថ្នាក់លើតែងតាំងជាប្រធានគណៈកម្មា-ធិការពាណិជ្ជកម្ម[544] ហើយដែលត្រូវផ្ទេរមកធ្វើការនៅក្រុងភ្នំពេញ ។[545]

១៩៦ បន្ទាប់ពីផ្លាស់មកបំរើការនៅភ្នំពេញមិនបានប៉ុន្មានផង កុយ ធួន ហៅ ធុច ក៏ត្រូវបានថ្នាក់លើសម្រេចឲ្យចាប់ខ្លួនដោយមន្ទីរសន្តិសុខ ស-២១ នៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៧៧ មានលេខរៀងទី ៦១៦៥ ក្នុងបញ្ជីឈ្មោះអ្នកទោសនៅមន្ទីរសន្តិសុខ ស-២១ ។[546] អំណេះក្រោយមកចាប់តាំងពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៧៧ ការចាប់ខ្លួនកម្មាភិបាលផ្សេងៗទៀតនៅភូមិភាគកណ្តាល (អតីតភូមិភាគឧត្តរ) បានកើតមានជាបន្តបន្ទាប់ ដោយអង្គការបានចោទប្រកាន់ថាជាប់ខ្សែរយៈ កុយ ធួន [547] ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

១៩៧ ការចាប់ខ្លួនកម្មាភិបាល ពាក់ព័ន្ធនៅភូមិភាគកណ្ដាលស្ទើរតែទាំងអស់តែម្ដង លើកលែងតែ កែ ពក តែម្នាក់គត់ដែលត្រូវបានគេគិតថា ជាអ្នកស្អាតស្អំបំផុតក្នុងភូមិភាគ ។[548] ជាក់ស្ដែង តាមលទ្ធផលបែបនេះ និង ក្រោយពីការបំបែកភូមិភាគឧត្ដរ អង្គការថ្នាក់លើបានតែងតាំង កែ ពក[549] ជាលេខាភូមិភាគកណ្ដាល រីឯអតីតលេខាតំបន់ ៣៥ កង ចាប[550]ហៅ សែ[551] ត្រូវបានក្លាយជាលេខាភូមិភាគឧត្ដរថ្មី ។[552] សាក្សីឈ្មោះ ព្រំ ស៊ូ បាននិយាយថា "*នៅចុង ឆ្នាំ១៩៧៧ ... នួន ជា បានប្រកាសបង្កើតភូមិភាគឧត្ដរថ្មី និងតែងតាំង កង ចាប ហៅ សែ ជាលេខាភូមិភាគឧត្ដរថ្មី*" ។[553]

១៩៨ នៅដើមដំបូងគណៈកម្មាធិការភូមិភាគកណ្ដាលមាន កែ ពក[554] ជាលេខាភូមិភាគ, អាង[555] ជាអនុលេខា, ស៊ីម[556](ជាក្មួយប្រសារតាម៉ុក) ជាសមាជិកគណៈភូមិភាគ ។[557] សាក្សីឈ្មោះ ទេព ប៉ូច អតីតលេខាស្រុកបារាយណ៍ បាននិយាយថា "*តាមខ្ញុំដឹងឈ្មោះ ស៊ីម គឺជាអនុម្នាក់របស់ កែ ពក ហើយឈ្មោះ ចន ដែលជាលេខាតំបន់ ៤៣ គឺជាអនុម្នាក់ទៀត*" ។[558] ក្រោយមកគណៈកម្មាធិការភូមិភាគកណ្ដាលមានសមាជិក ៥ (ប្រាំ) រូប៖ កែ ពក ជាលេខាភូមិភាគ, ស្រេង អនុលេខា, តុល, ចន, និង អឿន ជាសមាជិកគណៈភូមិភាគ ។[559]

១៩៩ បន្ទាប់មក នៅពេលក្រុមនិរតីចូលមក គណៈកម្មាធិការភូមិភាគកណ្ដាល ត្រូវបានផ្លាស់ប្ដូរសមាសភាពមួយចំនួនជាបន្តទៀតដោយ កែ ពក ជាលេខាភូមិភាគ[560], **អោ អាន** ជាអនុលេខា[561], អឿន[562], ស៊ីម[563], និង យុត[564] ជាសមាជិក ។[565] ជាក់ស្ដែង ក្រោយពី ស្រេង អនុលេខាភូមិភាគ ត្រូវបានថ្នាក់លើចាប់ខ្លួន គេបានយកមនុស្សមកពីក្រុមនិរតីមកជំនួសនៅពេលក្រោយមកគឺ **អោ អាន** ។[566] បើផ្អែកលើទំព័រក្របមុខនៃចម្លើយសារភាពមន្ទីរសន្ដិសុខ ស-២១ ទាក់ទិនចម្លើយសារភាពរបស់ឈ្មោះ ជ ឆាន ហៅ ស្រេង ដោយមានសំណេរជាលាយលក្ខណ៍អក្សរ វាបានបញ្ជាក់ឱ្យឃើញថា ស្រេង ត្រូវបានឃាត់ខ្លួននៅ**ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧** ។[567]

២០០ បើតាមអះអាង ក្នុងសក្ខីកម្មសាក្សីឈ្មោះ សួន កានិល ដែលជាអតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល និង ព័ត៌មានស្ដីពីថ្ងៃចាប់ខ្លួនអនុលេខាភូមិភាគ ស្រេង ដែលមាន នៅទំព័រមុខនៃចម្លើយសារភាពរបស់អ្នកទោសនៅមន្ទីរសន្ដិសុខ ស-២១ ជនត្រូវចោទ **អោ អាន** អាចបានឡើងជំនួស ស្រេង ក្រោយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧ តែមិនមុន

ភ្លាមទេ ។ គេពុំឃើញមានពិធីប្រកាស ឬ លិខិតជាផ្លូវការណាមួយពាក់ព័ន្ធតួនាទី **អោ អាន** ជាអនុលេខាភូមិភាគកណ្តាល ។[568] ប៉ុន្តែ សាក្សីឈ្មោះ គុច វ៉ា បាននិយាយថា *"តួនាទី តា អាន ជាអនុលេខាភូមិភាគ គឺត្រូវបានប្រកាសជាផ្លូវការនៅក្នុងសន្និបាតក្នុងភូមិភាគ"* ។[569]

២០១ ការណ៍នេះបង្ហាញឲ្យឃើញ នូវភាពស៊ីសង្វាក់គ្នាទៅនឹងព្រឹត្តិការណ៍ដែលពួកនិរតី ចេញទៅពាយ័ព្យប្រហែលជានៅក្នុងខែមីនា ឆ្នាំ១៩៧៧ ។[570] សាក្សីមួយរូបលើកឡើងថា *"ខ្ញុំនៅចាំថាមាន តា អាន ដែលទៅជាមួយគ្នានោះដែរ ប៉ុន្តែគាត់ជិះឡានផ្សេង"* ។[571] សាក្សីជាអតីតបុគ្គលិកតំបន់ ៣៥ លើកឡើងដែរថា *"តា អាន ចេញទៅកំពង់ចាមម៉ុំខែមេសាឬឧសភាក្នុងឆ្នាំ១៩៧៧"* ។[572] ប៉ុន្តែ បើតាមរយៈការសាកសួរសាក្សីកន្លងមក ឃើញថាមានតែសាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) តែម្នាក់គត់ដែលបានផ្តល់សក្ខីកម្មថា *"ខ្ញុំ តា អាន និង តា ស៊ឹម គឺចេញទៅភូមិភាគកណ្តាលនៅថ្ងៃជាមួយគ្នា ... **នៅថ្ងៃទី១៤ ខែ២ ឆ្នាំ១៩៧៦** ខ្ញុំបានទៅដល់ភូមិភាគកណ្តាល"* ។[573] សាក្សីរូបនេះនៅបានបន្ថែមថា **តា អាន** បានធ្វើដំណើរទៅដល់ភូមិភាគកណ្តាលក្នុងថ្ងៃជាមួយគ្នាពុំមែនក្នុងឆ្នាំ១៩៧៧ ទេ ។[574]

២០២ តាមឯកសារជាលាយលក្ខណ៍អក្សររបស់ កែ ពក ដែលជាថ្នាក់ដឹកនាំកំពូលរបស់ភូមិភាគកណ្តាលបានបង្ហាញថា **នៅខែមិថុនា ឆ្នាំ១៩៧៧** កម្មាភិបាលនិរតីបានមកភូមិភាគកណ្តាល ។ ជាក់ស្តែងឯកសារនោះ បានសរសេរថា *"... ដល់ខែមិថុនា ឆ្នាំ១៩៧៧ ចប់ការចាប់មួយវគ្គដំបូងហើយ ។ ពេលនោះនៅសល់តែខ្ញុំ (កែ ពក) ពេលនោះធ្វើការពិនិត្យនៅភូមិភាគកណ្តាលអស់កម្មាភិបាល ។ ខាងលើក៏សម្រេចយកកម្មាភិបាលពីនិរតីមកដាក់ ។ ខាងលើហៅកម្មាភិបាលនិរតីមក ២០០ នាក់ជាង"* ។[575] ចំណុចនេះស៊ីសង្វាក់គ្នានឹងចម្លើយដែលទទួលបានពីជាសក្ខីកម្មសាក្សីជាច្រើនមានចំនួនរហូតដល់ ៣៤ (សាមសិបបួន) នាក់ ។[576]

២០៣ ជាក់ស្តែង សាក្សីជាបានច្រើនបានឆ្លើយស្រដៀងៗគ្នាថា **ប្រហែលជានៅពាក់កណ្តាលឆ្នាំ ១៩៧៧** ទើបបាន **អោ អាន** ត្រូវផ្ទេរទៅភូមិភាគកណ្តាល ។[577] ខណៈដែលសាក្សីផ្សេងទៀតលើកឡើងថា កម្មាភិបាលក្នុងតំបន់ ៣៥ នៃភូមិភាគនិរតីប្រមាណជា ៤០ (សែសិប) រូបដោយ ក្នុងនោះក៏មាន **អោ អាន** ត្រូវបានផ្លាស់ចេញទៅបំរើការនៅតំបន់ផ្សេងៗទូទាំងភូមិភាគកណ្តាល ។[578] ក្រោយពេលការមកដល់របស់ក្រុមនិរតីក្នុងភូមិភាគកណ្តាល លេខា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ភូមិភាគកណ្ដាល កែ ពក បានចាត់ចែងធ្វើការបែងចែកឱ្យអ្នកទាំងនោះឱ្យតាមតំបន់ និង ស្រុកភ្លាមៗតែម្ដង ។[579]

២០៤ ភូមិភាគកណ្ដាលមានមន្ទីរសំខាន់ៗចំនួនពីរ ដែលដឹកនាំការងារទាំងមូលមាន៖ មន្ទីរគណៈភូមិភាគកណ្ដាល និង មន្ទីរកណ្ដាល (ឬមន្ទីរ៧១) ។[580] មន្ទីរគណៈភូមិភាគកណ្ដាលមានទីតាំងស្ថិតនៅទីរួមខេត្តកំពង់ចាមបច្ចុប្បន្ន (ឆ្នាំ២០១៨) ត្រង់សណ្ឋាគារ ៧ មករា ។[581] សាក្សីឈ្មោះ កែ អ៊ុន ហៅ ឌិក ជាអតីតអ្នកបើកឡានឱ្យលេខាភូមិភាគកណ្ដាល កែ ពក និងជាក្មួយបង្កើតរបស់ កែ ពក បានលើកឡើងថា *"ខ្លួនធ្លាប់បើកឡានជូន កែ ពក ទៅមន្ទីរ ៧១ ដែលមានទីតាំងស្ថិតនៅក្នុងឃុំតាប្រុក ស្រុកចំការលើ ខេត្តកំពង់ចាម"*។[582] មន្ទីរកណ្ដាលជាការិយាល័យ កែ ពក ហើយក៏ជាកន្លែងអាចចាត់ចែងការងារដ៏សំខាន់បំផុតមួយនៅភូមិភាគកណ្ដាល ។[583] ការចាត់ចែងការងារទូទៅ និងសំខាន់ៗ របស់ភូមិភាគកណ្ដាល ត្រូវនៅលើមន្ទីរគណៈភូមិភាគកណ្ដាល ដែលស្ថិតនៅទីរួមខេត្តកំពង់ចាម ។[584]

២០៥ ថ្នាក់ភូមិភាគជាទូទៅតែងមានការប្រជុំចំនួន ២ (ពីរ) ដងក្នុងមួយខែ ។[585] នៅពេលមានកិច្ចប្រជុំផ្ទៃក្នុងថ្នាក់ភូមិភាគម្ដងៗមានតែលេខាភូមិភាគ កែ ពក តែម្នាក់គត់មានសិទ្ធិធ្វើជាប្រធានអង្គប្រជុំ[586] និងដឹកនាំកិច្ចប្រជុំប្រចាំខែជាទៀងទាត់ ហើយគ្មានអ្នកផ្សេងណាអាចជំនួសគាត់បានឡើយ ។[587] ចំពោះការប្រជុំនៅភូមិភាគនេះ ជាធម្មតា មានការចូលរួមពីគណៈតំបន់ គណៈស្រុក និង គណៈឃុំ ដោយត្រូវរាយការណ៍អំពីលទ្ធផលការងារ ។[588] រីឯ ការប្រជុំពិសេស មានតែគណៈកម្មាធិការភូមិភាគកណ្ដាលទេ ដែលមានសិទ្ធិចូលរួមបាន ។[589]

## ៤.១. អំណាចលេខាភូមិភាគកណ្ដាល កែ ពក

២០៦ លេខាភូមិភាគ កែ ពក មានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ជាមួយសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុំម្មុយនីស្តកម្ពុជា ។[590] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច បាននិយាយថា *"កែ ពក ជួនកាលក៏ត្រូវបានកោះអញ្ជើញឱ្យចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្សកុំម្មុយនីស្តកម្ពុជាដែរ"*។[591] អតីតប្រធានមន្ទីរសន្តិសុខរូបនេះ នៅនិយាយចំៗថា *"មានថ្ងៃមួយមានមនុស្សម្នាក់ដែលមកពីភូមិ*



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*ភាគកណ្តាល បាននិយាយនៅក្នុងចម្លើយសារភាពរបស់គាត់ថា កែ ពក បានក្បត់ដោយស្តុកអាវុធនៅខេត្តកំពង់ចាមនៅវត្តធីជុះ ។ ខ្ញុំបានរាយការណ៍ទៅ នួន ជា ហើយគាត់(នួន ជា) បានឆ្លើយថា កែ ពក មិនបានក្បត់ទេ ។ សេចក្តីសម្រេចស្តុកអាវុធគឺបានធ្វើដោយ ប៉ុល ពត*" ។[592]

២០៧ លើសពីនេះ ឌុច ក៏នៅបានលើកឡើងបន្ថែមទៀតដែរថា "*តាមពិតដល់ចម្លើយលើកទីបី (បើតាមខ្ញុំចាំ) កុយ ធួន ចាប់ផ្តើមឆ្លើយដាក់ កែ ពក ។ ចម្លើយលើកទីបីនេះ សុន សេន សម្រេចឲ្យ កុយ ធួន ឆ្លើយគេច កែ ពក សិន ។ ចម្លើយលើកទីបួនទើប កុយ ធួន ត្រូវបានអនុញ្ញាតឲ្យឆ្លើយពាក់ព័ន្ធនឹង កែ ពក ។ ពេលចប់ចម្លើយ សុន សេន គាត់ឲ្យ ស-២១ យក Bic លុបតែឈ្មោះ កែ ពក តែមួយម៉ាត់ក្នុងច្បាប់ចម្លងតែមួយច្បាប់ តែឲ្យគ្រប់កន្លែងណាដែលមានឈ្មោះ កែ ពក*" ។[593]

២០៨ សាក្សីឈ្មោះ កែ អ៊ុន ហៅ ឌិក ជាអតីតអ្នកបើកឡានឲ្យលេខាភូមិភាគកណ្តាល កែ ពក និងជាក្មួយបង្កើតរបស់ កែ ពក បានលើកឡើងថា "*គាត់ (កែ ពក) ជាមេភូមិភាគកំពង់ចាម ហើយធំជាងគាត់គឺ ប៉ុល ពត*" ។[594] សាក្សីឈ្មោះ កែ អ៊ុន បន្ថែមទៀតថា "*ខ្ញុំមិនដែលបាននិយាយជាមួយអ្នកណាទេ នៅពេលដែលខ្ញុំនៅលើទំនប់នោះ ពីព្រោះថា គេខ្លាចឡានរបស់ កែ ពក ណាស់ខ្លាចគេយកទៅសម្លាប់ គ្រាន់តែដកដំឡូងមួយ ក៏ត្រូវគេយកទៅសម្លាប់ដែរ កុំថាឡើយដល់មកនិយាយលេងជាមួយខ្ញុំដែលជាអ្នកនៅក្បែរអ្នកធំនោះ*" ។[595]

២០៩ អតីតប្រធានគណៈប្រធានរដ្ឋ ខៀវ សំផន ហៅ ហែម ធ្លាប់បាននិយាយថា "*តាមខ្លួនយល់ក្នុងរបបខ្មែរក្រហមភូមិភាគនីមួយៗ ពិសេសលេខាភូមិភាគគឺជាស្តេចត្រាញ់ ចាត់ចែងការងារនៅតាមភូមិភាគតាមតែចិត្ត មជ្ឈិមមិនអាចត្រួតត្រាបានទេ។ ដូច្នេះ ទទួលតែរបាយការណ៍*"។[596] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ ឌុច ក៏បានបង្ហាញការយល់ឃើញស្រដៀងគ្នាដែរថា "*អ្វីដែលខ្ញុំដឹងគឺ កែ ពក មានអំណាចធ្វើការសម្រេចចាប់ខ្លួន ឬ ឃុំខ្លួន*"។[597]

២១០ ផ្អែកលើទីតាំងភូមិសាស្ត្រដែនដីនៃការគ្រប់គ្រងរដ្ឋបាល ភូមិភាគកណ្តាលមានចម្ការកៅស៊ូធំៗចំនួន ៤ (បួន) មាន៖ ចម្ការកៅស៊ូចម្ការអណ្តូង ចម្ការកៅស៊ូស្វាយមាស ចម្ការកៅស៊ូ-



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ព្រៃកកក់ និងចម្ការកៅស៊ូអណ្តូងស្វាយ ។[598] ចម្ការកៅស៊ូទាំងនេះត្រូវស្ថិតក្រោមការគ្រប់គ្រងដោយផ្ទាល់ពី កែ ពក លេខាភូមិភាគកណ្តាលតែម្តង ។[599] សាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់(ស្រុក១០៥)បានលើកឡើងថា *"ខ្ញុំទទួលផែនការពីភូមិភាគផ្ទាល់ ។ ខ្ញុំទៅរៀនសូត្រ និង ប្រជុំភូមិភាគដោយផ្ទាល់ ។ ការប្រជុំគឺក្នុងមួយខែម្តង ដោយមានសំបុត្រហៅទៅប្រជុំ ។ ជួលកាលគឺ កែ ពក ចុះមកពិនិត្យដោយផ្ទាល់តែម្តង"* ។[600]

២១១ ជាក់ស្តែងជាញឹកញាប់ កែ ពក តែងចុះទៅមូលដ្ឋាននានាក្នុងភូមិសាស្ត្រភូមិភាគកណ្តាល រួមមាន៖ ការដ្ឋាននានាក្នុងស្រុកកំពង់សៀម[601] មន្ទីរសន្តិសុខភ្នំប្រុស[602] ទំនប់០១មករា[603] ការដ្ឋានទំនប់អន្លង់ជ្រៃ[604] ចំការកៅស៊ូអណ្តូង[605] មន្ទីរសន្តិសុខវត្តតាមះ[606] ស្រុកចំការលើ[607] រោងចក្រផលិតឱសថ (នៅបឹងស្នាយ)[608] មន្ទីរ៧១[609]... និង កន្លែងផ្សេងៗទៀតក្នុងភូមិភាគកណ្តាល ជាអាទិ៍ ។[610]

២១២ បន្ថែមពីលើភ័ស្តុតាងបង្ហាញជូនក្នុងកថាខណ្ឌខាងលើ កែ ពក មានអំណាចយ៉ាងខ្លាំងនៅក្នុងភូមិភាគកណ្តាល ។ កែ ពក បានធ្វើការងារផ្ទាល់ជាមួយមជ្ឈិម និងមន្ទីរសន្តិសុខ ស-២១ ក្នុងបរិបទនៃការបង្ក្រាបនៅភូមិភាគកណ្តាល ។ ក្នុងចំណោមចម្លើយសារភាពនៅមន្ទីរសន្តិ-សុខ ស-២១ ចំនួន ១៦០[611] (មួយរយហុកសិប) មានចម្លើយសារភាពចំនួន ៤[612](បួន) ដែលមានចំណាររបស់ កែ ពក ដោយមានខ្លឹមសារថា **"ជូន ស/ម ពក ១ ច្បាប់"**[613] និង **"ស្រង់ឈ្មោះជូន ស/ម ពក វិញ"**[614] ។ មានសារទូរលេខសរុបចំនួន ២២៥[615] (ពីររយម្ភៃប្រាំ) ក្នុងនោះមានសារទូរលេខចំនួន ១៣[616] (ដប់បី) ស្តីពីទំនាក់ទំនងរវាង កែ ពក ក្នុងឋានៈជាលេខាភូមិភាគកណ្តាល និងគណៈមជ្ឈិម ។ ប៉ុន្តែ មានឯកសារតែមួយគត់និយាយយោងថា **អោ អាន** ស្នើយោបល់ពីមជ្ឈិមតាមរយៈ កែ ពក ពាក់ព័ន្ធនឹងទាហាន ២ (ពីរ) រូប ត្រូវបានចាប់ក្នុងតំបន់ ៤១ ។[617]

## ៤.២. ការបោសសម្អាតនៅភូមិភាគកណ្តាល

២១៣ ជុំវិញការបោសសម្អាតនៅភូមិភាគកណ្តាល មានសាក្សីជាច្រើនរូបបានលើកឡើងដូចៗគ្នាថា អ្នកកាន់តំណែងចាស់ពីមុន ក្នុងឋានានុក្រមរដ្ឋបាលគ្រប់គ្រងថ្នាក់ភូមិភាគកណ្តាល ត្រូវបានគេដកចោលស្ទើរតែទាំងអស់ ។[618] ប៉ុន្តែ សំណួរអាចត្រូវបានលើកឡើងថា តើមានការ

ដកចោលរួចហើយ ទើបក្រុមនិរតីចូលមកគ្រប់គ្រង[619] ឬ មានការចូលមកគ្រប់គ្រងដោយក្រុមនិរតីរួចហើយទើបដកអ្នកចាស់ៗចេញ[620] ។ ទាក់ទិនចំណុចនេះ មានសក្ខីកម្មជាច្រើនបានបញ្ជាក់យ៉ាងច្បាស់ថា ថ្នាក់លើបានចេញបញ្ជាឱ្យយកអ្នកចាស់ៗទៅសម្លាប់អស់ ហើយទើបចាត់បញ្ជូនក្រុមនិរតីមកធ្វើការគ្រប់គ្រងជំនួស ។[621]

២១៤ ជាក់ស្តែង សាក្សីឈ្មោះ វី ញ៉ បានលើកឡើងថា *"មុនគេចាប់ផ្តើមបញ្ជូនពួកនិរតីមកគេហៅពួកអ្នកនៅកំពង់ចាមឱ្យទៅរៀនរួមទាំង ប្រធានតំបន់ ចៅហ្វាយស្រុកអីទាំងអស់រួមទាំង ផាន់ ផង ។ ទៅរៀនហើយបាត់ទាំងអស់ទៅ មិនឃើញត្រឡប់មកវិញ ។ បន្ទាប់មកបានឃើញពួកនិរតីមក"* ។[622] សាក្សី សំរិទ្ធិ អន អះអាងដែរថា *"ពេលមិត្តសីមហ្នឹងសម្លាប់មុនពួកនិរតីចូលមកដល់"* ។[623] ពាក់ព័ន្ធការចាប់ខ្លួនគណៈតំបន់ចាស់ៗ សាក្សីឈ្មោះ ព្រៀម ចេន អតីតអ្នកការពារ **អោ អាន** បាននិយាយថា *"ចាប់មុនពេល **តា អាន** មកដល់ ... គេចាប់អស់ហើយបាន **តា អាន** មកដល់នៅតែមេកងមេអី"* ។[624] ខណៈសាមី **អោ អាន** ក៏បានលើកឡើងត្រង់ចំណុចនេះដែរថា **"អស់អាលីញអាលាត់ហើយនៅតែ កែ ពក មួយទេ"** ។[625]

២១៥ បើទោះបីជា ការមកដល់របស់ក្រុមនិរតីចូលមកភូមិភាគកណ្តាល ក៏ការចាប់ខ្លួននៅបន្តកើតមានដែរ ។[626] ចំពោះរលកនៃការជំនួសរបស់ក្រុមនិរតីនេះ មិនត្រឹមតែកើតមាននៅភូមិភាគកណ្តាលនោះទេ ក៏កើតមាននៅភូមិភាគបូព៌ា និងភូមិភាគពាយ័ព្យដែរ ។[627] ម្យ៉ាងវិញទៀតតាមសាក្សីឈ្មោះ ញឹម កុល បានលើកឡើងថា *"សឿន (លេខាស្រុកកំពង់សៀម) និង ម៉េងបានបាត់ខ្លួនបន្ទាប់ពី ប្រាក់ យុត បានមកដល់ស្រុកកំពង់សៀមបានពីរបីសប្តាហ៍ ... ខ្ញុំច្បាស់ថាមុនពេល ប្រាក់ យុត និងកូនចៅរបស់គាត់មកដល់ស្រុកកំពង់សៀមមិនមានការចាប់ខ្លួនកម្មាភិបាលទេ"* ។[628]

២១៦ តាមបរិបទក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ពាក្យថា **"បញ្ជាពីថ្នាក់លើ"** បើនិយាយឱ្យចំជាបញ្ជាលេខាភូមិភាគ ។[629] ការបញ្ជូនមនុស្សយកទៅសម្លាប់ទាំងឡានៗ មានការពាក់ពន្ធ័បញ្ជាពីថ្នាក់លើនេះ ។[630] តាមសេចក្តីសម្រេចរបស់គណៈកម្មាធិការអចិន្ត្រៃយ៍បក្ស បានបញ្ជាក់យ៉ាងច្បាស់ថា មានតែភាគទេទើបមានសិទ្ធិ ក្នុងការសម្រេចឱ្យចាប់ខ្លួននរណាម្នាក់



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES

។[631] ការសួរសាក្សីជាច្រើនរូបបានឱ្យដឹងថា ការបោសសម្អាតក្នុងភូមិភាគកណ្ដាលស្ថិតក្រោមការដឹកនាំ និងចាត់ចែងដោយផ្ទាល់ពីលេខាភូមិភាគកណ្ដាល កែ ពក ។[632]

២១៧ ទោះបីជាយ៉ាងនេះក្ដី កែ ពក ខ្លួនឯងក៏ធ្លាប់រុញការទទួលខុសត្រូវទៅឱ្យថ្នាក់លើរបស់គាត់ទៀត ។ នេះបើតាមសាក្សីមួយរូបលើកឡើងថា *"កែ ពក គាត់ថា បទបញ្ជាពីថ្នាក់លើ ។ គាត់ថា ដកស្មៅត្រូវដកទាំងឫស"* ។[633] ជារួមនៅបណ្ដាភូមិភាគ មិនថាភូមិភាគនិរតី ឬភូមិភាគកណ្ដាលឡើយ អំណាចសម្រេចចាប់ខ្លួននរណាម្នាក់ **ជាបញ្ជារបស់លេខាភូមិភាគតែម្ដង** ។ សក្ខីកម្មសាក្សីឈ្មោះ នុត នូវ បានបង្ហាញចំៗថា *"មានតែភូមិភាគទេ ដែលមានសិទ្ធិសម្រេច ហៅនរណាមួយឱ្យទៅរៀនសូត្រ"* ។[634]

២១៨ ពាក់ព័ន្ធនឹងការសម្រេចចាប់ខ្លួនប្រជាជនសាមញ្ញ សាក្សីខ្លះអះអាងថា ពេលខ្លះបញ្ជាចេញភូមិភាគ ហើយពេលខ្លះចេញពីតំបន់ជាអ្នកសម្រេច ។ ជាគោលការណ៍ប្រជាជនធម្មតាពុំមែនជាកម្មវត្ថុនៃការបញ្ជូនទៅមន្ទីរសន្តិសុខ ស-២១ ទេ ។[635] សាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) ក៏ធ្លាប់បានឆ្លើយតបនឹងការចេញបញ្ជាឱ្យសម្លាប់ពី កែ ពក ដោយបានឆ្លើយថា *"កែ ពក បាននិយាយ និងណែនាំខ្ញុំឱ្យបោសសម្អាតបន្ត ។ ខ្ញុំនិយាយថា ខ្ញុំធ្វើមិនកើតទេ ខ្ញុំស្អែកខ្មៅណាស់ ម៉ែឪគេទៅហើយឱ្យខ្ញុំធ្វើបាបកូនប្រពន្ធគេម៉េចទៀត បងឯងធ្វើកើតធ្វើទៅ"* ។[636]

២១៩ នៅក្រោមការគ្រប់គ្រងរបស់ កុយ ធួន ហៅ ធុច ជាលេខាភូមិភាគមិនសូវឃើញមានការសម្លាប់ទេ ផ្ទុយទៅវិញ ក្រោយពី កែ ពក បានឡើងធ្វើជាលេខាភូមិភាគជំនួស កុយ ធួន ឃើញថា មនុស្សជាច្រើនត្រូវបានសម្លាប់ ។[637] សាក្សីមួយរូបក៏និយាយថា *"លេខាស្រុកបាធាយឈ្មោះ ភឹម ... បានប្រាប់ខ្ញុំថាមនុស្សរាប់ពាន់នាក់ ត្រូវបានចាប់ខ្លួននៅភូមិភាគកណ្ដាលពិសេស ចន្លោះឆ្នាំ១៩៧៧ ដល់ ៧៩ ... ហើយបញ្ជាចេញមកពីថ្នាក់លើមកថ្នាក់ភូមិភាគ"* ។[638] រហូតដល់ពេលមួយ កែ ពក បានចេញបទបញ្ជាថា មិនឱ្យមានការសម្លាប់មនុស្សទៀតទេ ចាប់ពីពេលនេះតទៅ ខណៈក្មួយស្រីរបស់ កែ ពក ក៏ធ្លាប់បានលើកឡើងនូវសម្ដីផ្ដែផ្ដាំ និងជាបទបញ្ជារបស់ កែ ពក ថា៖ *"យើងទាំងអស់គ្នាឈប់សម្លាប់មនុស្សទៀតហើយ អ្នកណាសម្លាប់មនុស្សទៀត អ្នកនោះនឹងមានទោសហើយ"* ។[639]

01581381



២២០ ដោយសារផលវិបាកនៃការអនុវត្តន៍គោលនយោបាយបោសសម្អាតនេះ មានកម្មាភិបាលនៃភូមិភាគកណ្ដាលតិចតួចប៉ុណ្ណោះ ដែលនៅបានរស់រានមានជីវិត ។ ជាក់ស្ដែង ពុំមានអតីតលេខាតំបន់ ៤៣ ណាមួយនៅរស់នោះទេ ។ នៅថ្នាក់ស្រុក មានលេខាស្រុកមួយចំនួនតូចតែប៉ុណ្ណោះ ដែលរស់រានមានជីវិតរហូតដល់បច្ចុប្បន្ននេះ ។

## ៤.៣. អវត្តមាន កែ ពក

២២១ បន្ថែមលើតួនាទីជាលេខាភូមិភាគកណ្ដាល កែ ពក ក៏មានតួនាទីជា មេបញ្ជាការសេនាធិការភូមិភាគកណ្ដាល ។[640] សាក្សីឈ្មោះ ឈូក រីន ជាអតីតកម្មាភិបាលកងទ័ព បាននិយាយថា *"ថ្នាក់ភូមិភាគនាសម័យនោះ មានសិទ្ធិបញ្ជាទាំងយោធា និងស៊ីវិល"* ។[641] លើសពីនេះ កែ ពក ក៏នៅមានតួនាទីក្នុងជួរកងទ័ពបន្ថែមទៀតដែរក្នុងតំណែងជា អគ្គមេបញ្ជាការរងរបស់ សុន សេន ប្រចាំជួរមុខពេលមានការវាយជាមួយប្រទេសវៀតណាម និងជាសមាជិកគណៈកម្មាធិការយោធារបស់ ប.ក.ក ។[642] កែ ពក ជាកម្មាភិបាលដ៏មានឥទ្ធិពលមួយទៀតក្នុងជួរកងទ័ពដោយ កែ ពក ជាបុគ្គលលំដាប់ទី៤ នៅក្នុងជួរមជ្ឈិមទទួលបន្ទុកផ្នែកយោធា។[643]

២២២ វត្តមានរបស់ កែ ពក ក្នុងភូមិភាគកណ្ដាលត្រូវបានសាក្សីឈ្មោះ គុច វ៉ា បាននិយាយថា *"ជួនកាល កែ ពក ត្រូវមកចូលរួមសន្និបាតនៅទីក្រុងភ្នំពេញ ឬ ក៏ដឹកនាំការប្រជុំធំៗនៅតាមតំបន់ ។ ប៉ុន្ដែ ខ្ញុំមិនដឹងថាគាត់អវត្តមានយូរប៉ុនណាដែរទេ"* ។[644] ខណៈដែលការអះអាងរបស់សាក្សីឈ្មោះ សួន កានិល ថា *"តាមខ្ញុំដឹង កែ ពក មិនដែលចេញទៅណាទេក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ នោះ ។ គាត់អវត្តមានតែនៅពេលដែលគាត់ទៅសមរភូមិ ទៅប្រជុំនៅភ្នំពេញ ឬ ទៅមើលការដ្ឋានទំនប់ប្រឡាយមួយរយៈប៉ុណ្ណោះ"* ។[645]

២២៣ ផ្ទុយទៅវិញ មានតែសាក្សី កែ អ៊ុន ជាអតីតអ្នកបើកឡានឲ្យលេខាភូមិភាគកណ្ដាល កែ ពក និងជាក្មួយបង្កើតរបស់ កែ ពក និយាយថា *"មិនដែលមានអ្នកណាបើកឡានជូនគាត់ (កែ ពក) ទៅភ្នំពេញទេតី គាត់ (កែ ពក) ទាក់ទងទៅតាមតេឡេក្រាម ពីព្រោះខ្លាចបែកការណ៍"* ។[646] នេះស៊ីគ្នានឹងសក្ខីកម្មរបស់សាក្សី ឈូក រីន ដែលបង្ហាញថា *"នេះជាទម្លាប់របស់មេដឹកនាំខ្មែរក្រហម ។ អវត្តមានគឺកម្រណាស់"* ។[647]

២២៤ សាក្សីឈ្មោះ លឹម សេង បានលើកឡើងដែរថា *"តាមខ្ញុំចាំយ៉ាងយូរបំផុត គាត់ (កែ ពក) គាត់អវត្តមានពីក្នុងភូមិភាគចំនួនបីថ្ងៃ"* ។[648] ជាក់ស្តែង កែ ពក មិនដែលអវត្តមានពីភូមិភាគកណ្តាលញឹកញាប់ទេ តែគាត់ក៏អវត្តមានដែរពីភូមិភាគតែមានមួយរយៈខ្លី ប្រមាណជាប្រាំទៅប្រាំមួយថ្ងៃប៉ុណ្ណោះ ។[649]

២២៥ សាក្សីឈ្មោះ សារាយ ហៀន អះអាងថា *"នៅទីងថ្នាក់ភូមិភាគគឺរៀបចំដូចគ្នាដែរ គឺមានលេខារបស់ភូមិភាគ រួចហើយគណៈតំបន់ទាំងអស់ នៅក្នុងភូមិភាគជាស្វ័យប្រវត្តិគឺជាសមាជិករបស់គណៈភូមិភាគ ដោយគេដាក់លេខរៀង ១, ២ តទៅ ។ សម្រាប់ការទទួលខុសត្រូវលើការងារ ខ្ញុំដឹងថានៅពេលដែលលេខារបស់ភូមិភាគអវត្តមានសមាជិកម្នាក់នៅក្នុងគណៈភូមិភាគ បន្ទាប់ពីលេខាជាអ្នកទទួលខុសត្រូវ"* ។ [650] ទោះបីយ៉ាងនេះក្តី ជាក់ស្តែងពេលលេខាភូមិភាគកណ្តាល កែ ពក មិននៅគឺ "ប្រធានមន្ទីរគណៈភូមិភាគកណ្តាល" ជាអ្នកទទួលខុសត្រូវជំនួស ។[651]

២២៦ សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្តាល បានលើកឡើងត្រង់បញ្ហានេះថា *"ក្នុងករណី កែ ពក អវត្តមានគឺ គេមកជួបប្រធានមន្ទីរគណៈភូមិភាគឈ្មោះ សូ"* ។[652]បុគ្គលដែលធ្លាប់ជាប្រធានមន្ទីរគណៈភូមិភាគកណ្តាលមានៈ សូ, ញៀន, សែន, និង មឿន ជាអាទិ៍ ។[653] នេះគាំទ្រដោយអង្គហេតុថា ភូមិភាគដទៃដូចជាភូមិភាគបូព៌ាក៏លេខាភូមិភាគនេះ បានបញ្ជូនប្រធានមន្ទីររបស់ខ្លួនឱ្យទៅចូលរួមប្រជុំជំនួសខ្លួនជាលេខាភូមិភាគដែរ ។[654]

២២៧ នៅភូមិភាគកណ្តាល ពេលដែលលេខាភូមិភាគ កែ ពក មិននៅ ឬ មានបេសកកម្មចេញទៅក្រៅភូមិភាគ តើមានអ្នកណាម្នាក់ជាអ្នកទទួលខុសត្រូវជំនួសគាត់ ? សាក្សីឆ្លើយថា *"អ្នកដែលអាចជំនួសគាត់ (កែ ពក) នៅពេលដែលគាត់អវត្តមាន គឺមានតែប្រធានមន្ទីររបស់គាត់ឈ្មោះ មឿន ដែលជាក្មួយរបស់ កែ ពក"* ។[655] ច្បាស់ជាងនេះ មានសាក្សីម្នាក់ទៀតក៏ឆ្លើយស្រដៀងគ្នាថា *"ខ្ញុំនៅចាំតែឈ្មោះ មឿន និង ហៃន ដែលពួកគាត់ទាំងពីរនាក់ធ្វើការជំនួសឱ្យកែ ពក នៅពេលដែល កែ ពក មានភារកិច្ច ឬ អវត្តមានពីភូមិភាគ"* ។[656]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ៦៥

២២៨ លើសពីនេះទៀត បើមានការងារដែលត្រូវតែឆ្លង និងសម្រេចជាបន្ទាន់ពីលេខាភូមិភាគ គេនឹងប្រើនិរសាបញ្ជូនឯកសារនោះទៅឱ្យ កែ ពក ដោយផ្ទាល់ភ្លាមតែម្តង ។[657] កែ ពក មាននិរសាសរុបរហូតដល់ប្រហែល ១០ (ដប់) នាក់ ឯណោះដើម្បីរ៉ាប់រងការងារខាងបញ្ជូននេះ ។[658] សាក្សី ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) និងជាអតីតប្រធានចម្ការកៅស៊ូចំការអណ្តូង បានឆ្លើយយ៉ាងច្បាស់ថា *"ខ្ញុំតែងតែធ្វើរបាយការណ៍របស់ខ្ញុំត្រង់ផ្តោះទៅ កែ ពក ។ ប្រសិនការងារបន្ទាន់ គេមានអ្នកបញ្ជូនរបាយការណ៍នេះទៅអោយគាត់ភ្លាម ទោះបីគាត់នៅទីណាក៏ដោយ"* ។[659]

## ៤.៤. តួនាទី តា អាន

២២៩ ពាក់ព័ន្ធតួនាទី និងភារកិច្ចរបស់ **អោ អាន** នៅថ្នាក់ភូមិភាគ ឆ្លើយតបនឹងសំណួររបស់អ្នកស៊ើបអង្កេតដែលសួរថា "តើលោកដឹងថា **តា អាន** ធ្លាប់មានតួនាទីនៅកម្រិតភូមិភាគដែរឬទេ ? សាក្សីឈ្មោះ សាត ភា ដែលជាអ្នកមានព័ត៌មានជាច្រើនពាក់ព័ន្ធ **អោ អាន** បានឆ្លើយថា "**ខ្ញុំមិនដឹងទេ**" ។[660]

២៣០ កន្លងមក សហចៅក្រមស៊ើបអង្កេត បានសួរទៅសាក្សីឈ្មោះ រ័ត្ន ពៅ *"តើ **តា អាន** បានដឹងពីការបញ្ជូនមនុស្សទាំងនោះទេ ?"* រ័ត្ន ពៅ បានឆ្លើយថា *"នោះគឺជាផែនការណ៍ពីថ្នាក់លើ ហើយខ្ញុំមិនដឹងថា តើ **តា អាន** បានដឹង ឬអត់ទេ ។ វាក្លាយទៅជាប្រពៃណីទៅហើយ ដែលមនុស្សនិយាយតៗថា វាជាបញ្ហាពីថ្នាក់លើ"* ។[661] ខណៈសាក្សីឈ្មោះ ញ៉ែម ចេន ដែលអតីតអ្នកការពារ **អោ អាន** បានលើកឡើងថា *"កែ ពក ទទួលពី ប៉ុល ពត ដែលហៅថា តាសាឡុត ស ឬ តាទី ១ ។ ហើយ **តា អាន** ទទួលពី កែ ពក កែ ពក ទទួលពី ប៉ុល ពត"* ។[662]

## ៤.៥. ប្រព័ន្ធទំនាក់ទំនងការងារនៅភូមិភាគកណ្តាល

២៣១ លក្ខន្តិកៈបក្សកុម្មុយនីស្តកម្ពុជាបានចែងអំពីប្រព័ន្ធនៃការរាយការណ៍ដោយបានលើកឡើងថា គណៈភូមិភាគត្រូវពិនិត្យតាមដាន និង វិនិច្ឆ័យសកម្មភាពរបស់សាមីភូមិភាគ ។[663] របៀបបញ្ជូន និងផ្ញើសារទូរលេខពីមជ្ឈិមទៅតំបន់ ត្រូវបានគេធ្វើទៅតាមលំដាប់ថានានុក្រម ដោយបញ្ជូនពីថ្នាក់មជ្ឈិមចុះមកភូមិភាគ[664] បន្ទាប់មកសម្រាប់ភូមិភាគត្រូវធ្វើការបញ្ជូនបន្ត



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

មកថ្នាក់តំបន់ ។[665] សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល បានថ្លែងថា *"គ្រប់សារទូរលេខ ផ្ញើចូលមកភូមិភាគកណ្ដាលដែលទាក់ទងជាមួយគ្រប់តំបន់ គឺបញ្ជូនមកតាមកន្លែងខ្ញុំមួយគត់"*។[666]

២៣២ ចំពោះការផ្ញើសារទូរលេខ រវាងភូមិភាគនិងភូមិភាគ ប.ក.ក បានកំណត់ដាច់ខាតថា សារទូរលេខត្រូវតែឆ្លងកាត់ គណៈកម្មាធិការមជ្ឈិមបក្សជាមុនសិន ដោយភូមិភាគនីមួយៗមិនអាចធ្វើការ ទំនាក់ទំនងគ្នាបានដោយផ្ទាល់ទេ ។[667] ជាក់ស្ដែង បណ្ដាភូមិភាគនីមួយៗ តែងមានសាមីអង្គភាពសារទូរលេខរៀងៗខ្លួន[668] ដោយមានសមាសភាពដូចជា អ្នកបកប្រែសារទូរលេខ[669] អ្នកដាក់លេខសម្ងាត់សារទូរលេខ[670] អ្នកបញ្ជូនសារទូរលេខ[671] អ្នកទទួលសារទូរលេខ[672] និង អ្នកវាយអង្គុលីលេខ[673] ឬ អ្នកវាយម៉ាក៍[674] ។

២៣៣ ខ្លឹមសាររបស់សារទូរលេខ ជាទូទៅពុំមែនជាប្រភេទព័ត៌មានដែលវែងនោះទេ តែជាប្រភេទព័ត៌មានខ្លីៗតែប៉ុណ្ណោះ ។ ពេលខ្លះបើគោលដៅនៃការបញ្ជូននោះ អាចទាក់ទងបាន គេអាចប្រើមធ្យោបាយម៉ូតូ ឬឡាន ដោយបញ្ជូនតាមរយៈនិរសាជាអ្នកយកទៅឲ្យ។[675] ម្យ៉ាងទៀតបើខ្លឹមសារនៃការជូនព័ត៌មានលក្ខណៈវែង ភាគច្រើនត្រូវផ្ញើតាមសំបុត្រ ឬ និរសា ។[676]

២៣៤ រាល់សារទូរលេខដែលត្រូវផ្ញើចេញពី គណៈកម្មាធិការមជ្ឈិមបក្ស ត្រូវធ្វើការផ្ញើចេញទៅតាមការកំណត់ក្នុងសៀវភៅតារាងពេលវេលា សម្រាប់ផ្ញើមកគណៈកម្មាធិការមជ្ឈិមបក្ស ។ សារទូរលេខ ដែលត្រូវបញ្ជូនពីភូមិភាគទៅកាន់តំបន់ ក៏ត្រូវធ្វើតាមសៀវភៅតារាងពេលវេលាដែលមានជារួចស្រេចនោះដែរ ដើម្បីធ្វើការទំនាក់ទំនងបញ្ជូនទៅតំបន់។[677] ការកំណត់តារាងពេលវេលា ដោយផ្អែកលើហេតុផលយ៉ាងសាមញ្ញថា ដើម្បីជៀសវាងការជាន់គ្នានៅក្នុងប្រព័ន្ធនៃការរាយការណ៍ និង/ឬ ការទទួលបទបញ្ជាពីថ្នាក់លើ ។[678]

២៣៥ នៅថ្នាក់ភូមិភាគ មានមធ្យោបាយទំនាក់ទំនងជាច្រើនប្រភេទ សម្រាប់សម្រួលដល់ការប្រាស្រ័យទាក់ទងក្នុងវិធីធ្វើការងារ ។ ប៉ុន្តែ ក្នុងការអនុវត្តន៍មានតែការបញ្ជូនព័ត៌មានតាមសារទូរលេខតែមួយប្រភេទនេះគត់ ដែលមានលក្ខណៈលឿន និង ឆាប់រហ័សហើយធានាបាននូវសុវត្ថិភាព ដោយទទួលបាននូវភាពសម្ងាត់ខ្ពស់បំផុត ក្នុងការបញ្ជូនសារទូរលេខពីភូមិភាគទៅគណៈកម្មាធិការមជ្ឈិមបក្ស និងពីភូមិភាគបន្តចុះទៅថ្នាក់តំបន់ដែរ ។



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៣៦ សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល អះអាងថា *"នៅថ្នាក់ភូមិភាគ យើងធ្វើការបញ្ជូនទូរលេខទៅកាន់តំបន់នានា"*[679] ហើយក៏មាន *"ករណីខ្លះដែរ ដែលខាងភូមិភាគទទួលទូរលេខ ត្រឡប់ពីថ្នាក់តំបន់វិញ"* ។[680] សាក្សីរូបនេះនៅបានបន្ថែមទៀតថា *"សារទូរលេខទាក់ទង ឬ បញ្ជូនចេញ-ចូលគឺចេញពីភូមិភាគកណ្ដាលទៅគឺ ភាគច្រើនទាក់ទងនៅតំបន់ដែលចំណុះភូមិភាគ ។ សារដែលត្រូវបញ្ជូនចេញគឺទាំឲ្យក្រុមខ្ញុំដោយនិរសារបស់ កែ ពក ដោយមានហត្ថលេខារបស់ កែ ពក ។ មូលហេតុដែលខ្ញុំដឹងថា ជាសាររបស់ កែ ពក ពីព្រោះរាល់សារទូរលេខចេញ និងចូលគឺត្រូវតែយកទៅឲ្យ កែ ពក"*។[681]

២៣៧ ចំពោះការបញ្ជូនសារទូរលេខភូមិភាគកណ្ដាល ត្រលប់ឡើងទៅគណៈកម្មាធិការមជ្ឈិមបក្សវិញត្រូវតែមានហត្ថលេខារបស់ កែ ពក ជាដាច់ខាត ។[682] ចំនួនសារទូរលេខដែលបានទទួលពីតាមតំបន់មិនសូវជាកំណត់ទេ លុះត្រាតែ រឿងសំខាន់ទើបខាងតំបន់បញ្ជូនមក ។ ជាធម្មតាក្នុងមួយថ្ងៃៗ ភូមិភាគទទួលបានសារទូរលេខពីតំបន់ចំនួនមួយប៉ុណ្ណោះ ។[683] រីឯចំនួនសារទូរលេខរបស់មជ្ឈិម ដែលផ្ញើចុះឲ្យបណ្ដាភូមិភាគ ជាក់ស្ដែងមានការកើនឡើងលើសពីធម្មតា ជាពិសេសនៅឆ្នាំ១៩៧៨ មានចំនួនសារទូរលេខដែលបញ្ជូនចេញពីគណៈ-កម្មាធិការមជ្ឈិមបក្ស មកតាមបណ្ដាភូមិភាគមានរហូតដល់ ២ (ពីរ) ដង ឬ ច្រើនជាងនេះក្នុងមួយថ្ងៃៗ ។[684] នេះបើតាមការលើកឡើងរបស់សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល ក៏មានលើកឡើងដែរថា *"ទំនាក់ទំនងជាមួយមជ្ឈិមមានឡើងញឹកញាប់នៅឆ្នាំ១៩៧៨"* ។[685]

២៣៨ សារទូរលេខដែលផ្ញើមកមន្ទីរគណៈភូមិភាគកណ្ដាល ត្រូវបានគេថែរក្សាទុកតែ ៣ (បី) ខែ ហើយបើផុត ៣ (បី) ខែ គឺត្រូវតែកម្ទេចចោល ។[686] ទោះបីយ៉ាងណា ចំនួនសារទូរលេខដែលនៅសេសសល់សរុប ហើយដែលមានក្នុងសំណុំរឿងនេះមានចំនួន ២២៩ (ពីររយម្ភៃ-ប្រាំបួន)[687] សារទូរលេខ ។ សាក្សីឈ្មោះ សួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល បាននិយាយដែរថា *"ការគ្រប់គ្រងរបស់គណៈភូមិភាគគឺថាមិនដូចគ្នាទេ វាអាស្រ័យទៅលើចំណេះវិជ្ជារបស់គណៈភូមិភាគ ។ ចំណែកឯ កែ ពក ជាកសិករសុទ្ធសាធ ដូច្នេះការដែលនាំយ៉ាងម៉េចគឺ គាត់ធ្វើអីចឹង"* ។[688]



ECCC CETC CO-INVESTIGATING JUDGES

## ៤.៦. តំបន់ ៤១

២៣៩ តំបន់ ៤១ ជាតំបន់មួយក្នុងចំណោម ៣ (បី) តំបន់នៅភូមិភាគកណ្តាល ។ ទីតាំងភូមិសាស្ត្រនៃតំបន់ ៤១ គ្របដណ្តប់លើស្រុកចំនួន ៥ (ប្រាំ)[689] រួមមាន៖ ស្រុកព្រៃឈរ[690], ស្រុកកងមាស[691], ស្រុកជើងព្រៃ[692], ស្រុកបាធាយ[693], និងស្រុកកំពង់សៀម[694] (ឬស្រុក៨៨) [695] ។ រីឯ ទីស្នាក់ការរបស់មន្ទីរតំបន់ ៤១ ស្ថិតនៅក្បែរផ្សារព្រៃទទឹងក្នុងឃុំជ្រៃវៀន ស្រុកព្រៃឈរ ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[696] ប្រធានមន្ទីរតំបន់ ៤១ ដំបូងមានឈ្មោះ សង់ ដាំ ហៅ អាំ ។[697] ក្រោយពី អាំ ត្រូវបានគេចាប់ខ្លួនទើបមានឈ្មោះ អួន បានឡើងជំនួសជាប្រធានមន្ទីរតំបន់៤១ ហើយឈ្មោះ អួន ក៏ជាអនុលេខាតំបន់ ៤១ ដែរ ។[698]

២៤០ សាក្សីឈ្មោះ សាត ភា បាននិយាយពាក់ព័ន្ធនឹងការស្លាប់របស់ តា អាំ ថា "*រឿងនេះកើតឡើងក្រោយពេលដែល* ***អោ អាន*** *មកដល់ ។ តា អាំ ត្រូវបានគេឃុំ និងឆក់ខ្សែងភ្លើង នៅព្រៃទទឹង ប៉ុន្តែ ខ្ញុំមិនដឹងថា គេយកទៅសម្លាប់នៅទីណានោះទេ ។* ***តា អាន*** *បញ្ជាឲ្យមានការចាប់ខ្លួន តា អាំ ។ រឿងរ៉ាវទាំងអស់នេះគឺនិរសាម្នាក់របស់ តា អួន ជាអ្នកប្រាប់ខ្ញុំ ខ្ញុំភ្លេចឈ្មោះគាត់ហើយ*"។[699] ខណៈដែលសាក្សីឈ្មោះ អ៊ឹម ប៊ុន បានលើកឡើងថា "*ប្តីយាយយុត (អួន) ប្រធានស្រុកកំពង់សៀមហ្នឹង គេចាប់ខ្លួនដែរចាប់នៅក្នុងមន្ទីរខ្ញុំហ្នឹងឯង ។ ចាប់បញ្ជូនទៅខេត្តកំពតវិញ អ្នកខេត្តកំពតគេមកយក*" ។[700]

២៤១ មន្ទីរតំបន់ ៤១ មានមនុស្សរស់នៅជាប្រចាំប្រហែលពី ៤០ (សែសិប) ទៅ ៥០ (ហាសិប) នាក់ ។[701] រីឯ និរសានៅមន្ទីរតំបន់ ៤១ មានចំនួនប្រមាណជា ៧ (ប្រាំពីរ) នាក់ ដោយនិរសាម្នាក់ៗ មានម៉ូតូម្នាក់មួយគ្រឿង ដើម្បីបំពេញការងារ។[702] នៅឆ្នាំ១៩៧៥-១៩៧៦ លេខាតំបន់ ៤១ ដំបូងឈ្មោះ ជ ឆាន ហៅ ស្រេង[703] និងឈ្មោះ តាំង[704]ជាអនុលេខាតំបន់ ៤១ ។ ផ្អែកតាមព័ត៌មានលើក្របមុខនៃចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ ស្រេង ត្រូវបានឃាត់ខ្លួននៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ១៩៧៧[705] ក្រោមហេតុផលបញ្ជូនយកទៅរៀនសូត្រ ។[706]



E.C.C.C * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581387



២៤២ ក្រោយមកនៅឆ្នាំ១៩៧៧ ជុន ឈុំ ហៅ តាំង[707] បានក្លាយជាលេខាតំបន់ ៤១ ជំនួស ស្រេង ។[708] តាំង ជាលេខាតំបន់ ៤១ ក៏ត្រូវចាប់ខ្លួនមុនពេលដែលក្រុមនិរតីបានមកដល់ភូមិភាគកណ្តាលដែរ ។[709] ការចាប់ខ្លួនលេខាតំបន់ តាំង ត្រូវបានធ្វើឡើងប្រហែលជាកន្លះឆ្នាំ ឬបីបួនខែប៉ុណ្ណោះមុនពេលពួកនិរតីមកដល់ ។[710] នាពេល **អោ អាន** បានទៅដល់ភូមិភាគកណ្តាល កែ ពក បានចាត់តាំងគាត់ជាលេខាតំបន់ ៤១ ជំនួស តាំង ។[711] មានភាពមិនស៊ីសង្វាក់គ្នារវាងសាក្សីពាក់ព័ន្ធនឹងពេលវេលាដែល **អោ អាន** ជំនួសតំណែង តាំង ។

២៤៣ សាក្សីម្នាក់និយាយថា "*តា ស្រេង ដែលជាអតីតប្រធានតំបន់ ៤១ គាត់ត្រូវបានជំនួសដោយ តា អាន ដែលជាមនុស្សមកពីភូមិភាគនិរតី*"។[712] ការលើកឡើងអំពីការជំនួសតំណែងនេះដោយ **អោ អាន** នេះភ្លាមដោយរំលង លេខាតំបន់ ៤១ ឈ្មោះ តាំង[713] នោះអាចនាំឱ្យមានការភាន់ច្រឡំ លើការផ្លាស់តំណែងតួនាទីជាលេខាតំបន់ ៤១ នេះ ។ សាក្សីជាច្រើនរូបបានលើកឡើងយ៉ាងច្បាស់ថាឈ្មោះ តាំង ជាលេខាតំបន់ ៤១ ត្រូវបានចាប់ខ្លួនរួចហើយទើប **អោ អាន** បានឡើងជំនួស ។[714]

២៤៤ តាមភ័ស្តុតាងដែលប្រមូលបាន ប្រហែលជាក្រោយខែមីនា ឬខែមេសា ឆ្នាំ១៩៧៧ **អោ អាន** ពុំទាន់បានមកកាន់តួនាទីជាលេខាតំបន់ ៤១ ទេ បើទោះបីជាមានសាក្សីមួយចំនួនបាននិយាយថា **អោ អាន** បានមកដល់នៅក្នុងអំឡុងពេលខាងលើនេះក៏ដោយ ។[715] មិនមានឯកសារជាផ្លូវការអំពីការតែងតាំង **អោ អាន** ជាលេខាតំបន់ ៤១ ទេ ។[716] ក្រោយពេលដែល **អោ អាន** បានក្លាយជាលេខាតំបន់ ៤១ សមាសភាពគណៈតំបន់ ៤១ រួមមាន៖ **អោ អាន** ជាលេខាតំបន់[717],ស៊ុម[718],ភីម[719],ម៉ុន[720],កាន[721] និង យុត[722]ជាសមាជិក ។[723]

២៤៥ សាក្សីក៏បានបញ្ជាក់ដែរថា "*ខ្ញុំជាលេខាស្រុកកំពង់សៀម ក្នុងភូមិភាគកណ្តាល ហើយជាសមាជិកទី ៤ នៃតំបន់៤១*"។[724] ជារួមសមាសភាពគណៈតំបន់ ៤១ តែងមានការប្រែប្រួលជារឿយៗ ដូចនេះ ពុំមានព័ត៌មានច្បាស់ណាមួយ អំពីអំឡុងពេលកាន់តួនាទីនោះឱ្យបានជាក់លាក់នោះទេ ។ ក្នុងនាមជាលេខាតំបន់ ៤១ **អោ អាន** មានអំណាចចាត់តាំងដោយផ្ទាល់លើប្រធានក្រុមនិរសានៅមន្ទីរតំបន់ ៤១ ។ ជាក់ស្តែង អតីតនិរសានៅមន្ទីរតំបន់ ៤១ ឈ្មោះ ហុង ហេង បាននិយាយថា "*ក្នុងហ្នឹងគាត់ចាត់ផ្ទាល់តែម្តង ។ តា អាន គាត់ចាត់តាំងផ្ទាល់ ហើយយើងប្តូរវេនគ្នាទៅ*" ។[725]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៤៦ របៀបគ្រប់គ្រងនៅតំបន់ ៤១ មាន ២ (ពីរ) ប្រភេទ៖ ការគ្រប់គ្រងខាងរដ្ឋបាល និង ការគ្រប់គ្រងខាងបក្ស ។[726] ការគ្រប់គ្រងរដ្ឋបាលមាន **អោ អាន** ជាលេខាតំបន់ ៤១ ជាអ្នកគ្រប់គ្រង រីឯឈ្មោះ ស៊ឹម ទទួលខុសត្រូវខាងការងារបក្ស ។[727] ការងាររដ្ឋបាល និងការងារបក្សមិនខុសគ្នាទេ ប៉ុន្តែ បើខាងបក្សសម្រេចលើរឿងណាមួយ នោះខាងរដ្ឋបាលត្រូវគោរពតាមជាដាច់ខាត ។[728] ដូចនេះ លេខាតំបន់ទទួលការងាររដ្ឋបាល ត្រូវតែគោរពតាមការសម្រេចការងារបក្ស ។[729]

២៤៧ នៅតំបន់ ៤១ មានការប្រជុំជាទៀតទាត់ក្នុងមួយខែម្តង[730] មិនខុសពីតំបន់ផ្សេងៗទេ ។[731] សាក្សីឈ្មោះ ជិន ស៊ីណាល់ បានលើកឡើងថា *"ក្នុងមួយខែយើងត្រូវជួបគ្នានៅស្នាក់ការតំបន់"* ។[732] សាក្សីជាច្រើនរូបបានផ្តល់សក្ខីកម្មប្រហាក់ប្រហែលគ្នាថា ក្នុងនាមលេខាតំបន់ ៤១ **អោ អាន** តែងណែនាំប្រជាជនឱ្យចូលរួមធ្វើការងារជីកប្រឡាយ និងការលើកទំនប់ ។[733] សាក្សីជាច្រើនក៏ធ្លាប់បានឃើញ **អោ អាន** ចុះទៅតាមទីកន្លែងផ្សេងៗក្នុងតំបន់ ៤១ ដូចជា៖ ការដ្ឋានទំនប់អន្លង់ជ្រៃ[734] ចំការកៅស៊ូជប់[735] ទំនប់១មករា[736] ទំនប់៥មករា[737] មន្ទីរសន្តិសុខមិត្តសុប[738] មន្ទីរសន្តិសុខវត្តបាធាយ[739] ចំការលើ[740] ស្គន់[741] ជើងព្រៃ[742] មន្ទីរសន្តិសុខភ្នំប្រុស[743] មន្ទីរសន្តិសុខវត្តអូរត្រកួន[744] ស្រុកកំពង់សៀម[745] វត្តតាមៈ[746] ជាអាទិ៍ ។

២៤៨ សាក្សីម្នាក់ជាអ្នករស់នៅស្រុកកំពង់សៀម បាននិយាយថា *"ខ្ញុំបានជួប តា អាន តែពីរដងប៉ុណ្ណោះ ។ លើកទី១ នៅភូមិអង្គុញដី នៅពេលដែលគាត់បានមកមើលផ្ទះបាយ ដែលបានសាងសង់ថ្មី ។ លើកទី២ ខ្ញុំបានឃើញគាត់នៅព្រៃឈរ នៅពេលដែលខ្ញុំធ្វើដំណើរទៅស្រុកកងមាស"* ។[747] ការចុះទៅតាមមូលដ្ឋានរបស់ **អោ អាន** ដើម្បីទៅមើលការជីកប្រឡាយ លើកទំនប់ និងការធ្វើស្រែ បានធ្វើឱ្យ **អោ អាន** បានដឹងពីបញ្ហាបានច្រើន ទាក់ទិនការបង្កបង្កើតផលរបស់ប្រជាជននៅតាមមូលដ្ឋាន ។[748]

២៤៩ ប្រជាជននៅតាមមូលដ្ឋានក្នុងតំបន់ បាននិយាយស្ទើរតែដូចៗគ្នាថា **អោ អាន** ជាមនុស្សដែលដឹងពីស្ថានភាពជាក់ស្តែង តាមរយៈការចុះផ្ទាល់ជាប់ជាមួយប្រជាជន។[749] លើសពីនេះ ប្រជាជនបានឃើញ **អោ អាន** និងប្រពន្ធឈ្មោះ កាន តែងតែចុះមកត្រួតពិនិត្យមើល...



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581389



តាមវាលស្រែជានិច្ចជាកាល ដើម្បីដឹងស្ថានភាពនៃការវិវឌ្ឍន៍ការបង្កបង្កើតផល ។ មិនតែប៉ុណ្ណោះពេលខ្លះ **អោ អាន** បានចុះជួយស្ទូងស្រូវជាមួយប្រជាជនថែមទៀត ។[750]

២៥០ សាក្សីម្នាក់ដែលឃើញដោយផ្ទាល់ភ្នែកបាននិយាយថា *"ខ្ញុំឃើញគាត់ (អោ អាន)ជិះឡានទៅទិសខាងលិច ។ ពេលខ្លះទៅជាមួយនិរសាររបស់គាត់ ហើយពេលខ្លះទៀតទៅជាមួយប្រពន្ធកូនរបស់គាត់ ។ ពេលខ្លះឃើញសំណាបនៅខាងក្រោយឡានរបស់គាត់ ។ មានម្តងនោះមានគេប្រាប់ខ្ញុំថា តា អាន ចុះទៅជួយស្ទូងស្រូវសហករណ៍ត្រពាំងទូកជាមួយនិរសានិងគ្រួសាររបស់គាត់"* ។[751] សាក្សីឈ្មោះ ឈឹម ប៊ុនសេរី បានលើកឡើងថា *"ពេលប្រជុំនោះ តា អាន បាននិយាយប្រាប់ឲ្យយើងទាំងអស់គ្នាខំរែកដីធ្វើទំនប់ ។ ការប្រជុំនោះគឺមួយព្រឹក"* ។[752]

២៥១ នៅចុងឆ្នាំ១៩៧៧ **អោ អាន** ក៏ធ្លាប់បានផ្តល់ការបង្រៀនផ្នែកនយោបាយដល់កម្មាភិបាលក្នុងតំបន់ ៤១ ផងដែរ ។[753] ពាក់ព័ន្ធនឹងសារនយោបាយដែល **អោ អាន** បានលើកឡើងនាពេលបង្រៀននោះគឺមានទាក់ទិន ការងារប្រចាំថ្ងៃ ការធ្វើស្រែ ការបង្កបង្កើតផល និងរបៀបធ្វើការកែលម្អការងារ ជាអាទិ៍ ។[754] លើសពីនេះ ក្នុងនាមជាលេខាតំបន់ ៤១ **អោ អាន** តែងមានវត្តមានជាប្រចាំនៅតំបន់ ៤១ ដោយមិនសូវចេញទៅណាទេ ។[755] នេះជាទម្លាប់របស់ខ្មែរក្រហម ដែលកម្រអវត្តមានពីមូលដ្ឋានខ្លួនណាស់ ។[756]

២៥២ សាក្សីឈ្មោះ សួន កានិល ក៏បានផ្តល់សក្ខីកម្មត្រង់ចំណុចនេះដែរថា *"គាត់ (អោ អាន) គឺជាអនុលេខាភូមិភាគ ប៉ុន្តែ គាត់កាន់ការងារដោយផ្ទែករបស់គាត់នៅតំបន់ ៤១ ទាល់តែមានការងាររួមនៅភូមិភាគទើបគាត់មកចូលរួម"* ។[757] ជាក់ស្តែង **អោ អាន** បានធ្វើការងារជាច្រើនទាក់ទិនតែតំបន់ ៤១ ដែលគាត់គ្រប់គ្រង ។[758] អតីតនិរសានៃមន្ទីរតំបន់ ៤១ នាឆ្នាំ១៩៧៧ បានផ្តល់សក្ខីកម្មដែរថា *"ថ្ងៃមិនដែលឃើញទេ យប់ទើបបានឃើញ ពេលគាត់ (អោ អាន) ត្រឡប់មកវិញ"* ។[759]

២៥៣ ពេលខ្លះ **អោ អាន** ក៏បានទៅចូលរួមប្រជុំថ្នាក់ស្រុកផងដែរ ។[760] សាក្សីម្នាក់បានផ្តល់សក្ខីកម្មថា *"ខ្ញុំបានឃើញ តា អាន ម្តងគត់នៅនឹងការដ្ឋានរបស់តំបន់(សូរទិព ព្រៃទទឹង ស្រុកព្រៃឈរ) ។ ខ្ញុំឃើញ តា អាន កាន់ស្បោងថ្នាំខ្លាំង គៀបនៅក្រោមក្លៀករបស់គាត់*



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01581390



*ពេលដែលគាត់ចុះពីលើឡានហ្ស៊ីបរបស់គាត់*" ។[761] នៅពេលមកចូលរួមប្រជុំនោះ **អោ អាន** តែងតែមានអ្នកមកជាមួយប្រមាណ ៥ (ប្រាំ) នាក់ មានកងការពារ និង អ្នកបើកឡានឱ្យគាត់ ។[762] អ្នកបើកឡានឱ្យ **អោ អាន** មានជាច្រើននាក់ដូចជា[763]៖ ប៊ុន[764] ហ៊ុយ[765] ឡាយ[766] មឿន[767] ហ៊ុំ[768] ។

២៥៤ បើទោះបី ក្រោយក្រុមនិរតីបានចូលមកដល់ទីនេះក្តី ក៏នៅមានការផ្លាស់ប្តូរមេឃុំ និងមេភូមិដែរ ។ សាក្សីមួយរូបលើកឡើងថា "*បទបញ្ជាច្បាស់ជាចេញពី តា **អាន** ហើយ ព្រោះគាត់ជាប្រធានតំបន់ ... តាមខ្ញុំស្មាន បទបញ្ជាគឺចេញពីស្រុក ហើយស្រុកទទួលបញ្ជាមកពីថ្នាក់តំបន់ ។ ខ្ញុំពុំបានឮផ្ទាល់ពី ប្រាក់ យុត ទេ ប៉ុន្តែ មេឃុំចាស់ៗមួយចំនួនបានបាត់ខ្លួន ២ ថ្ងៃ បន្ទាប់ពីគាត់ចូលរួមប្រជុំនៅថ្នាក់តំបន់ជាមួយ **តា អាន** ។ ៤ ថ្ងៃក្រោយមកទៀត មេឃុំថ្មីៗក៏ត្រូវតែងតាំងជំនួសមេឃុំចាស់ៗ*" ។[769]

២៥៥ ចំពោះការចាប់ខ្លួននរណាម្នាក់ក្នុងតំបន់ ថ្នាក់តំបន់ពុំមានសិទ្ធិឡើយ លុះត្រាតែ មានបញ្ជាពីភូមិភាគ ។ ជាក់ស្តែង អតីតលេខាស្រុកកំពង់សៀមក៏ធ្លាប់បាននិយាយដែរថា "*ខ្ញុំមិនចាំទេថាសំបុត្រនោះមកពីថ្នាក់ណា តែតាមទម្លាប់សំបុត្រនោះ ចេញមកពីភូមិភាគ រួចបន្តមកថ្នាក់តំបន់ ហើយបានថ្នាក់តំបន់បញ្ជូនមកថ្នាក់ស្រុក*" ។[770] តាមដឹង **អោ អាន** ក៏ធ្លាប់បានចុះទៅជួប ប្រាក់ យុត នៅស្រុកកំពង់សៀម ។[771] លើសពីនេះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម ក៏ធ្លាប់ឡើងមកជួប **អោ អាន** ដែរ ។ នេះបើតាមសាក្សីដែលបាននិយាយថា "*គាត់ (ប្រាក់ យុត) ទៅប្រជុំនៅព្រៃឈរពីរទៅបីដងក្នុងមួយខែ*" ។[772]

២៥៦ សាក្សីឈ្មោះ សំរិត មុយ បានឆ្លើយថា "*នៅដើមឆ្នាំ១៩៧៧ គេមានធ្វើការប្រជុំមួយនៅកីឡាដ្ឋានពាម ។ ពេលនោះ អ្នកភូមិគ្រប់រូបត្រូវតែចូលរួម ។ **អាន** ជាគណៈតំបន់ និង កានជាគណៈស្រុក បានមកបើកការប្រជុំហើយបានប្រាប់យើងថា ឱ្យធ្វើឱ្យខ្លាំងសម្រាប់ឱ្យអង្គការ រួចហើយនិយាយថា មានខ្មាំងនៅក្នុងចំណោមប្រជាជន ។ បន្ទាប់ពីការប្រជុំនោះមក ការចាប់ចងក៏មានសន្ទុះឡើងថែមទៀតទាំងថ្ងៃទាំងយប់*" ។[773]

២៥៧ អ្នកទទួលខុសត្រូវខាងយោធាតំបន់ ៤១ ដំបូង តា ហ៊ុម ។ ក្រោយមកគាត់ត្រូវបានចាប់ខ្លួន ហើយឈ្មោះ ទ្រី បានឡើងជំនួស ប៉ុន្តែពុំមានព័ត៌មានជាក់លាក់អំពីពេលវេលានោះទេ ។[774]

01581391



ការចាប់ខ្លួនឈ្មោះ ហ៊ុម ដែលជាប្រធានឃោធាតំបន់ ដោយសារគាត់ខុសសីលធម៌ជាមួយប្អូនថ្លៃស្រីរបស់ **អោ អាន** ។ ទាក់ទិនបញ្ហានេះដែរ សាក្សីឈ្មោះ សូ សារ៉េន បានប្រាប់ថា "*អ្នកបញ្ជាខ្ញុំអត់ច្បាស់ទេ ។ ប៉ុន្តែ បើប៉ះប្អូនថ្លៃរបស់ **តា អាន** មានតែ **តា អាន** ហើយបញ្ជាឱ្យចាប់*" ។[775]

២៥៨ ចំពោះការចាប់ខ្លួនប្រជាជនធម្មតា មានថ្នាក់ឃុំជាអ្នកបញ្ជាឱ្យចាប់ ។[776] សាក្សីឈ្មោះ សូ សារ៉េន អះអាងទាំងស្រពិចស្រពិលថា "*តាមពិតគាត់ **(អោ អាន)** មិនមែនជាអ្នកសម្លាប់ផ្ទាល់ទេ ការសម្លាប់ហ្នឹងមានតែនៅតាមស្រុក និងមូលដ្ឋានដទៃទៀត ។ តែខ្ញុំធ្លាប់ឃើញព្រឹត្តិការណ៍មួយ គឺមានប្រពន្ធឃោធាតំបន់ដែលមានផ្ទៃពោះ ហើយប្តីរបស់គាត់ត្រូវបានគេចាប់ ។ ប្រពន្ធឃោធានោះចេះតែមកសួរ **តា អាន** អំពីប្តីគាត់ញឹកញាប់*"។[777] សាក្សីបានអះអាងថា **តា អាន** បញ្ជាឱ្យឃោធាយកទៅសម្លាប់ ។[778]

២៥៩ ជាក់ស្តែង សាក្សី សាត ភា បានលើកឡើងដែរថា "*គាត់ **(អោ អាន)** ក៏បានធ្វើការប្រៀបធៀបជាមួយនឹងឡាន ដែលមានកង់ចាស់ៗដែលត្រូវដកចេញ និងដៀរសម្រាប់ផលិតស្បែកជើង ។ មានន័យថា អ្នកដែលជាខ្មាំងទាំងនេះត្រូវតែយកទៅសម្លាប់ចោល*"។[779] សាក្សី សាត ភាព បានបន្ថែមថា "*ចំនួនមនុស្សដែលត្រូវបានចាប់ខ្លួនមានការកើនឡើង ក្រោយពេលដែល **តា អាន** មកដល់ ។ ខ្ញុំដឹងរឿងនេះដោយសារ តែពួកគេកំពុងកម្ទេចខ្មាំង ។ វាជាផែនការរបស់ **តា អាន***" ។[780]

២៦០ សាក្សីម្នាក់បាននិយាយថា "***អាន** បានអនុវត្តគោលនយោបាយត្រជាក់ដើម្បីរកខ្មាំង ។ អ្នកណាដែលតវ៉ាត្រូវបានចាប់ខ្លួន*" ។[781] មានការអះអាងថា ក្រោយពេលបញ្ចប់កិច្ចប្រជុំប្រចាំខែ **អោ អាន** ធ្លាប់បានចេញបញ្ជាឱ្យចាប់ខ្លួនមនុស្ស ។[782] ហេតុការណ៍នេះត្រូវបានសាក្សីដដែលបន្ថែមថា "*តាមពិតទទួលបញ្ជាឱ្យអនុវត្តធ្វើអ្វីមួយពី **តា អាន** ប៉ុន្តែ ខ្ញុំមិនច្បាស់ថា **តា អាន** ជាអ្នកផ្តួចផ្តើមបញ្ជានោះ ឬក៏គាត់ទទួលបញ្ជានោះមកពីថ្នាក់លើ ឬយ៉ាងណានោះទេ*"។[783] មិនតែប៉ុណ្ណោះ សាក្សីដដែលរូបនេះនៅបានបន្ថែមទៀតថា "*ខ្ញុំមិនដែលបានទទួលបញ្ជាពី **តា អាន** ឱ្យចាប់ខ្លួនអ្នកណាទេ*"។[784]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUDGES D'INSTRUCTION

២៦១ សាក្សីឆ្លើយមានលក្ខណៈជាការសន្និដ្ឋានខាងលើពាក់ព័ន្ធការចេញបញ្ជារបស់ **អោ អាន**។[785] ជាក់ស្តែង សាក្សីឈ្មោះ សូ សារ៉េន បានផ្តល់សក្ខីកម្មថា *"កាលពេលនោះគាត់ (អោ អាន) ធ្វើដំណើរចេញពីចំការលើ ខ្ញុំឮថាគាត់ (អោ អាន) ទទួលបញ្ជាមកកំពង់សៀម តែខ្ញុំមិនដឹងគាត់ទទួលបញ្ជាពីខាងណាទេ"*។[786] យ៉ាងណាក៏ដោយ ចំពោះការផ្តួចផ្តើមគំនិតចេញបញ្ជាណាមួយឱ្យសម្លាប់មនុស្ស **អោ អាន** ពុំមានសិទ្ធិសម្រេចទេនាពេលនោះ ។ សាក្សីមួយរូបបានលើកឡើងថា *"តា អាន ទទួលបញ្ជាពីភូមិភាគ"*។[787]

២៦២ នៅក្នុងពេលប្រជុំមួយនោះ កែ ពក ជាលេខាភូមិភាគកណ្តាលបានចេញបញ្ជាទៅ **អោ អាន** ថា *"នៅតំបន់ហ្នឹង អាន មើលខ្មាំងចាប់ឱ្យនាប់អស់ហើយផែនការ ព្រោះពីលើមកគេបង្ខំ"*។[788] ជាក់ស្តែង **អោ អាន** ក្នុងនាមជាលេខាតំបន់ ៤១ ពិតជាធ្លាប់បានចូលរួមប្រជុំរួមគ្នាអំពីការចាប់ខ្លួនខ្មាំងក្រោមការណែនាំនិងដាក់បញ្ជាពី កែ ពក ជាលេខាភូមិភាគ ។[789] មិនតែប៉ុណ្ណោះ សាក្សីម្នាក់ក៏បានផ្តល់សក្ខីកម្មថា វាជាបញ្ជាពីលេខាភូមិភាគ *"លេខាស្រុកបាធាយឈ្មោះ ភឹម ប្រពន្ធរបស់គាត់សព្វថ្ងៃរស់ ...។ លោកបានប្រាប់ខ្ញុំថា ... មនុស្សរាប់ពាន់នាក់ ត្រូវបានចាប់ និងសម្លាប់នៅស្រុកកំពង់សៀម ហើយបញ្ជាចេញមកពីថ្នាក់លើ មកថ្នាក់ភូមិភាគ បន្ទាប់មកតមកថ្នាក់តំបន់ និង ស្រុក"*។[790]

## ៤.៧. តំបន់ ៤២

២៦៣ តំបន់ ៤២ ស្ថិតនៅក្នុងភូមិភាគកណ្តាល ។[791] តំបន់ ៤២ មានវិសាលភាពរដ្ឋបាលគ្របដណ្តប់លើ ៥ (ប្រាំ)[792]ស្រុករួមមានៈ ស្រុកស្ទឹងត្រង់[793] ស្រុកចំការលើ[794] ស្រុកបារាយណ៍[795] ស្រុកព្រៃកប្រសប់[796] និងស្រុកតាំងគោក[797] ។ ទីស្នាក់ការមន្ទីរតំបន់ ៤២ ស្ថិតនៅទល់មុខនឹងសាលាស្រុកចំការលើសព្វថ្ងៃ ។[798] វ៉ាំ ជាអ្នកទទួលខុសត្រូវនៅមន្ទីរតំបន់ ៤២ ។[799]

២៦៤ តំបន់ ៤២ មុនដំបូងមានឈ្មោះ ចាន់ ម៉ុន ហៅ តុល ជាលេខាតំបន់ ។[800] បន្ទាប់មក លឹម សំអឿន[801] ហៅ អឿន[802] បានឡើងជំនួស តុល ។[803] នាពេលនោះដើមឆ្នាំ១៩៧៧ អឿន បានកាន់តួនាទីជាលេខាតំបន់ ៤២ រហូតដល់ការដួលរលំរបបតែម្តង[804] ហើយបានស្លាប់នៅឆ្នាំ២០០១ ។[805] ក្រៅពីតួនាទីជាលេខាតំបន់ ៤២ អឿន នៅមានចំណងជាញាតិពន្ធ[illegible] ជិតស្និទ្ធជាមួយលេខាភូមិភាគកណ្តាល កែ ពក ថែមទៀត ។[806]



E.C.C.C * C.E.T.C * INVESTIGATING JUDGES * JUGES D'INSTRUCTION

01581393



២៦៥ ដោយហេតុថា អឿន ត្រូវជាប្អូនបង្កើតរបស់ សឿន[807] ជាប្រពន្ធរបស់ កែ ពក ចំណង ញាតិនេះហើយបានធ្វើឱ្យតំបន់នេះ សឹងតែគ្មានទាល់តែសោះនូវវត្តមានរបស់ថ្នាក់លើចុះមក ត្រួតពិនិត្យ ។[808] សាក្សីម្នាក់បាននិយាយអំពីបញ្ហានេះចំៗថា *"ខ្ញុំមិនដែលឃើញមានថ្នាក់លើ ចុះមកត្រួតពិនិត្យតំបន់ ៤២ ទេក្រៅពីប្រធានតំបន់តែម្តង"* ។ [809]

២៦៦ នៅក្នុងឆ្នាំ១៩៧៧ អឿន ជាលេខាតំបន់ ៤២ បានអានឯកសារសង្គ្រោះដែលមានខ្លឹមសារថា *"កុំភ័យអីបក្សឈប់កម្ទេច ឈប់បោសសំអាត ឬកាប់សម្លាប់ទៀតហើយ"* ។[810] អតីតនិរសា លេខាស្រុកកំពង់សៀមនិយាយថា *"ខ្ញុំបានឮពីបងប្អូនជនរងគ្រោះថា ជនរងគ្រោះទាំងនោះ ត្រូវបានគេបញ្ជូនមកពីចំការកៅស៊ូផ្សេងៗក្នុងតំបន់ ៤២ តាមបញ្ជារបស់តា កែ ពក"* ។[811] ដូចនេះ មុនមានឯកសារនេះក្នុងក្របខ័ណ្ឌនៃតំបន់ ៤២ វាទំនងជាមានរងការបោសសម្អាត ក្នុងទ្រង់ទ្រាយណាមួយជាក់ជាពុំខានទើប អឿន លេខាតំបន់ ៤២ បានថ្លែងដូចនេះ ។

២៦៧ ស៊ូ សឿន ហៅ សឿន[812] អតីតលេខាស្រុកចំការលើ ដែលត្រូវជាបងស្រីបង្កើតរបស់លេខា តំបន់ ៤២ រឹតតែមានភាពសកម្មខ្ពស់ លើការដឹកនាំក្នុងស្រុកចំការលើ ជុំវិញការងារមូល-ដ្ឋាន ។ នេះបើតាមអតីតអនុលេខាស្រុកចំការលើ ដែលបានអះអាងថា *"ខ្ញុំធ្លាប់បានចូល ប្រជុំជាមួយ ស៊ូ សឿន ភាគច្រើនខ្លឹមសារនៃអង្គប្រជុំ គឺផ្តោតទៅលើការងារនៅការដ្ឋាន ហើយមិនមានការពិភាក្សា អំពីការបោសសម្អាត ឬ ក៏ចាប់ខ្លួនមនុស្សនោះទេ"* ។[813]

២៦៨ ក្រៅពីតួនាទីជាលេខាស្រុកចំការលើ ស៊ូ សឿន ហៅ សឿន ក៏ជាសមាជិកគណៈតំបន់ ៤២ ។ លើសពីនេះ ស៊ូ សឿន ហៅ សឿន ក៏ជាប្រពន្ធរបស់លេខាភូមិភាគកណ្តាល កែ ពក ហើយត្រូវបានទទួលការតម្លើង តួនាទីជាបន្តបន្ទាប់យ៉ាងលឿន តាំងពីក្រោយថ្ងៃទី១៧ ខែ មេសា ឆ្នាំ១៩៧៥ ។ ដំបូងអ្នកស្រីជាសមាជិកគណៈស្រុកព្រៃកប្រសប់ មានភារកិច្ចទទួល អ្នកដែលគេជម្លៀសពីភ្នំពេញ ។[814] បន្ទាប់មក ក្រោយពីបានធ្វើការនៅស្រុកព្រែកប្រសប់ បានតែប្រហែលកន្លះឆ្នាំ ស៊ូ សឿន ត្រូវបានគេផ្ទេរឱ្យទៅបំរើការងារជាគណៈស្រុកចំការ លើ ។[815] ជាលេខាស្រុកចំការលើ សឿន តែងតែប្រជុំនៅនឹងផ្ទះរបស់គាត់ ជាមួយបណ្តា ប្រធានឃុំ ដើម្បីដាក់បញ្ហា និង ការណែនាំទៅឃុំទាំងនោះឱ្យអនុវត្តតាម ។[816]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581394



## ៤.៨. តំបន់ ៤៣

២៦៩ តំបន់ ៤៣ មានវិសាលភាពគ្របដណ្តប់លើ ៤ (បួន)[817] ស្រុករួមមាន៖ ស្រុកស្ទោង[818] ស្រុកកំពង់ស្វាយ[819] ស្រុកសណ្តាន់[820] និងស្រុកសន្ទុក[821]។ រីឯទីស្នាក់ការនៃមន្ទីរតំបន់ ៤៣ ស្ថិតនៅក្នុងទីរួមខេត្តកំពង់ធំ ។[822] រចនាសម្ព័ន្ធគ្រប់គ្រងតំបន់ ៤៣ មានសមាសភាពជាលេខាតំបន់ អនុលេខាតំបន់ និងសមាជិកគណៈតំបន់ ដូចតំបន់ទូទៅនៅទូទាំងប្រទេស ។[823]

២៧០ ក្នុងតំបន់ ៤៣ ដំបូងមានឈ្មោះ គាំ ចាន់ ហៅ ចន ជាលេខាតំបន់ ។[824] បន្ទាប់ពីឆ្នាំ១៩៧៧ ស៊ីម[825] បានក្លាយជាលេខាតំបន់ ៤៣ ជំនួសលេខាតំបន់ចាស់ឈ្មោះ ចន ដែលត្រូវរងការចាប់ខ្លួន ។[826] ក្រោយមកឈ្មោះ ស៊ីម ត្រូវបានចាប់ខ្លួនហើយឈ្មោះ ផែន បានឡើងជំនួសវិញ ។[827] ប៉ុន្តែ ទំនងជាអាចមានមនុស្សម្នាក់ទៀតមានឈ្មោះ តា ងិន ដែលកាន់តំណែងជាលេខាតំបន់ ៤៣ ។[828]

២៧១ នៅតំបន់ ៤៣ មានការដ្ឋានការងារជាច្រើនកន្លែង ប៉ុន្តែ ការដ្ឋានធ្វើការងារដែលទទួលការចាប់អារម្មណ៍ និងជាគម្រោងដ៏ធំជាងគេគឺ ការដ្ឋានទំនប់១មករា ដែលជាការដ្ឋានការងាររបស់ភូមិភាគ និងមានលេខាភូមិភាគកណ្តាល កែ ពក ជាអ្នកគ្រប់គ្រងផ្ទាល់ ។[829]

## ៥. តំបន់ស្វយ័ត

២៧២ តំបន់ស្វយ័ត មានសិទ្ធិអំណាចធ្វើការទំនាក់ទំនងផ្ទាល់ជាមួយ គណៈកម្មាធិការមជ្ឈិមបក្ស ពីព្រោះថា ថ្នាក់តំបន់ស្វយ័តមានឋានានុក្រមរដ្ឋបាលស្មើនឹងភូមិភាគដែរ ។[830] ជាក់ស្តែង តួយ៉ាងដូចជាតំបន់ ១០៥ ដែលជាតំបន់ស្វយ័ត មានសិទ្ធិរាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិមបក្ស ។[831]

២៧៣ សម្រាប់ការសម្រេចចាប់ខ្លួនមនុស្សវិញ លេខាតំបន់ស្វយ័ត មានសិទ្ធិសម្រេចក្នុងការចាប់មនុស្សបាន ។[832] ជាក់ស្តែង តំបន់ ១០៥ មានសិទ្ធិអំណាចចាប់ខ្លួនមនុស្សបាន ។ នេះត្រូវបានសាក្សីមួយរូបបានអះអាងថា *"ក្នុងនាមជាលេខាតំបន់ (តំបន់ ១០៥) តា សារុន គាត់មានសិទ្ធិសម្រេចទៅលើបញ្ហាចាប់ខ្លួននេះ"* ។[833]



ECCC * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581395



## ៦. តំបន់

២៧៤ រចនាសម្ព័ន្ធគ្រប់គ្រងនៅថ្នាក់តំបន់ជាទូទៅមាន"គណៈកម្មាធិការតំបន់" ឬ "គណៈតំបន់"។ គណៈកម្មាធិការតំបន់មានសមាសភាពដូចជា លេខាតំបន់ អនុលេខាតំបន់ និងសមាជិកគណៈតំបន់ ។[834] បណ្តាលេខាស្រុកភាគច្រើនក្នុងតំបន់ អាចមានតួនាទីជាសមាជិកគណៈតំបន់បន្ថែមទៀត តាមលំដាប់លេខរៀងជាសមាជិកទី ១, ២, និងបន្តបន្ទាប់ អាស្រ័យទៅតាមស្ថានភាពជាក់ស្តែងតាមតំបន់នីមួយៗ ។ ប៉ុន្តែ ការទទួលបានជាសមាជិកគណៈតំបន់នេះក៏មិនជាទូទៅ និងស្វ័យប្រវត្តិនោះទេ ។[835]

២៧៥ សាក្សីឈ្មោះ ពេជ្រ ជឹម អតីតលេខាស្រុកត្រាំកក់ (ស្រុក១០៥) បានលើកឡើងថា *"គណៈស្រុកមិនមែនជាសមាជិកគណៈតំបន់ទេ លើកលែងតែ មានសន្និបាតថ្នាក់តំបន់បានប្រកាសសម្រេច ដូចជាករណីឈ្មោះ សៀង ជាលេខាស្រុកកោះអណ្តែត ត្រូវបានសន្និបាតប្រកាសឱ្យចូលជាសមាជិកតំបន់ ១៣"*។[836] តួនាទីជាលេខាតំបន់ ត្រូវទទួលបន្ទុកគ្រប់គ្រងកិច្ចការទាំងឡាយ ក្នុងតំបន់ទាំងមូលរួមទាំងកងទ័ពផងដែរ ។[837]

២៧៦ លក្ខន្តិកៈរបស់ ប.ក.ក ចែងយ៉ាងច្បាស់ថា អង្គការដែលមានសិទ្ធិអំណាចធំជាងគេបំផុតសម្រាប់តំបន់គឺ **"សន្និបាតតំណាងតំបន់"** ។ ក្នុងរយៈពេលចន្លោះពីសន្និបាតមួយទៅមួយ មានអង្គការប្រតិបត្តិការខ្ពស់ជាងគេសម្រាប់តំបន់គឺ **"គណៈកម្មាធិការតំបន់"** ។[838] នៅថ្នាក់តំបន់ តែងមានរបបប្រជុំជាទៀងទាត់មួយខែម្តង ។[839] ពេលខ្លះករណីមមាញឹកការងារខ្លាំង អាចមានដល់ទៅ ២ (ពីរ) ដងក្នុងមួយខែ ។[840]

## III. សាវតារ តួនាទី និង ការចូលរួមរបស់ អោ អាន

### ក. សាវតាររបស់ អោ អាន

២៧៧ **តា អាន**[841], អោម អាន[842], ឌិម អាន[843], អោ យឿន[844], អោម យឿង[845], ឬ **អោ អាន**[846] មានឈ្មោះតាំងពីកំណើតមកថា អោម យឿង[847] ។ ឈ្មោះ **អោ អាន** ត្រូវបានហៅជាផ្លូវការ ក្រោយពីនីតិវិធីនៃការបង្ហាញខ្លួនលើកដំបូងរបស់ **អោ អាន** ដោយសហចៅក្រមស៊ើបអង្កេត



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581396



អង្កេតអន្តរជាតិ នាថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ ។[848] រីឯ ឈ្មោះថា "ថូ អាន" ត្រូវបាន **អោ អាន** អះអាងយ៉ាងដាច់អហង្ការថា ខ្លួនពុំដែលបានប្រើប្រាស់ឈ្មោះណាផ្សេង ក្រៅតែពីឈ្មោះ អោម អាន ដែលពីមុនបានហៅថា អោម យឿង នោះទេ ។[849]

២៧៨ ទោះបីជាយ៉ាងណាឈ្មោះ **តា អាន** ឬ **អោ អាន** ត្រូវបានកំណត់អត្តសញ្ញាណថា ជាបុគ្គលតែម្នាក់ ។ ដូចនេះការហៅឈ្មោះណាមួយ ក៏ពុំមានបញ្ហាក្នុងការកំណត់នូវអត្តសញ្ញាណលើជនត្រូវចោទនេះដែរ ។ ប៉ុន្តែ ដើម្បីងាយស្រួល និង កុំឱ្យមានបកស្រាយផ្ទុយណាមួយ គេគួរកំណត់ការហៅឱ្យមានការស៊ីសង្វាក់គ្នាក្រោមឈ្មោះតែមួយ ដែលកន្លងមកត្រូវបានគេទទួលស្គាល់ និង ត្រូវបានហៅជាទូទៅថា "**អោ អាន**" លើកលែងតែ ករណីដែលជាការស្រង់នូវសម្តីដើមរបស់ចម្លើយសាក្សីដែលនិយាយថា **អាន** ឬ **តា អាន** តែប៉ុណ្ណោះ ។

២៧៩ **អោ អាន** កើតនៅឆ្នាំ១៩៣៣[850] តែសំបុត្រកំណើតអត្រានុកូលដ្ឋានជាផ្លូវការសរសេរថា **អោ អាន** បានកើតនៅឆ្នាំ១៩៣៦ ។[851] គិតមកដល់ពេលនេះជនត្រូវចោទ **អោ អាន** មានអាយុ ៨៥[852]ឆ្នាំ(គិតត្រឹមឆ្នាំ២០១៨)។ **អោ អាន** មានស្រុកកំណើតនិងកើតនៅភូមិតាំងស្វាយ ឃុំពាម ស្រុកសាមគ្គីមានជ័យ (អតីតស្រុកកំពង់ត្រឡាចលើ)[853] ខេត្តកំពង់ឆ្នាំង។[854]

២៨០ **អោ អាន** មានលោកឪពុកឈ្មោះ ហ៊ឹង ឪ[855] ដែលលោកបានស្លាប់តាំងពីកុមារា **អាន** មានអាយុបានប្រមាណជា ១២ (ដប់ពីរ) ឆ្នាំ[856]។ **អោ អាន** មានម្តាយឈ្មោះ ឯក ទន់[857] បានស្លាប់តាំងពីឆ្នាំ១៩៧៩ ។[858] បន្ទាប់ពីឪពុកលាចាកលោក កុមារា **អាន** ត្រូវបានជីតាខាងម្តាយយកទៅចិញ្ចឹមបីបាច់ ហើយក្រោយមកបានបញ្ជូនកុមារា **អាន** ឱ្យបួសរៀន ។[859]

២៨១ នៅឆ្នាំ១៩៥៤ ក្នុងអាយុ ១២ (ដប់ពីរ) ឆ្នាំ កុមារា **អាន** ត្រូវបានបំបួសជាសាមណេរអស់រយៈកាលប្រមាណ ៦ (ប្រាំមួយ) ព្រះវស្សា[860] នៅវត្តតាំងខ្មៅ[861] ស្ថិតនៅក្នុងឃុំពាម ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។[862] នៅឆ្នាំ១៩៦០ **អោ អាន** លាចាកសិក្ខាបទដោយមូលហេតុមានជំងឺ ។[863] ចាប់ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៣ **អោ អាន** មានជំងឺគ្មានស្រាកស្រាន្ត អស់រយៈកាលរហូតដល់ ៣ (បី) ឆ្នាំ ។ [864] នាខណៈនោះដែរ **អោ អាន** បានប្តូរឈ្មោះពី អោម យឿង មកជាឈ្មោះ អោម អាន ។[865] ពីឆ្នាំ១៩៦៣-១៩៦៩ **អោ អាន** បានប្រកបមុខរបរជាកសិករធ្វើស្រែ និងរស់នៅជាមួយម្តាយ ។[866] **អោ អាន** មានប្រពន្ធនិងកូន



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ៨២

បង្កើតចំនួន ៤ (បួន) នាក់ ។[867] រហូតដល់ពេលបច្ចុប្បន្ននេះ បងប្អូនរបស់ **អោ អាន** បាន ស្លាប់អស់ ២ (ពីរ) នាក់នៅរស់តែ ២ (ពីរ) នាក់ ។

២៨២ សម្រាប់ជីវិតអាពាហ៍ពិពាហ៍ **អោ អាន** មានប្រពន្ធរហូតដល់ពីរនាក់[868] ដោយពីដំបូងនៅ ឆ្នាំ១៩៧៦ **អោ អាន** បានរៀបការជាមួយស្ត្រីម្នាក់ឈ្មោះ បាន គៅ[869] ហៅ កាន[870] ជាអ្នក មានស្រុកកំណើតនៅខេត្តកំពត[871] ហើយក្រោយមកនៅឆ្នាំ១៩៧៩ កាន បានទទួលមរណ-ភាព[872] ហើយបានបន្សល់នូវកូនស្រីម្នាក់ ។[873] បន្ទាប់មកនៅឆ្នាំ១៩៨០ **អោ អាន** បាន រៀបការជាមួយប្រពន្ធទីពីរ ឈ្មោះ ព្រំ វ៉ាន់ ដែលជាស្ត្រីមេម៉ាយកូនមួយ ។ ក្រោយមក ប្រពន្ធទីពីរ ក៏បានទទួលមរណភាពទៀតនាឆ្នាំ២០១៤ ក្នុងអាយុ ៦២ (ហុកសិបពីរ) ឆ្នាំ ។[874] **អោ អាន** មានកូន ២ (ពីរ) នាក់ ។[875]

២៨៣ នៅឆ្នាំ១៩៧០ **អោ អាន** បានចាប់ផ្តើមចូលរួម ក្នុងចលនាតស៊ូដើម្បីរំដោះសម្តេចឪ[876] ក្រោមការដឹកនាំរបស់ តា១៥[877] (ឬតាម៉ុក)[878] និងបានកាន់តួនាទីជាហូរហែរ ក្នុងស្រុក តំបន់នៃភូមិភាគនិរតីនិងនៅភូមិភាគកណ្តាល ក្រោយពីគាត់ត្រូវបានអង្គការបញ្ជូនពីភូមិភាគ និរតីទៅកាន់ភូមិភាគកណ្តាលនៅពាក់កណ្តាលឆ្នាំ១៩៧៧[879] ។ តួនាទីនិងតំណែងទាំងនោះ ត្រូវបានបង្ហាញជូនខាងលើរួចហើយ (កថាខណ្ឌទី ១៩០, ១៩១, និង ២៤២) ។

២៨៤ ក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ **អោ អាន** បានគេចខ្លួនទៅរស់នៅតាម បណ្តោយព្រំដែនកម្ពុជា-ថៃ ។ ក្រោយមកទៀត **អោ អាន** បានភៀសខ្លួនទៅរស់នៅស្រុក អន្លង់វែង ខេត្តឧត្តរមានជ័យ ។[880] នៅឆ្នាំ១៩៩៩ ក្រោយពីមានចលនាសមាហរណកម្ម កងទ័ពខ្មែរក្រហមចូលជាមួយរាជរដ្ឋាភិបាលកម្ពុជា **អោ អាន** ក៏បានផ្លាស់ទៅរស់នៅកន្លែង ផ្សេងនាប៉ែកខាងលិចនៃប្រទេសកម្ពុជា ។[881] បច្ចុប្បន្ន **អោ អាន** បានកំពុងរស់នៅក្នុងភូមិ អូរគគីរ ឃុំអូរដា ស្រុកកំរៀង ខេត្តបាត់ដំបង[882] ក្នុងនាមជាកសិករសាមញ្ញម្នាក់[883] ដែល មានវ័យចំណាស់ជរា ហើយសុខភាពក៏ទ្រុឌទ្រោមមែនទែនជាមួយជំងឺប្រចាំកាយ[884] ។



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ខ. ការចូលរួមរបស់ អោ អាន

២៨៥ មុននឹងបរិយាយអំពីការចូលរួមរបស់ **អោ អាន** យើងសូមបង្ហាញពីអង្គហេតុ ទាក់ទិនបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ដោយ ស.ព.អ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម ដែលមានៈ ១.ការបោសសម្អាតនៅភូមិភាគកណ្តាល, ២.មន្ទីរសន្តិសុខវត្តអូរត្រកួន, ៣.មន្ទីរសន្តិសុខវត្តបាធាយ, ៤.មន្ទីរសន្តិសុខមិត្តសុប (គរ), ៥.មន្ទីរសន្តិសុខភ្នំប្រុស, ៦.មន្ទីរសន្តិសុខគោកព្រីង, ៧.មន្ទីរសន្តិសុខចំការស្វាយចន្ទី, ៨.ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ, ៩.អំពើប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម, ១០.មន្ទីរសន្តិសុខវត្តស្រងែ, ១១.គុកនិងកន្លែងសម្លាប់ទួលតាផ្លុង, ១២.មន្ទីរសន្តិសុខវត្តកណ្តាល, ១៣.មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, ១៤.អំពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងស្រុកកំពង់សៀម និងស្រុកព្រៃឈរ, ១៥.មន្ទីរសន្តិសុខវត្តតាមះ, ១៦.អំពើប្រល័យពូជសាសន៍ជនជាតិចាមនិងមន្ទីរសន្តិសុខវត្តអូរត្រកួន និង ១៧.មន្ទីរសន្តិសុខនិងកន្លែងសម្លាប់មនុស្សនៅទួលបេង និងវត្តអង្គញ្ញដី ។ ស.ច.ស.ជ សូមធ្វើការកត់សម្គាល់ថាមានទីតាំងឧក្រិដ្ឋចំនួន ១៧ (ដប់ប្រាំពីរ) ដែលត្រូវបានចោទក្នុងដីកាទាំងពីរប្រភេទរបស់ ស.ព.អ ។[885]

២៨៦ ស.ច.ស.អ បានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យលើ **អោ អាន** ពាក់ព័ន្ធនឹងទីតាំងឧក្រិដ្ឋចំនួន ១០ (ដប់) ។ ក្រោយមក ស.ច.ស.អ ក្នុងដំណើរការស៊ើបសួរ បានកាត់បន្ថយនូវទីតាំងបទឧក្រិដ្ឋមួយចំនួន តាមខ្លឹមសារដីកាសម្រេចកាត់បន្ថយវិសាលភាព មានអង្គហេតុចំនួន ៨ (ប្រាំបី) ដូចជាៈ មន្ទីរសន្តិសុខវត្តកណ្តាល, មន្ទីរសន្តិសុខចំការស្វាយចន្ទី, មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, មន្ទីរសន្តិសុខវត្តស្រងែ, ការចាប់ខ្លួននិងការសម្លាប់ជនជាតិចាមនៅភូមិភាគបូព៌ា, ការធ្វើទារុណកម្មនៅទួលបេង/វត្តអង្គញ្ញដី, និងការដាក់ក្នុងមន្ទីរឃុំឃាំងនិងការធ្វើទុក្ខបុកម្នេញនៅវត្តភ្នំប្រុស, មន្ទីរសន្តិសុខទួលតាផ្លុង ។[886] ទោះបីជាយ៉ាងនេះក្តី នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ស.ព.អ បានប្រើពាក្យ "គុកនិងកន្លែងសម្លាប់ទួលតាផ្លុង" ដែលហាក់បីដូចជាបង្ហាញថា ទីតាំងនេះមានមន្ទីរសន្តិសុខផងនិងកន្លែងសម្លាប់មនុស្សផង ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES / CO-JUGES D'INSTRUCTION

២៨៧ ដូចដែលបានរៀបរាប់ពីខាងដើមរួចមកហើយ ស.ច.ស.ជ មិនបានឯកភាពលើការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យទេ ។ ទោះបីជាយ៉ាងនេះ ស.ច.ស.ជ ក៏នឹងពិនិត្យពិចារណានូវអង្គហេតុពាក់ព័ន្ធនឹងទីតាំងដាក់ក្រោមការពិនិត្យទាំង ១០ (ដប់) ជាលម្អិត ដោយអនុលោមតាមការទាមទារនៃគោលការណ៍ភ័ស្តុតាងសរុប ដើម្បីពិចារណាថា **អោ អាន** ស្ថិតចូលក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ឬ ទេ ?

២៨៨ ការដាក់ឲ្យស្ថិតក្រោមការពិនិត្យ ដើម្បីឲ្យជនត្រូវចោទបានដឹង និងត្រៀមលក្ខណៈតទល់ពាក់ព័ន្ធនឹងអង្គហេតុនៃទីតាំងទាំងនេះ ដែលជួយសម្រួលនូវការអនុវត្តន៍សិទ្ធិទទួលបានព័ត៌មាន ការប្រាស្រ័យសិទ្ធិក្នុងការពារខ្លួនតាមផ្លូវច្បាប់ ក្នុងសវនាការអង្គសេចក្តីប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ។ ស.ច.ស.ជ ក៏នឹងពិចារណាផងដែរ នូវព័ត៌មានពាក់ព័ន្ធនឹងអង្គហេតុដទៃ ដែលមិនត្រូវបានដាក់ក្រោមការពិនិត្យ ឬ ដកហូតពីការស៊ើបសួរ ។

## ១. ទីតាំងឧក្រិដ្ឋកម្ម

### ១.១. កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស

២៨៩ កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស មានទីតាំងស្ថិតក្នុងឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[887] កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ភូមិភាគ ។[888] ជឿន ជាអ្នកគ្រប់គ្រងផ្នែកសន្តិសុខនៅភ្នំប្រុស ។[889] កន្លែងសម្លាប់មនុស្សភ្នំប្រុស ស្ថិតនៅក្បែរមន្ទីរស្រុកកំពង់សៀម ។[890]

២៩០ អ្នកទោសដែលត្រូវនាំទៅយកសម្លាប់នៅភ្នំប្រុស ជាទូទៅត្រូវបានគេយកទៅសម្លាប់ភ្លាមៗ ដោយមិនបានឃុំទុកជាបណ្តោះសិននោះទេ ។[891] ប៉ុន្តែ បើសម្លាប់មិនទាន់ គេយកអ្នកទោសនោះទៅឃុំឃាំង នៅគុកទីរួមខេត្តកំពង់ចាម ដែលជាកន្លែងមន្ទីរភូមិភាគកណ្តាល (បច្ចុប្បន្នជាសណ្ឋាគារ៧មករា) ។[892] លើសពីនេះ សាក្សីឈ្មោះ មន ម៉ុត បានលើកឡើងថា "*នៅក្នុងឆ្នាំ១៩៧៧ ឬ ១៩៧៨ ។ អ្នកភូមិជាច្រើនគ្រួសារត្រូវបានគេប្រាប់ឲ្យរៀបចំអីវ៉ាន់ ដើម្បីទៅនៅផ្ទះថ្មី ប៉ុន្តែ តាមពិតដែលខ្ញុំដឹង អ្នកទាំងនោះត្រូវបានគេដឹកតាមឡានមកភ្នំប្រុស*" ។[893]


ECCC * CETC * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

២៩១ ពាក់ព័ន្ធឡានដឹកជញ្ជូនមនុស្សទៅវត្តភ្នំប្រុស នាពេលនោះសាក្សីបាននិយាយថា គេប្រើឡានដែលមានសញ្ញាសម្គាល់ជាឡានរបស់ភូមិភាគ ក្នុងការដឹកមនុស្សដែលបានជាប់ឃុំឃាំងនៅមន្ទីរសន្តិសុខវត្តតាមេះ ដើម្បីយកទៅសម្លាប់នៅភ្នំប្រុស ។[894] មិនតែប៉ុណ្ណោះ សក្ខីកម្មសាក្សីឈ្មោះ ញ៉ែម ចេន អតីតអ្នកការពារ **អោ អាន** បានបង្ហាញថា *"ឡានភូមិភាគគេដាក់ថា ឡានភូមិភាគកណ្តាលនៅស្លាកឡាន"*។[895] ទន្ទឹមនឹងនោះ នៅមានសាក្សីម្នាក់ទៀតបានផ្តល់ការកត់សម្គាល់ជុំវិញការកំណត់អត្តសញ្ញាណឡាននេះដែរថា *"នៅលើឡានជញ្ជាំង និង កាងខាងមុខ ឡានភូមិភាគមានសរសេរថា ភូមិភាគឧត្តរ៣០៤"*។[896]

២៩២ សាក្សីឈ្មោះ កែវ ពេជ្រវណ្ណៈ ធ្លាប់បានឆ្លើយថា *"ឪពុកខ្ញុំបានហៅ តាវ័យរាប ប្រធានកងពលថ្មីរបស់ភូមិភាគកណ្តាល បានឆ្លើយថា បង* ***អាន*** *ជាអ្នកបញ្ជាឲ្យដឹកប្រជាជនឲ្យទៅនៅភូមិថ្មី ឪពុកខ្ញុំសួរទៀតថាភូមិថ្មីនៅឯណា? តារាបឆ្លើយថា នៅម្តុំភ្នំប្រុសភ្នំស្រី ពេលនោះឪពុកខ្ញុំឆ្លើយថាម្តេចអញមិនដឹង តារាបឆ្លើយទៀតថា បង* ***អាន*** *ជាអ្នកបញ្ជាឲ្យដឹកប្រជាជនទាំងនោះយកទៅកម្ទេចនៅទីនោះ"* ។ [897]

២៩៣ ប៉ុន្តែ កន្លងមកមានសក្ខីកម្មសាក្សីឈ្មោះ វង សុគន្ធ បានបង្ហាញថា *"ខ្ញុំមិនដឹងថាអ្នកណាជាអ្នកបញ្ជាឲ្យចាប់មនុស្សទេ ប៉ុន្តែ ខ្ញុំដឹងថា តា ពក ជាគណៈភូមិភាគ ដូច្នេះខ្ញុំគិតថា គឺគាត់ជាអ្នកបញ្ជាឲ្យចាប់និងសម្លាប់មនុស្សទាំងនោះហើយ ។ រាល់ពេលបញ្ជូនមនុស្សមកភ្នំប្រុសដើម្បីសម្លាប់ គឺខ្ញុំបានឃើញបុរសម្នាក់មាឌក្រអាញមកជាមួយ ដែលក្រោយមកខ្ញុំសួរជឿនថា តើម្នាក់នោះជានរណា ជឿនបានប្រាប់ខ្ញុំថា គាត់គឺជា តា ពក"*។[898] ខណៈដែលសាក្សីម្នាក់ទៀតឈ្មោះ សា ណូ ក៏ធ្លាប់ផ្តល់សក្ខីកម្មទាក់ទង កែ ពក ដែរថា *"ខ្ញុំបានឃើញមេខ្មែរក្រហមម្នាក់មាឌធំ បានមកមើលការដ្ឋានការងារខ្ញុំ ។ គេប្រាប់ខ្ញុំថាគាត់ជា កែ ពក"* ។[899] សាក្សីឈ្មោះ អ៊ិន គឹមអេង ជាអតីតយោធាប្រចាំការនៅភ្នំប្រុស តាំងពីដើមឆ្នាំ១៩៧៧ បាននិយាយថា *"បានត្រឹមត្រូវហើយ កែ ពក គឺជាអ្នកគ្រប់គ្រងទាំងមន្ទីរសន្តិសុខរបស់ភូមិភាគ និង ទីសម្លាប់មនុស្សនៅភ្នំប្រុស"*។[900]

២៩៤ កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស មានទីតាំងស្ថិតនៅក្បែរមន្ទីរស្រុកកំពង់សៀម ប៉ុន្តែចំពោះការគ្រប់គ្រងមន្ទីរសន្តិសុខ ពុំមែនជាសមត្ថកិច្ចរបស់ខាងតំបន់នោះទេ ដោយហេតុថា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581401



ភ្នំប្រុសស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់ពីគណៈភូមិភាគដែលមាន កែ ពក ជាលេខាភូមិភាគ ។

២៩៥ ជុំវិញការកត់សម្គាល់លើបញ្ហានេះ មានសាក្សីមួយរូបបានផ្តល់សក្ខីកម្មថា *"ខ្ញុំឮថាគាត់ (អោ អាន) ជាលេខាតំបន់ ៤១ ខ្ញុំមិនដែលឃើញគាត់នៅភ្នំប្រុសនោះឡើយ"* ។[901] អតីតកងការពារឲ្យ **អោ អាន** បាននិយាយថា *"ខ្ញុំអត់បានទៅ(ភ្នំប្រុស)ព្រោះ **តា អាន** គ្រប់គ្រងតែកងមាស ជើងព្រៃ បាធាយ និង ចំការលើ"* ។[902] ដូចគ្នាដែរ សាក្សីឈ្មោះ អ៊ឹម ប៊ុន បាននិយាយថាខ្លួនមិនដែលបានជូន **តា អាន** ទៅភ្នំប្រុសទេ ។[903]

២៩៦ កន្លែងសម្លាប់មនុស្សនៅវត្តភ្នំប្រុស ត្រូវបានគេចាត់ទុកជា ទីកន្លែងសម្លាប់មនុស្សយ៉ាងសាហាវ ។[904] ជាក់ស្តែង តំបន់ភ្នំប្រុសនេះត្រូវបានកាន់កាប់ ដោយកងទ័ពខ្មែរក្រហមតាំងពីមុនឆ្នាំ១៩៧៥ ។ នេះបើតាមសាក្សីឈ្មោះ មន ម៉ុត ជាអតីតកងទ័ពដែលបានប្រាប់ថា *"នៅប្រហែលចាប់ពីឆ្នាំ១៩៧៣ ទីតាំងនោះ(ភ្នំប្រុស)ស្ថិតក្រោមការគ្រប់គ្រងរបស់យោធាខ្មែរក្រហម ហើយខ្ញុំគិតថា ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់របស់ភូមិភាគ"* ។[905]

២៩៧ មានមនុស្សចំនួនប្រមាណជា ១០.០០០ (មួយម៉ឺន) នាក់ បានស្លាប់នៅភ្នំប្រុស ផ្អែកលើមូលដ្ឋានឯកសាររបស់រដ្ឋាភិបាលក្រោយថ្ងៃរំដោះ តាមរយៈការគាស់កកាយប្រមូលឆ្អឹងសាកសពនៅជុំវិញបរិវេណកន្លែងសម្លាប់មនុស្សភ្នំប្រុស ក្នុងអំឡុងឆ្នាំ១៩៨២ ។[906] ប៉ុន្តែក៏មានដែរនូវបណ្តាតួលេខផ្សេងៗពីនេះ ដោយផ្អែកលើការប៉ាន់ស្មានរបស់សាក្សី ឬឯកសារផ្សេងៗដែល បានពីការអះអាងដោយអាជ្ញាធរមូលដ្ឋាន ។[907]

## ១.២. មន្ទីរសន្តិសុខវត្តអូរត្រកួន

២៩៨ មន្ទីរសន្តិសុខវត្តអូរត្រកួន ស្ថិតក្នុងភូមិសំបួរមាស ឃុំពាមជីកង ស្រុកកងមាស ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[908] មន្ទីរសន្តិសុខវត្តអូរត្រកួន ជាមន្ទីរសន្តិសុខថ្នាក់ស្រុក ។[909] មន្ទីរសន្តិសុខត្រូវបានបង្កើត និងបានដាក់ឲ្យដំណើរការនៅឆ្នាំ១៩៧៦ តាំងពីមុនក្រុមនិរតីផ្ទេរមកភូមិភាគកណ្តាល ។[910] នាពេលនោះស្ថានភាពបរិវេណនៃមន្ទីរសន្តិសុខវត្តអូរត្រកួន ត្រូវបានហ៊ុំព័ទ្ធដោយរបងបន្លាលួស ។[911]



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

២៩៩ ប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួន ដំបូងឈ្មោះ ឃុន ។ ឃុន ធ្វើការងារបានប្រមាណ ៣ (បី) ខែត្រូវគេចាប់ខ្លួនយកទៅសម្លាប់ ។[912] បន្ទាប់មកឈ្មោះ ហ៊ិន[913] បានឡើងជាប្រធានមន្ទីរសន្តិសុខជំនួស និងមានឈ្មោះ បុត្រ ជាអនុប្រធាន ដែលក្រោយមកឈ្មោះ បុត្រ នេះក៏ត្រូវបានអង្គការចេញបញ្ជាចាប់យកទៅសម្លាប់នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ ដោយសារទង្វើខុសសីលធម៌ ហើយឈ្មោះ គួង បានឡើងជំនួស បុត្រ ។[914] ហ៊ិន បានកាន់តួនាទីជាប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួន រហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ។[915]

៣០០ អគារធំៗក្នុងបរិវេណវត្តអូរត្រកួន ត្រូវបានគេប្រើជាកន្លែងរបស់មន្ទីរសន្តិសុខរួមទាំងព្រះវិហារ ។[916] អ្នកទោសនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ក្រោយពីចាប់បានត្រូវបានគេនាំយកមកឃុំឃាំងក្នុងវិហារវត្ត ។ អ្នកទោសប្រុស និងអ្នកទោសស្រី ស្ថិតនៅដាច់ពីគ្នាដោយមានរបាំងជញ្ជាំងក្តារចែកជាពីរនៅចំពីមុខព្រះពុទ្ធបដិមា ។[917] អ្នកទោសប្រុសៗ ត្រូវគេដាក់ខ្នោះជើងជាជួរៗភ្ជាប់ទៅនឹងរបាដែក ។[918]

៣០១ ការចាប់ខ្លួនមនុស្សមកកាន់មន្ទីរសន្តិសុខ ត្រូវបានអនុវត្តដោយមនុស្ស ២ (ពីរ) ក្រុមមានក្រុមកងឈ្លបឃុំ និង ក្រុមដាវវែង ដែលមានសិទ្ធិអំណាចចាប់មនុស្សនៅទូទាំងស្រុកកងមាស ។[919] ក្រុមឈ្លបឃុំមានសមាជិកប្រហែល ៧ (ប្រាំពីរ) នាក់ដោយមានឈ្មោះ សំរិតមុយ ជាប្រធានតាំងពីឆ្នាំ១៩៧៣ រហូតដល់ឆ្នាំ១៩៧៩ ។[920] ក្រុមដាវវែង មានសមាជិកប្រហែល ៦ (ប្រាំមួយ) នាក់ ដោយមានឈ្មោះ ចូយ ជាប្រធាន, តាយ គឹមហ៊ិន ជាអនុប្រធាន, គួង, មឿន, និង ហ៊ាន់ ជាសមាជិក ។[921] ក្រុមដាវវែង ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៧ ក្នុងគោលដៅដើរចាប់មនុស្ស ។[922] ហ៊ិន ជាប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួន និងជាអ្នកគ្រប់គ្រងក្រុមដាវវែងដោយផ្ទាល់ ។[923]

៣០២ អ្នកទោសនៅមន្ទីរសន្តិសុខវត្តអូរត្រកួន ភាគច្រើនជាប្រជាជននៅក្នុងស្រុកកងមាស ។[924] ជាទូទៅ ប្រធានមន្ទីរសន្តិសុខអូរត្រកួន ជាអ្នកដែលមានសិទ្ធិអំណាច ក្នុងការចេញបញ្ជាឱ្យបញ្ជូនមនុស្សមកមន្ទីរសន្តិសុខ ។[925] មន្ទីរសន្តិសុខវត្តអូរត្រកួន តែងមានការដឹកជញ្ជូនមនុស្សដែលចាប់បានចូលស្ទើរតែជារៀងរាល់ថ្ងៃ តាមមធ្យោបាយដូចជា រទេះសេះ ឬ រទេះគោ ។[926] វិធីនៃការចាប់មនុស្សមកកាន់មន្ទីរសន្តិសុខភាគច្រើនមាន ២ (ពីរ) របៀប៖ ទី១ ប្រធានមន្ទីរសន្តិសុខ និងក្រុមដាវវែងបានចុះទៅចាប់ដោយផ្ទាល់ដល់មូលដ្ឋាន និង ទី២ ប្រើ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ឧបាយកលបំភាន់ ដោយប្រាប់ឲ្យជនមុខសញ្ញាដែលរងការចោទ ក្រោមហេតុផលផ្សេងៗ ដើម្បីឲ្យសាមីខ្លួនធ្វើដំណើរមកមន្ទីរសន្តិសុខវត្តអូរត្រកួនដោយខ្លួនឯង ។[927]

៣០៣ អ្នកទោសត្រូវបានគេបែងចែកជា ២ (ពីរ)៖ អ្នកទោសស្រាល និង អ្នកទោសធ្ងន់ ។[928] អ្នកទោសមានទាំងប្រជាជនថ្មី ប្រជាជនមូលដ្ឋាន និង ជនជាតិចាម ។[929] អ្នកទោសស្រាលត្រូវគេឃុំមួយរយៈពេលខ្លីអាច ១ (មួយ) ឬ ២ (ពីរ) ខែ ហើយក្រោយមកអាចត្រូវបានដោះលែងវិញ ។[930] ផ្ទុយទៅវិញ អ្នកទោសធ្ងន់មិនត្រូវបានដោះលែងទេ ដោយអ្នកទាំងនោះត្រូវបានគេយកទៅសម្លាប់ ។[931] នៅពេលសួរចម្លើយ អ្នកទោសត្រូវបានគេធ្វើទារុណកម្មយ៉ាងខ្លាំងដើម្បីទទួលបាននូវចម្លើយសារភាព ។[932] ជាក់ស្តែង សាក្សីជាអតីតកងការពារផ្ទាល់របស់ ហ៊ាន បានផ្តល់សក្ខីកម្មថា "*អ្នកទោសធ្ងន់ដែលត្រូវបានសួរចម្លើយរួច ត្រូវបានគេយកទៅសម្លាប់*" ។[933] អ្នកទោសត្រូវនាំទៅសម្លាប់ នៅខាងកើតរបង មន្ទីរសន្តិសុខវត្តអូរត្រកួន លើផ្ទៃដីទំហំប្រហែលជា ៣ (បី) ហិចតា ។[934]

៣០៤ អ្នកទោសដែលបញ្ជូនទៅសម្លាប់ម្តងៗមានគ្នាប្រមាណ ១០ (ដប់) នាក់ ។[935] អ្នកទាំងនោះត្រូវគេចងស្លាបសេក និងចងបិទមុខរួចបញ្ជូនទៅសម្លាប់ ពេលខ្លះនៅខាងមុខវត្តអូរត្រកួនចម្ងាយប្រមាណ ២០០ (ពីររយ) ម៉ែត្រ ដែលនៅទីនោះមានរណ្តៅជីករួចជាស្រេច ។[936] សាក្សីមួយរូបនិយាយថា "*មនុស្សមួយគ្រួសារដែលរស់នៅជិតខាងខ្ញុំ ត្រូវបានគេយកទៅវត្តអូរត្រកួន និងសម្លាប់ចោលនៅទីនោះ ដោយសារតែពួកគេហូបចេក និងដំឡូងដែលពួកគេដាំដោយខ្លួនឯង*" ។[937]

៣០៥ អ្នកទោសត្រូវបានគេវៃសម្លាប់ដោយដែកភ្លៅរទេះ ។[938] ពួកគេត្រូវបានគេយកទៅសម្លាប់ភាគច្រើននាពេលយប់ៗចាប់ពីម៉ោងប្រហែល ៧ (ប្រាំពីរ) យប់ទៅដល់រំលងអាធ្រាត។[939] ជាធម្មតានៅពេលមានការសម្លាប់មនុស្ស គេតែងចាក់មេក្រូដោយសម្លេងខ្លាំងៗ ។[940] អំពើនៃការសម្លាប់មនុស្ស បានកើតមានច្រើនជាងគេបំផុតនៅឆ្នាំ១៩៧៧ ដោយភាគច្រើននៃជនរងគ្រោះជាប្រជាជនថ្មី ។ ប៉ុន្តែ ចាប់ពីខែកញ្ញា ដល់ខែតុលា ឆ្នាំ១៩៧៧ ក៏មានជនជាតិចាមជាច្រើននាក់ត្រូវបានគេសម្លាប់ដែរ ។[941]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣០៦ ពាក់ព័ន្ធការសម្លាប់ជនជាតិចាមសាក្សីឈ្មោះ សេង ស្រ៊ុន បានលើកឡើងថា *"គេចាប់ជនជាតិចាមទាំងក្មេងទាំងចាស់ ៣០០ នាក់ ដាក់នៅលើផ្លូវមុខក្លោងទ្វារចូលវត្ត ពេលនោះគេបានចាត់ពីរនាក់ឱ្យនៅខាងជើង និង ពីរនាក់ទៀតនៅខាងត្បូង ។ គេបានចាប់ប្រជាជនចាមបីភូមិ (សំបួរមាសក, សំបួរមាសខ និង សាច់ស្ង) ក្នុងពេលចាប់នោះ ក្រុមឈ្លបដាវវែងត្រូវបានចែកចេញជាបីក្រុម ក្នុងមួយក្រុមមានគ្នាបួននាក់ ។ បន្ទាប់ពីចាប់ជនជាតិចាមរួចហើយពួកដាវវែងក៏ទៅបាត់អស់ទៅ ដោយបានទុកគ្នាខ្ញុំបួននាក់បណ្ដើរពួកចាម មកមន្ទីរសន្តិសុខក្នុងវត្តអូរត្រកួន ។ នាពេលដែលកំពុងធ្វើដំណើរនោះ ខ្ញុំមានគំនិតថាចង់ឱ្យជនជាតិចាមទាំងនោះរត់ តែពួកគេហាក់ដូចជាមិនដឹងពីការស្លាប់ គឺពួកគេមិនបានរត់ទេ។ ការចាប់នេះគឺមានបញ្ជាពីខាងស្រុកជាអ្នកបញ្ជា ក្នុងការចាប់ជនជាតិចាមគឺខាងគណៈស្រុក ។ ឈ្មោះ កានជាអ្នកបញ្ជា"* ។[942]

៣០៧ អតីតកងការពារផ្ទាល់ប្រធានមន្ទីរសន្តិសុខនេះ បានលើកឡើងថា *"ខ្ញុំគ្រាន់តែដឹងថាគេមានគម្រោងការដើម្បីសម្លាប់ក្រុមចាមទាំងអស់"* ។[943] នាពេលនោះថ្នាក់មូលដ្ឋាន មានការរៀបចំជាបញ្ជីស្ថិតិប្រជាជន ដើម្បីកំណត់មុខសញ្ញាជាប្រជាជនខ្មែរ ឬជនជាតិចាម ។[944] សាក្សីមួយរូបដែលធ្លាប់ជាអតីតមេភូមិនាពាក់កណ្ដាលឆ្នាំ១៩៧៨ បាននិយាយថា *"ខ្ញុំប្រាកដមេឃុំអត់មានឱ្យធ្វើបញ្ជីស្ថិតិជនជាតិចាមទេ ។ ពេលខ្ញុំក្លាយជាមេភូមិ ជនជាតិចាមត្រូវបានគេយកអស់ហើយ"* ។[945] រីឯសាក្សី ម៉ៅ សារឿន បានលើកឡើងថា *"ជនជាតិចាមមួយជំនាន់ខ្មែរក្រហម យកទៅសម្លាប់ស្ទើរតែទាំងអស់នៅឯវត្តអូរត្រកួន ក្នុងឃុំពាមជីកងស្រុកកងមាស។ នៅស្រុកកងមាសស្លាប់ស្ទើរទាំងអស់ នៅសល់តែមួយទេឈ្មោះ តា ម៉ាន"*។[946]

៣០៨ សាក្សីមួយរូបលើកឡើងថា *"ខ្ញុំជួបគាត់ (**តា អាន**) ចំនួនពីរដង។ ម្ដងនោះខ្ញុំជួបគាត់នៅវត្តអូរត្រកួននេះតែម្ដងគឺគេមកធ្វើមិទ្ទិញ ប៉ុន្តែ តាមយោបល់ខ្ញុំ មិទ្ទិញនេះហាក់បីដូចជាធ្វើបំភាន់ភ្នែកប្រជាជនតែប៉ុណ្ណោះ ដូចជាការសួរថា ពួកគេបានហូបចុកគ្រប់គ្រាន់ ឬអត់"*។[947] សាក្សីរូបនេះបន្ថែមទៀតថា *"មិទ្ទិញនេះគឺមានរយៈពេលប្រហែលជាបីម៉ោង ។ អ្នកដែលនិយាយនៅក្នុងកិច្ចប្រជុំនោះគឺ **អាន** គាត់និយាយតែម្នាក់ឯង និង អ្នកផ្សេងទៀតគ្រាន់តែស្ដាប់ប៉ុណ្ណោះ"* ។[948]

៣០៩ សាក្សី សេង ស្រ៊ុន និយាយថា *"ខ្ញុំធ្លាប់បានឃើញ **អាន** នៅក្នុងអង្គប្រជុំក្នុងវត្តអូរត្រកួន ។ នៅក្នុងអង្គប្រជុំនោះ **អាន** បានប្រាប់ប្រជាជនថា បើប្រធានកងឬប្រធានភូមិមិនឱ្យប្រជាជនហូបគ្រប់គ្រាន់ ឬមិនឱ្យប្រជាជនជីកដំឡូង សូមឱ្យប្រជាជនរាយការណ៍ប្រាប់គាត់ ។ ពេលនោះមនុស្សបីនាក់ នៅក្នុងភូមិឈ្មោះ ខិន, ហេង, អៀង បានរាយការណ៍ទៅ **អាន** ថា ប្រធានភូមិមិនបាន ឱ្យពួកគាត់ជីកដំឡូងនោះទេ ។ បន្ទាប់ពីបានរាយការណ៍ប្រាប់ **អាន** រួចមក ខិន, ហេង និង អៀង ត្រូវបានចាប់ខ្លួន និង ដឹកតាមរទេះសេះ មកសម្លាប់ក្នុងវត្ត (អូរត្រកួន)"* ។[949]

៣១០ នៅឆ្នាំ១៩៧៧ ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខវត្តអូរត្រកួន មានការកើនឡើង ក្នុងនោះក៏មានជនជាតិចាមដែរ ។[950] សាក្សីមួយរូបបានលើកឡើងថា *"អ្នកដែលទទួលខុសត្រូវពីថ្នាក់លើ ក្នុងការបញ្ជាឱ្យសម្លាប់មនុស្សគឺជា ប្រធានមន្ទីរសន្តិសុខនេះឯង"* ។[951] សាក្សីម្នាក់ទៀតបាននិយាយថា *"ខ្ញុំដឹងថាមានប្រជាជនប្រហែល ១០.០០០ (មួយម៉ឺន) នាក់ ត្រូវបានគេសម្លាប់ ដោយក្រោយពីបែកសម័យខ្មែរក្រហមនៅឆ្នាំ១៩៧៩ ខ្ញុំទៅទីនោះហើយខ្ញុំឃើញមានរណ្តៅជាច្រើន"* ។[952]

៣១១ ក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ គេឃើញមានលលាដ៏ក្បាលជាច្រើនពាន់នៅមន្ទីរសន្តិសុខវត្តអូរត្រកួន ដែលប្រហែលស្មើនឹងនៅមន្ទីរសន្តិសុខ ស-២១ ដែរ ។[953]ម្យ៉ាងវិញទៀត បន្ទាប់រំដោះ បើតាមអ្នករដ្ឋការសម័យរដ្ឋកម្ពុជា ចំនួនជនរងគ្រោះដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តអូរត្រកួនមានប្រហែលជា ៣០.០០០ (បីម៉ឺន) នាក់ ។ បើទោះបីជាមាន ការបញ្ជាក់នូវអត្រាពាក់ព័ន្ធចំនួនអ្នកស្លាប់នេះក៏ពិតមែន ប៉ុន្តែ វាគ្រាន់តែជាការប៉ាន់ស្មានរបស់មន្ត្រីខ្លះប៉ុណ្ណោះ ។ មិនមានតួលេខណាមួយឱ្យបានច្បាស់លាស់ ឬការស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដែលត្រូវបានទទួលស្គាល់ជាផ្លូវការនោះឡើយ ។[954]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

## ១.៣. មន្ទីរសន្តិសុខវត្តបាធាយ

៣១២ មន្ទីរសន្តិសុខវត្តបាធាយ មានទីតាំងស្ថិតនៅភូមិបាធាយ ឃុំបាធាយ ស្រុកបាធាយ ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[955] មន្ទីរសន្តិសុខវត្តបាធាយ ជាមន្ទីរសន្តិសុខថ្នាក់ស្រុក[956] ត្រូវបានបង្កើតឡើង នៅប្រហែលជាចុងឆ្នាំ១៩៧៦ និង ដើមឆ្នាំ១៩៧៧ ហើយដំណើរការរហូតដល់ការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។[957]

៣១៣ មន្ទីរសន្តិសុខនេះ មានបរិវេណនៅលើទំហំផ្ទៃដីប្រមាណជា ២ (ពីរ) ហិចតា។[958] បរិវេណប៉ែកខាងកើតវត្ត ស្ទើរតែទាំងមូលត្រូវបានប្រើសម្រាប់កប់សាកសព ។[959] មន្ទីរឃុំឃាំងមិនមានរបងមាំទាំទេតែមានអ្នកយាម ដើម្បីធានានូវសន្តិសុខដល់មន្ទីរសន្តិសុខ ។[960] មន្ទីរសន្តិ-សុខមានរោង ៤ (បួន) សម្រាប់ដាក់អ្នកទោសដោយរោងចំនួន ២ (ពីរ) ស្ថិតនៅខាងឆ្វេងដៃសម្រាប់ដាក់អ្នកទោសស្រី និង នៅខាងស្តាំដាក់អ្នកទោសប្រុស ។[961] សាក្សីម្នាក់រូបបានលើកឡើងថា *"តាមពិតវត្តបាធាយមិនត្រូវបានប្រើជាមន្ទីរសន្តិសុខទេ ប៉ុន្តែ មន្ទីរសន្តិសុខមានទីតាំងនៅជាប់នឹងវត្តបាធាយ"* ។[962]

៣១៤ ប្រធានមន្ទីរសន្តិសុខដំបូងឈ្មោះ ហាស់ ។[963] ក្រោយមកឈ្មោះ ស៊ីន បានឡើងជំនួសនិងបានបំពេញតួនាទីនេះបានប្រមាណ ៣ (បី) ខែក៏ត្រូវថ្នាក់លើចាប់ខ្លួនយកទៅសម្លាប់។[964] បន្ទាប់មកឈ្មោះ ពៅ បានឡើងជាប្រធានជំនួសទៀត ។[965] ចុងក្រោយឈ្មោះ ឃុន ឃឹម ហៅ ឃឹម បានឡើងជាប្រធានរហូតដល់របបដួលរលំ ។[966]

៣១៥ ប្រធានក្រុមអ្នកយកមនុស្សទៅសម្លាប់មានឈ្មោះ រិន រីឯឈ្មោះ លឹម, ទី និង រឿនជាសមាជិក ។[967] ទីកន្លែងសម្លាប់មនុស្សរបស់មន្ទីរសន្តិសុខ ស្ថិតនៅខាងកើតក្លោងទ្វារវត្តចម្ងាយប្រហែល ៣០ (សាមសិប) ម៉ែត្រ ។[968] ការសម្លាប់មនុស្សភាគច្រើន ធ្វើឡើងនាពេលថ្ងៃតែម្តង ។[969] ចំពោះប្រជាជនដែលបញ្ជូនមកពីភូមិភាគបូព៌ា ភាគច្រើនត្រូវបានគេឃុំឃាំងទុកមួយយប់សិន ហើយក្រោយពីការកត់ត្រាស្ថិតិរួចរាល់ គេយកចេញទៅសម្លាប់ចោលតែម្តង ពីព្រោះ បើឃុំទុកយូរនឹងចាល់មនុស្សក្នុងឃុំ ។[970]



C.E.T.C. CO-JUGES D'INSTRUCTION

៣១៦ អ្នកទោសនៅមន្ទីរសន្តិសុខនេះមាន មនុស្សពេញវ័យ មនុស្សចាស់ និង កុមារ ។[971] រីឯកម្មាភិបាលតាមមូលដ្ឋានខ្លះ ក៏ត្រូវបានចាប់ខ្លួននិងយកមកសម្លាប់ នៅមន្ទីរសន្តិសុខវត្តបាធាយដែរដូចជាមេឃុំ មេភូមិ និង មេកង ជាអាទិ៍ ។[972] លើសពីនេះ មន្ទីរសន្តិសុខនេះក៏មានអ្នកទោសជាជនជាតិចាមដែរ ។[973] អ្នកទោសត្រូវបានគេបញ្ជូនមកពីតំបន់ផ្សេងៗក្នុងស្រុកបាធាយទាំងមូល ។[974] អ្នកទោសជាប្រជាជនថ្មី ពេលជាប់ឃុំត្រូវបានគេធ្វើទារុណកម្មយ៉ាងទារុណ ដោយត្រូវចងដៃភ្ជួរឡើងលើ ។ ពេលដេកយប់គេដាក់ខ្នោះជើងថែមទៀត ។[975]

៣១៧ នៅឆ្នាំ១៩៧៦ ចំនួនការសម្លាប់មានការកើនឡើង នៅមន្ទីរសន្តិសុខវត្តបាធាយ ផ្តោតលើប្រជាជនដែលត្រូវចាប់បានមកពី ព្រៃកអញ្ចាញ វិហារសួគ៌ វការកោង ព្រៃកពោធិ៍ ស្វាយរំពារ អន្លង់ឡែង ព្រៃកកុយ ជាអាទិ៍ ។[976] នាពីរឆ្នាំក្រោយមក នៅឆ្នាំ១៩៧៨ ខណៈដែល ឃឹម ជាប្រធានមន្ទីរសន្តិសុខ មានការដឹកជនជាតិចាម មានទាំងក្មេងនិងចាស់លាយជាមួយប្រជាជនមកពីភូមិភាគបូព៌ា យកមកសម្លាប់ចោលនៅមន្ទីរសន្តិសុខវត្តបាធាយនេះដែរ ។[977] សាក្សីឈ្មោះ ធូ លាង បានអះអាងថា "*ចាំបានខាងបូព៌ាដែលគេយកទៅសម្លាប់មួយល្ងាច ឡានអាកាត់ៗអាមេរិកកាំង ឡានមួយមានសណ្តោង និងមួយទៀតអត់សណ្តោងគឺ ដឹកទៅពេលល្ងាច ។ ឡានមួយបើកដោយឈ្មោះ ហាត់ និងមួយទៀតឈ្មោះ ម៉ម ការដឹកនេះប្រហែលមួយខែជាងដែលដឹកយកមកសម្លាប់នៅបាធាយ*" ។[978]

៣១៨ អ្នកទោស ត្រូវបានគេធ្វើទារុណកម្មនាពេលគេសួរចម្លើយ ហើយពេលខ្លះបន្ទាប់ពីសួរចប់គេយកអ្នកទោសនោះទៅសម្លាប់ភ្លាមៗក៏មាន ។[979] អ្នកទោសខ្លះត្រូវបានគេទុកមួយរយៈមុនពេលសម្លាប់ ។[980] អ្នកទោសដែលចាប់បញ្ជូនមកមន្ទីរសន្តិសុខវត្តបាធាយ ភាគច្រើនត្រូវបានគេសម្លាប់ចោល ហើយកម្រណាស់អ្នកដែលអាចនៅរស់រានមានជីវិត ។[981] អ្នកទោសត្រូវបានគេវាយធ្វើបាបដោយចងស្លាបសេក មុននឹងបណ្តើរយកទៅសម្លាប់នៅរណ្តៅ ។ សាក្សីមួយចំនួនសង្កេតឃើញថា មានសាកសពខ្លះត្រូវបានគេវាយចំក្បាល និងខ្លះទៀតត្រូវបានគេអារក ។[982]

៣១៩ សាក្សីមួយរូបបាននិយាយថា "*ខ្ញុំឃើញប្រជាជនថ្មី គេឲ្យពាក់ច្រវាក់ជើងលូនពួន[illegible] ពាក់ច្រវាក់ជើងទៅកាប់ព្រៃអត់ឲ្យបាយហូបឲ្យតែទឹក ។ ក្នុងប្រជាជនដែលដាក់មួយច្រវាក់[illegible]*



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581408



*មានបួននាក់ អ្នកដែលចាស់អស់ដៃអស់ជើងថាអស់ហើយ ខ្មែរក្រហមបានឲ្យបីនាក់ជីករណ្ដៅរួច គេឲ្យម្នាក់នោះអង្គុយនៅមាត់រណ្ដៅ ហើយវាវ៉ៃនឹងត្បូងចបចូលក្នុងរណ្ដៅ ហើយកប់នៅកន្លែងនោះតែម្ដង ហើយគេយកអ្នកថ្មីមកដាក់ម្នាក់ទៀត ។ មួយចង្កាក់អីចឹងអស់ម្នាក់ គេយកម្នាក់ទៀតមកបញ្ចូល គេធ្វើរបៀបនេះរហូត*" ។[983]

៣២០ លើសពីនេះ សាក្សីរូបនេះបានបន្ថែមថា "*មនុស្សស្រីត្រូវគេរះយកប្រមាត់ ។ មនុស្សស្រីស្អាតៗភាគច្រើនត្រូវគេធ្វើបាប និង វះយកប្រមាត់យកមកចងភ្ជួរ តែមិនដឹងគេយកទៅណាទេ តែចំពោះមនុស្សប្រុស វាមិនសូវធ្វើបាបទេ គឺយកទៅសម្លាប់របៀបផ្សេងៗ ។ ការសម្លាប់មានច្រើនបែបយ៉ាងណាស់ ដោយវ៉ៃនឹងញ្ញៅរទេះ គល់ឬស្សី ត្បូងចប មានគ្រប់បែបយ៉ាង ដោយអត់បាយ និងទារុណកម្ម ។ នៅកន្លែងហ្នឹងយកមនុស្សទៅប្រើគឺ មិនដែលបានឲ្យបាយហូបទេ ហើយបើអស់ដៃជើងធ្វើការលែងកើតគេឲ្យជីករណ្ដៅ*" ។[984]

៣២១ នៅមន្ទីរសន្តិសុខវត្តបាធាយ ពុំឃើញមានថ្នាក់លើចុះមកទេ មានត្រឹមតែលេខាស្រុកដែលតែងតែចេញចូលមន្ទីរសន្តិសុខនេះ ។[985] នេះបើតាមសាក្សីឈ្មោះ ធូ លាង ដែលបានលើកឡើងថា "*អត់មានឃើញអ្នកណា អត់មានអ្នកណាចេញចូលមានតែចៅហ្វាយស្រុក ភឹមអីឃើញ ។ ទាហានខ្មែរក្រហមប្រាំ ប្រាំមួយនាក់ មកពីខេត្តកំពង់ចាមនៅពេលដាច់ឆ្នាំចូលខែមួយអីចឹង វាជិះម៉ូតូហុងដាមកដើម្បីបោសសម្អាតអ្នកទោសនៅគុកបាធាយមួយសា*" ។[986] ក្នុងមន្ទីរសន្តិសុខវត្តបាធាយក៏មានការសម្លាប់ជនជាតិចាមដែរ ។ សាក្សីរៀបរាប់ថា "*ក្នុងចំណោម ១00 (មួយរយ) ជនជាតិចាម ១0 (ដប់) នាក់*" ។[987] តាមការកត់សម្គាល់របស់សាក្សីគេអាចកំណត់អត្តសញ្ញាណបានថា ជាជនជាតិចាម ដោយហេតុថា ពេលគេបណ្ដើរចុះពីលើឡានឮគេនិយាយភាសាចាម ។[988]

៣២២ សក្ខីកម្មសាក្សីម្នាក់ទៀតថា "*ខ្ញុំពិបាកនិយាយថា មានអ្នកទោសប៉ុន្មាននាក់ នៅមន្ទីរសន្តិសុខ(វត្តបាធាយ)នោះណាស់ ពីព្រោះអ្នកដែលត្រូវគេយកមកដល់ត្រូវបានសម្លាប់ភ្លាមៗ ឬនៅថ្ងៃបន្ទាប់*" ។[989] បើគេមិនយកអ្នកទោសទៅសម្លាប់ភ្លាម គេយកអ្នកទោសដាក់ក្នុងរោងពីព្រោះពេលខ្លះអ្នកនាំទៅសម្លាប់មិនមានពេលគ្រប់គ្រាន់ ដើម្បីសម្លាប់ភ្លាមៗទេ ។[990] តាមការប៉ាន់ស្មានមានជនរងគ្រោះរាប់ពាន់នាក់ ឬ ប្រហែល ១0.000 (ម៉ឺន) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តបាធាយ ។[991]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C. * C.E.T.C.

## ១.៤. មន្ទីរសន្តិសុខមិត្តសុប (គរ)

៣២៣ មន្ទីរសន្តិសុខមិត្តសុប[992] ឬ មន្ទីរសន្តិសុខគរ[993] មានទីតាំងស្ថិតនៅក្នុងភូមិតាកែវ ឃុំគរ ស្រុកព្រៃឈរ ខេត្តកំពង់ចាម ។[994] មន្ទីរសន្តិសុខមិត្តសុប ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៧៥ ។[995] មន្ទីរសន្តិសុខនេះជាមន្ទីរសន្តិសុខថ្នាក់តំបន់ ។[996]

៣២៤ បរិវេណនៃមន្ទីរសន្តិសុខនេះ ត្រូវបានហ៊ុំព័ទ្ធដោយរបងធ្វើពីឈើ និង មានបន្លាលួស ។[997] នៅជុំវិញមន្ទីរសន្តិសុខមានរណ្ដៅកប់សាកសពជាច្រើន ប៉ុន្តែ បច្ចុប្បន្នទីតាំងទាំងនោះត្រូវបានប្រែក្លាយទៅជាវាលស្រែល្វឹងល្វើយ និង រុំព័ទ្ធដោយដើមត្នោតដុះជាច្រើនដើម ហើយនៅមានសល់ស្រះទឹកយ៉ាងហោចចំនួន ៣ (បី) ដែលត្រូវបានជីកក្នុងរបបនោះ ។[998]

៣២៥ មន្ទីរសន្តិសុខមិត្តសុប ដំបូងមានប្រធានឈ្មោះ សុប[999] ដែលជាអតីតគ្រូបង្រៀននៅសាលាត្រពាំងអំពិល[1000] និងជាអ្នកមានស្រុកកំណើតនៅក្នុងឃុំសំរោង ស្រុកព្រៃឈរ ខេត្តកំពង់ចាម[1001] និងឈ្មោះ ហេង[1002] ជាអនុប្រធានមន្ទីរសន្តិសុខ ។[1003] នៅឆ្នាំ១៩៧៧ ប្រធានមន្ទីរសន្តិសុខឈ្មោះ សុប ត្រូវបានគេបោសសម្អាត ហើយឈ្មោះ ង៉ូវ បានឡើងជំនួស ។[1004] សាក្សីឈ្មោះ សាត ភាព បានលើកឡើងថា *"គាត់ (មិត្ត សុប) ត្រូវបានគេចាប់ខ្លួនដោយពួកតំបន់"* ។[1005] មន្ទីរសន្តិសុខមានអ្នកយាមប្រហែលជា ១០ (ដប់) ទៅ ២០ (ម្ភៃ) នាក់ ដែលប្រដាប់ដោយអាវុធ ហើយមានអ្នកសួរចម្លើយប្រហែលជា ២ (ពីរ) នាក់ ។[1006]

៣២៦ មន្ទីរសន្តិសុខមិត្តសុប មានស្ថានភាពជារោងដាក់អ្នកទោសចំនួន ៣ (បី) រោងអ្នកធ្វើការ ២ (ពីរ) រោងបាយ ១ (មួយ) រោងគោ ១ (មួយ) និង ជង្រុកស្រូវ ១ (មួយ) ។[1007] អ្នកទោសប្រុស និងអ្នកទោសស្រី ត្រូវបានគេឃុំឃាំងឲ្យនៅដាច់ពីគ្នា ហើយអ្នកទោសភាគច្រើនមានសមាសភាពជាគណៈឃុំ គណៈស្រុក កងទ័ព និង ជាពិសេសអ្នកជាប់និន្នាការ ពាក់ព័ន្ធនឹងរបប លន់ នល់ ។[1008]

៣២៧ អ្នកទោសក្នុងមន្ទីរសន្តិសុខមិត្តសុប តែងទទួលរងនូវការធ្វើទារុណកម្ម[1009] នៅពេលសួរចម្លើយម្ដងៗ ។[1010] អ្នកទោសខ្លះ ក្រោយពីបានសួរយកចម្លើយរួចរាល់ហើយ ត្រូវបានគេដោះលែងឲ្យធ្វើការខាងក្រៅដូចជា ដាំបន្លែបង្ការ ចិញ្ចឹមជ្រូក ធ្វើស្រែ ជាអាទិ៍ ។[1011] ឈ្មោះ

ផែង ជាអ្នកទទួលខុសត្រូវនៅការដ្ឋានធ្វើស្រែ ។[1012] អ្នកទោសត្រូវបានគេឱ្យដេកនៅលើរនៀបបន្ទះក្តារដែលខ្ពស់ពីដី តែត្រូវគេដាក់ខ្នោះ ជាក្រុមៗរួមទាំងខ្នោះជើងផង ។[1013] អ្នកទោសភាគច្រើន គេឱ្យហូបបបរជាប្រចាំទាំងព្រឹក និងល្ងាច ប៉ុន្តែ ពេលខ្លះគេឱ្យហូបបាយម្តងម្កាលដែរ ។[1014]

៣២៨ ក្នុងអំឡុងឆ្នាំ១៩៧៧ **អោ អាន** បានទៅមន្ទីរសន្តិសុខមិត្តសុបជាច្រើនលើក ។ នេះបើតាមសាក្សី ញ៉ែម ចេន អតីតអ្នកការពារ **អោ អាន** បាននិយាយថា “*មួយខែអីទៅម្តង ឬពីរខែម្តង គាត់ (**អោ អាន**) ទៅទីនោះ ពេលមានបញ្ហាពីលើគាត់ (**អោ អាន**) ទៅ*” ។[1015] ប៉ុន្តែ **អោ អាន** ក៏ធ្លាប់បានប្រាប់ការពិតទៅកងការពារផ្ទាល់ថា **អ្វីៗដែលគាត់បានធ្វើជាបញ្ជាពីថ្នាក់លើ ដែលតម្រូវដាច់ខាតឱ្យគាត់ត្រូវតែធ្វើតាម បើមិនធ្វើតាមទេគាត់ក៏ត្រូវស្លាប់ដែរ** ។ សាក្សីដដែលបាននិយាយយ៉ាងច្បាស់ថា “*បាទដោយសារខ្ញុំនៅជិតស្និទ្ធជាមួយ **តា អាន** ខ្ញុំសួរគាត់ថា អ៊ំឯងមិនចេះអាណិតគាត់ទេ ? គាត់ថា* **បើអញមិនធ្វើតាមបញ្ជាគេទេគេសម្លាប់អញដែរ**” ។[1016]

៣២៩ សាក្សីឈ្មោះ សាត ភាព បានលើកឡើងថា “*តា ង៉ូវ រាយការណ៍ទៅ **តា អាន** ខ្ញុំដឹងរឿងនេះដោយសារតែ **តា អាន** គឺជាលេខាតំបន់។ ខ្ញុំធ្លាប់ឃើញ តា ង៉ូវ បើកឡានរបស់គាត់ទៅមន្ទីររបស់ **តា អាន** រៀងរាល់ប្រាំថ្ងៃ ឬមួយអាទិត្យម្តង*” ។[1017] រីឯសាក្សីម្នាក់ទៀតបានបង្ហាញអំពីទំនាក់ទំនងរវាងថ្នាក់លើ និងថ្នាក់ក្រោមដែលត្រូវធ្វើតាមបញ្ជា ។[1018]

៣៣០ អ្នកទោសភាគច្រើននៅមន្ទីរសន្តិសុខមិត្តសុបត្រូវបានសម្លាប់ ដោយការវាយនឹងដំបងឈើ ឬ ដំបងដែកក៏មាន ។[1019] សាក្សីជាអតីតកងការពារឱ្យ **អោ អាន** ធ្លាប់បាននិយាយថា “*គាត់ (**អោ អាន**)បញ្ជាថា ធ្វើម៉េចឱ្យផែនការគេត្រឹមឆ្នាំ៧៧ ត្រូវធ្វើតាមផែនការគេសម្លាប់ឱ្យអស់ព្រោះ ៧៨ លែងមានសម្លាប់ហើយ ។ ដល់ចូល ៧៨ ដូចរាងស្បើយ ហើយលែងមានសម្លាប់ហើយមានបបររាងខាប់ហូប*” ។[1020] ជាក់ស្តែង នៅឆ្នាំ១៩៧៨ គណៈកម្មាធិការមជ្ឈិមបក្ស បានចេញសារាចរដែលមានខ្លឹមសារថា មនុស្សទាំងអស់ដែលបានចូលរួមក្នុងសកម្មភាព សេអ៊ីអា ការហៀរបេ ឬ ភ្នាក់ងារវៀតណាម មុនខែកក្កដា ឆ្នាំ១៩៧៨ ត្រូវបានលើកលែងទោស ។[1021]

01581411



៣៣១ សាកសពជនរងគ្រោះត្រូវបានកប់នៅទីតាំងផ្សេងៗគ្នា នៅជិតមន្ទីរសន្តិសុខដូចជា អូរតាគង់ ទួលក្រសាំង ត្នោតជួរ និង ទួលអំពិល ។[1022] តាមការប៉ាន់ប្រមាណ មន្ទីរសន្តិសុខមិត្តសុប មានមនុស្សប្រហែល ២.០០០ (ពីរពាន់) នាក់ ត្រូវបានសម្លាប់ ឬស្លាប់ដោយសារជំងឺ ។[1023] ក្រោយការដួលរលំកម្ពុជាប្រជាធិបតេយ្យ អដ្ឋិធាតុរបស់ជនរងគ្រោះនៅមន្ទីរសន្តិសុខមិត្តសុប ត្រូវបានគេប្រមូលយកទៅបូជានៅទួលក្រសាំង ។[1024]

## ១.៥. ទីកន្លែងសម្លាប់មនុស្សគោកព្រីង

៣៣២ កន្លែងសម្លាប់មនុស្សគោកព្រីង មានទីតាំងស្ថិតនៅជិតបឹងធំមួយក្បែរភូមិក្តីបឹង ឃុំវិហារធំ ស្រុកកំពង់សៀម ខេត្តកំពង់ចាម ។[1025] គោកព្រីងនេះ ត្រូវបានគេចាប់ផ្តើមសម្លាប់មនុស្ស តាំងពីឆ្នាំ១៩៧០ ។[1026] នៅឆ្នាំ១៩៧៧ ក្រោយពីក្រុមនិរតីបានចូលមកដល់ការអនុវត្តន៍គោលនយោបាយនៃការបោសសម្អាត នៅតែបន្តកើតមានលើប្រជាជន ។[1027] រីឯ ស្ថានភាពធ្វើការរបស់ប្រជាជនកាន់តែមានសភាពធ្ងន់ធ្ងរឡើងៗ បើធៀបមុននឹងក្រុមនិរតីផ្ទេរមកកាន់ភូមិភាគកណ្តាល ។[1028]

៣៣៣ សាក្សីម្នាក់បានលើកឡើងថា *"ខ្ញុំបានឃើញគេបណ្តើរមនុស្សទៅកាន់បឹងនោះនៅឆ្នាំ១៩៧៧ ពួកគេតែបណ្តើរមនុស្សចេញទៅនៅពេលយប់ ... ហើយមនុស្សដែលគេបណ្តើរទៅកាន់បឹងនោះ មិនដែលឃើញត្រលប់មកវិញទេ ... ហើយការបាត់ខ្លួនចាប់ផ្តើមពេញទំហឹងនៅចុងឆ្នាំ១៩៧៦ និងនៅដើមឆ្នាំ១៩៧៧"* ។[1029] ជារៀងរាល់យប់មានមនុស្សចាប់ពី ២០ (ម្ភៃ) ទៅ ៥០ (ហាសិប) នាក់ត្រូវនាំទៅសម្លាប់នៅបឹងធំ ដែលភាគច្រើនជាប្រជាជន១៧មេសា។[1030] អ្នកសម្លាប់មនុស្សនៅមន្ទីរសន្តិសុខគោកព្រីងរួមមានឈ្មោះ កាន, កេន, និង មាស ។[1031]

៣៣៤ នៅមន្ទីរសន្តិសុខគោកព្រីង ប្រជាជនមុននឹងសម្លាប់ ត្រូវបានគេធ្វើទារុណកម្មដោយគេវាយនឹងដំបង រីឯជនរងគ្រោះជានារី ពេលខ្លះមានការរំលោភជាមុនសិន រួចទើបគេអារកសម្លាប់ ។[1032] ជាធម្មតា គេយកមនុស្សទៅសម្លាប់វិលវងមួយយប់ម្តង ហើយពេលខ្លះគេយកមនុស្សចេញទៅសម្លាប់រៀងរាល់យប់ជាប់ៗគ្នា ។[1033] ចំនួនមនុស្សដែលត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខបានកើនឡើងខ្លាំងបំផុតនៅដើមឆ្នាំ១៩៧៧ ។[1034] សាក្សីឈ្មោះ កាក់ ស្រឿន បាន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

លើកឡើងថា "*ចាប់ផ្ដើមសម្លាប់នៅឆ្នាំ១៩៧០ នៅពេលដែលមានរដ្ឋប្រហារ ... ការសម្លាប់ធំមែនទែនគឺនៅដើមឆ្នាំ១៩៧៧*" ។[1035]

៣៣៥ នៅមន្ទីរសន្តិសុខគោកព្រីង មានរណ្ដៅសពយ៉ាងតិច ២០ (ម្ភៃ) កន្លែងនៅតាមមាត់បឹងធំ និង រណ្ដៅជាច្រើនទៀត នៅបរិវេណមន្ទីរសន្តិសុខគោកព្រីងតែម្ដង ។[1036] នៅក្រោយឆ្នាំ ១៩៧៩ រណ្ដៅជាង ៧០ (ចិតសិប)កន្លែងត្រូវបានរកឃើញ។[1037]សាក្សីឈ្មោះ កាក់ ស្រឿន អះអាងថា "*ខ្ញុំចាំ ៥០ រណ្ដៅនៅឯគោកព្រីង និង ២០ រណ្ដៅទៀតនៅតាមជួរមាត់បឹងធំ ។ សរុបទាំងអស់ប្រហែល ៧០ រណ្ដៅ*"។[1038] រណ្ដៅនីមួយៗមានទំហំទទឹងមួយម៉ែត្រកន្លះ បណ្ដោយបីម៉ែត្រ និងមានជម្រៅមួយម៉ែត្រ ។[1039]

៣៣៦ តាមចម្លើយសាក្សីមួយចំនួនថា ចំនួនជនរងគ្រោះមានប្រហែលជាង ១.០០០ (មួយពាន់) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខគោកព្រីង ។[1040] ខណៈដែលរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបង្ហាញថា ប្រជាជនពី ៥.០០០ (ប្រាំពាន់) ទៅ ៧.០០០ (ប្រាំពីរពាន់) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខគោកព្រីង ។[1041] មានតែសាក្សីខ្លះបានធ្វើប៉ាន់ប្រមាណលើសគេថា មានអ្នកស្លាប់ប្រហែលរហូតដល់ ២៥.០០០ (ពីរម៉ឺនប្រាំពាន់) នាក់ ។[1042]

## ១.៦. ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ

៣៣៧ ការដ្ឋានធ្វើពលកម្មទំនប់អន្លង់ជ្រៃមានទីតាំងស្ថិតនៅក្នុងស្រុកព្រៃឈរ ខេត្តកំពង់ចាម ។[1043] អន្លង់ជ្រៃជាឈ្មោះស្ពានដែលស្ថិតនៅជិតទំនប់ ។ ការដ្ឋានទំនប់អន្លង់ជ្រៃបានចាប់ផ្ដើមសាងសង់នៅចុងឆ្នាំ១៩៧៧ ហើយ បានសង់រួចនៅខែឧសភា ឆ្នាំ១៩៧៨ ។[1044] ការដ្ឋានធ្វើពលកម្មទំនប់អន្លង់ជ្រៃជាទំនប់ថ្នាក់តំបន់ ។[1045]

៣៣៨ កន្លងមកមានសាក្សីអះអាងថា ធ្លាប់បានឃើញ **អោ អាន** ចុះមកពិនិត្យមើលការដ្ឋានទំនប់អន្លង់ជ្រៃ ។[1046] សាក្សី ផន សុផល ជាអតីតអ្នកធ្វើការនៅការដ្ឋានទំនប់នេះ បានលើកឡើងស្រដៀងគ្នាដែរថា "*ខ្ញុំឃើញ តា **អាន** ប្រហែលជានៅក្នុងឆ្នាំ១៩៧៩ នៅពេលដែលគាត់មកពិនិត្យការដ្ឋាន ហើយ តា **អាន** បានចោទពួកយើងថាជាភ្នាក់ងារ សេ.អ៊ី.អា និង ភ្នាក់ងារ*

*ឃួទ*" ។[1047] ការចុះមកមើលការដ្ឋានរបស់ **សោ អាន** ប្រហែលនាអំឡុងពេលជិតរដ្ឋលរលំរបបកម្ពុជាប្រជាធិបតេយ្យ ។[1048] ការដ្ឋានទំនប់អន្លង់ជ្រៃត្រូវបាន កែ ពក ជាលេខាភូមិភាគកណ្ដាល បានចុះពិនិត្យការដ្ឋានជាញឹកញាប់ផងដែរ ។ នេះបើតាមសាក្សីឈ្មោះ ជិន ស៊ីណាល់ ដែលបានអះអាងថា "*កែ ពក ដោយគាត់ធ្លាប់បានមកត្រួតពិនិត្យការសាងសង់ទំនប់ (ទំនប់អន្លង់ជ្រៃ) ជាច្រើនដង*" ។[1049]

៣៣៩ តា ឈិន ជាអ្នកមើលការខុសត្រូវនៅការដ្ឋានទំនប់អន្លង់ជ្រៃ ។[1050] ប្រជាជនដែលត្រូវបានគេកែនមកលើកទំនប់មកពី ៥ (ប្រាំ) ស្រុករួមមាន៖ ស្រុកព្រៃឈរ ស្រុកជើងព្រៃ ស្រុកកងមាស ស្រុកចំការលើ និង ស្រុកកំពង់សៀម ។[1051] តាមការប៉ាន់ស្មានមានប្រជាជនប្រហែលជា ១.០០០[1052] (មួយពាន់) ឬ ១.៥០០[1053] (មួយពាន់ប្រាំរយ) នាក់ ដែលត្រូវបានអង្គការកែនឱ្យធ្វើការនៅការដ្ឋានទំនប់អន្លង់ជ្រៃ ។[1054]

## ១.៧. មន្ទីរសន្តិសុខវត្តតាមៈ

៣៤០ មន្ទីរសន្តិសុខវត្តតាមៈ មានទីតាំងស្ថិតនៅក្នុងភូមិព្រៃទទឹង ឃុំជ្រៃវៀន (អតីតឃុំខ្ពង់ពណ៌)[1055]ស្រុកព្រៃឈរ ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្ដាលដែលនៅក្បែរមន្ទីរតំបន់ ៤១ និងមន្ទីរផ្សេងៗទៀតចំណុះតំបន់ ៤១ ។ [1056] មន្ទីរសន្តិសុខវត្តតាមៈមានវិសាលភាពលើផ្ទៃដីប្រមាណបីហិចតា ។[1057] មន្ទីរសន្តិសុខវត្តតាមៈជាមន្ទីរសន្តិសុខតំបន់ ។[1058]

៣៤១ ដំបូងមន្ទីរសន្តិសុខនេះ គ្រាន់តែជាមន្ទីរសន្តិសុខបណ្ដោះអាសន្នតូចមួយ[1059] ដោយទទួលឃុំអ្នកទោសយ៉ាងយូរមួយសប្ដាហ៍[1060] មុនបញ្ជូនទៅសម្លាប់នៅកន្លែងផ្សេង ។[1061] វត្តតាមៈបានក្លាយទៅជាមន្ទីរសន្តិសុខផ្លូវការនៅចន្លោះចាប់ពីខែមេសា ឆ្នាំ១៩៧៨ រហូតដល់ការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។[1062] ព្រះវិហាររបស់វត្តតាមៈ ត្រូវគេយកធ្វើជារោងប្រជុំ ។[1063]

៣៤២ អ៊ួន ជាអនុលេខាតំបន់ ៤១[1064] និង ជាប្រធានយោធាតំបន់ ៤១[1065] មានអំណាចលើកងទ័ពឃាម[1066] និងចាត់ចែងការងារក្នុងមន្ទីរសន្តិសុខវត្តតាមៈ[1067]។ តាមសក្ខីកម្មដែលប្រមូលបាន អ៊ួន បានធ្វើឡើងជាប្រធានមន្ទីរតំបន់ជំនួស អាំ ។[1068] អ្នកដែលចុះទៅចាប់អ្នកទោស



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

មានឈ្មោះ អាំ ហើយ អួន ជាអ្នកអនុវត្តបញ្ជាចាប់ខ្លួន ដើម្បីយកមកឃុំឃាំងនៅមន្ទីរសន្តិសុខ ។[1069] លើសពីនេះមានឈ្មោះ សុខ និងនិរសារបស់គាត់ក៏ជាអ្នកចាប់អ្នកទោសដោយផ្ទាល់ដែរ ។[1070] ក្រោយពីចាប់បាន អ្នកទោសត្រូវបានច្រកចូលបាវ និងដឹកតាមរទេះគោ ឬ ឡានមកកាន់មន្ទីរសន្តិសុខ ។[1071] មន្ទីរសន្តិសុខនេះមានឃោធាតំបន់ជាអ្នកយាមកាមយ៉ាងម៉ត់ចត់មានចំនួនប្រហែលពី ៥០ (ហាសិប) ទៅ ៦០ (ហុកសិប) នាក់ ។[1072]

៣៤៣ អ្នកទោសនៅមន្ទីរសន្តិសុខនេះ មានប្រជាជនថ្មី និងប្រជាជនចាស់ ទាំងប្រុស ស្រី និងកុមារ ដែលត្រូវបានចាប់ខ្លួនពីតាមបណ្តាសហករណ៍និងភូមិ ហើយភាគច្រើនជាប្រជាជនពីស្រុកព្រៃឈរ ស្រុកកងមាស និងស្រុកជើងព្រៃ ។[1073] ទន្ទឹមនឹងនោះមន្ទីរសន្តិសុខវត្តតាមះជាកន្លែងផ្ទុកអ្នកជម្លៀស និងអ្នកទោសដែលភាគច្រើន ជាប្រជាជនជម្លៀសពីភ្នំពេញនៅឆ្នាំ ១៩៧៥ ។[1074]

៣៤៤ អ្នកទោសទទួលបានបបររាវៗ ហើយហូបមិនឆ្អែតទេ បើទោះបីជាពួកគេអាចទទួលបានការហូបពីរដងក្នុងមួយថ្ងៃក៏ដោយ។[1075] ប៉ុន្តែ ពេលខ្លះអ្នកទោសក៏ត្រូវបានអនុញ្ញាតឱ្យដាំស្លហើយក៏អាចទទួលយករបស់របរប្រើប្រាស់បន្តិចបន្តួចពីសាច់ញាតិបាន ។[1076]

៣៤៥ អ្នកទោសវ័យចំណាស់ត្រូវគេដាក់ ច្រវ៉ាក់ ខ្នោះដៃ ខ្នោះជើង និងចងស្លាបសេកទៅក្រោយ ។[1077] នៅពេលសួរចម្លើយអ្នកទោសត្រូវគេធ្វើទារុណកម្មជាខ្លាំង ដោយវាយនឹងខ្សែតី ច្រវ៉ាក់ បន្ទះដែក ពេលខ្លះរហូតដល់សន្លប់ ពេលខ្លះក៏មិនបញ្ឈប់ការសួរសិនទេ ដោយគេជះទឹកឱ្យដឹងខ្លួនដើម្បីសួរទៀតក៏មាន ។[1078] រីឯ អ្នកទោសក្មេងៗ ត្រូវគេដាក់ខ្នោះដៃជើងរៀងរាល់ថ្ងៃ ហើយជារឿយៗត្រូវវាយនឹងខ្សែតី ។[1079]

៣៤៦ នៅមន្ទីរសន្តិសុខវត្តតាមះ អ្នកទោសមិនអនុញ្ញាតឱ្យដើរចេញទៅក្រៅមន្ទីរទេ លើសពីនេះទៀត សូម្បីតែការនិយាយគ្នាក៏ត្រូវហាមឃាត់ដែរ ។[1080] អ្នកទោសខ្លះត្រូវគេបង្ខំឱ្យកាប់ដី ឬកាប់ឆ្ការព្រៃនៅបរិវេណវត្តតាមះ នៅពេលព្រឹកហើយពេលថ្ងៃគេយកទៅឃុំខ្លួនវិញ។[1081] មន្ទីរសន្តិសុខវត្តតាមះ ជាកន្លែងដែលត្រូវយកមនុស្សមកសម្លាប់ ភាគច្រើនក្រោមលេសថាត្រូវបានអង្គការបញ្ជូនឱ្យមករៀនសូត្រ។[1082] ជាក់ស្តែងសាក្សីឈ្មោះ ញ៉ែម ចេន និយាយដែរថា *"គេគ្រាន់តែថាយកមកឱ្យរៀននៅវត្តតាមះ"* ។[1083] សាក្សីម្នាក់ទៀតលើកឡើងថា



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

*"តាមពិត ខ្ញុំឮចាស់ៗនិយាយ អ្នកទោសនៅនេះគេអត់មានឲ្យធ្វើការទេ គេយកមកស្តុកទុក រង់ចាំដល់ថ្ងៃគេយកទៅសម្លាប់តែម្តង"*។[1084]

៣៤៧ អ្នកទោសត្រូវបានគេបិទមុខ និងបញ្ជូនចេញពីមន្ទីរសន្តិសុខ នៅពេលចំនួនគ្រប់គ្រាន់ ។[1085] ចន្លោះម៉ោង ៥ (ប្រាំ) ទៅ ៦ (ប្រាំមួយ) ល្ងាច មានការដឹកអ្នកទោសចេញទៅសម្លាប់នៅមន្ទីរសន្តិសុខមិត្ត សុប[1086] មន្ទីរសន្តិសុខវត្តភ្នំប្រុស[1087] ឬ ទីកន្លែងផ្សេងទៀត[1088] ។ អ្នកទោសថ្មីត្រូវដឹកចូលនៅចន្លោះពីម៉ោង ៧ (ប្រាំពីរ) ទៅម៉ោង ៩ (ប្រាំបួន) យប់ដោយដឹកតាមឡានភូមិភាគ ឬ ឡានរបស់តំបន់ ។[1089]

៣៤៨ សាក្សីមួយរូបបាននិយាយថា **តា អាន** បានទៅប្រជុំនៅវត្តតាមះចំនួន ២ (ពីរ) ដងដោយហៅគណៈស្រុក គណៈឃុំមកធ្វើការប្រជុំ ។[1090] សាក្សីម្នាក់ផ្សេងទៀតថា **តា អាន** ក៏ធ្លាប់មកលេងវត្តតាមះដែរ តែមិនមានបញ្ជាក់កាលបរិច្ឆេទនិងសកម្មភាពផ្សេងៗរបស់ **តា អាន** នោះទេ ។[1091] រីឯ សាក្សីម្នាក់ផ្សេងទៀតថ្លែងថា **តា អាន** តែងតែទទួលព័ត៌មានអំពីមន្ទីរសន្តិសុខវត្តតាមះ ។[1092] សាក្សីតែម្នាក់គត់និយាយថា ការសម្លាប់ធ្វើឡើងតាមបញ្ជារបស់ **តា អាន** ។[1093] ផ្ទុយទៅវិញសាក្សីម្នាក់និយាយថា **តា អាន** មិនមានអំណាចសម្រេចធ្វើការចាប់ខ្លួនអ្នកណាម្នាក់ដោយឯកឯងបានទេ ។ គាត់ត្រូវរាយការណ៍ទៅថ្នាក់លើរបស់គាត់ជាមុនសិន ។[1094]

៣៤៩ នៅខែមេសា ឆ្នាំ១៩៧៨ ប៉ុល ពត បានដាក់ផែនការកម្ទេចយោធា និង ការបោសសម្អាតកម្មាភិបាលថ្នាក់ទាបដែលបានចាប់ខ្លួន និង សម្លាប់ប្រជាជនដោយខុសច្បាប់ ជាហេតុធ្វើឲ្យមានយោធា និងកម្មាភិបាលជាច្រើន ត្រូវបានចាប់មកឃុំខ្លួននៅវត្តតាមះ ។[1095] គ្មាននរណាដឹងច្បាស់ អំពីចំនួនអ្នកទោសនៅវត្តតាមះនោះទេ បើទោះបីជាអ្នកទោសត្រូវបានចាប់ និងដឹកចូលវត្តតាមះជារៀងរាល់ថ្ងៃក៏ដោយ ។[1096] សាក្សីឈ្មោះ សំរិទ្ធិ អន បាននិយាយថា *"ខ្ញុំមិនបានដឹងជាក់លាក់ទេ ។ ប៉ុន្តែ យើងយកតែលលាដ៏មកដាក់ក្នុងស្តូបច្រើន ប៉ុន្តែមិនមែនជាលក្ខណៈប្រាកដជាក់លាក់ទេ"* ។[1097] ពាក់ព័ន្ធជនជាតិចាម ឆ្លើយសំណួររបស់អ្នកស៊ើបអង្កេតអន្តរជាតិបានសួរសាក្សីឈ្មោះ ឈាន ប៊ាង ថា "តើមានគេចាប់ចាមមកឃុំនៅវត្តតាមះនេះទេ ? សាក្សីបានឆ្លើយថា*"ចាមដូចគ្មានទេជនជាតិចាម"*។[1098]



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

## ១.៨. មន្ទីរសន្តិសុខទួលតាផ្គុង

៣៥០ មន្ទីរសន្តិសុខទួលតាផ្គុង មានទីតាំងស្ថិតក្នុងបរិវេណនៃវិទ្យាល័យរស្មីសោភ័ណក្នុងភូមិត្រាច ឃុំកំពង់ចិនជើង ស្រុកស្ទោង ខេត្តកំពង់ធំ តំបន់ ៤៣ ភូមិភាគកណ្តាល ។[1099] មន្ទីរសន្តិសុខទួលតាផ្គុងជាមន្ទីរសន្តិសុខថ្នាក់ស្រុក ។[1100] ពីដំបូងឈ្មោះ វុន ជាប្រធានមន្ទីរសន្តិសុខ និង រ៉ែម ជាអនុប្រធាននិងជាអ្នកអនុវត្តការសម្លាប់ ។[1101] មន្ទីរសន្តិសុខនេះមានបុគ្គលិកប្រមាណពី ១០ (ដប់) ទៅ ២០ (ម្ភៃ) នាក់ និងមានអ្នកយាមប្រហែល ៥ (ប្រាំ) នាក់ ។[1102]

៣៥១ មន្ទីរសន្តិសុខទួលតាផ្គុង អតីតជាសាលារៀន តែក្រោយមកបានក្លាយជាគុកបែបនេះ តាំងពីឆ្នាំ១៩៧៥ ហើយបានដំណើការរហូតដល់ពេលដួលរលំនៃរបប ។[1103] ប៉ុន្តែ ក៏មានការលើកឡើងដែរថា មន្ទីរសន្តិសុខនេះមានតាំងពីមុនឆ្នាំ១៩៧៥ ។ នេះបើតាមសាក្សីមួយរូបឈ្មោះ លឹម យួយហ៊ួ ដែលបាននិយាយថា ទីកន្លែងសម្លាប់នេះត្រូវបានដំណើរការតាំងពីឆ្នាំ១៩៧០ រហូតដល់ឆ្នាំ១៩៧៩ ដោយដំបូងឡើយប្រើជាទីកន្លែងឃុំខ្លួនកងទ័ព របប លន់ នល់ ដែលចាប់បាន ។ [1104]

៣៥២ អ្នកទោសរាប់រយនាក់ត្រូវបានចាប់ឃុំខ្លួនដាក់តាមថ្នាក់រៀនក្នុងសាលានេះ ។[1105] ការឃុំខ្លួនអ្នកទោសត្រូវដាក់ជាជួរៗរហូតដល់ ៥ (ប្រាំ) ជួរដោយមួយជួរៗមានអ្នកទោសប្រមាណ ២៥ (ម្ភៃប្រាំ) នាក់ ។ អ្នកទោសត្រូវគេឱ្យដេកផ្ទាល់នៅលើដី និងត្រូវបានហាមមិនឱ្យជជែកគ្នាជាដាច់ខាត ។[1106] ការឃុំខ្លួនមានរយៈពេលពី ១ (មួយ) ទៅ ៣ (បី) ខែ ។[1107] នៅមន្ទីរសន្តិសុខទួលតាផ្គុងមានអ្នកទោសទាំងប្រុស ស្រី និង កុមារ ដោយភាគច្រើនជាប្រជាជនថ្មីដែលមកពីភ្នំពេញ សៀមរាប និង កន្លែងផ្សេងទៀត ។[1108] អ្នកទោសត្រូវគេបែងចែកជា ២ (ពីរ) ប្រភេទៈ អ្នកទោសស្រាល និង អ្នកទោសធ្ងន់ ហើយត្រូវដាក់ក្នុងបន្ទប់ឃុំដាច់ដោយឡែកពីគ្នា ។[1109]

៣៥៣ អ្នកទោសស្រាល គេឱ្យហូបតែបបរលាយជាមួយត្រកួន មួយកូនចានក្នុងមួយថ្ងៃ ។[1110] អ្នកទោសធ្ងន់គេមិនឱ្យអាហារ ឬទឹកហូបនោះទេ ដោយដាក់ខ្នោះ ២៤ (ម្ភៃបួន) ម៉ោងពេញ និងមិនអនុញ្ញាតឱ្យចេញទៅក្រៅបត់ជើងបត់ដៃទេ ។[1111] អ្នកទោសត្រូវគេឱ្យបត់ជើងធំ ឬ បន្ទោបង់នៅនឹងកន្លែងតែម្តង ។[1112]



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581417



៣៥៤ អ្នកទោសត្រូវបានគេសួរចម្លើយដោយការធ្វើទារុណកម្ម ។ ពេលខ្លះអ្នកទោសក៏ត្រូវគេវាយនឹងខ្សែតី ដើម្បីទទួលបានចម្លើយសារភាព ។[1113] អ្នកទោសស្រាលត្រូវគេបង្ខំឱ្យធ្វើការនៅក្នុងមន្ទីរសន្តិសុខដូចជា កប់សាកសព បោសសម្អាត ច្រូតកាត់ ធ្វើជីកំប៉ុស ជាអាទិ៍ ។[1114] សាក្សីឈ្មោះ គាំ ព្រឹក បានឆ្លើយថា "*ជួនកាលគេក៏បានប្រើខ្ញុំឱ្យទៅកប់សាកសពដែរ ខ្ញុំបានសង្កេតឃើញថា គេកប់សាកសពទាំងនោះបញ្ច្រាសជើងគ្នា ។ រីឯ កុមារៗត្រូវបានគេកប់ដោយដាក់នៅលើម្ដាយ*" ។ [1115]

៣៥៥ អ្នកទោសចន្លោះពី ៣០ (សាមសិប) ទៅ ៤០ (សែសិប) នាក់ ត្រូវបានគេយកទៅសម្លាប់ជារៀងរាល់យប់ ។[1116] ពេលខ្លះអ្នកទោសត្រូវគេវាយសម្លាប់ នៅមុខអាគារសាលារៀនតែម្ដង រួចដឹកតាមរទេះគោយកទៅកប់ ក្នុងតាមរណ្ដៅនៅពាសពេញភូមិតាផ្គុង ឬ ត្រូវយកទៅដុតនៅតាមមាត់បឹងក្បែរទួល ។[1117] អ្នកទោសមួយចំនួនត្រូវបញ្ជូនទៅសម្លាប់ នៅឯទុំពេជ្រនាមាត់ព្រៃអ្នកតាស្វាយ ដែលមានចម្ងាយ ៨ (ប្រាំបី) គីឡូម៉ែត្រ ពីវិទ្យាល័យរស្មីសោភ័ណ ។[1118] មុនពេលសម្លាប់ អ្នកទោសតែងស្រែកយំយ៉ាងកងរំពង និង សម្លេងថ្ងូរ ។[1119] សក្ខីកម្មបានបង្ហាញថា តា សំរេច ជាអ្នកបញ្ជាឱ្យសម្លាប់អ្នកទោស រីឯឈ្មោះ វ៉ែម ជាអ្នកអនុវត្តការសម្លាប់ ។ [1120]

៣៥៦ នៅមន្ទីរសន្តិសុខទួលតាផ្គុង មានរណ្ដៅសាកសពចន្លោះពី ២៥០ (ពីរយហាសិប) ទៅ ៥០០ (ប្រាំរយ) រណ្ដៅ ។[1121] អ្នកទោសមន្ទីរសន្តិសុខមានមួយចំនួនតូចតែប៉ុណ្ណោះ ដែលបានរួចជីវិត តែត្រូវគេបង្ខំអោយអ្នកទាំងនោះទទួលការអប់រំកសាងខ្លួនឡើងវិញ រួចទើបដោះលែងជាមួយល័ក្ខខ័ណ្ឌ មិនឱ្យនិយាយរឿងអ្វី ដែលពាក់ព័ន្ធនឹងមន្ទីរសន្តិសុខតាផ្គុងទេ ។[1122] ជាក់ស្ដែង មានអ្នកទោសប្រមាណជា ៣ (បី) នាក់ ដែលត្រូវបានរំដោះចេញពីមន្ទីរសន្តិសុខនាពេលដួលរលំរបប ។ [1123]

៣៥៧ អ្នកទោសខ្លះបានស្លាប់ទាំងដៃជាប់ខ្នោះ ប៉ុន្តែ មានអ្នកទោសខ្លះស្លាប់ដោយអត់អាហារ ឬ ជំងឺ ។[1124] ចំនួនការសម្លាប់នៅមន្ទីរសន្តិសុខទួលតាផ្គុង បានកើនឡើងខ្លាំងនៅរវាងឆ្នាំ ១៩៧៧-១៩៧៨ ជាពិសេស ការសម្លាប់ទៅលើអ្នកទោសដែលជាប្រជាជនថ្មី ។[1125] សាក្សី គាំ ព្រឹក បានលើកឡើងថា "មានជនរងគ្រោះរាប់ពាន់នាក់ត្រូវបានសម្លាប់នៅទីនេះ" ។[1126]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581418



## ១.៩. មន្ទីរសន្តិសុខវត្តកណ្តាល

៣៥៨ មន្ទីរសន្តិសុខវត្តកណ្តាលមានទីតាំងនៅស្ថិតនៅភូមិពោន ឃុំច្រនៀង ស្រុកបារាយណ៍ ខេត្តកំពង់ធំ តំបន់ ៤២ ភូមិភាគកណ្តាល ។[1127] ដំបូង អាត ជាប្រធានមន្ទីរសន្តិសុខវត្តកណ្តាល ក្រោយមកត្រូវបានចាប់ខ្លួន និងសម្លាប់នៅឆ្នាំ១៩៧៧ ។[1128] បន្ទាប់មក ផែន បានឡើងជាមន្ទីរសន្តិសុខវត្តកណ្តាលជំនួស អាត។[1129] នៅពេលក្រុមនិរតីចូលមកដល់ភូមិភាគកណ្តាល ការចាប់ខ្លួនប្រធានមិនមានទៀតទេ គឺមានតែចាប់ខ្លួន អាត មួយប៉ុណ្ណោះ ។

៣៥៩ មន្ទីរសន្តិសុខវត្តកណ្តាលមានអ្នកទោសជា ប្រជាជនមូលដ្ឋាន និង ប្រជាជនថ្មី ។[1130] អ្នកទោសត្រូវបានគេឃុំឃាំងក្នុងកុដិដោយដាក់ខ្នោះជើងជាប់ ។[1131] ប៉ុន្តែ ពេលគេបញ្ចេញអ្នកទោសឲ្យទៅធ្វើការខាងក្រៅ អ្នកទោសត្រូវគេដោះខ្នោះចេញ ។[1132] អ្នកទោសដែលគេចាត់ទុកថា ចេះកសាងខ្លួនបាន គេនឹងសម្រេចដោះលែងឲ្យត្រលប់ទៅកាន់មូលដ្ឋាន និងធ្វើការងារដូចធម្មតាវិញ ។[1133] រីឯ អ្នកទោសធ្ងន់ត្រូវបានបញ្ជូនបន្តទៅមន្ទីរសន្តិសុខថ្នាក់តំបន់នៅថ្នល់បែក ។[1134]

៣៦០ សក្ខីកម្មសាក្សីឈ្មោះ ប្រាក់ យុន បានបង្ហាញថា *"ប្រជាជនដែលគេនាំយកមកឃុំឃាំងនៅទីនេះ ត្រូវបានគេសម្លាប់នៅក្នុងបរិវេណវត្ត ព្រមទាំងនៅតាមវាលស្រែក្បែរវត្ត និងខ្លះត្រូវបានសម្លាប់ហើយបោះទម្លាក់ចូលអណ្តូង និងស្រះនៅតាមភូមិ"* ។[1135] រីឯ សាក្សីជាអតីតអ្នកយាមនៅមន្ទីរសន្តិសុខវត្តកណ្តាល ក៏បានលើកឡើងដែរថា *"ពេលពួកនិរតីចូលមកដល់មន្ទីរសន្តិសុខមានអ្នកទោសខ្លះៗ តែដល់ឆ្នាំ១៩៧៨ មិនមានអ្នកទោសទៀតទេ"* ។[1136] ផ្ទុយទៅវិញ សាក្សីតែមួយរូបដែលបានផ្តល់សក្ខីកម្មទាក់ទិនបញ្ហានេះថា *"ខ្ញុំបានឃើញមានអ្នកទោសនៅទីនោះ (មន្ទីរសន្តិសុខវត្តកណ្តាល) ប្រហែលជាសាមសិបនាក់"* ។[1137]

## ១.១០. មន្ទីរសន្តិសុខចំការស្វាយចន្ទី

៣៦១ មន្ទីរសន្តិសុខចំការស្វាយចន្ទីមានទីតាំងស្ថិតនៅភូមិវាលរីលិច ឃុំស្វាយទាប ស្រុកចំការលើ ខេត្តកំពង់ចាម តំបន់ ៤២ ភូមិភាគកណ្តាល ។[1138] មន្ទីរសន្តិសុខត្រូវបានដំណើរការតាំងពីឆ្នាំ១៩៧៥ រហូតដល់ជិតបែកឆ្នាំ១៩៧៩ មានទាំងការឃុំឃាំង និងការសម្លាប់ ។[1139]



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581419



មន្ទីរសន្តិសុខមានចម្ងាយប្រមាណពីររយម៉ែត្រ នាប៉ែកខាងលិចសាលារៀនស្វាយទាបមាន វិសាលភាពផ្ទៃដីក្នុងទំហំប្រមាណជា ៤ (បួន) ហិចតា ហ៊ុំព័ទ្ធដោយរបងជុំវិញជាព្រៃឬស្សីក្រាស់ ។[1140]

៣៦២ មន្ទីរសន្តិសុខមានរោងឈើ ២ (ពីរ) វែងៗធ្វើជាកន្លែងសម្រាប់ឃុំឃាំងមនុស្ស ។[1141] អ្នកទោសត្រូវដាក់ខ្នោះជើងទាំងថ្ងៃទាំងយប់ ដោយគ្មានការលើកលែង ។[1142] អ្នកទោសនៅមន្ទីរសន្តិសុខនេះ ត្រូវបានអង្គការចោទប្រកាន់ថា ប្រភេទមនុស្សខ្ជិលច្រអូសការងារ អ្នកប្រព្រឹត្តខុសសីលធម៌ ជាពិសេស អតីតអ្នករដ្ឋការនៃរបបមុនៗ ។[1143] អ្នកទោសនៅមន្ទីរសន្តិសុខនេះមានទាំងមនុស្សចាស់ មនុស្សពេញវ័យ និងកុមារ ។[1144] ជាទូទៅអ្នកទោសមាន ២ (ពីរ) ប្រភេទជាអ្នកទោសស្រាល និង អ្នកទោសធ្ងន់ ។[1145] អ្នកទោសក៏នៅមានបំណែងចែកជាអ្នកទោសជាប្រជាជនថ្មី និង ប្រជាជនមូលដ្ឋាន ។ [1146]

៣៦៣ អ្នកទោសដែលចាប់បានត្រូវដឹកតាមរទេះគោ ឬ ឡាន ។[1147] បើដឹកតាមឡានគេនឹងប្រើប្រាស់រថយន្តមានឃ្លុបបិទជិត ។[1148] នៅពេលដឹកតាមរទេះគោតែងមាន គណៈកងរទេះគោជាអ្នកដឹក និងអមដោយកងឈ្លបក្មេងៗ ដើម្បីការពារសន្តិសុខដែលប្រដាប់ដោយកាំបិតគ្រប់ដៃជាអ្នកដើរពីក្រោយ ដើម្បីការពារកុំឱ្យអ្នកទោសរត់ ។[1149] ម្យ៉ាងវិញទៀត សាក្សីឈ្មោះ ហាម គឹមសួរ អតីតអ្នកបររទេះគោដឹកមនុស្សថា ខ្លួនជាអ្នកដឹកមនុស្សពីភូមិថ្នល់បែកយកទៅសម្លាប់ដឹកបានប្រហែលជា ៤០ (សែសិប) ម៉ែត្រ ស្រាប់តែមានគណៈកងផ្សេងទៀត មកទទួលដឹកបន្តយកទៅចំការស្វាយចន្ទី ។[1150]

៣៦៤ សាក្សីម្នាក់បានលើកឡើងថា *"ខ្ញុំបានឃើញផ្ទាល់ ពេលគេនាំមនុស្សមកពីភូមិមួយចំនួនដូចជា៖ ភូមិមហា ភូមិចិន ភូមិត្រពាំងបេង ភូមិវាលវីខាងលិច ភូមិស្រែព្រាល និងភូមិព្រីកតាមរទេះគោចូលមកទីនេះ ។ ខ្ញុំឃើញអ្នកទាំងនេះ ដោយសារពេលនោះខ្ញុំត្រូវបានគេចាត់អោយបររទេះគោដឹកអុសសម្រាប់រោងបាយរួមរបស់ភូមិ ។ តាមខ្ញុំឮតែពុំបានឃើញផ្ទាល់ទេថា គេដឹកមនុស្សតាមរទេះគោមកពីភូមិវាលវីខាងកើត ភូមិស្វាយទាប ភូមិតាំងក្រុង ភូមិថ្នល់បែកខាងកើត ថ្នល់បែកខាងលិច និងភូមិប្រម៉ាត់ដី យកមកសម្លាប់នៅទីនេះដែរ"* ។[1151]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ១០១

៣៦៥ ចាប់ពីឆ្នាំ១៩៧៥ ដល់ពាក់កណ្តាលឆ្នាំ១៩៧៨ មានតែការសម្លាប់មនុស្សជាទ្រង់ទ្រាយតូចៗ តែប៉ុណ្ណោះ ។[1152] ប៉ុន្តែ ចាប់ពីខែមិថុនា ឆ្នាំ១៩៧៨ ការសម្លាប់មនុស្សនៅចំការស្វាយចន្ទី បានកើតឡើងស្ទើរតែរៀងរាល់ថ្ងៃ ដោយមនុស្សនៅតាមភូមិទាំង ១៣ (ដប់បី) ក្នុងឃុំស្វាយទាប ត្រូវយកទៅសម្លាប់នៅមន្ទីរសន្តិសុខនេះ ។[1153]

៣៦៦ នៅឆ្នាំ១៩៧៧ ពេលជាប់ឃុំរយៈ ៧ (ប្រាំពីរ) ថ្ងៃ ជាមួយអ្នកទោសប្រមាណជា ៣៥ (សាបសិបប្រាំ) នាក់ ផ្សេងទៀត សាក្សីឈ្មោះ ខែក ញ៉េ បានមើលឃើញតាមប្រហោងជញ្ជាំងនូវការសម្លាប់មនុស្សរៀងរាល់ថ្ងៃ ។[1154] ក្នុងឆ្នាំ១៩៧៨ កែ ពក បានបញ្ជាឲ្យកត់ឈ្មោះអ្នកចេះដឹងនៅតាមភូមិក្នុងឃុំស្វាយទាប ដើម្បីយកទៅសម្លាប់ ។[1155] ការចាប់ខ្លួនត្រូវបានធ្វើឡើងភ្លាមៗ បន្ទាប់ពីការប្រកាសរបស់ប្រធានកងឈ្មោះ យាង ។[1156] សាក្សីជាច្រើនរូបបាន ផ្តល់សក្ខីកម្មជាច្រើន អំពីការកាប់សម្លាប់ និង ការធ្វើទុក្ខបុកម្នេញនៅមន្ទីរសន្តិសុខចំការស្វាយចន្ទី ក៏ប៉ុន្តែពួកគេបានអះអាងថា ពុំដែលបានឮឈ្មោះ **តា អាន** នោះទេ ។[1157]

៣៦៧ យ៉ុន មានតួនាទីជាមេឃុំស្វាយទាប និងជាអ្នកទទួលខុសត្រូវរៀបចំក្នុងការចាប់ខ្លួន និងសម្លាប់មនុស្សនៅមន្ទីរសន្តិសុខចំការស្វាយចន្ទី។[1158] កងឈ្លបនៅតាមភូមិក្នុងឃុំស្វាយទាប សុទ្ធតែស្ថិតនៅក្រោមការបញ្ជារបស់ យ៉ុន ។[1159] ក្រៅពីកងឈ្លបរបស់ យ៉ុន ក៏នៅមានកងសន្តិសុខថ្នាក់ស្រុក និងកងសន្តិសុខតំបន់ ក៏ជាអ្នកទទួលបន្ទុកចាប់យកមនុស្សមកកម្ទេចនៅមន្ទីរសន្តិសុខនេះដែរ ។[1160] រីឯឈ្មោះ ផល ជាប្អូនថ្លៃរបស់ យ៉ុន ក៏ជាអ្នកទទួលបន្ទុកផ្នែកខាងយាម និងគ្រប់គ្រងលើអ្នកសម្លាប់មនុស្សដែលមាន ស៊ីន ប៉ាន់ ឈឿន និង ភោគ អ៊ុង សៅ ។[1161] ខណៈឈ្មោះ សួន ក៏ជាមនុស្សម្នាក់ដែលចេញបញ្ជាឲ្យចាប់មនុស្សទៅសម្លាប់ដែរ ។[1162] លើសពីនេះ ប្រធានកង កងឈ្លប និងប្រធានភូមិ ក៏ធ្លាប់បានចូលរួមក្នុងការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខចំការស្វាយចន្ទីដោយផ្ទាល់ដែរ ។[1163]ក្រោយពីមានសន្ទុះនៃការកើនឡើងការសម្លាប់ យ៉ុន ខ្លួនឯងក៏ត្រូវបានចាប់ខ្លួន និងសម្លាប់តាមបញ្ជា កែ ពក ដោយសារគាត់បានអនុវត្តបទបញ្ជាលើស ។[1164]

៣៦៨ ពេលខ្លះអ្នកទោស ត្រូវបានគេបង្ខំឲ្យកាប់រណ្តៅពេញមួយយប់ សម្រាប់ទុកកប់សពខ្លួនឯង ។[1165] អ្នកទោសត្រូវចងដៃទៅក្រោយ រួចបណ្តើរទៅមាត់រណ្តៅ ដោយឲ្យអ្នកទោសលុត



E.C.C.C * C.E.T.C * INVESTIGATING JUDGES * JUGES D'INSTRUCTION

ជង្គង់នៅគែមមាត់រណ្តៅ រួចគេយកដំបងឬស្សីវាយកញ្ចឹងក និងទម្លាក់ចូលរណ្តៅ ហើយខ្លះទៀតសម្លាប់រួច ទើបយកទៅបោះចូលរណ្តៅ ខណៈខ្លះទៀតសម្លាប់ហើយយកទៅបោះចូលអណ្តូងទឹកក៏មាន ។[1166] ឧបករណ៍ប្រើសម្លាប់អ្នកទោសមាន គល់ឫស្សី ឬ ដែកភ្លៅរទេះ ជាអាទិ៍ ។[1167] នៅពេលសម្លាប់ មានកម្មវិធីស៊ីផឹកសប្បាយរបស់ក្រុមអ្នកសម្លាប់ និងចាប់មេក្រូ និងការស្រែកថា ពួកអាខ្មាំងមីខ្មាំង ។ ស្របពេលអ្នកទោសវិញមានតែសម្លេងស្រែកថ្ងូរគួរឲ្យសង្វេគមែនទែន ។[1168]

៣៦៩ សាក្សីលើកឡើងថា មានអ្នកទោសតិចតួចដែលត្រូវបានដោះលែង ពីមន្ទីរសន្តិសុខចំការស្វាយចន្ទី រហូតដល់គេអះអាងថា មន្ទីរសន្តិសុខនេះជាកន្លែងសម្រាប់ឃុំឃាំង និង សម្លាប់មនុស្សច្រើនជាងគេយ៉ាងសាហាវបំផុត ក្នុងស្រុកចំការលើ ។[1169] ពាក់ព័ន្ធនឹងចំនួនអ្នកស្លាប់ មានសាក្សីលើកឡើងផ្សេងៗគ្នាថា ចំនួនចន្លោះពី ១.០០០[1170](មួយពាន់) ទៅ ២.០០០[1171] (ពីរពាន់) នាក់ ។ របាយការណ៍មជ្ឈមណ្ឌលឯកសារកម្ពុជាបញ្ជាក់ថា អ្នកស្លាប់មានចន្លោះពី ៥.០០០ (ប្រាំពាន់) ទៅ ១០.០០០ (មួយម៉ឺន) នាក់ ។[1172]

## ១.១១. មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក

៣៧០ មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ស្ថិតនៅវត្តបារាយណ៍ជាន់ដែក ដែលមានទីតាំងស្ថិតក្នុងភូមិត្រាស់ ឃុំបល្ល័ង្ក ស្រុកបារាយណ៍ ខេត្តកំពង់ធំ តំបន់ ៤២ ភូមិភាគកណ្តាល ។[1173] មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ជាមន្ទីរសន្តិសុខថ្នាក់ស្រុក ។[1174]

៣៧១ មន្ទីរសន្តិសុខវត្តនេះមានប្រធានដំបូងឈ្មោះ ទី១. សែន[1175] ក្រោយមក ទី២. ម៉ាង បន្ទាប់មកទៀត ទី៣. ម៉ៅ[1176] ហើយចុងក្រោយ ទី៤. សឿន ដែលជាអ្នកមកពីនិរតីដោយគាត់បានកាន់តំណែងរហូតដល់ការដួលរលំរបប ។[1177]ព្រះវិហារវត្តបារាយណ៍ជាន់ដែកត្រូវបានយកមកធ្វើជាកន្លែងឃុំឃាំងអ្នកទោសដែលចាប់បាន ដើម្បីធ្វើទារុណកម្ម និងសម្លាប់។[1178] មន្ទីរសន្តិសុខឃុំឃាំង អ្នកទោសជាប្រជាជនថ្មី ប្រជាជនមូលដ្ឋាន និង ជនជាតិចាម ។[1179]

៣៧២ អ្នកទោសតែងត្រូវគេវាយធ្វើបាបពេលសួរចម្លើយ ដើម្បីទទួលបានចម្លើយសារភាព ។[1180] ចម្លើយសារភាពត្រូវគេបញ្ជូនទៅឲ្យថ្នាក់ស្រុកដែលជាថ្នាក់លើផ្ទាល់ ។[1181] សាក្សីបានឆ្លើយ



E.C.C.C * CETC * CO-INVESTIGATING JUDGES

ថា *"ចម្លើយនោះ(ចម្លើយសារភាព)ត្រូវបានគេបញ្ជូនទៅថ្នាក់ស្រុកគណៈស្រុកជាអ្នកធ្វើការសម្រេចចិត្តថា តើត្រូវដោះលែងឬត្រូវកម្ទេច"* ។[1182] សាក្សីឈ្មោះ អ៊ុត សេង លើកឡើងថា *"នៅមានកន្លែងសម្លាប់ធំមួយទៀត នៅវត្តបារាយណ៍ជាន់ដែក នៅពេលមានការសម្លាប់មនុស្សគេនឹងធ្វើការចាក់មេក្រូ ហើយនាំមនុស្សទៅមុខវត្តធ្វើការសម្លាប់តែម្តង"* ។[1183]

៣៧៣ មន្ទីរសន្តិសុខនេះមានអ្នកទោសចន្លោះពី ២០ (ម្ភៃ) ទៅ ៣០ (សាមសិប) នាក់ ។[1184] អ្នកទោសត្រូវគេឃុំនៅសាលាឆាន់ នាប៉ែកខាងត្បូងកុដិ ។[1185] អ្នកទោសដែលជាប់ឃុំត្រូវគេដាក់ខ្នោះជើងជាជួរដោយក្នុងមួយជួរៗមានគ្នាពី ៧ (ប្រាំពីរ) ទៅ ៨ (ប្រាំបី) នាក់ ដោយមានខ្នោះដែកនៅកជើង ស៊កដោយរនុកដែកពេញមួយថ្ងៃ។[1186] ចំណែកអ្នកទោសស្ត្រីត្រូវគេដាក់នៅបន្ទប់តូចមួយតែមិនដាក់ខ្នោះទេ ។[1187] ការអនុវត្តន៍របៀបនេះ ដូចគ្នានឹងអ្នកទោសដែលជាកុមារ ។[1188]

៣៧៤ អ្នកទោសត្រូវទទួលបានអាហារ ២ (ពីរ) ដងក្នុងមួយថ្ងៃ ជាបបររាវៗ ២ (ពីរ) វែកមួយពេល ។[1189] ពេលត្រូវការបត់ជើងតូច អ្នកទោសនោមដាក់ក្នុងកន្ត្រ រួចហុចឱ្យគ្នាទៅវិញទៅមក រួចហុចឱ្យទៅអ្នកទោសស្រាលដែលត្រូវបានគេដោះខ្នោះចេញ ដើម្បីយកកន្ត្រទៅចាក់ចោល ។[1190] អ្នកទោសត្រូវបានអនុញ្ញាតមុជទឹកមួយអាទិត្យម្តង ។[1191]

៣៧៥ មានការលើកឡើងថា មានតែប្រជាជនថ្មីដែលត្រូវគេជម្លៀសពីភ្នំពេញប៉ុណ្ណោះ ត្រូវគេយកមកសម្លាប់នៅមន្ទីរសន្តិសុខនេះ ប៉ុន្តែ ក៏មានដែរអ្នកទោសជាជនចាមផងដែរ ។[1192] នៅចន្លោះឆ្នាំ១៩៧៦-១៩៧៧ ប្រជាជនជាច្រើនត្រូវបានគេចាប់ខ្លួនបញ្ជូនមកធ្វើការឃុំឃាំងនិងសម្លាប់នៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក។[1193] នៅពេលដែលក្រុមនិរតីមកដល់គេប្រើវត្តនេះជាមន្ទីរសន្តិសុខបានប្រហែលកន្លះខែ ទើបបានគេដូរទៅកន្លែងផ្សេងនៅមន្ទីរសន្តិសុខស្រឡៅទោង ។[1194] នៅដើមឆ្នាំ១៩៧៨ ការសម្លាប់មនុស្សនៅស្រឡៅទោងមានលក្ខណៈកើនឡើងខ្លាំងឡើងៗ ។[1195] ប៉ុន្តែ បែរជាមានសាក្សីឈ្មោះ ម៉ែន ឡេ បានលើកឡើងថា *"នៅឆ្នាំ១៩៧៨ ខ្ញុំឃើញមនុស្សច្រើនណាស់ដែលត្រូវគេដឹកយកទៅវត្ត (វត្តបារាយណ៍ជាន់ដែក) ប៉ុន្តែ គ្មាននរណាម្នាក់នៅរស់រានមានជីវិតទេ"* ។[1196]



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

៣៧៦ ចំនួនអ្នកស្លាប់នៅមន្ទីរសន្តិសុខនេះ មិនមានភាពជាក់លាក់ទេ ។ សាក្សីម្នាក់បានឆ្លើយថា *"ខ្ញុំមិនអាចប៉ាន់ស្មានថា មានមនុស្សប៉ុន្មាននាក់ត្រូវបានគេសម្លាប់នោះទេ ប៉ុន្តែ ខ្ញុំបានឃើញបន្ទប់មួយមានទំហំពីរម៉ែត្របួនជ្រុង ពេញដោយលលាដ៍ក្បាលដែលគេដាក់នៅទីនោះ"* ។[1197] សាក្សីម្នាក់ទៀតបានអះអាងថា មានអ្នកទោសរហូតដល់ជិត ១.០០០ (មួយពាន់) នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ។[1198] ប៉ុន្តែ ផ្អែកតាមអតីតអ្នកយាមនៅមន្ទីរសន្តិសុខ ចំនួនសរុបនៃអ្នកទោសដែលគេសម្លាប់នៅមន្ទីរសន្តិសុខ អាចមានចំនួនតិចជាង ១.០០០ (មួយពាន់) នាក់ ។[1199] ខណៈដែលសាក្សីមួយរូបបានប្រមាណថា មានមនុស្សរហូតដល់ *"ប្រហែល ៥.០០០ (ប្រាំពាន់) នាក់ ត្រូវបានគេសម្លាប់នៅក្នុងឆ្នាំ ១៩៧៨"* ។[1200]

## ១.១២. មន្ទីរសន្តិសុខវត្តស្រង៉ែ

៣៧៧ មន្ទីរសន្តិសុខវត្តស្រង៉ែស្ថិតនៅភូមិស្រង៉ែ ឃុំត្បែង ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ តំបន់៤៣ ភូមិភាគកណ្តាល ។[1201] មន្ទីរសន្តិសុខស្រង៉ែជាមន្ទីរសន្តិសុខថ្នាក់តំបន់ ។[1202] ប៉ុន្តែ អតីតអ្នកយាមអះអាងថា ជាមន្ទីរសន្តិសុខថ្នាក់ស្រុក ។[1203] មន្ទីរសន្តិសុខមានវិសាលភាពគ្របដណ្តប់លើ ទំហំផ្ទៃដីប្រមាណជា ១ (មួយ) ហិចតា ដោយមានគុម្ពឬស្សី ដុះព័ទ្ធជុំជិតជារបង ។[1204]

៣៧៨ មន្ទីរសន្តិសុខវត្តស្រង៉ែ បានបើកឱ្យដំណើរការតាំងពីឆ្នាំ១៩៧៦ មុនការមកដល់របស់ក្រុមនិរតីទៅទៀត ។[1205] ប៉ុន្តែ ក៏មានការអះអាងដែរថា មន្ទីរសន្តិសុខនេះបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៧៤ ។[1206] បើទោះជាមានវត្តមាននៃការមកដល់របស់ក្រុមនិរតី ក៏មិនមានការផ្លាស់ប្តូរសមាសភាពអ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខនេះដែរ ។[1207] មន្ទីរសន្តិសុខនេះត្រូវបានបិទលែងឱ្យដំណើរការនាចុងឆ្នាំ១៩៧៨ មុនការដួលរលំរបបនេះបន្តិច ។[1208] ការបិទនេះពុំមានព័ត៌មានឱ្យបានច្បាស់លាស់ពីមូលហេតុទេ ប៉ុន្តែ បែរជាមានការប្តូរទីកន្លែងនៃមន្ទីរសន្តិសុខ ដោយផ្លាស់ទៅបាំងកញ្ចក់ ស្ថិតនៅក្នុងភូមិព្រៃព្រៀល ឃុំត្រពាំងឫស្សី ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ ។[1209]



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581424



៣៧៩ សមាសភាពគ្រប់គ្រងនៅមន្ទីរសន្តិសុខមានឈ្មោះ គីន ជាប្រធានមន្ទីរសន្តិសុខ, ឡៃ ជាអនុប្រធាន, និង ឈឿង ជាសមាជិក ។[1210] ចំពោះអ្នកសួរចម្លើយមានឈ្មោះ គីន, ឡៃ, ជន, និង អេង ។[1211] ក្រុមអ្នកសម្លាប់មានប្រមាណជា ៦ (ប្រាំមួយ) នាក់មាន៖ សែម, ចាន់, យឿន, ថាង, ឡី, និង សក់ ។[1212] ក្រុមអ្នកយាមមានយ៉ាងតិច ៥ (ប្រាំ) នាក់ ដោយមាន៖ យឹម ជាប្រធាន, ឡាយ ជាអនុប្រធាន, ឈឿង, ផាត និង ជឿង ជាសមាជិកជាអាទិ៍ ។[1213]

៣៨០ មន្ទីរសន្តិសុខនេះមានទាហានប្រចាំការប្រហែលជា ២០ (ម្ភៃ) នាក់ ដើម្បីមើលការខុសត្រូវខាងសន្តិសុខក្នុងការការពារ ។[1214] អ្នកធ្វើការនៅមន្ទីរសន្តិសុខសុទ្ធតែជាអ្នកមូលដ្ឋាន។[1215] ចំពោះមនុស្សដែលត្រូវបានចាប់ខ្លួនមកមន្ទីរសន្តិសុខភាគច្រើន ជាអតីតអ្នកមាននិន្នាការជាមួយរបបលន់នល់ ប្រជាជនថ្មី ប្រជាជនមូលដ្ឋាន កម្មាភិបាលក្នុងមូលដ្ឋាន ឬ ចោរព្រៃដែលចាប់មកពីភូមិឃុំនានាក្នុងតំបន់ ។[1216]

៣៨១ អ្នកទោសដែលត្រូវចាប់បញ្ជូនមកមន្ទីរសន្តិសុខវត្តស្រងែ ពេលខ្លះស្ទើររាល់ថ្ងៃ ពេលខ្លះពីរបីថ្ងៃម្តង ដោយម្តងៗពីរបីនាក់ ហើយពេលខ្លះឈានរហូតដល់បួនប្រាំរទេះគោ ភាគច្រើននាំមកពេលយប់ ។[1217] សាក្សីមួយរូបជាអតីតប្រធានផ្នែកសេដ្ឋកិច្ចភូមិស្រងែ និងជាអ្នករស់នៅជិតមន្ទីរសន្តិសុខបានលើកឡើងថា *"ជួនកាលខ្ញុំឃើញមនុស្សត្រូវបានគេចង ហើយបណ្តើរជាជួរទៅមន្ទីរសន្តិសុខ"* ។[1218]

៣៨២ ការចាប់ខ្លួនភាគច្រើន ក្រោមរូបភាពជាការកោះហៅប្រជាជនឱ្យមកប្រជុំ ហើយចាប់ខ្លួន ។[1219] អ្នកទោសភាគច្រើនជាមនុស្សពេញវ័យ និងកុមារតិចតួច ដោយហេតុថា ឪពុកម្តាយត្រូវចាប់ខ្លួនហើយកូនត្រូវនាំមកដែរ ដោយដឹកតាមរទេះសេះ ឬរទេះគោ ។[1220] អ្នកទោសត្រូវគេឃុំក្នុងព្រះវិហាររបស់វត្តស្រងែតែម្តង ។[1221] សក្ខីកម្មសាក្សីបានបង្ហាញថាអ្នកទោសនៅក្នុងព្រះវិហារមានចន្លោះប្រហែលពី ៤០ (សែសិប) ទៅ ១០០ (មួយរយ) នាក់ ។[1222]

៣៨៣ អ្នកទោសទាំងនោះ ត្រូវគេដាក់ទាំងខ្នោះដៃ និងខ្នោះជើង ក្នុងរបាដែកវែងជាជួរៗមានរហូតដល់ប្រាំជួរ ដោយមួយជួរដាក់អ្នកទោស ២០ (ម្ភៃ) នាក់ ។ [1223] អាហាររបស់អ្នកទោសមានតែបបររាវៗ បានតែមួយវែកទេមួយពេល ហើយមួយថ្ងៃគេឱ្យហូបតែពីរដងប៉ុណ្ណោះ ។[1224]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581425



[1224] នៅពេលជាប់ឃុំឃាំង អ្នកទោសក៏ត្រូវបានបង្ខំ ឱ្យធ្វើការងារជាទម្ងន់ផងដែរ ។[1225] អ្នកទោសស្រី និង អ្នកទោសប្រុស ត្រូវគេឃុំដាច់ដោយឡែកពីគ្នា ។[1226]

៣៨៤ នៅបរិវេណវត្តមានរោងមួយដែលត្រូវបានគេស្គាល់ថា ជាកន្លែងសួរចម្លើយអ្នកទោស។[1227] ក្នុងអំឡុងពេលសួរចម្លើយ អ្នកទោសត្រូវគេធ្វើទារុណកម្មដោយ វាយនឹងខ្សែព្យួរនីឡុង យកឈើបុកដើមទ្រូង ចាក់ទឹកចូលច្រមុះ ជាអាទិ៍ ។[1228] បន្ទាប់ពីសួរយកចម្លើយ ក្រុមអ្នកសួរចម្លើយនឹងសម្រេច ដើម្បីធ្វើការបែងចែកអ្នកទោសជា អ្នកទោសធ្ងន់ ឬ អ្នកទោសស្រាល ។[1229] ពេលខ្លះក្រោយពីសួរចម្លើយរួច អ្នកទោសត្រូវបាននាំទៅសម្លាប់ភ្លាម ។[1230] អ្នកទោសធ្ងន់ ត្រូវគេបញ្ជូនទៅមន្ទីរសន្តិសុខនៅទីរួមខេត្តកំពង់ធំ រីឯ អ្នកទោសស្រាលក្រោយមកអាចត្រូវធ្វើការដោះលែងឱ្យទៅរស់នៅតាមភូមិវិញ ។[1231] នាពេលកំពុងជាប់ឃុំ អ្នកទោសស្រាលខ្លះ ក៏ត្រូវបានគេប្រើឱ្យយករបបហូកចុក ទៅឱ្យអ្នកជាប់ឃុំឃាំងផ្សេងៗទៀត ក្នុងមន្ទីរសន្តិសុខនេះ ។[1232]

៣៨៥ មន្ទីរសន្តិសុខនេះ មានកន្លែងសម្លាប់មនុស្សនៅក្រៅបរិវេណវត្តចំនួន ៣ (បី) កន្លែងធំៗដូចជា៖ នៅប៉ែកខាងជើង ខាងជើងឈៀងខាងលិចវត្តស្រង៉ែ និង នៅតាមព្រៃដងវែងក្នុងភូមិស្រង៉ែ។[1233] សាក្សីជាអតីតអ្នកយាមមន្ទីរសន្តិសុខវត្តនេះលើកឡើងថា "*សេចក្តីសម្រេចក្នុងការសម្លាប់មនុស្សគឺជាបញ្ជាពីថ្នាក់លើគឺពីគណៈស្រុក និងគណៈតំបន់*"។[1234] ការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខនេះ បានកើតមានឡើងទាំងលើប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន ។[1235] នាពេលសម្លាប់មនុស្សនៅមន្ទីរសន្តិសុខនេះម្តងៗ ជារឿយៗអ្នកទោសតែងស្រែកថ្ងូរយ៉ាងសង្វេគ ។[1236] ករណីខ្លះអ្នកទោសបានស្លាប់ នៅក្នុងកន្លែងឃុំឃាំងតែម្តងក៏មានដោយសារអត់អាហារ ។[1237] សាកសពអ្នកទោស ត្រូវគេយកទៅកប់នៅក្រៅរបងមន្ទីរសន្តិសុខ ។[1238]

៣៨៦ ពាក់ព័ន្ធចំនួនអ្នកស្លាប់នៅមន្ទីរសន្តិសុខវត្តស្រង៉ែ ពុំមានទិន្នន័យផ្តល់ជូនតាមការស្រាវជ្រាវពីអ្នកជំនាញឱ្យបានច្បាស់លាស់នោះទេ ប៉ុន្តែភាគច្រើនជាទិន្នន័យទាញចេញពីការសន្និដ្ឋាន ។ តាមសាក្សីឈ្មោះ ហៀង សយ បាននិយាយថា "*ខ្ញុំមិនដឹងចំនួនពិតប្រាកដទេ តែអ្នកស្លាប់អាចមានចំនួនរាប់ពាន់នាក់*"។[1239] ខណៈដែលប្រភពផ្សេងទៀត បានធ្វើការប៉ាន់ប្រមាណថា

មានអ្នកទោសប្រហែល ៣.៥០០ (បីពាន់ប្រាំរយ) នាក់ ត្រូវបានសម្លាប់នៅមន្ទីរសន្តិសុខវត្តស្រង៉ែ ។[1240]

## ១.១៣. មន្ទីរសន្តិសុខវត្តអង្គញ្ញដី

៣៨៧ មន្ទីរសន្តិសុខវត្តអង្គញ្ញដី មានទីតាំងស្ថិតនៅភូមិក្តីបឹង ឃុំក្រឡា ស្រុកកំពង់សៀម ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[1241] ពីមុនមន្ទីរសន្តិសុខនេះត្រូវបានធ្វើជាកន្លែងសម្លាប់មនុស្សតិចតួចខ្លះដែរ ។[1242] មន្ទីរសន្តិសុខវត្តអង្គញ្ញដី ជាមន្ទីរសន្តិសុខថ្នាក់ស្រុក ។ ជាទូទៅ មន្ទីរនេះត្រូវបានគេប្រើប្រាស់ជាកន្លែងឃុំឃាំងបណ្តោះអាសន្ន មុនបញ្ជូនទៅសម្លាប់ ទោះបីជាយ៉ាងណា មន្ទីរសន្តិសុខនេះក៏មានការសម្លាប់មនុស្សនៅទីនេះដែរ ។[1243] ជាក់ស្តែង ក្រោយការដួលរលំរបបកម្ពុជាប្រជាធិបតេយ្យ នៅអង្គញ្ញដីមានរណ្តៅជាច្រើនដែលផ្ទុកទៅដោយសាកសព ។[1244]

៣៨៨ មន្ទីរសន្តិសុខជារោងគ្មានជញ្ជាំងមានតែដំបូលប្រក់ក្បឿង ។[1245] អ្នកទោសនៅមន្ទីរសន្តិសុខត្រូវគេដាក់ខ្នោះជើងរនុកដែកជាពីរជួរ ។[1246] អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខ តែងត្រូវបានគេធ្វើទារុណកម្មនៅពេលសួរយកចម្លើយ។[1247] អ្នកទោសត្រូវគេឃុំក្នុងរយៈពេលមួយខ្លីមុននឹងបញ្ជូនទៅថ្នាក់តំបន់ ឬ ទៅកន្លែងសម្លាប់មនុស្សទួលបេង[1248] ដែលមានចម្ងាយប្រហែល ១,៥ គីឡូម៉ែត្រ ខាងលិចភូមិអង្គញ្ញដី នាប៉ែកខាងឆ្វេងដៃផ្លូវជាតិលេខ ៦ ឆ្ពោះទៅភ្នំពេញ ។[1249]

៣៨៩ បន្ទាប់ពីមានការផ្ទេរក្រុមនិរតីមកកាន់ភូមិភាគកណ្តាល យាយ យុត ត្រូវបានឡើងជាលេខាស្រុកកំពង់សៀម (លេខាស្រុក១០១) តា ស៊ី ជាអនុលេខាស្រុក និង ណន ជាគណៈស្រុកកំពង់សៀម ។[1250] ផ្នែកយោធាមានឈ្មោះ ផុន ជាអ្នកទទួលបន្ទុកជាប្រធានយោធាស្រុកកំពង់សៀម ។[1251] នី ជាប្រធានមន្ទីរសន្តិសុខស្រុកកំពង់សៀម ។[1252] នាចុងខែវិច្ឆិកាឆ្នាំ១៩៧៨ យាយ យុត ត្រូវបានថ្នាក់លើផ្លាស់ឲ្យទៅបំរើការនៅតំបន់ ៥ នៃភូមិភាគពាយ័ព្យវិញ ។[1253] នាពេលនោះ ណន ត្រូវបានឡើងជាលេខាស្រុកកំពង់សៀម ខណៈដែល តា ស៊ី ក៏ត្រូវបានបញ្ជូនទៅកន្លែងផ្សេងដែរ ។[1254] ជា ជាអ្នកទទួលបន្ទុកនៅមន្ទីរសន្តិសុខវត្តអង្គញ្ញដី ។[1255]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

៣៩០ មន្ទីរសន្តិសុខនេះ ជាកន្លែងឃុំខ្លួនមនុស្សទាំងប្រជាជនខ្មែរ និង ជនជាតិចាម ដែលចាប់បាន ពីតាមបណ្តាឃុំនានាក្នុងស្រុកកំពង់សៀម ។[1256] ចំពោះអ្នកដែលមានឋានៈ ចាប់ពីអនុភូមិ ដល់មេឃុំ និងអតីតទាហាន លន់ នល់ ត្រូវបញ្ជូនទៅឃុំនៅមន្ទីរសន្តិសុខតំបន់ ។[1257] ក្មេងៗក៏ត្រូវបានគេឃុំនៅវត្តអង្គញដីដែរ ។[1258] ពេលមានក្មេងលួចរត់បើទោះជាពេលយប់ ក៏កងឈ្លបតាមរកទាំងយប់ដែរ ។[1259] ដោយសារស្ថានភាពមន្ទីរសន្តិសុខនេះ ជាកន្លែងតូច ធ្វើឱ្យការឃុំខ្លួនអ្នកទោសបានតែជាង ១០ (ដប់) នាក់។[1260] សាក្សីឈ្មោះ ញឹម កុល បាន លើកឡើងថា *"មិនមានជនជាតិចាមណាម្នាក់ត្រូវបានទុកជីវិតទេ លើកលែងតែ ភា ដែល ត្រូវបាន យុត ការពារ"* ។[1261]

៣៩១ សាក្សី ញឹម កុល លើកឡើងថា *"ខ្ញុំបានជួប **តា អាន** ... នៅភូមិអង្គញដី នៅពេលដែលគាត់ បានមកមើលផ្ទះបាយដែលត្រូវបានសាងសង់ថ្មី"* ។[1262] រីឯ សាក្សីឈ្មោះ អោក ចន្ទី បាន និយាយថា *"ខ្ញុំធ្លាប់ឮឈ្មោះ **តា អាន** ថាគាត់មកប្រជុំនៅមន្ទីរស្រុកដែលទីតាំងនៅភូមិអង្គញ ដី ប៉ុន្តែខ្ញុំមិនដែលបានឃើញគាត់ទេ"* ។[1263]

## ១.១៤. ទីកន្លែងសម្លាប់មនុស្សនៅទួលបេង

៣៩២ កន្លែងសម្លាប់មនុស្សទួលបេង មានទីតាំងនៅខាងលិចវត្តក្នុងភូមិទួលបេង ឃុំក្រឡា ស្រុក កំពង់សៀម ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ។[1264] មន្ទីរសន្តិសុខទួលបេងនេះ ស្ថិតនៅប្រហែលជាបីបួនគីឡូម៉ែត្រពីមន្ទីរស្រុកកំពង់សៀម។[1265] ទួលបេងជាមន្ទីរសន្តិសុខ ថ្នាក់ស្រុក ។[1266] បច្ចុប្បន្ន បរិវេណនៃកន្លែងសម្លាប់មនុស្សទួលបេងជាកសិដ្ឋាន និង ដី កសិកម្ម ។[1267]

៣៩៣ នី ជាអ្នកគ្រប់គ្រងនៅមន្ទីរសន្តិសុខទួលបេង ។[1268] រ៉ុម ជាមេឃុំក្រឡានិងជាអ្នកបញ្ជូនមក ពីនិរតី ។[1269] រ៉ុម មាននិរសាយ៉ាងហោច ៤ (បួន) នាក់រួមមាន ហឿន, ឡុង, ចេក, និង សេង ។[1270] មន្ទីរឃុំក្រឡាជាកន្លែងធ្វើការរបស់ រ៉ុម ដែលមានទីតាំងស្ថិតនៅទល់មុខផ្លូវ ចូលទៅភូមិអង្គញដី ។[1271] មន្ទីរឃុំក្រឡាមានចម្ងាយប្រហែល ២០០ (ពីររយ) ម៉ែត្រពីមន្ទីរ ស្រុកកំពង់សៀម ។[1272]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៣៩៤ មន្ទីរសន្តិសុខទួលបេង មានអគាររោងឈើវែងៗ ពីរសម្រាប់ឃុំអ្នកទោស ដោយរោងនីមួយៗមានទំហំប្រហែល ៧ (ប្រាំពីរ) ម៉ែត្រ គុណ ២០ (ម្ភៃ) ម៉ែត្រ ។[1273] មន្ទីរសន្តិសុខមានអ្នកជាប់ឃុំប្រមាណជា ២០០ (ពីររយ) នាក់ ។[1274] អ្នកដែលត្រូវគេយកទៅសម្លាប់នៅទួលបេងនេះត្រូវបានគេឃុំឃាំងនៅមន្ទីរសន្តិសុខនេះសិន ។[1275] ទួលបេងជាទីកន្លែងសម្លាប់មនុស្ស[1276] ហើយការសម្លាប់នេះបានកើតមានតាំងពីមុនក្រុមនិរតីមកដល់[1277] ។ មុនការដួលរលំរបបប្រហែលជា ៣ (បី) ថ្ងៃ អ្នកជាប់ឃុំនៅមន្ទីរសន្តិសុខទួលបេង ត្រូវគេបញ្ជូនទៅគុកព្រៃទទឹង ក្រោយមកត្រូវគេសម្លាប់ចោលទាំងអស់ ដោយបោះគ្រាប់បែកចូលកន្លែងឃុំឃាំងនោះ ។[1278]

៣៩៥ នៅឆ្នាំ១៩៧៨ នៅមន្ទីរសន្តិសុខទួលបេងមាន ការកាប់សម្លាប់ខ្លាំងរហូតដល់អ្នកធ្វើដំណើរពិបាកឆ្លងកាត់ពីព្រោះមានក្លិនស្អុយខ្លាំង ។[1279] កន្លែងសម្លាប់មនុស្សទួលបេងមានរណ្តៅសាកសពជាង ២០ (ម្ភៃ) ទាំងធំទាំងតូច ។[1280] ផុន, កើត, និង ស៊ុន ជាអ្នកទទួលបន្ទុកចាប់មនុស្សទៅសម្លាប់នៅទួលបេង ។[1281] ជនជាតិចាមជាច្រើននាក់ ក៏ត្រូវបានគេចាប់បញ្ជូនទៅសម្លាប់នៅទួលបេងដែរ ។[1282] តាមសាក្សីមួយរូបបានប៉ាន់ប្រមាណថា មានចំនួនជនរងគ្រោះរាប់ពាន់ត្រូវបានសម្លាប់នៅទួលបេង ។[1283]

៣៩៦ អ្នកស៊ើបអង្កេតបានសួរថា "តើ យុត ដឹងអំពីមន្ទីរសន្តិសុខ និងទីតាំងសម្លាប់មនុស្សនៅទួលបេងដែរទេ ? សាក្សីឈ្មោះ ខឹម នារី បានឆ្លើយថា *"ពិតណាស់ វាស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ដែលជាគណៈស្រុក"* ។[1284] ម្យ៉ាងវិញទៀត មានសាក្សីជាច្រើនរូប ដែលធ្លាប់រស់នៅក្នុងស្រុកកំពង់សៀម នាពេលនោះបានឆ្លើយដែរថា ខ្លួនមិនដែលស្គាល់ទេ **តា អាន** ។[1285]

## ១.១៥. អាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ ៤១ (ស្រុកកំពង់សៀមនិងព្រៃឈរ)

៣៩៧ នៅស្រុកកំពង់សៀម ខេត្តកំពង់ចាម តំបន់ ៤១ ភូមិភាគកណ្តាល ក៏មានទម្រង់ការរៀបការដែលរៀបចំដោយអង្គការកើតមានក្នុងឆ្នាំ១៩៧៥ តាំងពីមុនក្រុមនិរតីមកដល់ ហើយបានបន្តរហូតដល់ពេលដួលរលំរបប ។[1286] ជាទូទៅ ការរៀបការដោយអង្គការតែងមានការរៀបចំ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ពិធីរៀបការជាទ្រង់ទ្រាយធំដោយមានច្រើនគូ ។ ជាពិសេស ក្នុងអំឡុងពេលមានពិធីបុណ្យជ័យជម្នះថ្ងៃទី១៧ ខែមេសា រៀងរាល់ឆ្នាំ ។[1287]

៣៩៨ ការរៀបការដោយអង្គការតម្រូវឱ្យបុរសនារីមានប្រវត្តិល្អដូចគ្នា ផ្អែកលើប្រភេទប្រជាជន ប្រជាជនថ្មី ប្រជាជនចាស់ ឬ សមាសភាពដូចគ្នា ។[1288] នាពេលមួយនៅមន្ទីរស្រុកកំពង់សៀម **អោ អាន** បាននិយាយប្រាប់ ប្រាក់ យុត ថា "*ពេលមិត្តរៀបការឱ្យគេ មិត្តត្រូវជ្រើសរើសសមាសភាពផង តែគាត់ពុំបានប្រាប់ពីមូលហេតុនោះទេ*" ។[1289] សាក្សីបានអះអាងថា ការនិយាយរបស់ **អោ អាន** នេះត្រូវបានអនុវត្តចំពោះប្រជាជនថ្មី និង ប្រជាជនចាស់ ។[1290] ប៉ុន្តែ ជាក់ស្តែងអង្គការក៏មានរៀបការឱ្យអ្នកដែលមានប្រវត្តិរូបខុសគ្នាដែរ ។[1291]

៣៩៩ ជាធម្មតា នារីមិនអាចស្នើសុំរៀបការបានទេ ប៉ុន្តែ បុរសទើបអាចស្នើបាន ជាពិសេសអ្នកធ្លាប់មានប្រវត្តិតស៊ូ អាចធ្វើសំណើទៅមេកង ឬមេភូមិ ដែលជាអ្នករៀបចំប្រវត្តិរូបបុរសនារីរួចបញ្ជូនបន្តទៅឃុំ ដើម្បីពិភាក្សានិងសម្រេច ។[1292] ការរៀបការភាគច្រើនធ្វើនៅមន្ទីរស្រុកកំពង់សៀម ពេលខ្លះតាមរោងបាយ ក្នុងភូមិដោយឱ្យបុរសនារីអង្គុយទល់មុខគ្នា ។[1293] បន្ទាប់មក បុរសនារីដែលត្រូវរៀបការឡើងចាប់ដៃគ្នាហើយធ្វើការប្តេជ្ញាចិត្តថាស្រលាញ់គ្នា ក្រោយមកទើបចូលដល់កម្មវិធីហូបអាហាររួម ។[1294]

៤០០ ករណីលេខាស្រុកចូលរួម ស្រុកជាអ្នកដឹកនាំនិងបញ្ជាឱ្យឡើងចាប់អារម្មណ៍ ដោយថ្នាក់ភូមិនិងឃុំក៏មានវត្តមានដែរ ។[1295] ប្រសិនបើខាងស្រុកមិនបានចូលរួម ឃុំជាអ្នកដឹកនាំជំនួស ។[1296] ជាទូទៅ មិនមានទេការចូលរួមពីឪពុកម្តាយ ប៉ុន្តែមានករណីដ៏តិចតួចមានវត្តមានបាន ។[1297] ក្រោយពីបញ្ចប់ពិធីរៀបការរួចរាល់ ឃុំធ្វើរបាយការណ៍ទៅលេខាស្រុកដើម្បីដឹងពីការរៀបការ ។[1298] ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម តែងបាននិយាយប្រកាសតាមមេក្រូ អំពីការរៀបការឱ្យតែមានអង្គប្រជុំហើយថា ការរៀបការជាការជួយអភិវឌ្ឍន៍ជាតិ បើអ្នកណាចង់រៀបការសុំស្នើមកកាន់ភូមិ ។[1299]

៤០១ នៅចុងឆ្នាំ១៩៧៧ នៅវត្តតាមះមានកិច្ចប្រជុំមួយទាក់ទិននឹងការរៀបការ ។ សាក្សីមួយរូបបានលើកឡើងថា "*គាត់ (អោ អាន) បាននិយាយអំពីផែនការរៀបការ ។ ពួកគេត្រូវធ្វើ បង្កើនកម្លាំងថ្មី ឬ ក៏ប្រជាជនថ្មីឱ្យដល់ ១៥ ទៅ ២០ លាននាក់នៅក្នុងរយៈពេលពី ០៥ ទៅ*

*២០ ឆ្នាំទៀត នេះជាផែនការអាស៊ីដែលសំដៅលើផែនការរបស់ ប៉ុល ពត*"។[1300] សាក្សី សាត ភា បានលើកឡើងដែរថា "*ខ្ញុំចង់បន្តនិយាយពីរឿងកម្លាំងនៅអាស៊ី ។ ផែនការរបស់គេគឺបង្កើតប្រជាជនដែលមានអាយុពី ១៥ ទៅ ២០ ឆ្នាំឱ្យបាន ២០ លាននាក់ ហើយវាយយកព្រៃនគរនិងខ្មែរសារិនមកវិញនៅឆ្នាំ២០០១ ។ **តា អាន** ជាអ្នកនិយាយបែបនេះ តែគាត់និយាយតែម្តងប៉ុណ្ណោះ*"។[1301]

៤០២ តាមសាក្សីមួយចំនួនបានលើកឡើងថា កម្រឃើញមានសាមីខ្លួនជាអ្នកស្នើសុំ ប៉ុន្តែភាគច្រើនមេកង មេភូមិ ឬ មេឃុំ ជាអ្នកស្នើសុំឱ្យមានការរៀបការ ។[1302] ទោះជាយ៉ាងណាថ្នាក់ឃុំមិនមានសិទ្ធិ ធ្វើការសម្រេចឱ្យមានការរៀបការទេ ប៉ុន្តែ ឃុំជាអ្នកស្នើទៅស្រុកហើយស្រុកស្នើសុំបន្តទៅតំបន់ដើម្បីសម្រេច ដោយត្រូវការរយៈពេលចន្លោះពីមួយទៅបីខែ ។[1303] នៅតំបន់ ៤១ សាក្សីម្នាក់និយាយថា **តា អាន** ឱ្យសិទ្ធិទៅថ្នាក់ស្រុកជាអ្នករៀបចំដោយខ្លួនឯង ។ **តា អាន** តែងតែសប្បាយចិត្តក្នុងការឯកភាព និង អនុញ្ញាតឱ្យរៀបការ។[1304]

៤០៣ កន្លងមក មានការលើកឡើងដែរថា ប្រាក់ យុត បានផ្ញើសំបុត្រទៅការដ្ឋានការងារ អំពីឈ្មោះបុរសនារីដែលត្រូវរៀបការ ។[1305] ក្រោយពីបានទទួលដំណឹងមួយសប្តាហ៍ក្រោយពិធីរៀបការត្រូវបានគេរៀបចំ ។[1306] ពេលរៀបការម្តងៗមានបុរសនារីជាច្រើនគូត្រូវរៀបការក្រោមហេតុផលថា រៀបការមានកាន់តែច្រើនគូកាន់តែល្អ ។[1307]

៤០៤ មានការតាមដានដើម្បីដឹងថា តើមានគូណាខ្លះរស់នៅមិនចុះដំណេកគ្នា ជាពិសេសពេលយប់ ។[1308] ភាគច្រើនអ្នកដែលមកប្តឹងពីបញ្ហានេះជាបុរស ដោយប្រពន្ធពុំព្រមរួមដំណេក ។ បើដូច្នេះមែន មេភូមិត្រូវហៅប្តីប្រពន្ធនោះទៅកសាង ហើយបើនៅតែមិនទាន់ចុះសម្រុងត្រូវទៅចំពោះមុខមេឃុំនឹងប្រឈមការបង្អត់អាហារ ឬយកទៅបាត់ខ្លួនរហូតតែម្តងក៏មាន។[1309] ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម ក៏ធ្លាប់បានប្រាប់សាក្សីថា **តា អាន** ជាអ្នកចេញបញ្ជាឱ្យអ្នកដែលរៀបការរួចហើយត្រូវតែរួមដំណេកជាមួយគ្នា ដើម្បីចម្រើនជាតិ ។[1310]

៤០៥ សាក្សីម្នាក់ឆ្លើយថា គាត់មិនដែលដឹងពីការបង្ខំឱ្យនារីរៀបការជាមួយយោធាទេ[1311] ខណៈសាក្សីម្នាក់ទៀតលើកឡើងថា នៅក្នុងកិច្ចប្រជុំគេបាននិយាយ ទាក់ទិននឹងអតីតយោធាជាជនពិការ មានសិទ្ធិអាទិភាពជ្រើសរើសនារីដើម្បីរៀបការ ។[1312]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤០៦ ប្រជាជនដែលរស់នៅតាមកងចល័តនៅក្នុងស្រុកព្រៃឈរ អ្នកពេញវ័យគ្រប់ការ អង្គការនឹងរៀបចំចាត់ចែងចាប់ឱ្យរៀបការតែម្តង ។[1313] ខណៈទីកន្លែងរៀបការត្រូវគេធ្វើនៅស្នាក់ការឃុំក្រោមការរៀបចំរបស់គណៈឃុំ ។[1314] ការរៀបការដែលចាត់ចែងឡើងដោយអង្គការបែបនេះ ពុំមាននរណាហ៊ានប្រកែកទេពីព្រោះខ្លាចគេយកទៅសម្លាប់ ។[1315]

៤០៧ នៅស្រុកព្រៃឈរ ពេលអង្គការរៀបការឱ្យម្តងៗមានច្រើនគូ ពេលខ្លះមានប្រាំគូហើយពេលខ្លះដល់ដប់គូ ឬលើសពីនេះក៏មាន អាស្រ័យតាមចំនួនប្រជាជនត្រូវរៀបការតាមភូមិ ។[1316] សាក្សីមួយរូបបាននិយាយថា តាមខ្លួនដឹងមានការរៀបការដោយបង្ខំចំនួនពីរលើក ដោយលើកទីមួយមាន ៣២ (សាមសិបពីរ) គូ និងលើកទីពីរ ១៥ (ដប់ប្រាំ) គូ ។[1317]

៤០៨ ការរៀបការនៅស្រុកព្រៃឈរ បានកើតមានតាំងដើមដំបូងនៃរបបកម្ពុជាប្រជាធិបតេយ្យរហូតដល់ពេលដួលរលំរបប ។[1318] ការរៀបការឱ្យអតីតយុទ្ធជនពិការបានកើតមានទាំងមុននិងក្រោយការមកដល់របស់ក្រុមនិរតី ។[1319] សាក្សីឈ្មោះ អៀង ឆាំ បាននិយាយថា "*ក្នុងសម័យនោះការរៀបការ គេគ្រាន់តែហៅឱ្យមកជុំៗគ្នា ដោយមានប្រធានមន្ទីរម្នាក់ជាអ្នកឡើងមកសួរដោយនិយាយថា តើមិត្តព្រមតាមការចាប់គូរបស់អង្គការដែរទេ ? បើព្រមគេរៀបការឱ្យ*"។[1320] ទន្ទឹមនោះដែរសាក្សី អៀង ឆាំ បានបន្ថែមថា"*យើងក៏មិនហ៊ានប្រកែកតវ៉ាអីដែរ ។ ការរៀបការនោះគឺមិនមែនដោយស្ម័គ្រចិត្តទេ ជាការរៀបការដែលអង្គការរៀបឱ្យ*"។[1321]

## ១.១៦. អំពើប្រល័យពូជសាសន៍លើជនជាតិចាមនៅខេត្តកំពង់ចាម

៤០៩ ជនជាតិចាម ត្រូវបានជម្លៀសចេញពីភូមិដ្ឋានដែលធ្លាប់រស់ នៅដោយអង្គការបានបញ្ជូនឱ្យទៅរស់នៅតាមស្រុកមួយចំនួន ក្នុងខេត្តកំពង់ចាមរួមមានស្រុកចំការលើជាដើម ។[1322] ម្យ៉ាងវិញទៀត នាចុងឆ្នាំ១៩៧៨ មានការប្រជុំមួយដែលមានការចូលរួមពីថ្នាក់ឃុំ ស្រុក និងតំបន់ ហើយក៏មានវត្តមានរបស់ កែ ពក ដែរ ។ នាពេលនោះ កែ ពក បានសួរគាត់ថា តើផែនការបក្សត្រូវបានអនុវត្តបានប៉ុន្មានភាគរយហើយ ។[1323]

៤១០ សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម បានលើកឡើងថា *"ខ្ញុំទទួលបញ្ជាពី តា អាន ឱ្យប្រមូលជនជាតិចាម និង អតីតទាហាន លន់ នល់"* ។ [1324] ការចេញបញ្ជាពី **តា អាន** ធ្វើឡើងនាពេលប្រជុំប្រចាំខែ ។ **តា អាន** បានចេញបញ្ជាដូចគ្នាទៅកាន់គណៈស្រុកផ្សេងៗទៀត ។[1325]

៤១១ លើសពីនេះទៀត សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម ដដែលបានរៀបរាប់ថា *"ថ្ងៃមួយ តា **អាន** មកជួបខ្ញុំហើយខ្សឹបប្រាប់ខ្ញុំថា គណៈមជ្ឈិមចាប់ផ្ដើមចាប់ខ្លួនជនជាតិចាម ហើយគាត់បញ្ជាឱ្យខ្ញុំស្រង់ឈ្មោះជនជាតិចាមទាំងអស់ដែលនៅក្នុងស្រុកខ្ញុំ"* ។[1326] មិនតែប៉ុណ្ណោះសាក្សី ប្រាក់ យុត បាននិយាយបន្ថែមថា *"ខ្ញុំធ្លាប់ចូលប្រជុំនៅថ្នាក់តំបន់ដែលនៅក្នុងកិច្ចប្រជុំនោះមានការសម្រេចឱ្យចាប់ខ្លួនជនជាតិចាម"* ។[1327]

៤១២ សាក្សីជាអ្នកស្រុកកំពង់សៀមវិញបានឆ្លើយថា *"ខ្ញុំដឹងថាមេឃុំបានឱ្យមេភូមិសរសេរឈ្មោះប្រជាជនទាំងអស់នៅក្នុងភូមិចូលទៅក្នុងសៀវភៅចំនួនពីរក្បាល ។ ក្នុងសៀវភៅនោះមេភូមិត្រូវផ្ដល់ព័ត៌មានលម្អិតដូចជា ជាតិសាសន៍ និង ប្រវត្តិរូបរបស់អ្នកភូមិ ។ សៀវភៅមួយក្បាលទុកនៅភូមិ ហើយមួយក្បាលទៀតទុកនៅឃុំ ។ ខ្ញុំដឹងថាអ្នកដែលគេយកទៅនោះត្រូវបានគេកុហកថា ពួកគេត្រូវយកទៅឱ្យធ្វើការនៅសហដីពចំការកៅស៊ូ តាមពិតទៅពួកគាត់ត្រូវបានគេយកទៅសម្លាប់"* ។[1328] ការធ្វើបញ្ជីនេះ ជាបញ្ជាចេញពីថ្នាក់លើ ឱ្យមកមូលដ្ឋានដើម្បីធ្វើ ។[1329] សាក្សី ពៅ សារ៉ុម ជាអ្នកធ្លាប់ចូលរួមធ្វើបញ្ជីផ្ទាល់បានប្រាប់ថា *"គាត់បានបញ្ជាឱ្យធ្វើបញ្ជីលម្អិត អំពីចំនួនប្រជាជននៅក្នុងឃុំក្រឡាដូចជា ភេទប្រុស ភេទស្រី ក្មេង ចាស់ ជាតិសាសន៍ ប្រជាជនថ្មី ឬ ក៏អតីតទាហាន លន់ នល់"* ។[1330]

៤១៣ កន្លងមក មានការលើកឡើងដោយអតីតលេខាស្រុកកំពង់សៀមថា ខ្លួនក៏ធ្លាប់បានទទួលបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ខ្លួនពី **តា អាន** តែខ្លួនមិនដឹងអំពីតួនាទីនិងមុខតំណែងរបស់បុគ្គលទាំងអស់នោះទេ ដោយសារខ្លួនមិនចាប់អារម្មណ៍ ប៉ុន្តែ ខ្លួនគិតថាប្រហែលជាភូមិធ្វើបញ្ជីឈ្មោះទាំងអស់នេះមកឱ្យ **តា អាន** ហើយ **តា អាន** ផ្ញើបញ្ជីនោះឱ្យខ្លួន ព្រោះបញ្ជីឈ្មោះមនុស្សដែលត្រូវចាប់ទាំងអស់នេះ ស្ថិតនៅក្នុងស្រុករបស់ខ្លួន ។[1331] ស្របគ្នានេះ សាក្សីឈ្មោះ សុខ ហ៊ាន់ ជាអ្នករស់ក្នុងស្រុកកំពង់សៀមបានផ្ដល់សក្ខីកម្មដែរថា *"ជំទាវ ប៉ុល ពត ប្រធានឃុំដាក់បញ្ជាឱ្យសម្លាប់ចាម ។ អ្នកសម្លាប់ត្រូវបានគេបញ្ជូនពីឃុំ"* ។[1332]

01581433



៤១៤ ចំពោះជនជាតិចាមទាំងអស់ ដែលរស់នៅក្នុងស្រុកកំពង់សៀម ភាគច្រើនត្រូវបានគេចាប់ខ្លួននិងសម្លាប់នៅក្នុងស្រុកនេះតែម្តង ។ ធ្លាប់មានការលើកឡើងនូវករណីដែលថា ពុំមានជនជាតិចាមណាម្នាក់ត្រូវបានទុកជីវិតទេ លើកលែងតែឈ្មោះ ភា ដែលត្រូវបានអតីតលេខាស្រុកកំពង់សៀមឈ្មោះ យុត ការពារ ។[1333]

៤១៥ សាក្សីឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀម បាននិយាយដែរថា "*អ្នកស្រីបានទទួលបញ្ជាពី តា អាន ដើម្បីកំណត់អត្តសញ្ញាណស្វែងរក និង ចាប់ខ្លួនជនជាតិចាម ដែលរស់នៅក្នុងស្រុកកំពង់សៀម ដែលជាស្រុកមួយធំដោយមាន ១១ ឃុំ*" ។[1334] គាត់បានបន្ថែមថា "*ខ្ញុំបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីចាប់ខ្លួន និង សម្លាប់ជនជាតិចាមទាំងអស់ ។ បញ្ជាដែលខ្ញុំបានទទួលមានភាពច្បាស់លាស់ អំពីការសម្លាប់ជនជាតិចាមទាំងនោះ បន្ទាប់មកខ្ញុំបានបញ្ជូនបញ្ជានេះបន្តទៅថ្នាក់ឃុំ និងអនុរបស់ខ្ញុំនៅថ្នាក់ស្រុក ។ ខ្ញុំមិនដឹងថា ជនជាតិចាមទាំងអស់នោះ ត្រូវបានគេសម្លាប់ដោយរបៀបណា ឬ នៅកន្លែងណាឡើយ ។ នៅពេលដែលការសម្លាប់ជនជាតិចាមទាំងនោះត្រូវបានធ្វើរួចរាល់ ខ្ញុំបានទទួលរបាយការណ៍មួយពីអនុរបស់ខ្ញុំ ឬ មេឈ្លប អំពីចំនួនជនជាតិចាមដែលគេសម្លាប់ ហើយខ្ញុំក៏បញ្ជូនរបាយការណ៍នោះទៅឱ្យ តា អាន ដែលស្ថិតនៅថ្នាក់តំបន់*"។[1335] សាក្សីបានលើកឡើងទៀតថា "*ពេលអនុវត្តបញ្ជាចប់សព្វគ្រប់ហើយ មេឃុំទាំងអស់បានរាយការណ៍មកខ្ញុំផ្ទាល់ ។ ក្រោយមកខ្ញុំបានពិភាក្សាជាមួយ តា ស៊ី ហើយធ្វើរបាយការណ៍បញ្ជូនទៅ តា អាន នៅថ្នាក់តំបន់*" ។[1336]

៤១៦ ក្នុងរបាយការណ៍នោះ ក្នុងនាមជាលេខាស្រុកកំពង់សៀម ខ្ញុំបានផ្ញើទៅ តា អាន ដោយបានរៀបរាប់អំពីចំនួនឈ្មោះនិងមូលហេតុនៃការចាប់ខ្លួន ដាក់ឃុំឃាំង ដោះលែងនិងការសម្លាប់ ។[1337] ប៉ុន្តែ ជាក់ស្តែងសាក្សីដដែលនេះបានបញ្ជាក់បន្ថែមថា "*ខ្ញុំមិនដឹងថា តា អាន សម្រេចចេញបញ្ជានេះដោយចិត្តឯង ឬក៏ទទួលបញ្ជាពីថ្នាក់លើយ៉ាងណានោះទេ ។ ប៉ុន្តែ ខ្ញុំគិតថា គាត់មិនអាចចេញបញ្ជាដោយចិត្តឯងនោះទេ គឺគាត់ច្បាស់ជាទទួលបទបញ្ជាពីថ្នាក់លើ*"។[1338]

៤១៧ មានការលើកឡើងដែរថា ការសម្រេចចិត្តឱ្យសម្លាប់ជនជាតិចាមទាំងអស់នោះ គឺជាបញ្ជាដែលទទួលពីថ្នាក់លើ ក្នុងកម្រិតមួយដែលខ្ពស់ជាង តា អាន ទៅទៀត ។ តា អាន



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក៏ទទួលបញ្ជាពីលើផងដែរ ខ្ញុំមិនបានសួរ តា អាន ទេថាតើអ្នកណាជាអ្នកចេញបញ្ជាឱ្យសម្លាប់ជនជាតិចាមបែបនេះ ។[1339] ដូចនេះ ពាក់ព័ន្ធនឹងការសម្លាប់ជនជាតិចាមជាគឺ ជាបញ្ជារបស់ថ្នាក់លើ ដោយថ្នាក់ក្រោមត្រូវតែអនុវត្តតាម ។[1340]

៤១៨ ការចាប់ខ្លួនលើប្រជាជនចាម ត្រូវគេអនុវត្តរបៀបនេះជាហូរហែរ ប៉ុន្តែ នាចុងរបបមានគម្រោងចាប់ខ្លួនចាមជាបន្តទៀត ក្រោយការបញ្ជារបស់ថ្នាក់លើ ។ សាក្សីមួយរូបអះអាងថា *"ក្នុងការប្រជុំនោះ តា អាន ប្រាប់ថា ពួកយើងត្រូវចុះទៅតាមភូមិដោយផ្ទាល់ស្រង់ឈ្មោះនិងធ្វើបញ្ជីនោះ"*។[1341] ប៉ុន្តែ មិនទាន់បានរៀបចំបញ្ជីថ្មីគ្រប់គ្រាន់ផងស្រាប់តែ របបកម្ពុជាប្រជាធិបតេយ្យដួលរលំតែម្តង ។[1342]

## ២. ចំនួនជនរងគ្រោះ

៤១៩ ពាក់ព័ន្ធនឹងចំនួនជនរងគ្រោះ សហព្រះរាជអាជ្ញាអន្តរជាតិ (ស.ព.អ) បានអះអាងថាមានជនរងគ្រោះដែលបានស្លាប់ជាច្រើនរហូតដល់ ៤00.000 (សែសិបម៉ឺន) នាក់ នៅក្នុងភូមិភាគកណ្តាល ។ ចំណុចនេះប្រាកដជាការអះអាង ដែលអាចជំទាស់បានដោយហេតុថាចំនួននេះមិនត្រូវបានគាំទ្រដោយភ័ស្តុតាងឡើយ ។ ភ័ស្តុតាងដែលប្រមូលបានបង្ហាញថាចំនួនជនរងគ្រោះមានទាបជាងនេះឆ្ងាយណាស់ ដូចដែលយើងនឹងបង្ហាញខាងក្រោម ។ ជាបឋម លើបញ្ហានេះ ស.ព.អ មិនបានបែងចែកថា តំបន់ ៤១ ជនរងគ្រោះបានស្លាប់ ឬត្រូវបានសម្លាប់មានចំនួនប៉ុន្មានទេ ។

៤២០ លទ្ធផលនៃការស៊ើបសួរមិនបានបង្ហាញថា មានចំនួនជនរងគ្រោះបានស្លាប់ និងត្រូវបានសម្លាប់ជាក់លាក់ប៉ុន្មានឡើយ ។ តាមសក្ខីកម្មសាក្សីខ្លះ មានតួលេខជនរងគ្រោះអាចមានរាប់ពាន់នាក់ ឬ ប្រហែលមួយម៉ឺននាក់ នៅមន្ទីរសន្តិសុខវត្តបាធាយ និងរាប់ពាន់នាក់នៅមន្ទីរសន្តិសុខវត្តតាផ្លុង ។ បន្ថែមពីលើនេះ សាក្សីបានអះអាងថា នៅមន្ទីរសន្តិសុខវត្តអូរត្រកួនមានជនរងគ្រោះប្រមាណពី ២00-៣0.000 (ពីររយទៅបីម៉ឺន) នាក់ ។ ខណៈដែល ២.000 (ពីពាន់) នាក់ នៅមន្ទីរសន្តិសុខមិត្តសុប ១.000 (មួយពាន់) នាក់ នៅកន្លែងសម្លាប់មនុស្សគោកព្រីង ៣.៥00 (បីពាន់ប្រាំរយ) នាក់ នៅមន្ទីរសន្តិសុខវត្តស្រង៉ែ ៥.000 (ប្រាំពាន់) នាក់ នៅមន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក ១.000-១.៥00 (មួយពាន់ទៅមួយ



*E.C.C.C* C.E.T.C* INVESTIGATING JUDGES *CO-JUGES D'INSTRUCTION ១១៦

ពាន់ប្រាំរយ) នាក់ នៅការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំបន់អន្លង់ជ្រៃ និង ១.០០០-១០.០០០ (មួយពាន់ទៅមួយម៉ឺន) នាក់ នៅមន្ទីរសន្តិសុខចំការស្វាយចន្ទី ។ ទិន្នន័យទាំងនេះមិនអាចមានអ្វីមកបញ្ជាក់ឲ្យពិតប្រាកដបានទេ ។

## IV. ច្បាប់ជាធរមាន ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅ អ.វ.ត.ក

៤២១ ផ្អែកលើកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត "អ.វ.ត.ក" ជាអាទិ៍ មានការបញ្ជាក់យ៉ាងច្បាស់ថា អ.វ.ត.ក ត្រូវបានបង្កើតឡើងក្នុងគោលដៅដើម្បីកាត់សេចក្តីមេដឹកនាំជាន់ខ្ពស់កម្ពុជានៃរបបកម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរ ទៅលើច្បាប់ព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៥៦ និងការរំលោភទៅលើច្បាប់មនុស្សធម៌ និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងការរំលោភលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាបានទទួលស្គាល់ ហើយដែលអំពើនោះត្រូវបានប្រព្រឹត្តចន្លោះ ក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ ។

៤២២ មាត្រា ២ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក បានចែងថា "*ត្រូវបានបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញ នៅក្នុងរចនាសម្ព័ន្ធតុលាការដែលមានស្រាប់ពោលគឺ សាលាដំបូង និងតុលាការកំពូល ដើម្បីធ្វើការជំនុំជម្រះមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះបទឧក្រិដ្ឋកម្មនិងការរំលោភយ៉ាងធ្ងន់ធ្ងរទៅលើច្បាប់កម្ពុជាដែលពាក់ព័ន្ធនឹង អំពើឧក្រិដ្ឋ ការរំលោភទៅលើច្បាប់មនុស្សធម៌អន្តរជាតិ និងទម្លាប់អន្តរជាតិ និងការរំលោភទៅលើអនុសញ្ញាអន្តរជាតិ ដែលប្រទេសកម្ពុជាទទួលស្គាល់ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ១៧ មេសា ១៩៧៥ ដល់ថ្ងៃ៦ មករា ១៩៧៩ ។ មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះអំពើឧក្រិដ្ឋខាងលើនេះហៅថា ជនសង្ស័យ*" ។[1343]

៤២៣ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) បកស្រាយពាក្យថា 'មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និង ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" សំដៅលើជន ២ (ពីរ) ប្រភេទគឺ មេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ដែលស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួល

ខុសត្រូវខ្ពស់បំផុត និង ជនដែលមិនមែនជាមេដឹកនាំខ្មែរក្រហមជាន់ខ្ពស់ ប៉ុន្តែក៏ជាជនស្ថិតនៅក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ។ ជនទាំង ២ (ពីរ) ប្រភេទនេះត្រូវតែជាមន្ត្រីខ្មែរក្រហម និង ស្ថិតនៅក្នុងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ដើម្បីឲ្យតុលាការអនុវត្តយុត្តាធិការបុគ្គលឲ្យបានត្រឹមត្រូវ ។ ហេតុនេះលក្ខណៈវិនិច្ឆ័យទាំងនេះមានលក្ខណៈត្រួតលើគ្នាមិនមែនដាច់ដោយឡែកពីគ្នាទេ ។[1344]

៤២៤ មេដឹកនាំជាន់ខ្ពស់សំដៅលើមន្ត្រីជាន់ខ្ពស់ចូលរួមគ្នា ក្នុងការរៀបចំនូវគោលនយោបាយការអនុវត្តន៍ និងតាមដានមើលការអនុវត្តនយោបាយទាំងនោះ ។[1345] តាមឯកសារពិភាក្សាបង្កើត អ.វ.ត.ក មេដឹកនាំជាន់ខ្ពស់សំដៅដល់ សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និងគណៈកម្មាធិការមជ្ឈិមបក្សកម្ពុជាប្រជាធិបតេយ្យ ។[1346] លក្ខណៈវិនិច្ឆ័យដើម្បីសម្រេចថាបុគ្គលណាមួយជា ជនទទួលខុសត្រូវខ្ពស់បំផុតមានធាតុផ្សំសំខាន់ ២ (ពីរ) រួមមាន៖ (១)-ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ និង (២)-កម្រិតនៃការទទួលខុសត្រូវរបស់ជនត្រូវចោទ ។[1347]

៤២៥ ដើម្បីវាយតំលៃធាតុទីមួយ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្ដីរបស់ តុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានផ្អែកទៅលើកត្តានានាដូចជា (១)- ចំនួនជនរងគ្រោះ (២)- ដែនកំណត់ភូមិសាស្ត្រ និង ពេលវេលា ព្រមទាំងរបៀបនៃការប្រព្រឹត្ត និង (៣)- ចំនួននៃអង្គហេតុនីមួយៗ ដែលកើតមានឡើង ។[1348] ចំណែក ឯធាតុទីពីរ ក្រុមប្រឹក្សាកំណត់សមត្ថកិច្ចរឿងក្ដីរបស់ តុលាការព្រហ្មទណ្ឌសម្រាប់អតីតប្រទេសយូហ្គោស្លាវី បានផ្ដោតការពិចារណាជាមូលដ្ឋានទៅលើចំណុចដូចជា (ក)-កម្រិតនៃការចូលរួមក្នុងឧក្រិដ្ឋកម្ម (ខ)-ឋានានុក្រម ឬ មុខតំណែងរបស់ជនជាប់ចោទរួមបញ្ចូលទាំង (គ)-ចំនួននៃអ្នកនៅក្រោមបង្គាប់ និងថ្នាក់លើរបស់ជននោះ និងភាពអចិន្ត្រៃយ៍នៃមុខតំណែង ។[1349] ការពិចារណាដូចគ្នានេះ ត្រូវបានយកមកប្រើផងដែរដោយ អង្គបុរេជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។[1350]

៤២៦ អ.ជ.ត.ក បានប្រកាសដោយខ្លួនឯងស្ដីអំពីលក្ខណៈយុត្តិសាស្ត្រលើមាត្រា ១ នៃច្បាប់ស្ដីពីការបង្កើត អ.វ.ត.ក ។ ទាក់ទិនចំណុចនេះ អ.ជ.ត.ក បានសន្និដ្ឋានថា បញ្ហាតើជនជាប់ចោទ ជាកម្មាភិបាលខ្មែរក្រហម ឬ យ៉ាងណា *"ពាក់ព័ន្ធជាមួយនឹងបញ្ហាអង្គហេតុ*



* E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581437



*ប្រវត្តិសាស្ត្រ ដែលមានលក្ខណៈងាយយល់និងច្បាស់លាស់ ហើយផ្តល់ឆន្ទានុសិទ្ធិតិចតួច ឬ មិនបានផ្តល់ឆន្ទានុសិទ្ធិទាល់តែសោះ ដល់អង្គជំនុំជម្រះសាលាដំបូង"* ។ ហេតុនេះជាបញ្ហាដែលអាចវិនិច្ឆ័យបានដែលគ្របដណ្តប់ដោយយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ។[1351]

៤២៧ ផ្ទុយទៅវិញ ទាក់ទិនពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អ.ជ.ត.ក ក៏បានសន្និដ្ឋានដែរថា ប្រភេទទាំងពីរនេះពុំមែនជាលក្ខណៈវិនិច្ឆ័យផ្នែកយុត្តាធិការតាមន័យចង្អៀត *(stricto sensu)* ទេ ។ វាគ្រាន់តែពិពណ៌នាអំពីទម្រង់នៃគោលនយោបាយសម្រាប់ការចោទប្រកាន់ដោយ ស.ព និងការស៊ើបសួរដោយឯករាជ្យពី ក.ស.ច.ស ប៉ុណ្ណោះ ។ អង្គជំនុំជម្រះបានសន្និដ្ឋានថា ជាគោលការណ៍ប្រភេទទាំងពីរនេះ មិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារវាពុំអាចធ្វើការវិនិច្ឆ័យបាននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង (អ.ជ.ស.ដ) ឬ អ.ជ.ត.ក បានទេ ប្រសិនបើគ្មានការបំពានឆន្ទានុសិទ្ធិ ដោយពុំសុចរិត ឬ ការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈនោះឡើយ ។[1352]

៤២៨ កន្លងមក សំណុំរឿងលេខ០០១ និង សំណុំរឿងលេខ០០២ ទាំងសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេត អង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះតុលាការកំពូល មិនបានបង្ហាញជាក់លាក់ថា លក្ខណៈវិនិច្ឆ័យអ្វីនឹងត្រូវយកមកពិចារណា ក្នុងការកំណត់ថា ជនណាមួយជា មេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ឬ ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ។ ការសន្និដ្ឋានដែលអាចទទួលយកបានត្រឹមទំហំតែ មេដឹកនាំជាន់ខ្ពស់ អាចជាជនដែលទទួលខុសត្រូវខ្ពស់បំផុត ។ ប៉ុន្តែ ជនដែលទទួលខុសត្រូវខ្ពស់បំផុត អាចមិនមែនជាមេដឹកនាំជាន់ខ្ពស់ ។ ដូចនេះ វាមិនចាំបាច់បង្ហាញបន្ថែមថា បើជនណាមួយជាមេដឹកនាំជាន់ខ្ពស់រួចហើយ ពុំមានភាពចាំបាច់ក្នុងការបញ្ជាក់ថា ជននោះជាជនដែលទទួលខុសត្រូវខ្ពស់បំផុតទៀតទេ ។[1353]

៤២៩ បំណកស្រាយនេះ បង្ហាញឲ្យឃើញថា ស.ច.ស មានឆន្ទានុសិទ្ធិពេញលេញក្នុងការពិចារណានិងសម្រេចថា បុគ្គលណាមួយជា មេដឹកនាំជាន់ខ្ពស់ ឬ ជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត ដោយផ្អែកលើសម្អាងហេតុសមស្រប តាមបរិបទច្បាប់នៅ អ.វ.ត.ក ។ មានន័យថា លក្ខណៈវិនិច្ឆ័យអ្វី ? ឬផ្អែកលើកត្តាអ្វីខ្លះ? សម្រាប់យកមកពិចារ-



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581438



ណាជាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេត ។ ហេតុដូចនេះ ជាបឋមការកំណត់ថាជនណាមួយជាមេដឹកនាំជាន់ខ្ពស់ ឬ ជាបុគ្គលទទួលខុសត្រូវខ្ពស់បំផុត ជាឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតក៏ពិតមែន ប៉ុន្តែ សម្រាប់ទឡ្ហីករណ៍គតិយុត្តទាំងនោះ ត្រូវស្របតាមគោលការណ៍ ស្តីពីការបកស្រាយច្បាប់ក្នុងរឿងព្រហ្មទណ្ឌត្រូវមានលក្ខណៈតឹងរ៉ឹង[1354] ដោយធ្វើការពិចារណាឱ្យប្រយោជន៍ដល់ជនជាប់ចោទ ល្មឹកណាពន្លកនៃវិមតិសង្ស័យកំពុងកើតមាន ក្នុងបញ្ហាយុត្តាធិការនេះ[1355] ។ ទោះបីជាយ៉ាងណា ការបកស្រាយទាំងឡាយនោះគួរធ្វើឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងយុត្តិសាស្ត្រដែលមានពីមុន (*Uniformity of Jurisprudence*) និង អនុលោមតាមបរិបទនៃខ្លឹមសារច្បាប់ ដែលបានកំពុងអនុវត្តនៅកម្ពុជាផងដែរ ។

៤៣០ លក្ខណៈវិនិច្ឆ័យសំខាន់បែបនេះ មិនអាចបកស្រាយដោយពុំបានពិចារណាទៅដល់ចំណុចជាមូលដ្ឋាននានាបានទេ ទោះបីវាមានលក្ខណៈផ្លូវច្បាប់ជាក់លាក់បែបណាក៏ដោយ ។ តាមពិត ការលើកឡើងពីការបំពានឆន្ទានុសិទ្ធិ ដោយផ្អែកលើភាពពុំសុចរិត ឬ ការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ ជាការសន្មតជាមុនថា មានរង្វាស់ដែលអាចវាស់វែងនិងត្រូវតែវាស់វែងដល់ការអនុវត្តន៍ឆន្ទានុសិទ្ធិ ពោលគឺអ្វីដែលបង្កើតជាព្រំដែននៃសុចរិតភាព និង ការវិនិច្ឆ័យត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ មុនពេលសេចក្តីសម្រេចស្ថិតក្នុងសភាពមិនត្រឹមត្រូវ ។ អ.ជ.ត.ក មិនបានគិតថា វិធីសាស្ត្រជ្រើសរើសដោយ ក.ស.ព ឬ ក.ស.ច.ស គ្មានការកម្រិតទាំងស្រុងនោះទេ ។

៤៣១ ជាគោលការណ៍ ស.ច.ស ក៏មិនយល់ស្របផងដែរទៅនឹងទឡ្ហីករណ៍ដែលថា ការប្រៀបធៀបទៅនឹងបុគ្គលផ្សេងទៀតជា ការមិនសមរម្យ ឬ ស័ក្តិសមនោះទេ ។[1356] ផ្ទុយពីសាវតារនេះវាក្លាយជាបញ្ហាបន្ទាប់បន្សំនៃពាក្យពេចន៍ថា តើគេហៅលក្ខណៈវិនិច្ឆ័យនោះជាល័ក្ខខ័ណ្ឌ តម្រូវផ្នែកយុត្តាធិការ ឬ ជាការណែនាំផ្នែកគោលនយោបាយ ។ ជាខ្លឹមសារវាមានសារៈសំខាន់ជាកម្រិតទូលំទូលាយ ប៉ុន្តែ មិនមែនមិនអាចធ្វើការវិនិច្ឆ័យបានទាំងស្រុងនៃការទទួលយកសម្រាប់ ក.ស.ព និង ក.ស.ច.ស នោះទេ ។

៤៣២ ស.ច.ស មិនយល់ស្របទៅនឹងការធ្វើចំណាត់ថ្នាក់របស់ អ.ជ.ត.ក អំពីយុត្តាធិការបុគ្គលថា លក្ខណៈវិនិច្ឆ័យមិនមែនយុត្តាធិការក៏ដោយ ប៉ុន្តែ ស.ច.ស យល់ថា ដោយសារមូលហេតុ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581439



នៃការគោរព តាមផ្លូវតុលាការចំពោះស្ថាប័នកំពូល ដែលពិនិត្យមើលបណ្តឹងសាទុក្ខ ស.ច.ស មានកាតព្វកិច្ចក្នុងការអនុវត្តន៍តាមខ្លឹមសារនៃយុត្តិសាស្ត្ររបស់ អ.ជ.ត.ក ។ ប៉ុន្តែ ស.ច.ស អាចយល់ផ្សេងបាន លុះត្រាតែ មានសំអាងហេតុពិសេស ក្នុងការមិនយល់ស្រប និង ប្រកាន់ជំហរជំទាស់ជាចំហរ ។

៤៣៣ ជាក់ស្តែង អ.ប.ជ ជាស្ថាប័នតែមួយគត់ ដែលទទួលពិនិត្យមើលបណ្តឹងឧទ្ធរណ៍ទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ហើយថា នៅក្នុងប្រព័ន្ធស៊ីវិលឡ (*Civil Law System*) ដូចនៅប្រទេសកម្ពុជា ពុំមានទ្រឹស្តីប្រកាន់តាមអ្វីដែលបានសម្រេចមក *(Stare Decisis)* ។ ទោះជាយ៉ាងណា ពាក់ព័ន្ធនឹងភាពច្បាស់លាស់ និងភាពដូចគ្នានៃច្បាប់នៅក្នុងបរិយាកាសផ្លូវច្បាប់ដែលស្រដៀងនឹង អ.វ.ត.ក វាជាការមិនអាចទទួលយកបានទេ ដែលតម្រូវឱ្យចៅក្រមថ្នាក់ក្រោមនៅក្នុងឋានានុក្រមតុលាការបដិសេធច្បាប់យុត្តិសាស្ត្ររបស់ អ.ជ.ត.ក លុះត្រាតែ មានការទទួលស្គាល់ថា មានសំអាងហេតុពិសេស ក្រៅពីទឡ្ហីករណ៍ដែលមានស្រាប់ ។

## ក. ជំហររបស់ អ.វ.ត.ក នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ៖ យុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និង យុត្តាធិការបទល្មើស

៤៣៤ ទោះជាយ៉ាងណាក្តី លក្ខណៈវិនិច្ឆ័យនៃយុត្តាធិការបុគ្គលនៅ អ.វ.ត.ក អាចបណ្តាលឱ្យមានការព្រួយបារម្ភធ្ងន់ធ្ងរមួយទៀតផ្នែកគោលនយោបាយ ដែលតម្រូវឱ្យមានការឆ្លើយតបនៅក្នុងបរិបទនេះ ដើម្បីកំណត់អំពីផលវិបាកនៃការសន្និដ្ឋានថា ពុំមានយុត្តាធិការបុគ្គល និងផលប៉ះពាល់អ្វីខ្លះ ដែលអាចកើតមាន ចំពោះការអនុវត្តន៍ឆន្ទានុសិទ្ធិនៃគោលនយោបាយរបស់ ស.ច.ស នៅពេលសម្រេចលើកលែងការចោទប្រកាន់ ក្នុងរឿងក្តីណាមួយដោយផ្អែកលើយុត្តាធិការបុគ្គលតែមួយ ។

៤៣៥ បញ្ហាដែលកំពុងពិភាក្សា ជាការមិនផ្តល់យុត្តាធិការជូនតុលាការធម្មតារបស់កម្ពុជា ទៅលើឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តដោយមនុស្សដែលស្ថិតក្នុងប្រភេទ "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះទេ ។ បន្ទាប់ពីបានពិនិត្យយ៉ាងល្អិតល្អន់ទៅលើប្រវត្តិនៃការចរចាមុនពេលបង្កើត អ.វ.ត.ក និងការប្រែប្រួល ចាប់តាំងពីពេលនោះមក ជាពិសេស

01581440



អ.ជ.ត.ក បានលើកឡើងកន្លងមក ស.ច.ស យល់ឃើញថា នាពេលបច្ចុប្បន្ននេះតុលាការកម្ពុជាផ្សេងទៀត ពុំមានយុត្តាធិការបុគ្គល ឬព្រឹត្តិការណ៍នានា ដែលស្ថិតនៅក្នុងយុត្តាធិការបុគ្គល យុត្តាធិការពេលវេលា និង យុត្តាធិការរឿងក្តីរបស់ អ.វ.ត.ក ទេ ។ ហេតុនេះអាចមានទឡ្ហីករណ៍ថា ស.ច.ស គួរទប់ទល់ទៅនឹងឥទ្ធិពលជាក់ស្តែងនៃទិដ្ឋភាពនេះ និងអនុវត្តឆន្ទានុសិទ្ធិយើងឲ្យបានទូលំទូលាយតាមតែអាចធ្វើទៅបាន ដើម្បីជាប្រយោជន៍នៃការសន្និដ្ឋាន អំពីយុត្តាធិការបុគ្គល ដើម្បីបញ្ចៀសនូវគម្លាតនៃនិទណ្ឌភាពដែលពុំសមរម្យ ។ ស.ច.ស ពុំយល់ស្របទៅនឹងការលើកឡើងខាងលើនេះទេ ដោយសារមានសំអាងហេតុផ្សេងដូចមានក្នុងបំណកស្រាយខាងក្រោមនេះ ។

៤៣៦ នៅពេលលើកឡើងអំពីគោលការណ៍ខាងលើ អ.ជ.ត.ក បានដឹងថា វាខុសពីយុត្តាធិការ (ដែលមានលក្ខណៈ)អន្តរជាតិនានា ដែលអង្គជំនុំជម្រះបានដកស្រង់ ក្នុងទឡ្ហីករណ៍ខ្លួនអំឡុងប្រវត្តិនៃការចរចា រវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាលើទម្រង់នៃច្បាប់ស្តីពីការបង្កើត "អ.វ.ត.ក" ហើយបានបង្ហាញថា ពុំមានការចរចាអំពីយុត្តាធិការសម្រាប់តុលាការកម្ពុជាធម្មតា ឬ ពីប្រព័ន្ធដែលមានលក្ខណៈអន្តរជាតិ ដែលដំណើរការនៅតុលាការផ្សេងទៀតនោះទេ ។ ជាឧទាហរណ៍៖ នៅបូស្នៀ កូសូវ៉ូ ឬ តុលាការយោធាក្រោយសង្គ្រាមលោកលើកទី ២ ចំពោះចារីនានាដែលនៅសេសសល់ ដែលស្ថិតនៅទាបជាងល័ក្ខខ័ណ្ឌនៃការទទួលខុសត្រូវដែលបានកំណត់សម្រាប់ អ.វ.ត.ក នោះឡើយ ។

៤៣៧ ជាការពិត អ.ជ.ត.ក បានទទួលស្គាល់យ៉ាងច្បាស់ អំពីជំហរពិសេសរបស់ អ.វ.ត.ក ដោយប្រៀបធៀបទៅនឹងតុលាការផ្សេង ។ ឧទាហរណ៍ តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) ដោយលើកឡើងថា "អ.វ.ត.ក មានអត្ថិភាពនៅក្នុងប្រព័ន្ធច្បាប់កម្ពុជាដែល អ.វ.ត.ក អនុវត្តនូវសមត្ថកិច្ចផ្តាច់មុខ ហើយពុំមានការបញ្ជូនរឿងក្តីណាមួយទៅតុលាការមួយផ្សេងទៀតឡើយ" ។[1357]

៤៣៨ ស្រដៀងគ្នាដែរនៅឆ្នាំ២០១១ អ.ប.ជ បានសម្រេចរួចហើយថា រាជរដ្ឋាភិបាលកម្ពុជាអាចប្រើប្រាស់តុលាការធម្មតារបស់ខ្លួនក្នុងការជំនុំជម្រះក្រុមខ្មែរក្រហម តែផ្ទុយទៅវិញរាជរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសការបង្កើត អ.វ.ត.ក៖"*... រដ្ឋាភិបាលកម្ពុជា ... មានសេរីភាព នៅក្នុងការចោទប្រកាន់បទល្មើសបែបនេះ ... នៅលើដែនដីដែលខ្លួនមានយុត្តាធិការ[illegible]*

01581441



*ទេ ...។ ទោះបីជាយ៉ាងនេះក្តី ជាជាងការប្រើប្រាស់វចនាសម្ព័ន្ធតុលាការរបស់ខ្លួនដែលមានស្រាប់រួចទៅហើយរដ្ឋាភិបាលកម្ពុជា ... បានព្រមព្រៀងជាមួយ អង្គការសហប្រជាជាតិ បង្កើត អ.វ.ត.ក ... ហើយបានផ្ទេរយុត្តាធិការទៅឱ្យ អ.វ.ត.ក ធ្វើការជំនុំជម្រះលើរឿងក្តីទាំងនេះ*"។[1358]

៤៣៩ អង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មិនបានព្យាយាមកំណត់ឱ្យមានការស៊ើបអង្កេត និងការជំនុំជម្រះទៅលើបុគ្គល ដែលមិនស្ថិតក្នុងល័ក្ខខ័ណ្ឌនៃយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ទេ ដោយសារបុគ្គលនោះមិនស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ។ គេផ្តល់មូលហេតុដែលនាំឱ្យមានការធ្វើសមាហរណកម្ម ក្រុមខ្មែរក្រហមចូលមកក្នុងសង្គម ជាមូលហេតុសំខាន់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងគោលបំណងថែរក្សាសន្តិភាពនិងការផ្សះផ្សាជាតិ ។[1359] ចំពោះ "គម្លាតនៃនិទណ្ឌភាព" និងទំនាក់ទំនងដែលទាក់ទិនគោលនយោបាយការធ្វើសមាហរណកម្ម ត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយ ។ ឧទាហរណ៍ នៅដើមឆ្នាំ២០០៨ អតីតប្រធានអង្គភាពគាំពារការការពារក្តី Rupert Skilbeck យល់ថា មានភាពខុសប្រក្រតី បើប្រៀបធៀបទៅនឹងតុលាការផ្សេងទៀត ។[1360]

៤៤០ ជាពិសេស អ.វ.ត.ក ខុសពីតុលាការ ឬសាលាក្តីផ្សេងទៀត ដែលត្រូវបានបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិ ឬជាតុលាការ(ជាតិ)ចម្រុះ[1361] កិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ពុំមានខចែងអំពីគោលការណ៍ គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ *(ne bis in idem)* តាមខ្សែបណ្តោយ ឬ ប្រការឧត្តមានុភាព *(primacy clause)* ពោលគឺ បញ្ញត្តិមួយដែលគ្រប់គ្រងទំនាក់ទំនងរវាង ការស៊ើបសួរ ការជំនុំជម្រះ និងសេចក្តីសម្រេចនៅថ្នាក់ជាតិ ក្នុងតុលាការធម្មតា ជាមួយការស៊ើបសួរ ការជំនុំជម្រះ និងសេចក្តីសម្រេចនៅកម្រិតតុលាការពិសេស ។ ហេតុនេះច្បាប់ជាធរមាននៅ អ.វ.ត.ក មិនបានប្រមើលមើលជាមុននូវស្ថានភាពមួយ ដែលអាចមានទំនាស់ផ្នែកយុត្តាធិការ ដែលតម្រូវឱ្យមានបញ្ញត្តិបែបនេះទេ ។

៤៤១ ហេតុនេះជាឧទាហរណ៍ ការប្រៀបធៀបដោយមិនត្រឹមត្រូវទៅនឹងច្បាប់យុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ច *(referral bench)* នៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) អនុលោមតាមវិធាន ១១ ស្ទួន នៃវិធានស្តីពីនីតិវិធី និងភស្តុតាង ដើម្បី



E.C.C.C. * C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581442



វាស់ស្ទង់នូវកម្រិតធ្ងន់ធ្ងរ និងការទទួលខុសត្រូវ ពុំមានប្រយោជន៍ទេ ដោយសារបរិបទនៃការចរចានៅក្នុងករណី អ.វ.ត.ក មានភាពខុសគ្នាទាំងស្រុង ។ បណ្ដាអ្នកតាក់តែងច្បាប់ចង់កំហិតយុត្តាធិការបុគ្គល ចំពោះអ្នកដែលមានការទទួលខុសត្រូវខ្ពស់ជាងគេបំផុត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៤៤២ ឧទាហរណ៍ ដែលបានដឹងយ៉ាងច្បាស់ពីចំនួនសរុបនៃការស្លាប់ ដែលត្រូវបានប៉ាន់ស្មានក្នុងកម្រិតទាបចំនួន ១.៧០០.០០០ (មួយលានប្រាំពីរសែន)[1362] នាក់ នៅពេលនោះដែលជាថែដន្យមានចំនួនស្មើនឹងជម្លោះធំៗក្នុងសម័យទំនើបរួមគ្នា រួមទាំងស្ថានភាពទាំងអស់នៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC) មកដល់សព្វថ្ងៃ ។ នរណាៗក៏ដឹងដែរថាមានបុគ្គលអាចជាចារីក្នុងចំនួនដ៏ច្រើន[1363] ដែលម្នាក់ៗអាចទទួលខុសត្រូវ ក្នុងការស្លាប់មនុស្សរាប់រយឬរាប់ពាន់នាក់ ជាសេណារីយ៉ូដែល អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី (ICTY) បានច្រានចោលសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាផ្ទេរសមត្ថកិច្ច ។ ដោយសារ អង្គជំនុំជម្រះពិចារណា នៅក្នុងចំណោមបញ្ហាផ្សេងទៀតថា ជនល្មើសអាចមានការទទួលខុសត្រូវ ចំពោះការស្លាប់ជនរងគ្រោះចំនួន ១៤០ (មួយរយសែសិប) នាក់ ។[1364]

៤៤៣ វិសាលភាពដោយឡែកនៃការស្លាប់មនុស្ស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រវត្តិនៃការចរចាដែលកំណត់ដោយ អ.ជ.ត.ក[1365] ព្រមទាំងភស្តុតាងដែលបានមកពី ការស៊ើបសួរក្នុងសំណុំរឿងលេខ០០៤/២ តែមួយ មិនអាចប្រកាន់យកវិធីសាស្ត្រស្រដៀងគ្នាបានទេ ។ ដោយសារ ការវាស់វែងទៅតាមប្រភេទនៃចំនួនទាំងនេះ នឹងធ្វើឱ្យទាហានធម្មតាជាច្រើននាក់ ដែលបានសម្លាប់មនុស្សជាទ្រង់ទ្រាយធំជាប្រចាំ ក្នុងរយៈពេលជាយូរ ឬថ្នាក់លើរបស់ពួកគេដែលបានបញ្ជាពួកគេ ក្លាយជាបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុត ដែលអាចនាំឱ្យមានការស៊ើបសួរថ្មីៗជាច្រើនទៀតទៅតាមវិធាន ៥៥ (៤) នៃវិធានផ្ទៃក្នុង ។ ប្រការនោះច្បាស់ជាពុំមែនជាអ្វីដែលអ្នកតាក់តែងច្បាប់គ្រប់គ្រង អ.វ.ត.ក បានប្រមើលមើលនោះទេ តែពួកគេបានដឹងថា នៅមានចារីប្រភេទនេះជាច្រើនសន្ធឹកសន្ធាប់ទៀត ហើយពួកគេនឹងមិនត្រូវបាននាំមកកាត់ទោសទេ ។



E.C.C.C * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៤៤ ជាឧទាហរណ៍បើតាមក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ មានចែងអំពីបទឧក្រិដ្ឋប្រល័យពូជសាសន៍ បទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទឧក្រិដ្ឋកម្មសង្គ្រាម ចាប់ពីមាត្រា ១៨៣ ដល់មាត្រា ១៩៨ និងបទប្បញ្ញត្តិទូទៅនៅក្នុងមាត្រា ៨ នៃក្រមព្រហ្មទណ្ឌចែងថា "*បទប្បញ្ញត្តិនៃក្រមនេះ ពុំអាចនាំឱ្យមានការបង្កើតនូវស្ថានភាពយុត្តិនិសេធ ចំពោះជនរងគ្រោះនៃបទល្មើសធ្ងន់ធ្ងរ ដែលកំណត់ដោយច្បាប់ដោយឡែក ទាក់ទងដល់ការរំលោភនីតិមនុស្សធម៌អន្តរជាតិ ទំនៀមទម្លាប់អន្តរជាតិ ឬ អនុសញ្ញាអន្តរជាតិ ដែលទទួលស្គាល់ដោយព្រះរាជាណាចក្រកម្ពុជាឡើយ*" ។ ដូចនេះ មិនអនុញ្ញាតឱ្យមានការសន្និដ្ឋានដែលថាមានយុត្តាធិការសម្រាប់តុលាការសាមញ្ញធម្មតាទេ ការយោងខាងលើសំដៅដល់ច្បាប់ អ.វ.ត.ក ពុំសំដៅដល់ច្បាប់នានាដែលផ្តល់អំណាចបែបប្រតិសកម្មដល់តុលាការធម្មតាឡើយ ។

៤៤៥ មាត្រា ៣ និងមាត្រា ១០ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ រួមគ្នាមានចែងអំពីគោលការណ៍គ្មានបទល្មើសបើគ្មានច្បាប់ចែង *(Nullum crimen sine lege)* និង វិធាននៃច្បាប់ដាក់ទោសស្រាលជាងមុន *(lex mitior )*ពោលត្រូវយកច្បាប់ដែលមានលក្ខណៈបន្ធូរបន្ថយជាងគេមកអនុវត្ត ប្រសិនបើមានការកែប្រែច្បាប់នៅពេលប្រព្រឹត្តបទល្មើស និងពេលជំនុំជម្រះក្តី ។ ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ពុំមានចែងបទប្បញ្ញត្តិស្តីអំពីឧក្រិដ្ឋកម្មនានា ដែលបានលើកឡើងខាងលើទេ ដែលមានកំណត់ត្រឹមតែបទល្មើសថ្នាក់ជាតិ ។

៤៤៦ ជាក់ស្តែង ពុំមានភាពច្បាស់លាស់ផងដែរថា តើច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជានឹងអនុញ្ញាតឱ្យមានការអនុវត្តន៍ដោយផ្ទាល់ ចំពោះបទល្មើសនានាដែលត្រូវបានទទួលស្គាល់ទៅតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមិនស្ថិតក្នុងការទទួលខុសត្រូវនៃកិច្ចព្រមព្រៀងបង្កើត អ.វ.ត.ក និងច្បាប់ អ.វ.ត.ក ឬយ៉ាងណា ? ។ ដោយសារមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ ត្រឹមតែយោងដល់បទដ្ឋានសិទ្ធិមនុស្ស ដែលអាចអនុវត្តដោយផ្ទាល់តែប៉ុណ្ណោះ ។ ដូចដែល ស.ច.ស បានពន្យល់នៅក្នុងបរិបទផ្សេងថា ការរំលោភទៅលើបទដ្ឋានសិទ្ធិមនុស្សបែបនោះ ពុំចាំបាច់សុទ្ធតែបណ្តាលឱ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌទេ ។[1366]

៤៤៧ ជាសរុបមក យើងយល់ឃើញថា ប្រសិទ្ធភាពនៃច្បាប់ អ.វ.ត.ក ទៅលើយុត្តាធិការរបស់... មាន ២ (ពីរ) ទិដ្ឋភាពៈ ទី១. កំហិតនូវយុត្តាធិការបុគ្គលផ្ទាល់របស់ អ.វ.ត.ក ... ត្រឹមតែ



ECCC CETC CO-INVESTIGATING JUDGES CO-JUGES D'INSTRUCTION

01581444



ចំពោះអ្នកទទួលខុសត្រូវខ្ពស់បំផុត និង ទី២. មិនរាប់បញ្ចូលយុត្តាធិការបុគ្គល ឬយុត្តាធិការលើរឿងក្តីរបស់តុលាការកម្ពុជាធម្មតាទៅលើព្រឹត្តិការណ៍នានា ដែលស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ឡើយ ។

៤៤៨ សេចក្តីសន្និដ្ឋានបែបទ្រឹស្តីនេះ ត្រូវបានបញ្ជាក់ដោយអង្គហេតុជាក់ស្តែងដែលថា ពុំមានការស៊ើបសួរ ឬ ការជំនុំជម្រះទៅលើរឿងក្តីប្រភេទនេះ ចំពោះចារីថ្នាក់ក្រោមនៅចំពោះមុខតុលាការកម្ពុជាធម្មតា ក្រោយពេលបង្កើត អ.វ.ត.ក ទេ ។ បើទោះបីជា របបកម្ពុជាប្រជាធិបតេយ្យ បានបន្សល់ទុកការប៉ះទង្គិចផ្លូវចិត្តនៅក្នុងសង្គមកម្ពុជា ហើយមានបុគ្គលច្រើននាក់អាចជាចារី ដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរដោយផ្ទាល់ ឬ ក្នុងនាមជាថ្នាក់លើនៅរស់រានមានជីវិតក៏ដោយ ។

៤៤៩ ហេតុនេះមានគម្លាតនិទណ្ឌភាពជាខ្លាំង សម្រាប់ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ទោះជាយ៉ាងណា ការធ្វើសេចក្តីសន្និដ្ឋាននេះមិនត្រូវមានឥទ្ធិពលផ្នែកគោលនយោបាយមកលើការអនុវត្តឆន្ទានុសិទ្ធិរបស់ ស.ច.ស.ជ ពាក់ព័ន្ធទៅនឹងយុត្តាធិការបុគ្គលទេ ដោយសារយើងមានសំអាងហេតុនានាផ្សេងៗទៀត ។

## ខ. គោលការណ៍ច្បាប់ព្រហ្មទណ្ឌៈ ការបកស្រាយចង្អៀត យុត្តាធិការបែបជ្រើសរើស

៤៥០ ដើម្បីអនុវត្តឆន្ទានុសិទ្ធិ មានគោលការណ៍ការបកស្រាយតាមន័យចង្អៀតនៃច្បាប់ព្រហ្មទណ្ឌ ។ នៅក្នុងយុត្តាធិការមួយចំនួន គេអាចសម្រេចបានប្រសិទ្ធភាពដូចគ្នា តាមរយៈការអនុវត្តន៍ការបកស្រាយក្នុងន័យចង្អៀត ឧទាហរណ៍៖នៅក្នុងច្បាប់កម្ពុជា[1367] និង នៅតុលាការឧក្រិដ្ឋកម្មអន្តរជាតិ (ICC)[1368] ។ តាមវិធាន ២១ (១) នៃវិធានផ្ទៃក្នុងបានចែងថា "*ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា វិធានផ្ទៃក្នុង សេចក្តីណែនាំអនុវត្ត និង បទបញ្ជារដ្ឋបាលទាំងអស់ជាធរមាន ត្រូវតែបកស្រាយក្នុងន័យការពារជានិច្ចដល់ប្រយោជន៍របស់ជនសង្ស័យ ... ដើម្បីធានាអំពីសច្ចភាពផ្លូវច្បាប់ និងកិច្ចដំណើរការនីតិវិធីប្រកបដោយតម្លាភាពដោយគិតដល់លក្ខណៈពិសេស របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*" ។[1369]



*E.C.C.C* C.E.T.C* CO-JUGES D'INSTRUCTION * INVESTIGATING JUDGES

៤៥១ ការអនុវត្តន៍គោលការណ៍ការបកស្រាយក្នុងន័យចង្អៀត មានសារៈសំខាន់ជាងគេនៅក្នុងប្រព័ន្ធដែលច្បាប់មិនបានចែងពេញលេញ ហើយដែលនៅតែកើតមាននៅក្នុងបញ្ហាច្បាប់ព្រហ្មទណ្ឌ ។ ជាពិសេស ការបកស្រាយផ្សេងៗគ្នាទៅលើទស្សនៈច្បាប់ដូចគ្នាបេះបិទនៅ អ.វ.ត.ក និងតុលាការផ្សេងៗទៀត ។ លើសពីនេះ បញ្ហាយុត្តាធិការបុគ្គលតែម្តង[1370] ជាភស្តុតាងយ៉ាងច្បាស់ដែលបានឆ្លុះបញ្ចាំងលើបញ្ហានេះ[1371] ។ ករណីរបស់តុលាការពិសេសដែលមានយុត្តាធិការបុគ្គល យុត្តាធិការបទល្មើស និងយុត្តាធិការពេលវេលា ដែលចង្អៀតដោយផ្អែកលើការចរចាយ៉ាងតឹងតែងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិនៅក្នុងសេណារីយ៉ូអន្តរកាល ក្រោយពេលមានជម្លោះ ដែលបានចាប់ផ្តើមដំណើរការអស់រយៈកាលជាង ២០ (ម្ភៃ) ឆ្នាំ ក្រោយពេលមានព្រឹត្តិការណ៍ហើយនោះ ទើបការពិភាក្សាត្រូវបានលើកយកមក ជាឧទាហរណ៍ចម្បងមួយដែលចាំបាច់ តម្រូវឱ្យមានការកំហិតចំពោះការបកស្រាយតាមផ្លូវតុលាការ ។

៤៥២ នេះជាការពិត ជាពិសេសដោយសារមានសម្ពាធ ពីការរំពឹងរបស់សាធារណជន ពីសារព័ត៌មាន ដែលព្រួយបារម្ភជុំវិញទស្សនៈនិទណ្ឌភាព ចំពោះអំពើឃោរឃៅជាទ្រង់ទ្រាយធំជារបៀបវារៈនយោបាយ ព្រមទាំងការស្រាវជ្រាវផ្នែកប្រវត្តិសាស្ត្រទៅលើព្រឹត្តិការណ៍ជាមូលដ្ឋានកន្លងមក ។ ម្យ៉ាងវិញទៀត ជាញឹកញាប់នៅក្នុងសេណារីយ៉ូរបៀបនេះ ពិរុទ្ធភាពរបស់ជនសង្ស័យហាក់ដូចជា ហួសពីការពិភាក្សាដេញដោលតាំងពីដំបូង *(Ab initio)* ហើយកិច្ចដំណើរការនីតិវិធីតាមផ្លូវតុលាការ ពុំមែនគ្រាន់តែជាការយល់ស្របនិងការបញ្ជាក់ជាផ្លូវការដែលមានបោះត្រា ចំពោះទស្សនៈទូទៅផ្នែកប្រវត្តិសាស្ត្រដែលមានស្រាប់ប៉ុណ្ណោះទេ ។

៤៥៣ ទោះបីជាយ៉ាងណា វាជាការសមស្របដែលត្រូវរំឭកឡើងវិញ នូវពាក្យពេចន៍របស់ Robert H. Jackson នៅសន្និសីទនៃសង្គមអាមេរិកកាំងនៃច្បាប់អន្តរជាតិកាលពីថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៤៥ ស្តីអំពីវិធីសាស្ត្រតុលាការដ៏ចម្រូងចម្រាស់ ក្នុងការដាក់ទោសលើឧក្រិដ្ឋជនសង្គ្រាមនៃរបបណាហ្ស៊ី (Nazi) មុនពេលចាប់ផ្តើម ការជំនុំជម្រះនៅនូរ៉ែមប៊ើក (Nuremberg)៖ *"នោះគឺជាហានិភ័យមួយ ក្នុងចំណោមហានិភ័យនានា ដែលត្រូវបានប្រថុយប្រថាន នៅពេលណាដែលការជំនុំជម្រះបានចាប់ផ្តើម ។ គោលការណ៍ចុងក្រោយគឺ*



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581446



*តុលាការមិនត្រូវយកបុគ្គលណាម្នាក់មកជំនុំជម្រះ ក្រោមទម្រង់នៃកិច្ចដំណើរការនីតិវិធីតុលាការ ប្រសិនបើតុលាការ មិនចង់មើលឃើញបុគ្គលរូបនោះមានសេរីភាព ក្នុងករណីរកមិនឃើញពិរុទ្ធភាព"* ។[1372]

៤៥៤ ការច្រានចោលការពិត ទោះវាមានន័យសាមញ្ញក៏ដោយ វាដូចនឹងការគាំទ្រលើសេចក្តីថ្លែងការណ៍ដ៏មិនសមរម្យរបស់ Benedict Carpzov តាំងពីឆ្នាំ១៦៥២ ថា៖ *"គេដឹងឮទូទៅថា នៅក្នុងរឿងក្តីជំនុំជម្រះលើបទល្មើសធ្ងន់ធ្ងរបំផុត ព្រំដែននៃច្បាប់អាចត្រូវបានច្រានចោលដោយសារលក្ខណៈព្រៃផ្សៃនៃឧក្រិដ្ឋកម្ម"* ។[1373]

៤៥៥ ជាក់ច្បាស់ណាស់ថា អ.វ.ត.ក ជាតុលាការមួយដែលស្វែងរកយុត្តិធម៌ តាមបែបជ្រើសរើសយោងតាមគោលបំណងនៃពាក្យពេចន៍ដែលបានចែង ពីព្រោះថាមានតែមនុស្សមួយក្រុមតូចតែប៉ុណ្ណោះ ដែលនឹងត្រូវយកមកចោទប្រកាន់នៅក្នុងតុលាការនេះ ចំពោះអំពើឃោរឃៅដែលបានប្រព្រឹត្តឡើង នៅក្នុងអំឡុងនៃរបបកម្ពុជាប្រជាធិបតេយ្យពោលគឺ អ្នកទាំងឡាយដែលស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការតែប៉ុណ្ណោះ ។ ពោលគឺសំដៅដល់តែអ្នកដឹកនាំនយោបាយ ដែលបង្កវិនាសកម្មដល់សង្គមកម្ពុជា គឺគ្មាននិទណ្ឌភាពសម្រាប់អ្នកទាំងនោះឡើយ ។

៤៥៦ ការចុះកិច្ចព្រមព្រៀង ដោយអវត្តមាននៃយុត្តាធិការនៅមានផ្សេងទៀត នៅក្នុងតុលាការជាតិកម្ពុជា ជាជម្រើសមនសិការនយោបាយនៅក្នុងអំឡុងពេលនៃការចរចា ដោយបានថ្លឹងថ្លែងលើការអំពាវនាវឱ្យមាន ការធ្វើសមាហរណកម្មក្រុមខ្មែរក្រហម ដែលនៅសេសសល់ឱ្យចូលមករួមរស់ក្នុងសង្គមជាតិ ជាមួយនឹងគោលបំណងចង់បាន និងបញ្ចប់តាមផ្លូវតុលាការ សម្រាប់ការឈឺចាប់ខ្លោចផ្សារបស់ជនរងគ្រោះ បើទោះបីជាពួកគេបានស្លាប់ ឬនៅរស់រានមានជីវិតនៅឡើយ ព្រមទាំងសម្រាប់គ្រួសារ និងសង្គមរបស់ពួកគេទាំងមូល ។

៤៥៧ នៅក្នុងន័យនេះ ក.ស.ព ខ្លួនឯងកាលពីថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ២០០៩[1374] និងកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤[1375] ជាថ្មីម្តងទៀតបានចង្អុលបញ្ជាក់ជាសាធារណៈរួចហើយថា ស.ព ពុំចាំបាច់ផ្តួចផ្តើមឱ្យមានការស៊ើបអង្កេតបន្ថែមទៀត ក្រោយសំណុំរឿងលេខ០០៣ និងសំណុំរឿងលេខ០០៤ នោះទេ ។ អនុលោមតាមច្បាប់ ទោះបីជាគ្មានជនល្មើសណាម្នាក់ត្រូវរួចពី



ECCC * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581447



អះអាងថា ពួកគេទទួលរងនូវការប្រព្រឹត្តិដោយអយុត្តិធម៌ ពីព្រោះមានបុគ្គលជាច្រើនទៀត ពុំត្រូវបានចោទប្រកាន់ដែលបុគ្គលទាំងនោះ អាចមានការទទួលខុសត្រូវ ដូចពួកគេក៏ដោយ ដរាបណា ពួកគេទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ការចោទប្រកាន់តាមបែបជ្រើសរើស នៅក្នុងក្របខ័ណ្ឌយុត្តាធិការជ្រើសរើសបែបនេះ អាចបង្ហាញនូវភាពយុត្តិធម៌តាមផ្លូវសីលធម៌ ។[1376] ចំណុចនេះជួយលើកតម្កើងភាពចាំបាច់ ក្នុងការទទួលស្គាល់ថាការវាយតម្លៃដ៏ហ្មត់ចត់និងរឹងប៉ឹងមួយ លើភ័ស្តុតាងប្រឆាំងនឹងបុគ្គលមួយចំនួនតូចនោះ ដែលកំពុងត្រូវបានស៊ើបសួរគឺជាការចាំបាច់បំផុត ។

៤៥៨ យោងតាមទស្សនៈនៃគោលនយោបាយព្រហ្មទណ្ឌទូទៅ ជាការពិបាកឱ្យសាធារណជន និងជនរងគ្រោះទទួលយកបាន ក្នុងន័យនៃពាក្យពេចន៍ទូលាយជាងនេះ ។ ឧទាហរណ៍ សូម្បីទាហានដែលធ្លាប់បានសម្លាប់ក្មេងតូចៗដោយបោកនឹងគល់ឈើ[1377] ឬ ដែលបានប្រណាំងប្រជែងគ្នាថា តើនរណាអាចសម្លាប់មនុស្សបានច្រើនជាងគេ[1378] មិនគួរមិនយកមកប្រឈមនឹងការកាត់ទោសនោះទេ ។ ករណីនេះដូចគ្នា ចំពោះបុគ្គលដែលបានប្រព្រឹត្តអំពើឃោរឃៅសាហាវយង់ឃ្នងជាច្រើនទៀត ឧទាហរណ៍ដូចជា អំពើវះពោះជនរងគ្រោះនៅមុនពេលសម្លាប់ ពួកគេយកប្រមាត់ឬថ្លើម និងនៅក្នុងករណីខ្លះយកគ្រឿងក្នុងរបស់ជនរងគ្រោះនោះមកចម្អិនសម្រាប់ហូបទៀតផង។[1379] នៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌជាច្រើន ទង្វើបែបនេះនឹងនាំដល់ការដាក់ទោសអស់មួយជីវិត ដោយពុំមានការលើកលែងទោស ហើយនៅក្នុងប្រទេសខ្លះអាចមានទោសប្រហារជីវិត ចំពោះអំពើរបស់ជនល្មើសម្នាក់ៗនោះទៀតផង ។

៤៥៩ ដើម្បីបញ្ជាក់ឡើងវិញនូវសម្តីដែលបានលើកឡើងខាងលើ គេបានដឹងអំពីចន្លោះប្រហោងនេះ នៅក្នុងអំឡុងពេលចរចារវាងភាគីជាតិ និង ភាគីអន្តរជាតិ ។ វាក៏ជាលក្ខណៈទូទៅនៃប្រព័ន្ធយុត្តាធិការ ដែលមានលក្ខណៈអន្តរជាតិដែលបានបង្កើតឡើង ដើម្បីបញ្ចប់សេណារីយ៉ូក្រោយពីមានជម្លោះ ដោយដោះស្រាយតាមផ្លូវតុលាការ ។ វិធីសាស្ត្របែបជ្រើសរើសសម្រាប់យុត្តាធិការលើនិទណ្ឌភាព តាមរយៈការចរចាជាក់ស្តែង ចំពោះអតីតក្រុមខ្មែរក្រហមទាំងមូលនឹងទំនងជាពុំពេញចិត្ត និងអយុត្តិធម៌ចំពោះមនុស្សភាគច្រើន ។ ទោះបីជាយ៉ាងនេះក្តី ចៅក្រមនៅ អ.វ.ត.ក ត្រូវគោរពតាមសេចក្តីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ក្រោយទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយ ហើយម្យ៉ាងទៀតការងារនេះមិនត្រូវ និង មិនអាចប្រដូចនឹងសច្ចធារណ៍និរទោស ឬសច្ចធារណ៍ដោយស្វ័យប្រវត្តិនៃការ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION
១៣៥

ទទួលខុសត្រូវខ្ពស់ ចំពោះបុគ្គលដែលត្រូវបាននាំមកចំពោះមុខតុលាការ ដោយសារការចោទប្រកាន់របស់ ក.ស.ព នោះឡើយ ។

៤៦០ សច្ចធារណ៍បែបនេះ ប្រសិនបើសន្មតមែននោះ ត្រូវធ្វើឡើងក្នុងលក្ខណៈផ្សេងពីនេះ ។ ក្រោយរយៈពេលកន្លងហួសយូរមក ភ័ស្តុតាងសំខាន់ខ្លះតាមរយៈសាក្សី ឬប្រភពផ្សេងទៀតអាចធ្លាក់ដុនដាបដល់កម្រិតមួយ ដែលពិបាករកព័ត៌មានលម្អិតអាចទុកចិត្តបាន ហើយតាមពិតសាក្សីអាចពិបាកនឹងមកផ្តល់សក្ខីកម្ម ។ ករណីនេះគឺពុំមែនការងារដែលត្រូវទម្លាក់ការទទួលខុសត្រូវលើភាគីណាមួយ ឬ នាំឲ្យក្លាយជាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងក្នុងកម្រិតទាបសម្រាប់ការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះ ឬ ការផ្តន្ទាទោសនោះឡើយ ។ ប៉ុន្តែផ្អែកលើហេតុផលនៃភ័ស្តុតាង និង ការបកស្រាយច្បាប់នៅក្នុងឋានានុក្រមតុលាការនៅ អ.វ.ត.ក គ្រប់ជាន់ថ្នាក់ ដោយត្រូវគិតចាប់ផ្តើមពីការិយាល័យសហចៅក្រមស៊ើបអង្កេតឡើងទៅ ។

## គ. លក្ខណៈវិនិច្ឆ័យក្នុងការអនុវត្តន៍ឆន្ទានុសិទ្ធិៈ ការធ្វើសេចក្តីសម្រេចនៅក្នុងរចនាសម្ព័ន្ធនៃរបបកម្ពុជាប្រជាធិបតេយ្យ

៤៦១ សហចៅក្រមស៊ើបអង្កេតជាតិ បានកត់សម្គាល់ឃើញថា នៅពេលប្រើប្រាស់និយមន័យដែលបានកំណត់នៅក្នុងសាលដីកានៃសំណុំរឿងលេខ០០១ អ.ជ.ត.ក ក៏បានសម្រេចដោយប្រយោលថា វាពុំមានប្រយោជន៍អ្វីត្រូវអះអាងក្នុងន័យប្រវត្តិសាស្ត្រ និងនយោបាយដែលថា ការចរចាជុំវិញការបង្កើត អ.វ.ត.ក នាំឲ្យមានការយល់ឃើញតាមផ្លូវច្បាប់ជារួមថា មានតែបុគ្គល(មានឈ្មោះ)មួយចំនួនប៉ុណ្ណោះ ដែលត្រូវស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ ពោលគឺការជ្រើសយកបុគ្គលមួយចំនួនមកធ្វើការស៊ើបអង្កេត និងចោទប្រកាន់បញ្ជូនទៅជំនុំជម្រះកន្លងមក និងបច្ចុប្បន្នជាបញ្ហាឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ក.ស.ច.ស ហើយបានផ្អែកសុទ្ធសាធលើអង្គហេតុនៃរឿងក្តីនីមួយៗ ។

៤៦២ តាមទ្រឹស្តីមេដឹកនាំជាន់ខ្ពស់ ដែលពុំបានចូលរួមអ្វីជាធំដុំនៅក្នុងសកម្មភាពល្មើស ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ អាចស្ថិតនៅក្រៅក្របខ័ណ្ឌនៃយុត្តាធិការរបស់តុលាការថា ពុំមែនជាអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ។ ផ្ទុយមកវិញ បុគ្គលណាម្នាក់ដែល



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ស្ថិតនៅក្នុងឋានានុក្រមថ្នាក់ក្រោម អាចត្រូវបានចាត់ទុកជា អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត អាស្រ័យលើការចូលរួមចំណែកដោយឡែកៗរបស់បុគ្គលនោះ ចំពោះអំពើឃោរឃៅ ។ វិសាលភាពនៃសកម្មភាពផ្ទាល់របស់បុគ្គលម្នាក់ និង អានុភាពនៃអំពើទាំងនោះ គឺជាចំណុចត្រូវពិនិត្យមើលដ៏ត្រឹមត្រូវមួយ លើកលែងតែ ដូចអ្វីដែលត្រូវបានលើកឡើងខាងលើ អំពីផលប៉ះពាល់រួមនៃចំនួនជនរងគ្រោះ ។ ដូច្នេះ ការពិចារណាដែលត្រូវធ្វើឡើងលើបញ្ហាចោទ អំពីយុត្តាធិការបុគ្គលពុំមែនខុសគ្នាទាំងស្រុង នឹងការពិចារណាដែលយើងត្រូវគិតនៅពេលកំណត់ទោស ។

៤៦៣ ករណីនេះពុំគួរងាកចេញពីផលវិបាកជាក់ស្តែងដំបូង ដែលតួនាទីផ្លូវការដែលបុគ្គលម្នាក់មាននៅក្នុងឋានានុក្រមនោះទេ ។ ចំណុចពិចារណាមួយសំខាន់ ប៉ុន្តែពុំមែនសំខាន់ខ្លាំងដាច់ខាតនោះទេក្នុងការសម្រេចថា តើបុគ្គលណាស្ថិតនៅក្នុងចំណោមអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតគឺ កម្រិតដែលជនល្មើសអាចចូលរួមចំណែក ក្នុងការសម្រេចលើគោលនយោបាយ និង/ឬ ការអនុវត្តន៍គោលនយោបាយ ។

៤៦៤ ដូចការវិភាគយើងក្នុងភ័ស្តុតាងខាងក្រោម ការពិតទូទៅមួយទៀតដែលត្រូវចងចាំដក់ជាប់ក្នុងចិត្ត ។ បើទោះបីជា ការប្រជុំត្រូវបានធ្វើឡើងយ៉ាងទៀងទាត់ ក៏ការធ្វើសេចក្តីសម្រេចនៅក្នុងឋានានុក្រមខ្មែរក្រហម ពុំមែនធ្វើឡើងក្នុងដំណើរប្រជាធិបតេយ្យផ្លូវការមួយ ដែលអាចឱ្យមាន ការលើកយោបល់ដោយសមភាព នៅចំពោះអ្នកមុខអ្នកការនៅគ្រប់ថ្នាក់ ហើយនាំឱ្យមានការពិភាក្សាគ្នារកច្រកចេញនោះទេ ។ សេចក្តីសម្រេចត្រូវបានធ្វើឡើងនៅថ្នាក់កំពូល និងបន្ទាប់មកត្រូវបានអនុវត្តដោយថ្នាក់ក្រោមៗ ដោយមិនខ្វល់ពីផលវិបាកក្នុងលក្ខណៈបុគ្គលទោះនៅថ្នាក់ណាក៏ដោយ ប៉ុន្តែ ផលវិបាកកើតមានកាន់តែច្រើននៅថ្នាក់ក្រោម តាមរយៈខ្សែសង្វាក់នៃការបញ្ជាដែលអាចមើលឃើញ ប្រសិនបើបញ្ជាទាំងនោះពុំត្រូវបានគោរពតាម ។ ករណីនេះ មិនផ្ទុយពីការពិតដែលថា ជារឿយៗគោលនយោបាយត្រូវបានសរសេរ ក្នុងន័យទូទៅដោយថ្នាក់លើហើយកម្មាភិបាលថ្នាក់ក្រោមៗ ត្រូវបានផ្តល់លទ្ធភាពស្វែងយល់លម្អិត ក្នុងពេលអនុវត្តគោលនយោបាយទាំងនោះ ក៏គោលនយោបាយនោះមានអត្ថន័យច្បាស់លាស់ពីការបោសសម្អាត ការកម្ទេច ជាអាទិ៍ ។

៤៦៥ ការលំបាកកាន់តែខ្លាំង ក្នុងការរក្សារចនាសម្ព័ន្ធនៃអង្គការលេខ រហូតដល់ចុងបញ្ចប់នៃរបបកម្ពុជាប្រជាធិបតេយ្យ មិនបានបង្ហាញអ្វីផ្សេងពីការអះអាងខាងលើទេ ។ ករណីបុគ្គលម្នាក់បានបង្កើត ឬត្រូវបង្កើតគំនិតផ្តួចផ្តើមរបស់ខ្លួន នៅក្នុងកាលៈទេសៈទាំងនេះឬក៏យ៉ាងណានោះគឺ ពុំមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចនឹងឱ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ ។ អង្គហេតុនៅតែបង្ហាញថា ទោះក្នុងពេលណាៗក៏ដោយ ការកំណត់ន័យលើខ្លឹមសារនៃគោលនយោបាយ និងមធ្យោបាយអនុវត្តគោលនយោបាយស្ថិតនៅលើថ្នាក់កំពូលដែលអាចជ្រៀតជ្រែកតាមចិត្តចង់របស់ពួកគេ ។

៤៦៦ ករណីនេះរួមផ្សំជាមួយនឹងការប្រើប្រាស់ទូលំទូលាយ នូវប្រព័ន្ធទំនាក់ទំនងខ្សែបណ្តោយនៅក្នុងខ្សែសង្វាក់នៃការបញ្ជា និង គោលការណ៍រក្សាការសម្ងាត់ជាប់មកជាមួយ ដែលជាទូទៅពុំអនុញ្ញាតឬយ៉ាងហោចណាស់ ពុំលើកទឹកចិត្តឬជួយសម្រួលដល់ការផ្លាស់ប្តូរព័ត៌មានយុទ្ធសាស្ត្រនិងប្រតិបត្តិ តាមលក្ខណៈសមភាពនៃខ្សែទទឹងនៅតាមថ្នាក់ក្រោមៗនៃការដឹកនាំថ្នាក់លើ ។ តាមពិតការណែនាំដែលបានពិភាក្សាគ្នាជាចំហរពី **"អង្គការ"** ឧទាហរណ៍ថារវាងមេបញ្ជាការវរៈសេនាធំ ឬ វរៈសេនាតូច អាចត្រូវបានពិចារណាដោយថ្នាក់លើថា ជាវិធីទាញយកអំណាចដោយថ្នាក់ក្រោម ហើយគ្មាននរណាម្នាក់អាចមានសុវត្ថិភាពទេ ដោយសារមានការសន្មតថា ការសន្ទនាបែបនោះនឹងត្រូវបានរាយការណ៍ នៅក្នុងក្រុមពាក់ព័ន្ធ ហើយដែលទទួលរងនូវផលប៉ះពាល់អវិជ្ជមានមកលើខ្លួន ។

## ឃ. សារសំខាន់នៃដំណើរការស្វែងរកយុត្តិធម៌

៤៦៧ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ បើទោះបីជាប្រព័ន្ធយុត្តិធម៌នៅប្រទេសកម្ពុជា មិនទាន់មានដំណើរការក្តី ដោយសារឆន្ទៈក្នុងការស្វែងរកការពិត និង យុត្តិធម៌សម្រាប់ជនរងគ្រោះរដ្ឋាភិបាលកម្ពុជាបានរៀបចំបង្កើតឱ្យមានតុលាការជាផ្លូវការមួយ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ក្រឹត្យច្បាប់លេខ០១ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ បានចែងអំពីយុត្តាធិការថា៖ *"ដើម្បីវិនិច្ឆ័យបទឧក្រិដ្ឋប្រល័យពូជសាសន៍របស់បន ប៉ុល ពត - អៀង សារី"*។[1380] មេដឹកនាំមាន អៀង សារី និង ប៉ុល ពត ត្រូវបានផ្តន្ទាទោសដោយកំបាំងមុខ ពីបទប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មមួយចំនួនទៀត ក្នុងខែសីហា ឆ្នាំ១៩៧៩ ។[1381]



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION*

៤៦៨ ក្នុងឆ្នាំ១៩៩៤ ក្រោយការបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ នាពេលនោះក្រុមអតីតកម្មាភិបាលនៃរបបកម្ពុជាប្រជាធិបតេយ្យមិនបានចូលរួម ហើយនៅតែបង្កសង្គ្រាមស៊ីវិលជាមួយគ្នានោះ រាជរដ្ឋាភិបាលក្នុងគោលបំណងចំបងនៃការផ្សះផ្សាជាតិ បញ្ចប់សង្គ្រាមដើម្បីស្វែងរកសុខសន្តិភាព បានអនុម័តនូវច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យ ឱ្យនៅក្រៅច្បាប់ ។[1382] ច្បាប់បានលើកលែងទោសដល់ក្រុមកម្មាភិបាល ដែលបានចុះចូលជាមួយរាជរដ្ឋាភិបាលក្នុងអំឡុងពេល ៦ (ប្រាំមួយ) ខែ ក្រោយច្បាប់នេះចូលជាធរមាន ។ ទោះបីជាយ៉ាងនេះក្តី ច្បាប់នោះក៏មិនបានអនុគ្រោះទោសដល់ មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យទេ ហើយបទល្មើសដែលត្រូវបានលុបលាងនោះ គឺជាបទល្មើសចែងក្នុងច្បាប់ជាតិតែប៉ុណ្ណោះ ។ ជាក់ស្តែង មាត្រា ៦ នៃច្បាប់នេះបានបញ្ញត្តិយ៉ាងច្បាស់ថា "*ចំពោះមេដឹកនាំនៃក្រុមកម្ពុជាប្រជាធិបតេយ្យ មិនអាចមានការអនុគ្រោះ ដូចមានចែងក្នុងច្បាប់នេះឡើយ*" ។[1383] នេះបង្ហាញ អំពីចេតនារបស់រាជរដ្ឋាភិបាល ក្នុងការផ្សះផ្សាជាតិ និងស្របពេលគ្នានេះទុកច្រកសម្រាប់រកយុត្តិធម៌ជូនជនរងគ្រោះ តាមរយៈការមិនអនុគ្រោះដល់មេដឹកនាំនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលអាចជាមុខសញ្ញាដ៏ចង្អៀត សម្រាប់តុលាការដែលអាចនឹងត្រូវបានបង្កើតនាពេលខាងមុខ ។ មុខសញ្ញាអាចជាមេដឹកនាំកំពូលដែលមាន អៀង សារី ខៀវ សំផន ប៉ុល ពត ដែលពេលនោះគេដឹងឮជាទូទៅ ។

៤៦៩ នាខែកញ្ញា ឆ្នាំ១៩៩៦ ក្នុងគោលបំណងស្វែងរកសន្តិភាព ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានចេញព្រះរាជក្រឹត្យលើកលែងទោសប្រហារជីវិត តាមខ្លឹមសារនៃសាលក្រមកំបាំងមុខនៅឆ្នាំ១៩៧៩ និងទោសតាមបទល្មើស កំណត់ដោយច្បាប់ស្តីពីការដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៩៤ ដល់លោក អៀង សារី ។[1384] ឆន្ទៈនយោបាយក្នុងគោលបំណងផ្សះផ្សាជាតិ បញ្ចប់សង្គ្រាម បញ្ចប់ជម្លោះប្រដាប់អាវុធក្នុងឆ្នាំ១៩៩៨ នយោបាយរបស់រាជរដ្ឋាភិបាលដែលហៅថា "នយោបាយឈ្នះៗ" បាននាំឱ្យមានសមាហរណកម្មកងទ័ពខ្មែរក្រហមចូលទៅក្នុងកងទ័ពជាតិ ជាមួយការធានារក្សានូវកម្មសិទ្ធិ ការរស់នៅ និងមុខរបររបស់ពួកគេ ។

៤៧០ បន្ទាប់មកនាឆ្នាំ១៩៩៧ រាជរដ្ឋាភិបាលកម្ពុជាបានទាក់ទងជាមួយនឹងអង្គការសហប្រជាជាតិដើម្បីបង្កើតនូវតុលាការ ដើម្បីវិនិច្ឆ័យសេចក្តីជនទទួលខុសត្រូវលើបទឧក្រិដ្ឋ ដែលប្រព្រឹត្តឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។[1385] ជាក់ស្តែង ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គ



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ត្រូវបានអនុម័តក្នុងឆ្នាំ២០០១ មុននឹងកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យមានរូបរាងឡើងក្នុងខែមិថុនា ឆ្នាំ២០០៣ ។ កាលបរិច្ឆេទបានបង្ហាញនូវរយៈពេលជិត ១០ (ដប់) ឆ្នាំ ចាប់តាំងពីឆ្នាំ១៩៩៧ រហូតដល់ថ្ងៃដែល អ.វ.ត.ក បានចាប់ផ្តើមដំណើរពេញលេញក្នុងឆ្នាំ២០០៧ ក្រោយវិធានផ្ទៃក្នុងបានចូលជាធរមាន ។

៤៧១ ដំណើរនៃការចរចាបង្កើតកិច្ចព្រមព្រៀង ប្រកបដោយភាពប្រុងប្រយ័ត្ន ដើម្បីធានានូវការផ្សះផ្សាជាតិនិងការស្វែងរកយុត្តិធម៌ ឆ្លងកាត់នូវការពិភាក្សាយ៉ាងក្តៅគគុក លើខ្លឹមសារជាពិសេស បញ្ហាយុត្តាធិការឆ្លុះបញ្ចាំងនូវភាពជាម្ចាស់ និង អធិបតេយ្យភាពនៃកម្ពុជា ។ ខ្លឹមសារនៃបទប្បញ្ញត្តិមួយចំនួន ដែលបង្កប់នូវមន្ទិលអធម្មនុញ្ញភាពដូចជា ទោសប្រហារជីវិត បញ្ហាអាជ្ញាយុកាលនៃការចោទប្រកាន់ និងភាពប្រតិសកម្មនៃច្បាប់ ត្រូវបានស្នើដាក់ជូនក្រុមប្រឹក្សារដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិនិត្យមើលធម្មនុញ្ញភាពនៃច្បាប់ ។ ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញបានរកឃើញថា មាត្រាទាំងអស់នៃច្បាប់ស្តីពី អ.វ.ត.ក ស្របនឹងរដ្ឋធម្មនុញ្ញ លើកលែងតែ មាត្រា ៣ ដែលយោងដល់ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦ ដាក់ទោសប្រហារជីវិត ដែលនាំឲ្យផ្នែកនេះនៃមាត្រា ៣ មិនស្របនឹងរដ្ឋធម្មនុញ្ញ ។[1386] ជាលទ្ធផលមិនមានទោសប្រហារជីវិតសម្រាប់បទល្មើសទាំងនោះទេ ពីព្រោះបើមិនដូចនេះទេ វាផ្ទុយនឹងមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ដែលបានលុបចោលនូវទោសប្រហារជីវិត ។

៤៧២ ដំណាក់ដំបូងនៃការចរចារៀបចំកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក ពាក្យថា"**មេដឹកនាំ**" ត្រូវបានប្រើប្រាស់ ប៉ុន្តែក្រោយមកពាក្យនេះត្រូវបានដាក់ "**ជាន់ខ្ពស់**" ជាបន្ថែម ដើម្បីកម្រិតយកតែមេដឹកនាំមួយចំនួនតូចតែប៉ុណ្ណោះ ដែលត្រូវអាចចាត់ចូលក្នុងសមត្ថកិច្ច អ.វ.ត.ក ។ នេះសំដៅទៅលើតែ សមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស និង សមាជិកនៃគណៈកម្មាធិ-ការអចិន្ត្រៃយ៍បក្ស ។ ទោះបីមិនមានតារាងបញ្ជីឈ្មោះជនទាំងនោះ ប៉ុន្តែ ក្រុមការងារ ទំនងសំដៅជាសំខាន់លើមេដឹកនាំកំពូលដូចជា៖ ប៉ុល ពត, នួន ជា, ខៀវ សំផន, សុន សេន, អៀង សារី ឧបនាយករដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការបរទេស, កែ ពក, អៀង ធីរិទ្ធ អតីត



*E.C.C.C* C.E.T.C. CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581453



រដ្ឋមន្ត្រីសង្គមកិច្ច, វ៉ាន់ រិទ្ធ អតីតរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម, តា ម៉ុក ។[1387] ខណៈបុគ្គលទាំងនេះ ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍ និង/ឬ ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្ស ។[1388]

៤៧៣ អំឡុងពេលនៃការចរចា កាំង ហ្កេកអ៊ាវ ហៅ ឌុច ជាអតីតប្រធានមន្ទីរសន្តិសុខ ស-២១ ត្រូវបានរកឃើញថានៅរស់រានមានជីវិត ហើយក្រោយមក ត្រូវបានឃុំនៅមន្ទីរឃុំឃាំងតុលាការយោធា ។[1389] អាស្រ័យហេតុនេះ ពាក្យថា"**ជនដែលទទួលខុសត្រូវ**" ត្រូវបានដាក់បញ្ចូលនៅក្នុងខ្លឹមសារមាត្រា ២ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ។ បន្ទាប់ពីការពិភាក្សាយ៉ាងផុសផុលទាំងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា បានឯកភាពបន្ថែមនូវពាក្យ"**ខ្ពស់បំផុត**" ទៅលើកម្រងពាក្យ"**ជនដែលទទួលខុសត្រូវ**" ដែលមានស្រាប់ជាបន្ថែម ដោយមានកម្រងពាក្យពេញថា "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ។ ភាគីមានជំហរស្រដៀងគ្នា អំពីបុគ្គលដែលនឹងស្ថិតក្រោមយុត្តាធិការបុគ្គលនៃ អ.វ.ត.ក គឺមេដឹកនាំជាន់ខ្ពស់ និង ឌុច ជាកម្មាភិបាលម្នាក់ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត ។ ជារួមគេអាចនិយាយបានថា ពាក្យ "**ជនដែលទទួលខុសត្រូវខ្ពស់បំផុត**" ត្រូវបានដាក់បញ្ចូលសម្រាប់តែករណីពិសេសលើអតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច ។ មានន័យថា ប្រសិនបើអតីតប្រធានមន្ទីរសន្តិសុខ ស-២១ មិនត្រូវបានរកឃើញទេ ច្បាស់ណាស់ថាកម្រងពាក្យនេះនឹងមិនមានវត្តមានក្នុងច្បាប់ អ.វ.ត.ក ឡើយ ។

៤៧៤ ការដាក់បញ្ចូល ឌុច ក្នុងន័យថា ជនទទួលខុសត្រូវខ្ពស់បំផុតនេះជាបុគ្គលដែលដើរតួនាទីសំខាន់ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋ កៀកកិតនឹងការប្រព្រឹត្ត មានស្វ័យភាពក្នុងការងារនិងអំណាចតាមការអនុវត្តន៍ជាក់ស្តែង (*De Facto Authority*) ។ ខណៈដែលបុគ្គលទាំង ២ (ពីរ) ប្រភេទនេះត្រូវបានចាត់ចូលជា ជនក្នុងយុត្តាធិការរបស់ អ.វ.ត.ក ទាំងពាក្យថា "**ជាន់ខ្ពស់**" និង "**ខ្ពស់បំផុត**" សុទ្ធតែឆ្លុះបញ្ចាំងឲ្យឃើញថា មានចំនួនមេដឹកនាំតិចតួចបំផុត ដែលអាចស្ថិតក្នុងយុត្តាធិការនៃ អ.វ.ត.ក ។

៤៧៥ បញ្ហាយុត្តាធិការដ៏ចង្អៀតបែបនេះ ត្រូវបានលើកឡើងដោយតំណាងរាជរដ្ឋាភិបាលកម្ពុជានាពេលប្រជុំនៅរដ្ឋសភា ដើម្បីពិភាក្សានិងការអនុម័ត លើសេចក្តីព្រៀងច្បាប់ស្តីអំពីការបង្កើត អ.វ.ត.ក បង្ហាញក្នុងខ្លឹមសារដ៏ជាក់លាក់ថា *"ជនមុខសញ្ញាត្រូវតែមានចំនួនតិច ទីវ*



ECCC * CETC * INVESTIGATING JUDGES * JUGES D'INSTRUCTION

01581454



*មិនទូលំទូលាយ ដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះ"* ។[1390] ជំហរនេះបាន បង្ហាញជាដដែលៗបន្តបន្ទាប់មកទៀត ។[1391]

៤៧៦ ច្បាប់ស្តីពី អ.វ.ត.ក បានចែងនូវសំឡេង សម្រាប់អនុម័តសេចក្តីសម្រេច អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង អង្គជំនុំជម្រះតុលាការកំពូល និង អង្គស៊ើបអង្កេតមានការិយាល័យសហព្រះរាជអាជ្ញា និង ការិយាល័យសហចៅក្រមស៊ើបអង្កេត ដែលមន្ត្រីក្នុងអង្គនីមួយៗ ត្រូវធ្វើការងាររួមគ្នា ។ រាល់ការសម្រេចដែលចេញពីអង្គភាពទាំងនេះ សុទ្ធតែត្រូវទាមទារឱ្យមានការចូលរួមពីភាគីកម្ពុជាដោយខានតែបាន ។ អង្គជំនុំជម្រះសាលាដំបូង តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រម ៤ (បួន) រូបយ៉ាងតិចក្នុងចំណោមចៅក្រម ៥ (ប្រាំ) រូប ខណៈដែលអង្គជំនុំជម្រះតុលាការកំពូល តម្រូវឱ្យមានសំឡេងគាំទ្រពីចៅក្រម ៥ (ប្រាំ) រូបយ៉ាងតិចក្នុងចំណោមចៅក្រម ៧ (ប្រាំពីរ) រូប រីឯ អង្គបុរេជំនុំជម្រះតម្រូវឱ្យមានសំឡេងគាំទ្រដោយចៅក្រមយ៉ាងតិច ៤ (បួន) រូប ក្នុងចំណោមចៅក្រម ៥ (ប្រាំ) រូប ។[1392] នេះបង្ហាញពីប្រព័ន្ធនៃអង្គជំនុំជម្រះ ដែលមានចៅក្រមភាគីជាតិចូលរួមច្រើន ខុសពីតុលាការអន្តរជាតិផ្សេងទៀត ដូច្នេះជាប្រភេទថ្មីដែលមានឈ្មោះថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ។ [1393]

៤៧៧ ការចែងតម្រូវឱ្យមានដំណើរការងាររួមគ្នាជា "សហ" ក្រៅពីផ្តល់នូវភាពជាម្ចាស់ដោយប្រយោល យន្តការនេះផ្តល់លទ្ធភាពនូវការខ្វែងយោបល់រវាងចៅក្រមភាគីជាតិ ឬ អន្តរជាតិពាក់ព័ន្ធនឹងដំណើរការនៃកិច្ចនីតិវិធី ហើយដំណោះស្រាយអាចធ្វើឡើងតាមបណ្តឹងឧទ្ធរណ៍ទៅកាន់អង្គបុរេជំនុំជម្រះ ។ យោងតាមឯកសារនៃការចរចាបង្កើតឱ្យមានកិច្ចព្រមព្រៀង បញ្ហាខ្វែងយោបល់គ្នានេះ ត្រូវបានពិភាក្សាយ៉ាងផុសផុល ហើយយន្តការនៃដំណោះស្រាយតាមរយៈអង្គបុរេជំនុំជម្រះ ត្រូវបានអនុម័តយក ក្រោយមកជាមួយនឹងការព្រមព្រៀង តាមភាគីជាតិដែលស្នើឱ្យមានសំឡេងរបស់ចៅក្រមជាតិច្រើនជាង នៅក្នុងអង្គនីមួយៗដែលពីមុនត្រូវបានស្នើ ដាក់សំឡេងចៅក្រមអន្តរជាតិច្រើនជាង ។[1394] នេះបានបង្ហាញពីចេតនារបស់ភាគីជាតិជាអ្នកតាក់តែងច្បាប់ ។ ជារួម ប្រព័ន្ធនៃរបៀបរបបនីតិវិធីនៃការសម្រេចរបស់សហព្រះរាជអាជ្ញាក្តី សហចៅក្រមស៊ើបអង្កេតក្តី ចៅក្រមនៃអង្គជំនុំជម្រះក្តីជាទឡ្ហីករណ៍ផ្ទុះបញ្ចាំងដល់ការបកស្រាយ បញ្ហាច្បាប់ស្តីអំពីយុត្តាធិការនេះកាន់តែច្បាស់មិនអាចប្រកែកបានឡើយ ពីយុត្តាធិការចង្អៀត ធានាដល់ការផ្សះផ្សាជាតិ សុខសន្តិភាពនៃជាតិ



E.C.C.C * C.E.T.C * CO-JUGES D'INSTRUCTION * INVESTIGATING JUDGES

គោលបំណងនៃការបង្កើត អ.វ.ត.ក នេះ ។ ប្រព័ន្ធនៃដំណើរការនីតិវិធីនៅក្នុងកថាខណ្ឌទី ៤៧៦ នេះជាលក្ខណៈពិសេសដាច់ដោយឡែកខុសពីតុលាការផ្សេងទៀត ។

៤៧៨ ជាចុងក្រោយ ឆ្លើយតបនឹងបញ្ហាលើកលែងទោស ភាគីទាំងពីរបានឯកភាពបញ្ចូលមាត្រា ៤០ ថ្មី ដែលមានខ្លឹមសារទុកអំណាចឲ្យតុលាការ ជាអ្នកសម្រេចពាក់ព័ន្ធ ការលើកលែងទោសដែលត្រូវបានធ្វើកន្លងមក ។ មាត្រានេះបង្ហាញពីការគោរពដល់អង្គតុលាការ និងក៏អាចបង្ហាញពីចេតនាមិនឲ្យជនសង្ស័យ ដែលជាមេដឹកនាំជាន់ខ្ពស់ដូចជា អៀង សារី រួចខ្លួនពីការទទួលខុសត្រូវ ។ បន្ថែមពីលើនេះ វាក្នុងអត្ថន័យថា ការកាត់ទោសមេដឹកនាំកំពូលទាំងនេះ នឹងមិនរាលដាលដល់កម្មាភិបាលនៅថ្នាក់ក្រោមឡើយ ក្រៅពី ឌុច ដែលមានឈ្មោះក្នុងគំនិតនៃអ្នកធ្វើច្បាប់ ។

៤៧៩ ក្នុងខែមីនា ឆ្នាំ១៩៩៩ ក្នុងអំឡុងពេលនៃការចរចាបង្កើត អ.វ.ត.ក អ៊ុង ជឿន ហៅ តាម៉ុក ត្រូវបានចាប់ខ្លួនក្នុងខែមីនា ឆ្នាំ១៩៩៩ ទៅលើបទចោទថា បានប្រព្រឹត្តបទឧក្រិដ្ឋ (ប្រល័យពូជសាសន៍) ក្នុងតួនាទីជា *មេដឹកនាំខ្មែរក្រហម* [1395] ហើយ ឌុច ជាអតីត *មេគុកទួលស្លែង* ត្រូវបានចាប់ខ្លួនក្នុងខែឧសភា ឆ្នាំ១៩៩៩ ជាមួយបទចោទប្រឆាំងនឹងសន្តិសុខជាតិ និងបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ តាមច្បាប់ អ.វ.ត.ក ឆ្នាំ២០០១ ។[1396] ក្នុងពេលនោះដែរ ឆ្នាំ២០០៣ អតីតកម្មាភិបាលខ្មែរក្រហមមួយចំនួនមាន លោក ឈូក រីន ត្រូវបានកាត់ទោសដោយតុលាការជាតិពីបទភេរវកម្មសំលាប់ជនបរទេស ។[1397] ការកាត់ទោសនេះធ្វើឡើងអនុលោមតាមច្បាប់ជាតិ ចំពោះកម្មាភិបាលដែលបានប្រព្រឹត្តបទល្មើសក្រោយថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ។ នេះមិនបង្ហាញពីចេតនាចាកឆ្ងាយពីមុខសញ្ញាមេដឹកនាំជាន់ខ្ពស់តិចតួច ដែលនឹងត្រូវទទួលខុសត្រូវសម្រាប់បទឧក្រិដ្ឋកម្មអន្តរជាតិ ប្រព្រឹត្តក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។

៤៨០ នៅក្នុងដំណើរការនៃការរៀបចំការចរចាលើកិច្ចព្រមព្រៀងនេះ រាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សុទ្ធតែមានជំហរនិងឆន្ទៈដ៏ច្បាស់លាស់ ដោយសង្កត់ធ្ងន់និងផ្តល់តំលៃខ្ពស់បំផុតលើ ការរក្សាបាននូវសុខសន្តិភាព និងការផ្សះផ្សាជាតិ ដោយបានសំដែងនូវក្តីបារម្ភអំពីអសន្តិសុខដែលនឹងអាចកើតមានឡើងពីការចោទប្រកាន់ណាមួយ នៅក្នុងការដំណើរការ



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581456



របស់ អ.វ.ត.ក ដែលអាចនាំឲ្យប៉ះពាល់ដល់ការផ្សះផ្សាជាតិ ដែលទើបតែបានមកវិញទាំងលំបាក ។[1398]

៤៨១ អង្គការសហប្រជាជាតិ កន្លងមកបានអនុម័តសេចក្តីសម្រេចនាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៣ ដោយបានបង្ហាញទទួលនូវការទទួលស្គាល់ពីការបារម្ភរបស់ប្រជាជន និង រាជរដ្ឋាភិបាលកម្ពុជា ក្នុងដំណើរការស្វែងរកយុត្តិធម៌ ដែលអាចនាំឲ្យប៉ះពាល់ស្ថេរភាព ការបង្រួបបង្រួមជាតិ និងសុខសន្តិភាព ។[1399] ជាលទ្ធផល គោលបំណងពីរក្នុងន័យថ្លឹងថ្លែងគឺ "យុត្តិធម៌" និង "ការផ្សះផ្សាជាតិ" ត្រូវបានឯកភាពឲ្យសរសេរបញ្ចូលក្នុងកិច្ចព្រមព្រៀង ។[1400]

៤៨២ ក្នុងន័យនេះ គោលបំណងរបស់ អ.វ.ត.ក និងចេតនារបស់អ្នករៀបចំតាក់តែងកិច្ចព្រមព្រៀងស្តីពីការបង្កើត អ.វ.ត.ក មានន័យយ៉ាងច្បាស់ថា បុគ្គលដែលនឹងស្ថិតចូលក្នុងយុត្តាធិការរបស់ អ.វ.ត.ក ពិតជាមានចំនួនតិចតួចបំផុត ដោយសំដៅតែទៅលើមេដឹកនាំជាន់ខ្ពស់ដែលមានអំណាច និង ជនដែលទទួលខុសត្រូវខ្ពស់បំផុត ដែលបានចូលរួមយ៉ាងសកម្មក្នុងការប្រព្រឹត្តបទឧក្រិដ្ឋកម្ម និងកៀកជិតនឹងទង្វើប្រព្រឹត្ត តាមរយៈអំណាចនិងឥទ្ធិពលជាក់ស្តែងហួសពីអំណាចផ្លូវការដែលមាន ។

៤៨៣ ជនជាមុខសញ្ញាទាំងនោះរួមមាន នួន ជា, អៀង សារី, ខៀវ សំផន, អៀង ធីរិទ្ធ, ឌុច, និង តាម៉ុក ខណៈដែល តាម៉ុក ជាមេដឹកនាំជាន់ខ្ពស់បានស្លាប់ក្នុងឆ្នាំ២០០៦ ហើយគាត់ជាមេដឹកនាំរបស់ យឹម ទិត្យ រីង កែ ពក ជាអតីតលេខាភូមិភាគកណ្តាលបានស្លាប់ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០២ ដែលជាចៅហ្វាយនាយរបស់ **អោ អាន** ហើយ សុន សេន បានស្លាប់នាថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧ និង ប៉ុល ពត បានស្លាប់នាថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៩៨ ។

៤៨៤ ជាសរុប ក្រោយពីបានពិនិត្យមើលសាវតារនៃការស្វែងរកយុត្តិធម៌ មុនការបង្កើត អ.វ.ត.ក ជំហររបស់ភាគីក្នុងអំឡុងពេលធ្វើច្បាប់ និង កិច្ចព្រមព្រៀង អ.វ.ត.ក ការបកស្រាយច្បាប់ព្រហ្មទណ្ឌតាមអត្ថន័យចង្អៀត យុត្តិការបែបជ្រើសរើស ខ្លឹមសារជាក់ស្តែងនៃច្បាប់ អ.វ.ត.ក ព្រមទាំងជំហររបស់ភាគី ជាពិសេសភាគីជាតិតាំងពីមុនការបង្កើត អ.វ.ត.ក ផ្តោតលើការផ្សះផ្សាជាតិ និងការស្វែងរកយុត្តិធម៌ វាទាមទារឲ្យមានការថ្លឹងថ្លែងដោយផ្តោតលើមេដឹកនាំជាន់ខ្ពស់ជាមុខសញ្ញា តិចតួច តូចចង្អៀត ។ តំណាងរាជរដ្ឋាភិបាល ក្នុង



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

អំឡុងពេលពិភាក្សាច្បាប់នៅរដ្ឋសភាជាតិបានបង្ហាញនូវជំហរនេះ ។[1401] សហចៅក្រម-ស៊ើបអង្កេតទាំងជាតិ និងអន្តរជាតិ ធ្លាប់បានអះអាងនូវការគោរពស្នារតីនៃភាគីចរចាបង្កើត អ.វ.ត.ក ។[1402]

## V. ការពិចារណាទៅលើភស្តុតាង

### ក. ការធ្វើសម្ភាសន៍ដែលមិនមែនជាកំណត់ហេតុស្តាប់ចម្លើយ ដែលបង្កើតឡើងដោយសហចៅក្រមស៊ើបអង្កេត

៤៨៥ ភាគច្រើនលើសលុប ចំពោះភស្តុតាងត្រូវបានពឹងផ្អែកក្នុងសំណុំរឿងលេខ០០៤/២ រួមមានៈ កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ដែលត្រូវបង្កើតឡើងដោយ ក.ស.ច.ស ក្នុងពេលស៊ើបសួរដែលត្រូវបានរៀបចំក្រោមការត្រួតពិនិត្យពីតុលាការ និង ជាកម្មវត្ថុនៃការធានាយ៉ាងជាក់លាក់ ដោយអនុលោមតាមនីតិវិធីត្រឹមត្រូវ ។ ហេតុដូច្នេះ ប្រភេទនៃភស្តុតាងបែបនេះត្រូវទទួលបាននូវសច្ចធារណ៍នៃភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន ។[1403] យើងពិចារណាថា ប្រតិចារឹកនៃកិច្ចដំណើរការនីតិវិធីសវនាការមកពីសំណុំរឿងផ្សេងទៀតនៅ អ.វ.ត.ក ហើយដែលត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងលេខ០០៤/២ ដោយសារតែភាពពាក់ព័ន្ធរបស់ប្រតិចារឹកទាំងនោះជាមួយការចោទប្រកាន់នានា ត្រូវទទួលបាននូវសច្ចធារណ៍ដូចគ្នា ។

៤៨៦ ការធ្វើសម្ភាសន៍ ឬ ភស្តុតាងដទៃទៀត ដែលត្រូវបានប្រមូលដោយមិនមានការត្រួតពិនិត្យមើលតាមផ្លូវតុលាការ ដោយស្ថាប័នណាមួយដែលមិនស្ថិតក្នុង អ.វ.ត.ក នោះមិនត្រូវទទួលបាននូវសច្ចធារណ៍បែបនេះឡើយ ។[1404]ករណីលើកលែង សម្រាប់វិធាននេះត្រូវបានតំណាងដោយការស្តាប់ចម្លើយដែលរៀបចំឡើងដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលអង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ត្រូវទទួលបាននូវសច្ចធារណ៍អាចបដិសេធបាននៃភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បានបឋម ។[1405] ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានបង្កើតឡើងដោយមិនមានការធានាតាមផ្លូវតុលាការ និងមិនមានភាពផ្លូវការដែលកំណត់លក្ខណៈនៃកំណត់ហេតុនោះឡើយ ។

ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៨៧ ជុំវិញការស្តាប់ចម្លើយដែលធ្វើឡើងដោយ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងអំឡុងពេលស៊ើបអង្កេតបឋម បើទោះបីជាត្រូវបានរៀបចំដាច់ដោយឡែក សម្រាប់កិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌក៏ដោយ ក៏ការស្តាប់ចម្លើយនេះមិនត្រូវបានធ្វើឡើងដោយមានការស្បថនិងហត្ថលេខា ឬ/និង ស្នាមមេដៃពីអ្នកផ្តល់ចម្លើយនោះទេ ។ ខណៈការយកចម្លើយនោះត្រូវបានរៀបចំឡើងដោយតែ សាមីសហព្រះរាជអាជ្ញាអន្តរជាតិដែលជាភាគី ក្នុងគោលបំណងរំលេចឲ្យឃើញនូវផលប្រយោជន៍ជាក់ស្តែង ដូចមានលទ្ធផលក្នុងសំណុំរឿងស្រាប់ ។ ទោះជាយ៉ាងនេះក្តី ការស្តាប់ចម្លើយបែបនេះត្រូវបានប្រមូលឡើង សម្រាប់គោលបំណងនៃសវនាការព្រហ្មទណ្ឌ ។ ដូច្នេះ ជាគោលការណ៍ត្រូវទទួលបាននូវតម្លៃជាភស្តុតាងខ្ពស់ជាងភស្តុតាង ដែលមិនត្រូវបានប្រមូលសម្រាប់គោលបំណងនេះ រួមទាំងភស្តុតាងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ។[1406]

៤៨៨ ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំអាចទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បាន ហើយត្រូវទទួលបាននូវតម្លៃជាភស្តុតាងទាបប៉ុណ្ណោះ ប្រសិនបើកាលៈទេសៈនៃការកត់ត្រាពាក្យសុំតាំងខ្លួននោះ មិនមានភាពច្បាស់លាស់ ។[1407] ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និង ពាក្យបណ្តឹងរបស់ជនរងគ្រោះ បានផ្តល់នូវការសន្និដ្ឋានទូទៅប៉ុណ្ណោះ ។ ហេតុដូច្នេះ តំណាង "ការរៀបរាប់ទូទៅ" ដែលខុសពីបទពិសោធន៍ផ្ទាល់ខ្លួនហើយជាលទ្ធផលត្រូវចាត់ទុកថា មិនគ្រប់គ្រាន់សម្រាប់កំណត់ពីអង្គហេតុពាក់ព័ន្ធ ។[1408] ខណៈដែលការស្តាប់ចម្លើយពីដើមបណ្តឹងរដ្ឋប្បវេណី ក្រៅពីតុលាការត្រូវទទួលបាននូវតម្លៃជាភស្តុតាងទាប ។[1409]

៤៨៩ ជាការសន្និដ្ឋាន និងថ្លឹងថ្លែង លើការពិចារណាទាំងអស់នេះ ចំពោះកំណត់ហេតុនៃការស្តាប់ចម្លើយជាលាយលក្ខណ៍អក្សរ ដែលបង្កើតឡើងដោយ ក.ស.ច.ស និងប្រតិចារឹកនាពេលសវនាការត្រូវទទួលបាននូវសច្ចធារណ៍នៃភាពអាចជឿជាក់បានខ្ពស់ ហើយត្រូវទទួលបាននូវតម្លៃជាភស្តុតាងខ្ពស់ជាង ការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នដទៃផ្សេងទៀត ។ ចំពោះការស្តាប់ចម្លើយដែលរៀបចំឡើងដោយស្ថាប័នផ្សេងទៀតនោះ គួរត្រូវអនុម័តយកវិធីសាស្ត្រប្រុងប្រយ័ត្នខ្លាំងជាង ក្នុងការវាយតម្លៃទៅលើឯកសារទាំងនោះហើយព័ត៌មានដែលមាននៅក្នុងនោះ គួរត្រូវបានពឹងផ្អែកតែក្នុងករណីដែលទទួលបានការគាំទ្រដោយប្រភពផ្សេងទៀតប៉ុណ្ណោះ ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES "CO-JUGES D'INSTRUCTION"

01581459



## ខ. ភស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម

៤៩០ អនុលោមតាមមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងនឹងការធ្វើទារុណកម្មគឺ មានការហាមឃាត់ដាច់ខាតមិនឱ្យពឹងផ្អែកទៅលើព័ត៌មានដែលមានក្នុងឯកសារ ដែលទទួលបានដោយការធ្វើទារុណកម្ម[1410] និងមិនឱ្យប្រើប្រាស់ចម្លើយបែបនេះ ជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីឡើយ ។[1411] ដោយហេតុថា ចម្លើយសារភាពរបស់អ្នកទោសដែលត្រូវបានឃុំឃាំងនៅមន្ទីរសន្តិសុខ ស-២១ ត្រូវបានសន្មតថា ជាប្រភេទចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម ។ នេះគឺជាសច្ចធារណ៍មិនអាចបដិសេធបាន ។[1412]

៤៩១ ព័ត៌មានដែលមាននៅក្នុងចម្លើយសារភាពពីមន្ទីរសន្តិសុខ ស-២១ ដែលផ្តល់ឱ្យដោយបុគ្គលដែលមិនមែនជាជនរងគ្រោះនៃការធ្វើទារុណកម្ម ជាឧទាហរណ៍ទាក់ទិន ចំណារដោយអ្នកធ្វើទារុណកម្ម មិនស្ថិតក្រោមការហាមឃាត់នេះឡើយ[1413] ពីព្រោះថា បើតាមមាត្រា ១៥ ដដែលខាងលើនេះ ក៏មិនបានហាមឃាត់ការប្រើប្រាស់ព័ត៌មាន ដែលមានក្នុងចម្លើយដែលធ្វើឡើង ដោយទារុណកម្មនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកសាក្សីនិងអាចឈានទៅស្តាប់ចម្លើយពួកគាត់ដែរ ។[1414] ហេតុដូច្នេះ មិនមានការហាមឃាត់ មិនឱ្យប្រើប្រាស់ភស្តុតាងរបស់សាក្សី ដែលត្រូវបានកំណត់នៅក្នុងចម្លើយ ដែលទទួលបានដោយការធ្វើទារុណកម្មដូចជា ចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ និង ការស្តាប់ចម្លើយនាពេលបន្ទាប់ដោយ ក.ស.ច.ស នោះទេ ។[1415]

## VI. សំអាងហេតុ និង សន្និដ្ឋាន បញ្ញាយុត្តាធិការបុគ្គលលើ អោ អាន

៤៩២ សេចក្តីសន្និដ្ឋានរបស់យើងលើ **អោ អាន** ថា តើគាត់ស្ថិតនៅក្រៅឬក្នុងយុត្តាធិការរបស់ អ.វ.ត.ក ត្រូវបានធ្វើឡើងដោយពិចារណា អំពីតួនាទីនិងការចូលរួមរបស់ **អោ អាន** ចរិតលក្ខណៈទូទៅនៃរបបកម្ពុជាប្រជាធិបតេយ្យ ក្នុងអំឡុងពេលគ្រប់គ្រងអំណាច និងគោលនយោបាយ ចេតនាពិតប្រាកដរបស់អ្នកចរចា ដើម្បីបង្កើតឱ្យមាន អ.វ.ត.ក ដែលមានទាំងរាជរដ្ឋាភិបាលកម្ពុជា និង អង្គការសហប្រជាជាតិ ។ ពាក់ព័ន្ធនឹងការចូលរួម យើងនឹងពិនិត្យដោយផ្តោតលើទីតាំងឧក្រិដ្ឋកម្មទាំងឡាយដែល **អោ អាន** ត្រូវបានដាក់ក្រោមការពិនិត្យ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និង ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើប



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ បើទោះបីជាអង្គហេតុមួយចំនួន ៨ (ប្រាំបី) ត្រូវបាន ស.ច.ស.អ បានចេញដីកាសម្រេចកាត់បន្ថយក៏ដោយ ។

៤៩៣ តាមអង្គហេតុដែលត្រូវបានចោទដោយ សហព្រះរាជអាជ្ញាអន្តរជាតិ មានទីតាំងបទឧក្រិដ្ឋដែលជាមន្ទីរសន្តិសុខកន្លែងឃុំឃាំង និងសម្លាប់មនុស្ស ការដ្ឋានធ្វើការងារ កម្រិតស្រុក តំបន់ ឬភូមិភាគដូចជា៖ ការបោសសម្អាតនៅភូមិភាគកណ្តាល, មន្ទីរសន្តិសុខវត្តអូរត្រកួន, មន្ទីរសន្តិសុខវត្តបាធាយ, មន្ទីរសន្តិសុខមិត្តសុប(គរ), មន្ទីរសន្តិសុខវត្តភ្នំប្រុស, មន្ទីរសន្តិ-សុខគោកព្រីង, មន្ទីរសន្តិសុខចំការស្វាយចន្ទី, ការដ្ឋានធ្វើពលកម្មដោយបង្ខំនៅទំនប់អន្លង់ជ្រៃ, អំពើប្រល័យពូជសាសន៍នៅខេត្តកំពង់ចាម, មន្ទីរសន្តិសុខវត្តស្រង៉ែ, គុកនិងកន្លែងសម្លាប់ទួលតាផ្លុង, មន្ទីរសន្តិសុខវត្តកណ្តាល, មន្ទីរសន្តិសុខវត្តបារាយណ៍ជាន់ដែក, មន្ទីរសន្តិសុខវត្តតាមះ, មន្ទីរសន្តិសុខកំពង់សៀមក្នុងវត្តអង្គញ្ញដី, ទីកន្លែងសម្លាប់មនុស្សនៅក្នុងភូមិទួលបេង, និងអាពាហ៍ពិពាហ៍ដោយបង្ខំនៅតំបន់ ៤១ (ស្រុកកំពង់សៀម និងស្រុកព្រៃឈរ) ។ ក្នុងនោះទីតាំងបទឧក្រិដ្ឋមួយចំនួនស្ថិតនៅក្នុងតំបន់ ៤១ ដែលមាន **អោ អាន** ជាលេខាតំបន់ ។

**តួនាទី និងការចូលរួមរបស់ អោ អាន**
**មិនហួសពីអំណាចផ្លូវការ ក្នុងការអនុវត្តន៍គោលនយោបាយ**

៤៩៤ ភ័ស្តុតាងដែលរកឃើញបានបង្ហាញថា **អោ អាន** ជាសមាជិកនៃគណៈតំបន់ ២៥ នៃភូមិភាគនិរតីក្រោយពីរំដោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ។ បន្ទាប់មក **អោ អាន** ត្រូវបានផ្ទេរទៅតំបន់ ៣៥ នៃភូមិភាគនិរតី និងកាន់កាប់ការងារតួនាទីនេះក្នុងរយៈពេលដ៏ខ្លី ។ ក្រោយមកនៅពាក់កណ្តាលឆ្នាំ១៩៧៧ **អោ អាន** ត្រូវបានបញ្ជូនមកជាមួយក្រុមកម្មាភិបាលភូមិភាគនិរតីទៅកាន់ភូមិភាគកណ្តាល ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ គោលនយោបាយបោសសម្អាត ។ កម្មាភិបាលទាំងនោះ ត្រូវបានពង្រាយចូលទៅបំពេញ ក្នុងបណ្តាតួនាទីជំនួសកម្មាភិបាលនៅភូមិភាគកណ្តាល ដែលរងការបោសសម្អាតរួចហើយ ។ សាក្សីជាច្រើននាក់ជាពិសេស កែ ពក ធ្លាប់បានអះអាងថា *"ដល់ខែមិថុនា ឆ្នាំ១៩៧៧ ចប់ការចាប់មួយវគ្គដំបូងហើយ ។ ពេលនោះនៅសល់តែខ្ញុំ (កែ ពក) ពេលនោះធ្វើការពិនិត្យនៅភូមិភាគកណ្តាលអស់កម្មាភិបាល ។ ខាងលើក៏សម្រេចយកកម្មាភិបាលពីនិរតីមកដាក់ ។ ខាងលើហៅកម្មាភិបាលនិរតីមក ២០០ នាក់ជាង"* ។[1416]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៩៥ នៅពេលមកដល់ភូមិភាគកណ្ដាល **អោ អាន** ត្រូវបាន កែ ពក លេខាភូមិភាគកណ្ដាល ចាត់តាំងឱ្យកាន់តួនាទីជាលេខាតំបន់ ៤១ ។ មួយរយៈក្រោយមក អនុលេខាភូមិភាគឈ្មោះ ស្រេង ត្រូវរងនូវការបោសសម្អាត ហើយតំណែងនេះក្នុងភាពទំនេរមួយរយៈទើប **អោ អាន** ត្រូវបានបន្ថែមការតែងតាំងមួយទៀតជាអនុលេខាភូមិភាគកណ្ដាល ។ **អោ អាន** បានទទួលស្គាល់តួនាទីគាត់ជាលេខាតំបន់ ៤១ ។ ទោះបីជាយ៉ាងនេះក្ដី មិនមានឯកសារផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យណាមួយ មកបញ្ជាក់អំពីការតែងតាំងជាផ្លូវការនូវតួនាទីនេះទេ ។

៤៩៦ ក្នុងឋានៈជាលេខាតំបន់ ៤១ **អោ អាន** ក្ដាប់ការងាររដ្ឋបាល និងគ្រប់គ្រងរួម (ផ្នែកទី II, ៤.៦) ។ តំបន់ ៤១ មិនមែនជាតំបន់ស្វយ័តទេ ហេតុដូច្នេះ **អោ អាន** ពុំមានសិទ្ធិរាយការណ៍ផ្ទាល់ទៅគណៈកម្មាធិការមជ្ឈិមបក្ស ឬ មន្ទីរ៨៧០ ទេ ។ រីឯ ក្នុងតួនាទីជាអនុលេខាភូមិភាគកណ្ដាល **អោ អាន** មិនមានភ័ស្តុតាងដែលបញ្ជាក់ថា **អោ អាន** ត្រូវទទួលខុសត្រូវលើការងារណាមួយឱ្យបានច្បាស់លាស់ខាងយោធា សន្តិសុខ ឬ សេដ្ឋកិច្ចឡើយ ។ អ្វីដែលច្បាស់នៅត្រង់ថា **អោ អាន** ត្រូវតែធ្វើការងារតាមរយៈ កែ ពក និងក្រោមបញ្ជា កែ ពក ដោយខានមិនបាន ។ សាក្សីឈ្មោះ ញ៉ែម ចេន អតីតអ្នកការពារ **អោ អាន** លើកឡើងថា "*ដោយសារខ្ញុំនៅជិតស្និទជាមួយ តា អាន ខ្ញុំសួរគាត់ថា អ៊ំឯងមិនចេះអាណិតគាត់ទេ ? គាត់ថា បើអញមិនធ្វើតាមបញ្ជាគេទេ គេសម្លាប់អញដែរ*"។[1417]

៤៩៧ ភ័ស្តុតាងបង្ហាញថា **អោ អាន** ក៏អាចមានការពាក់ព័ន្ធនឹងការចេញបញ្ជាឱ្យចាប់ និងសម្លាប់មនុស្សមួយចំនួនតូច ។ ដូចជាករណីការចាប់ខ្លួន តា អាំ (ប្ដីអ្នកស្រី ប្រាក់ យុត) ជាប្រធានមន្ទីរតំបន់ ៤១ និងការបញ្ជាឱ្យចាប់បុរសឈ្មោះ ហ៊ុម ដែលខុសសីលធម៌ជាមួយប្អូនថ្លៃស្រីរបស់ **អោ អាន** ជាដើម ។ សាក្សីជាអតីតកងការពារ **អោ អាន** បានលើកឡើងថា "*គាត់ (អោ អាន) បញ្ជាថា ធ្វើម៉េចឱ្យផែនការគេត្រឹមឆ្នាំ៧៧ ត្រូវធ្វើតាមផែនការគេសម្លាប់ឱ្យអស់ព្រោះ៧៨ លែងមានសម្លាប់ហើយ ។ ដល់ចូល៧៨ ដូចរាងស្ងើយហើយ លែងមានសម្លាប់ ហើយមានបបររាងខាប់ហូប*" ។[1418] ស្រដៀងគ្នានេះដែរ ក្នុងនាមជាលេខាតំបន់ ៤១ **អោ អាន** ពិតជាបានដឹកនាំប្រជុំថ្នាក់តំបន់ ដាក់ផែនការការងារ ចុះមើលតាមការដ្ឋាន មន្ទីរសន្តិសុខ ព្រមទាំងប្រជុំផ្សព្វផ្សាយពង្រឹងគោលជំហររបស់បក្ស ឱ្យខិតខំធ្វើការ និង កុំចូលដៃជាមួយខ្មាំងជាដើម ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៤៩៨ ពាក់ព័ន្ធនឹងការប្រព្រឹត្តលើជនជាតិចាម ភស្តុតាងបានបង្ហាញដែរថា **អោ អាន** បានចូលរួមដឹកនាំផ្សព្វផ្សាយ គោលនយោបាយលើជនជាតិចាម បន្តអនុវត្តបញ្ជាដោយឱ្យអ្នកក្រោមបង្គាប់ជាថ្នាក់ស្រុកធ្វើការស្រង់ទិន្នន័យជនជាតិចាម និងតាមដានការអនុវត្តន៍ការងារ តាមរយៈការបង្គាប់ឱ្យរាយការណ៍ និងការទទួលបាននូវរបាយការណ៍ ពីថ្នាក់ក្រោមត្រលប់មកវិញ ។ ការប្រព្រឹត្តលើជនជាតិចាមបានកើតមានឡើង គួរឱ្យកត់សម្គាល់ក្នុងស្រុកកងមាស និងស្រុកកំពង់សៀមក្នុងតំបន់ ៤១ ដែលជាស្រុកដែលមានជនជាតិចាម រស់នៅច្រើនជាងគេ ហើយក៏ដោយសារការងើបបះបោរកន្លងមករបស់ជនជាតិចាម ប្រឆាំងនឹងគោលនយោបាយរបបកម្ពុជាប្រជាធិបតេយ្យ ។ ហេតុនេះ ជនជាតិចាមត្រូវបានរងការបង្ក្រាបជាខ្លាំង ជាពិសេសដូចជា ការដុតគម្ពីរកូអាន (The Koran) ការហាមឃាត់ការប្រតិបត្តិសាសនា ការហាមមិនឱ្យនិយាយភាសាចាម ការបង្ខំឱ្យជនជាតិចាមហូបសាច់ជ្រូក និងសាច់ឆ្កែជាដើម ។ (កថាខណ្ឌទី ១៤០)

៤៩៩ ការប្រព្រឹត្តទាំងនោះត្រូវបានមើលឃើញក្នុងទម្រង់ជាខ្សែសង្វាក់ ចូលរួមដោយកម្មាភិបាលគ្រប់ជាន់ថ្នាក់ តាមបន្ទាត់គោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជា ។ សាក្សីឈ្មោះ សឡេះ អះម៉ាត់ បានរៀបរាប់ថា"*ការជម្លៀសបានចាប់ផ្តើមតាំងពីឆ្នាំ១៩៧៦ ហើយបន្តរហូតដល់ឆ្នាំ១៩៧៨ មុនពេលរំដោះ ។ ការប្រជុំនោះធ្វើឡើង ដើម្បីវាយតម្លៃពី**ការអនុវត្តន៍ផែនការបោសសម្អាតជនជាតិចាម ដើម្បីឱ្យដឹងថាសម្រេចបានប៉ុណ្ណាហើយ***" ។[1419] លើសពីនេះ សាក្សីរូបនេះបានបន្ថែមទៀតថា "*នៅចុងឆ្នាំ១៩៧៨ មានការប្រជុំមួយដែលមានការចូលរួមពីថ្នាក់ឃុំ ថ្នាក់ស្រុក និងថ្នាក់តំបន់ និង វត្តមានរបស់ **កែ ពក ដោយគេបានសួរថាតើផែនការបក្សត្រូវបានអនុវត្តបានប៉ុន្មានភាគរយហើយ***" ។[1420]

៥០០ ពាក់ព័ន្ធនឹងបញ្ហា អាពាហ៍ពិពាហ៍ដោយបង្ខំ **អោ អាន** បានចូលរួមនិងសម្របសម្រួលក្នុងក្របខ័ណ្ឌនៃតំបន់ ៤១ ។ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ជាគោលនយោបាយផ្លូវការក្នុងការបង្កើនចំនួនប្រជាជន មិនឱ្យចាញ់ប្រទេសជិតខាងពេក ។ សាក្សីបានលើកឡើងថា "*គាត់ (អោ អាន) បាននិយាយអំពីផែនការរៀបការ ។ ពួកគេគ្រោងនឹងបង្កើនកម្លាំងថ្មី ឬ ក៏ប្រជាជនថ្មីឱ្យដល់ ១៥ ទៅ ២០ លាននាក់ នៅក្នុងរយៈពេលពី ១៥ ទៅ ២០ ឆ្នាំទៀត នេះជាផែនការអាស៊ី ដែលសំដៅលើផែនការរបស់ ប៉ុលពត*" ។[1421]



E.C.C.C * C.E.T.C * CO. INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥០១ ជារួម ការចូលរួមទាំងប៉ុន្មានពាក់ព័ន្ធនឹង ការប្រព្រឹត្តលើជនជាតិចាម ក្នុងខេត្តកំពង់ចាម ការបង្ក្រាប ឬ ការប្រព្រឹត្តជាទូទៅលើប្រជាជនក្នុងភូមិភាគកណ្តាល ឬនិយាយដោយឡែក ប្រជាជននៅតំបន់ ៤១ រាប់ទាំងអាពាហ៍ពិពាហ៍ដោយបង្ខំនៅស្រុកកំពង់សៀម និងស្រុកព្រៃឈរ សុទ្ធតែត្រូវបានធ្វើឡើង តាមគោលនយោបាយជាខ្សែសង្វាក់ពីអង្គការថ្នាក់លើចុះមកថ្នាក់ក្រោម ។ ការចាប់ចង ការសម្លាប់ ដោយសារតែមូលហេតុថា ជាខ្មាំងត្រូវបានកើតមានឡើងនៅភូមិភាគកណ្តាល ចាប់តាំងពីមុន **អោ អាន** និងក្រុមនិរតីធ្វើដំណើរទៅដល់ភូមិភាគកណ្តាលមកម្លេះ ។

៥០២ មានភស្តុតាងតិចតួចដែលបង្ហាញថា **អោ អាន** បានចូលរួមប្រព្រឹត្តលើអង្គហេតុមួយចំនួន ប៉ុន្តែ ពេលខ្លះការលើកឡើងនោះ ហាក់ដូចជាពិបាកនឹងជឿទុកចិត្តបាន ដោយសារសម្តីរបស់សាក្សី ដែលទំនងជាចង់ដាក់បន្ទុកលើ **អោ អាន** ។ នេះដូចជាករណីសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត ជាអតីតលេខាស្រុកកំពង់សៀមនៃតំបន់ ៤១ ហើយធ្លាប់ធ្វើការងារនៅក្រោមបង្គាប់ **អោ អាន** និង សាក្សីសំខាន់ម្នាក់ទៀតឈ្មោះ កែ ពេជ្រវណ្ណៈ ដែលជាកូនប្រុសបង្កើតរបស់លេខាភូមិភាគកណ្តាល កែ ពក ។

៥០៣ កន្លងមក ការិយាល័យសហចៅក្រមស៊ើបអង្កេត បានសាកសួរសាក្សីឈ្មោះ ប្រាក់ យុត ហៅ យាយ យុត អតីតលេខាស្រុកកំពង់សៀម ចំនួន ១០ (ដប់)[1422]លើក ។ ពីដំបូង គាត់បានឆ្លើយថាមិនស្គាល់ **អោ អាន** ទេ ក្រោយមកទើបអះអាងថាស្គាល់ **អោ អាន** ដោយសារធ្លាប់ធ្វើការក្នុងភូមិភាគនិរតី និង បានផ្ទេរមកភូមិភាគកណ្តាលជាមួយគ្នា ។ ជុំវិញព្រឹត្តិការណ៍នៃការបង្ក្រាប និងការបោសសម្អាតលើជនជាតិចាម សាក្សីរូបនេះជាអ្នកអនុវត្តដោយផ្ទាល់ និង បានចូលរួមយ៉ាងសកម្ម ក្នុងឋានៈខ្លួនជាលេខាស្រុកកំពង់សៀម ។ ចម្លើយរបស់សាក្សីឈ្មោះ ប្រាក់ យុត នាពេលសម្ភាសន៍ក្រោយៗមក ហាក់និយាយទម្លាក់កំហុសលើ **អោ អាន** កាន់តែខ្លាំងឡើងៗ ។

៥០៤ ជាការកត់សម្គាល់ឈ្មោះ ប្រាក់ យុត អតីតលេខាស្រុកកំពង់សៀមអាចឆ្លើយតាមអារម្មណ៍ឈឺចាប់ ជាការអាក់អន់ចិត្ត ទៅលើរបបកម្ពុជាប្រជាធិបតេយ្យតែម្តង ។ ក្នុងបទសម្ភាសន៍លើកទី៤ និង ទី៥ ប្រាក់ យុត បានឆ្លើយយ៉ាងច្បាស់ថា “*តាំងពីចាប់ខ្លួនប្តីរបស់ខ្ញុំ ខ្ញុំបាត់បង់ជំនឿនិងទុកចិត្តលើបដិវត្តន៍ ព្រោះខ្ញុំស្រលាញ់ប្តីរបស់ខ្ញុំ ហើយខ្ញុំមិនអាចនិយាយនឹងអ្នក*



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C.

*ក្រៅបានទេ ប៉ុន្តែ ខ្ញុំមានការអស់សង្ឃឹមក្នុងខ្លួន*"[1423] ហើយ "*ខ្ញុំមិនពេញចិត្តនឹងបដិវត្តន៍ដោយសារការចាប់ខ្លួនប្តី និងការដកតំណែង*"[1424] ។

៥០៥ សាក្សីឈ្មោះ កែ ពេជ្រវណ្ណៈ បានឆ្លើយដាក់បន្ទុក ទាក់ទិនស្ថានភាពនៃការបញ្ជាឱ្យសម្លាប់មនុស្សនៅភ្នំប្រុស ដោយបានអះអាងថា តាមចម្លើយរបស់ តាវ៉យ រាប ជាប្រធានកងពលនៅភូមិភាគកណ្តាលថា "បង**អាន**ជាអ្នកបញ្ជា" ។ វាជាការឮតាមគ្នា និងគ្មានសក្ខីកម្មជាភ័ស្តុតាងណាបានគាំទ្រទេ ។ ផ្ទុយទៅវិញ សាក្សីឈ្មោះ វង សុគន្ធ ធ្លាប់បានឃើញ កែ ពក ឈរបញ្ជាឱ្យសម្លាប់មនុស្ស ។ វត្តមានរបស់ កែ ពក នៅភ្នំប្រុសនេះក៏ត្រូវបានបំពេញបន្ថែមដោយសាក្សីឈ្មោះ សា ណូ និងសាក្សីជាច្រើននាក់ទៀត ។[1425] វាអាចសមស្របដោយសារវត្តភ្នំប្រុសនេះ ជាមន្ទីរសន្តិសុខថ្នាក់ភូមិភាគ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កែ ពក ជាលេខាភូមិភាគតែម្តង ។[1426] កែ ពេជ្រវណ្ណៈ ក្នុងនាមជាកូនប្រុសបង្កើតអាចឆ្លើយដោះបន្ទុក កែ ពក ដែលជាឪពុក ។ យើងសូមបញ្ជាក់ថា មន្ទីរសន្តិសុខភ្នំប្រុសនេះត្រូវបានសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដកចេញពីសំណុំរឿងនិងមិនបន្តស៊ើបអង្កេតទេ ហើយសហព្រះរាជអាជ្ញាអន្តរជាតិ ក៏មិនបានធ្វើជំទាស់ដែរ។

៥០៦ ការជឿជាក់លើចម្លើយណាមួយនៃសាក្សីទាំងដោះ ឬ ដាក់បន្ទុកលើ **អោ អាន** ទាមទារនូវការថ្លឹងថ្លែងលើហេតុផលផ្សេងៗរួមមាន៖ បរិបទតឹងរ៉ឹងក្នុងរបបនោះ ***គឺរឿងអ្នកណាអ្នកនោះដឹង*** និងស្ថានភាពក្រោយព្រឹត្តការណ៍កើតមានជិត ៤០ (សែសិប) ឆ្នាំ អាចជាចំណោទមួយដ៏ធំផងដែរ ក្នុងការចងចាំអ្វីដែលកើតមាន ទាំងនេះនៅមិនទាន់ពិចារណាលើបញ្ហាដទៃទៀតឱ្យបានគ្រប់ជ្រុងជ្រោយ តាមលក្ខណៈវិទ្យាសាស្ត្រនោះទេ ។ សាក្សីម្នាក់បានផ្តល់ការកត់សម្គាល់ថា "*វា៣៦ ទៅ៣៧ ឆ្នាំហើយ អ្នកណាទៅកត់ត្រាទុករឿងហ្នឹង ។ ហើយបើសួរខ្ញុំជាថ្នាក់ដឹកនាំទាហានកំប៉ុកកំប៉ុកដែរ ខ្ញុំម៉េចនឹងដឹង ។ ខ្ញុំគ្រាន់តែដឹងថា ហេតុការហ្នឹងវាកើតឡើងមែន*"។[1427] នេះបង្ហាញអំពីមន្ទិលលើសក្ខីកម្មនិយាយពីការចូលរួម និងតួនាទីរបស់ **អោ អាន** ក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទ ។

៥០៧ **អោ អាន** មិនមែនជាសមាជិក ឬ សមាជិកបម្រុងនៃគណៈកម្មាធិការមជ្ឈិមបក្ស ។ បើតាមឋានានុក្រមរបស់ ប.ក.ក គិតពីលើចុះមក **អោ អាន** ប្រហែលជាមនុស្សនៅក្នុងលំដាប់ទី៤០ (សែសិប)នៃកម្រិតភូមិភាគ ឬលំដាប់ទី៧០ (ចិតសិប) នៃឋានៈជាថ្នាក់ដឹកនាំ



ECCC * CETC * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ក្នុងចំណោមសមាជិកនៃគណៈកម្មាធិការមជ្ឈិមបក្ស, សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍, គ្រប់លេខាភូមិភាគ និង គ្រប់លេខាតំបន់ស្វយ័ត ។ គាត់មានអ្នកនៅក្រោមឱវាទក្នុងមន្ទីរតំបន់ ៤១ ចំនួនមិនលើសពី ៤០ (សែសិប) រូបនោះទេ ។

៥០៨ ការចូលរួមរបស់ **អោ អាន** បានកើតឡើង ក្នុងបរិបទដែលការបោសសម្អាតក្នុងភូមិភាគកណ្តាល ស្ទើរតែចប់ទាំងស្រុងរួចរាល់ហើយ ។ សេចក្តីថ្លែងការណ៍របស់ ខៀវ សំផន ហៅ ហែម ដែលពេលនោះជាប្រធានគណៈប្រធានរដ្ឋ ទាក់ទិននឹង ការលើកលែងទោស (ឈប់សម្លាប់) បានបង្ហាញយ៉ាងច្បាស់ អំពីអត្ថិភាពនៃការបោសសម្អាតដែលមានកន្លងមក ហើយក៏អាចនិយាយបានថា អត្រានៃការចាប់ចង ឬ ការសម្លាប់ពិតជាបានចុះថមថយ នាពេល **អោ អាន** បានទៅដល់ភូមិភាគកណ្តាល ។

៥០៩ បន្ថែមពីលើនេះ ទាក់ទិននឹងអត្រានៃការស្លាប់បាននៅបន្ត ក្រោយពេល **អោ អាន** បានមកដល់ភូមិភាគកណ្តាល ដោយហេតុថា នាពេលនោះកម្ពុជាបានជួបបញ្ហាគ្រោះទុរ្ភិក្ស ការអត់ឃ្លានកើតមានពេញផ្ទៃប្រទេស ដែលជាផលវិបាកកើតចេញពីការអនុវត្តន៍នូវគោលនយោបាយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ជាពិសេស ការដាក់ចេញរបស់អង្គការថ្នាក់លើដោយតម្រូវឱ្យប្រជាជននៅតាមមូលដ្ឋានត្រូវធ្វើស្រូវឱ្យបាន “**បីតោនក្នុងមួយហិចតា**” ដើម្បីធានាបាននូវការនាំចេញ ដោយមិនអើពើនឹងការផ្គត់ផ្គង់អាហាររូបត្ថម្ភជូនដល់ប្រជាជនឱ្យបានគ្រប់គ្រាន់ ។ ខណៈប្រជាជនទទួលបានរបបអាហារមិនគ្រប់គ្រាន់ និង ស្ទើរគ្មានតែម្តងចំពោះការផ្តល់សេវាសុខាភិបាលជូនដល់ប្រជាជន ។ ការណ៍នេះបានបណ្តាលឱ្យមានផលវិបាកដល់ប្រជាជននៅទូទាំងប្រទេស ប្រឈមមុខការស្លាប់ដោយការអត់ឃ្លាន និងការស្លាប់ដោយសារជំងឺ ហើយដែលបញ្ហានេះ ក៏ត្រូវបានកើតមានដែរនៅតំបន់ ៤១ ក្នុងភូមិភាគកណ្តាលដែលមាន **អោ អាន** ជាលេខាតំបន់ ។

៥១០ **អោ អាន** បានកាន់តំណែងជាលេខាតំបន់ ៤១ ប្រមាណជាងមួយឆ្នាំ និងជាអនុលេខាភូមិភាគនេះក្នុងរយៈពេលខ្លី មុនរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅដើមឆ្នាំ១៩៧៩ ។ សាក្សីច្រើននាក់បានឆ្លើយថា មិនបានស្គាល់ **អោ អាន** មិនបានដឹងអំពីការចូលរួម និងការទទួលខុសត្រូវរបស់ **អោ អាន** ទេ ។ ខណៈសាក្សីខ្លះបានលើកឡើងថា **អោ អាន** គ្រាន់តែជាអ្នកទទួលបញ្ជាពីថ្នាក់លើ ដែលសំដៅទៅលើ តែ ពក ឬគណៈកម្មាធិការមជ្ឈិម-



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

បក្សដែលជាអ្នកដាក់ចេញនូវបទបញ្ជា ។ ជាការពិត លេខាភូមិភាគកណ្ដាល កែ ពក ធ្លាប់បានចេញបញ្ជាទៅ **អោ អាន** លេខាតំបន់ ៤១ ថា "*នៅតំបន់ហ្នឹង **អាន** មើលខ្លាំងចាប់ឱ្យឆាប់អស់ហើយផែនការ ព្រោះពីលើមកគេបង្ខំ*" ។[1428]

## កែ ពក មានអំណាច និង ឥទ្ធិពលគ្រប់គ្រងយ៉ាងមានប្រសិទ្ធភាព លើភូមិភាគកណ្ដាលទាំងមូល សូម្បីក្នុងអំឡុងពេលគាត់អវត្តមានម្ដងម្កាល

៥១១ ទោះបី **អោ អាន** ជាលេខាតំបន់ ហើយបានចូលរួមក្នុងការប្រព្រឹត្តបទឧក្រិដ្ឋក្ដី តែការចូលរួមនេះ មិនបានធ្វើអ្វីហួសពីបញ្ជា និងក្រោមអំណាច ព្រមទាំងការគ្រប់គ្រងរបស់លេខាភូមិភាគកណ្ដាល កែ ពក ទេ។

៥១២ ភស្តុតាងដែលមាន ពុំបានបង្ហាញឱ្យឃើញជាក់លាក់ថា **អោ អាន** ទទួលការងារគ្រប់គ្រងជំនួសក្នុងតួនាទីជាអនុលេខាភូមិភាគស្ដីទីពេល កែ ពក អវត្តមានម្ដងម្កាលនោះទេ ។ មានភស្តុតាងដែលជាចម្លើយរបស់សាក្សីជាច្រើននាក់ បានលើកឡើងចំៗថា មិនធ្លាប់បានឃើញវត្តមានរបស់ **អោ អាន** នៅមន្ទីរភូមិភាគកណ្ដាលដើម្បីជំនួសការងារ កែ ពក ពេលអវត្តមានទេ ក្រៅពីករណីដែល **អោ អាន** ត្រូវទៅចូលរួមប្រជុំថ្នាក់ភូមិភាគ ។

៥១៣ តាមបរិបទនាពេលនោះ ក្នុងតួនាទីជាលេខាភូមិភាគ កែ ពក កម្រអវត្តមានពីភូមិភាគណាស់ ។ សាក្សីឈ្មោះ ស្បួន កានិល ធ្លាប់បានលើកឡើងថា "*តាមខ្ញុំដឹង កែ ពក មិនដែលចេញទៅណាទេក្នុងរយៈពេល ៣ ឆ្នាំ ៨ ខែ ២០ ថ្ងៃ នោះ ។ គាត់អវត្តមានតែនៅពេលដែលគាត់ទៅសមរភូមិ ទៅប្រជុំនៅភ្នំពេញ ឬ ទៅមើលការដ្ឋានទំនប់ប្រឡាយមួយរយៈប៉ុណ្ណោះ*" ។[1429] កែ ពក អាចអវត្តមានពីមន្ទីរភូមិភាគតែលើការងារបីធំៗរួមមាន៖ (១)-ការចុះតាមមូលដ្ឋានក្នុងភូមិភាគ, (២)-ត្រូវទៅប្រជុំនៅភ្នំពេញ និង (៣)-ទៅឈរជើងនៅភូមិភាគបូព៌ា ដើម្បីសង្កត់ស្ថានការណ៍ និងការវាយប្រយុទ្ធជាមួយវៀតណាមតាមព្រំដែន ។

៥១៤ ពេលខ្លះ កែ ពក ត្រូវទៅប្រជុំនៅភ្នំពេញ អ្នកដែលជំនួសគាត់ជាប្រធានមន្ទីរភូមិភាគ ។ ស្បួន កានិល អតីតប្រធានក្រុមសារទូរលេខនៅមន្ទីរគណៈភូមិភាគកណ្ដាល បានលើកឡើងត្រង់បញ្ហានេះថា"*ក្នុងករណី កែ ពក អវត្តមានគឺគេមកជួបប្រធានមន្ទីរគណៈភូមិភាគឈ្មោះ*



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

01581467



*ស្វ* ។[1430] មិនមានសាក្សីណាអះអាងថា **អោ អាន** មកជំនួស កែ ពក នាពេលគាត់អវត្តមានទេ ។ ស្ថានភាពបែបនេះ ក៏ត្រូវបានអនុវត្តដូចគ្នាដែរ ក្នុងភូមិភាគបូព៌ា ។ សោ ភឹម លេខាភូមិភាគបូព៌ា បានឱ្យប្រធានមន្ទីរភូមិភាគបូព៌ា ជំនួសការងារគាត់នាពេលគាត់អវត្ត-មាន ។[1431] បញ្ហាជំនួសរបៀបនេះ អាចជារបៀបការងាររដ្ឋបាលមួយ ដែលត្រូវបានយកមកអនុវត្តក្នុងរបបនោះ ។ ម្យ៉ាងទៀត វាជាគោលការណ៍ទូទៅហើយ ដែលកម្មាភិបាលម្នាក់ៗត្រូវតែទទួលខុសត្រូវ ចំពោះការងារដែលខ្លួនទទួលបន្ទុក ។

៥១៥ កែ ពក ត្រូវប្រចាំការជួរមុខនៅភូមិភាគបូព៌ា ក្នុងអំឡុងពេលមានជម្លោះជាមួយវៀតណាម ។ កែ ពក នឹងមិនអវត្តមានយូរ ឬ គ្មានអវត្តមានសោះក៏អាចថាបាន ដោយសារ ទីតាំងបញ្ជាការដ្ឋានដែល កែ ពក ធ្វើការងារស្ថិតនៅពញាក្រែកក្នុងភូមិភាគបូព៌ា ។ ទីតាំងបញ្ជាការដ្ឋាននេះស្ថិតនៅផ្នែកខាងកើតនៃទន្លេមេគង្គ ដែលខណ្ឌចែកភូមិភាគកណ្ដាលនិងភូមិភាគបូព៌ា ។ វាមានចំងាយជាង ២០ (ម្ភៃ) គីឡូម៉ែត្រពីមន្ទីរភូមិភាគកណ្ដាល ។ គាត់ត្រូវធ្វើដំណើរតាមរថយន្តតែប្រហែល ២០ (ម្ភៃ) នាទី ដែលអាចធ្វើឱ្យគាត់ត្រឡប់មកភូមិភាគកណ្ដាលបានយ៉ាងងាយស្រួល ។ ដូចនេះ ការងារត្រួតពិនិត្យតាមដានការងារសំខាន់ ពីទីបញ្ជាការក្នុងភូមិភាគបូព៌ាមិនជាការពិបាកទេ ។ករណីមានការងារត្រូវឆ្លងជាបន្ទាន់ មន្ទីរអាចប្រើនិរសាយកឯកសារនោះទៅជួប កែ ពក ដោយផ្ទាល់ ។

៥១៦ សាក្សីមិនតិចនាក់ទេបានឆ្លើយថា កែ ពក បានគ្រប់គ្រងយ៉ាងតឹងរ៉ឹង ចេញបញ្ជារាល់ការងារទាំងអស់ក្នុងភូមិភាគ ។ ការងារទាំងអស់តម្រូវឱ្យមានការឆ្លងយោបល់ពីគាត់ ។ គាត់ជាបុគ្គលតែម្នាក់គត់ ដែលមានសិទ្ធិអំណាចដឹកនាំប្រជុំភូមិភាគបាន ។ លើសពីនេះ សក្ខីកម្មសាក្សីជាអតីតប្រធានក្រុមសារទូរលេខនៅមន្ទីរភូមិភាគកណ្ដាល បាននិយាយយ៉ាងច្បាស់ថា *"រាល់សារទូរលេខចេញនិងចូល គឺត្រូវតែយកទៅឱ្យ កែ ពក"*។[1432] ហេតុនេះពេលមានការងារត្រូវសម្រេចបន្ទាន់ គេត្រូវចាត់និរសាយកទៅជូនគាត់ភ្លាមៗតែម្ដង ។[1433]

៥១៧ ភស្តុតាងជាឯកសារសារទូរលេខឆ្លងឆ្លើយសរុបចំនួន ២២៥[1434](ពីររយម្ភៃប្រាំ) ជាមួយមេដឹកនាំថ្នាក់លើ ក្នុងនោះសារទូរលេខដែលមានឈ្មោះ កែ ពក មានរហូត ១៣[1435](ដប់បី) សារទូរលេខ ។ ជាក់ស្ដែង មានសារទូរលេខតែមួយប៉ុណ្ណោះ ដែលមានរំលេចត្រឹមតែឈ្មោះ **អាន** លេខាតំបន់ ៤១ ក្នុងខ្លឹមសារសារទូរលេខរបស់ កែ ពក ដែលជាអ្នកបញ្ជូនទៅមន្ទីរ-



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581468



៨៧0 ពាក់ព័ន្ធការចាប់បានកងទ័ព ២ (ពីរ) នាក់ ក្នុងតំបន់ ៤១ ។[1436] លើសពីនេះ មិនមានចម្លើយសារភាពណាមួយនៃមន្ទីរសន្តិសុខ ស-២១ ដែលមានចំណាររបស់ **អោ អាន** ក្នុងនាមគាត់ជាអនុលេខាភូមិភាគកណ្តាល ឬ ជាលេខាតំបន់ ៤១ ទេ ។ ផ្ទុយទៅវិញ មានចំណាររបស់ កែ ពក ដែលនៅមានសេសសល់លើចម្លើយសារភាពនៅមន្ទីរសន្តិសុខ ស-២១ យ៉ាងតិចចំនួន ៤[1437] (បួន) ក្នុងចំណោមចម្លើយសារភាពយ៉ាងតិចចំនួន ១៦0[1438] (មួយរយហុកសិប) ។

៥១៨ មានសាក្សីជាច្រើនបានអះអាងថា **តា អាន** មានតែតំណែងថាជាអនុលេខាភូមិភាគប៉ុណ្ណោះ ប៉ុន្តែ គាត់មិនមានអំណាចក្នុងការសម្រេចកិច្ចការអ្វីទេ ។ សេចក្តីសម្រេចទាំងអស់គឺធ្វើឡើងដោយ កែ ពក ម្នាក់ឯងក្នុងកម្រិតភូមិភាគ ។ តាមពិត **តា អាន** មានអំណាចសម្រេចតែការងារក្នុងតំបន់ ៤១ របស់គាត់តែប៉ុណ្ណោះ ។[1439] *កែ ពក ទទួលពី ប៉ុល ពត ដែលហៅថា តា សាឡុត ស ឬ តាទី ១ ។ ហើយ **តា អាន** ទទួលពី កែ ពក  កែ ពក ទទួលពី ប៉ុល ពត*" ។[1440]

៥១៩ ក្នុងចំណោមលេខាភូមិភាគទាំង ៧ (ប្រាំពីរ) រូប នៃរបបកម្ពុជាប្រជាធិបតេយ្យ កែ ពក ជាលេខាភូមិភាគដែលមានឥទ្ធិពលបំផុតលំដាប់ទីពីរ បន្ទាប់ពី តា ម៉ុក លេខាភូមិភាគនិរតី ។ គាត់ជាមនុស្សមានអំណាច និងឥទ្ធិពលខ្ពស់បំផុតនៅភូមិភាគកណ្តាល ។ តាមអំណាចឋានានុក្រមនៅភូមិភាគកណ្តាល **អោ អាន** ស្ថិតនៅក្រោមបង្គាប់ កែ ពក ជាលេខាភូមិភាគ និង ជាសមាជិកគណៈកម្មាធិការមជ្ឈិមបក្សនៃ ប.ក.ក ។ មិនតែប៉ុណ្ណោះ កែ ពក ក៏មានតួនាទីខាងកងទ័ពក្នុងលំដាប់ខ្ពស់បំផុត ព្រមទាំងចូលរួមដឹកនាំការប្រយុទ្ធជាមួយវៀតណាម និងបានដឹកនាំការបោសសម្អាតក្នុងភូមិភាគបូព៌ានាឆ្នាំ១៩៧៨ ថែមទៀត ។ កែ ពក បានធ្វើការងារយ៉ាងជិតស្និទ្ធ ជាមួយថ្នាក់ដឹកនាំសំខាន់ៗ របស់គណៈកម្មាធិការអចិន្ត្រៃយ៍របស់ ប.ក.ក រួមមាន៖ សុន សេន, តា ម៉ុក, នួន ជា, និង ប៉ុល ពត ។

៥២0 អតីតប្រធានគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យឈ្មោះ ខៀវ សំផន ហៅ ហែម បាននិយាយដែរថា "*មេភូមិភាគគឺជាស្តេចក្រាញ់*" ។[1441] ឌុច ក៏លើកឡើងដែរថា លេខាភូមិភាគមានសិទ្ធិចាប់និងបញ្ជាឲ្យកម្ទេច តាមខ្លឹមសារនៃសេចក្តីសម្រេចចុះថ្ងៃទី៣0 ខែមីនា ឆ្នាំ ១៩៧៦ ដែលចែងថា "*ចំពោះសិទ្ធិសម្រេចកម្ទេច ក្នុងជួរនិងក្រៅជួរ បើនៅក្នុងក្របខណ្ឌ*



*E.C.C.C*C.E.T.C* CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION

*មូលដ្ឋានត្រូវអចិន្ត្រៃយ៍ភាគសម្រេច'* ។[1442] អតីតប្រធានមន្ទីរសន្តិសុខ ស-២១ កាំង ហ្កេកអ៊ាវ ហៅ ឌុច រូបនេះនៅបានបញ្ជាក់យ៉ាងច្បាស់ថា ពាក្យថា "អចិន្ត្រៃយ៍ភាគ" សំដៅលើ "*លេខាភូមិភាគ*" ។ មិនតែប៉ុណ្ណោះ ទំនាក់ទំនងដ៏រឹងមាំជាមួយមេដឹកនាំជាន់ខ្ពស់ដទៃទៀតបានធ្វើឲ្យ កែ ពក មានឥទ្ធិពល និងអំណាចបំផុតនៅភូមិភាគកណ្តាល អាចនិយាយលើសពីនេះទៀតថា "**កែ ពក ជាមនុស្សមិនខ្លាចមិនបាន**" ហើយចំណោមថ្នាក់ដឹកនាំក្នុងភូមិភាគនេះមានតែ កែ ពក ម្នាក់គត់ដែលបានរួចផុតពីការបោសសម្អាតនៅភូមិភាគកណ្តាល ។

## គោលនយោបាយបង្ក្រាប ដែលត្រូវតែអនុវត្តតាមដោយខានមិនបាន ប្រសិនបើមិនដូចនេះទេ កម្មាភិបាលប្រឆាំងគោលនយោបាយត្រូវរងការបោសសម្អាត

៥២១ ដើម្បីពិចារណាអំពីយុត្តាធិការ មានកត្តាជាច្រើនដែលនឹងត្រូវពិនិត្យ តាមឆន្ទានុសិទ្ធិដែលយើងមានក្នុងឋានៈជាចៅក្រម ។ កត្តាមួយគឺគោលនយោបាយ និង រចនាសម្ព័ន្ធដែល **អោ អាន** ស្ថិតនៅជាពិសេសដើម្បីដឹងថា តើ **អោ អាន** មានអំណាច និងឥទ្ធិពលកម្រិតណា ។ គោលនយោបាយ និងរចនាសម្ព័ន្ធ ត្រូវបានលម្អិតនៅផ្នែកខាងលើរួចហើយ ក្នុងផ្នែកទី II ស្តីពីការកត់សម្គាល់ឃើញអំពីអង្គហេតុ ហើយផ្នែកនេះ គ្រាន់តែបង្ហាញជាសង្ខេប ។

៥២២ ក្រោយទទួលបានអំណាចគ្រប់គ្រងនាថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កម្ពុជាប្រជាធិបតេយ្យបានរៀបចំរចនាសម្ព័ន្ធយោធា និងស៊ីវិល ថ្នាក់ជាតិ និងក្រោមជាតិ ។ រចនាសម្ព័ន្ធស៊ីវិលមានៈ គណៈកម្មាធិការមជ្ឈិមបក្ស គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស ភូមិភាគ តំបន់ ស្រុក សហករណ៍ ។ បន្ថែមពីលើនោះ មានរដ្ឋាភិបាល ក្រសួង និងមន្ទីរ ។ កម្ពុជាប្រជាធិបតេយ្យមាន រដ្ឋធម្មនុញ្ញ ព្រមទាំងមានតុលាការ និង សភាតំណាងប្រជាជន ។ ទោះបីជាយ៉ាងនេះក្តី ទាំងតុលាការ និងសភា មិនមានអំណាច និងមិនមានដំណើរការទេនាអំឡុងពេលនោះ ។

៥២៣ តាមលក្ខន្តិកៈរបស់បក្សកុំម្មុយនីស្តកម្ពុជា គណៈកម្មាធិការមជ្ឈិមបក្ស មានសមាសភាពចំនួន ៣០ (សាមសិប) រូប មានអំណាចច្រើនណាស់ ក៏ប៉ុន្តែ ជាក់ស្តែង អំណាចទាំងនោះស្ថិតនៅក្នុងដៃរបស់ គណៈកម្មាធិការអចិន្ត្រៃយ៍នៃគណៈកម្មាធិការមជ្ឈិមបក្ស ជាស្ថាប័នបក្សដែលមានសមាសភាពចំនួន ៧ (ប្រាំពីរ) រូបៈ តា ម៉ុក, និង សោ ភឹម ជាលេខាភូមិភាគ



E.C.C.C. * C.E.T.C. * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ១៥៥

ឈរនៅមូលដ្ឋាន ហើយ ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន, និង វន វេត ដែលមេដឹកនាំទាំងអស់នេះធ្វើការងារនៅភ្នំពេញ ។ **អោ អាន** មិនមានឈ្មោះក្នុងគណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍នេះទេ ។ មេដឹកនាំទាំង ៥ (ប្រាំ) រូបមាន៖ ប៉ុល ពត, នួន ជា, អៀង សារី, សុន សេន, និង វន វេត ជាអ្នកមានសិទ្ធិអំណាច និងឥទ្ធិពល គ្រោបក្រសោបទូទាំងប្រទេស ។

៩២៤ របបកម្ពុជាប្រជាធិបតេយ្យ ត្រូវបានដឹកនាំជាសមូហភាព ដែលប្រកាន់តាមរបបសង្គមនិយម ដោយយកវិស័យកសិកម្មជាមធ្យោបាយអាទិភាព ។ ដើម្បីសម្រេចគោលបំណងចំបងនេះ តាំងពីមុនឆ្នាំរំដោះ ១៩៧៥ គោលនយោបាយសំខាន់ៗមួយចំនួន ត្រូវបានអនុវត្តដូចជា គោលនយោបាយបណ្តេញចេញ អាពាហ៍ពិពាហ៍ដោយបង្ខំ ការបង្ក្រាបលើខ្មាំង និងក្រុមជនជាតិជាក់លាក់ជាដើម ។ ការបណ្តេញចេញត្រូវបានអនុវត្តមានជា ៣ (បី) ដំណាក់កាលរួមមាន៖ ដំណាក់កាលទី១. ក្នុងឆ្នាំ ១៩៧៥ ដែលជាការបណ្តេញចេញពីទីក្រុងភ្នំពេញទៅកាន់ទីជនបទទូទាំងប្រទេស ដំណាក់កាលទី២. ការបណ្តេញពីខេត្តកណ្តាល និងតាកែវទៅកាន់ខេត្តបាត់ដំបង និងពោធិ៍សាត់ ។ ក្រៅពីមូលហេតុសន្តិសុខ ការបណ្តេញចេញមានបំណង ដើម្បីបង្កើនកំលាំងធ្វើកសិកម្មនៅតាមមូលដ្ឋាន សម្រេចទិន្នផលស្រូវខ្ពស់សម្រាប់ការនាំចេញ តាមការកំណត់នូវគោលនយោបាយធ្វើស្រូវឲ្យបាន **“បីតោនក្នុងមួយហិចតា”** ។ ក្នុងនោះក៏ដើម្បីស្វែងរកសមាសភាពក្បត់នៅក្នុងស្រទាប់ប្រជាជន ។ ការអះអាងនេះត្រូវបានគាំទ្រ ដោយគោលបំណងនៃការបណ្តេញក្នុងដំណាក់កាលទីបី ពីភូមិភាគបូព៌ាទៅកាន់ភូមិភាគពាយ័ព្យ ក្នុងចុងឆ្នាំ១៩៧៧ ឬ ដើមឆ្នាំ១៩៧៨ ដើម្បីរកខ្សែក្បត់ចូលដៃជាមួយនឹងវៀតណាម។

៩២៥ ប្រជាជនត្រូវបានចាត់ជាប្រជាជនមូលដ្ឋាន និង អ្នកចំណូលថ្មី (ប្រជាជន១៧មេសា១៩៧៥) ដែលទើបចូលមករស់នៅ ក្នុងមូលដ្ឋានក្រោយពេលរំដោះនាឆ្នាំ១៩៧៥។ ជនជាតិវៀតណាម និងខ្មែរកម្ពុជាក្រោម ក៏ត្រូវបានបង្ក្រាបយ៉ាងព្រៃផ្សៃផងដែរ ។ ប្រជាជនមូលដ្ឋានមានបុព្វសិទ្ធិមួយចំនួន ប៉ុន្តែ ក្រោយមកប្រជាជនទាំងអស់ត្រូវបានទទួលរងនូវការប្រព្រឹត្តមិនខុសគ្នានោះទេ ពីសំណាក់កម្មាភិបាលដែលជា ការបង្ខំឲ្យធ្វើការងារ ការដាក់ទណ្ឌកម្ម ហើយពេលខ្លះបានឈានដល់ការសម្លាប់ ប្រសិនបើជននោះមិនបានប្រព្រឹត្តទៅតាមគោលនយោបាយ

បាយអង្គការ ឬ ដោយសារមានញាតិរបស់ខ្លួន មានជាប់ពាក់ព័ន្ធនឹងក្រុម ដែលរបបកម្ពុជាប្រជាធិបតេយ្យត្រូវបានចាត់ទុកថា "ខ្មាំង" ។

៥២៦ សមាជិកគ្រួសារនីមួយៗ ត្រូវបានអង្គការបំបែកចេញពីគ្នា ដើម្បីចូលរួមធ្វើការងារតាមការដ្ឋានពេលខ្លះជិតឬឆ្ងាយ ទៅតាមកម្រិតស្រុកឬតំបន់ ដែលបក្សបានកំណត់ ។ រីឯ ម្ដាយទាំងឡាយត្រូវរងនូវបំបែកពីកូន រហូតក្នុងករណីខ្លះកូនភ្លេចមុខម្ដាយ ហើយហៅម្ដាយថាជាមីង ដោយសារមនោគមន៍វិជ្ជាផ្និនផ្ដៅថា ពួកគេជាកូនរបស់អង្គការ ។ ប្រពន្ធបែកពីប្ដី និងកម្របានជួបគ្នា ហើយប្រសិនបើគ្មានការអនុញ្ញាតឱ្យមានការជួបជុំគ្រួសារទេ បុគ្គលដែលបំពាននឹងទទួលនូវទណ្ឌកម្ម ។ របបអាហារ ត្រូវបានកំណត់ពីរដងក្នុងមួយថ្ងៃរៀបចំឡើងនៅក្នុងរោងបាយរួម ។ អាហារត្រូវបានបន្ថយ ឬ ដកហូត ដែលជាទណ្ឌកម្ម ប្រសិនបើបានប្រព្រឹត្តអំពើខុសឆ្គង ។ ប្រជាជនគ្មានទ្រព្យសម្បត្តិឯកជនទេ សូម្បីតែបន្លែ ឬផ្លែឈើដាំដុះជុំវិញផ្ទះក៏ត្រូវបានចាត់ជាទ្រព្យសម្ងហភាព ។ ទ្រព្យសម្បត្តិទាំងអស់ សុទ្ធតែជាទ្រព្យរួម ។ ទូទាំងប្រទេស មិនមានលុយ និងទីផ្សារដើម្បីធ្វើការងារទិញដូរទេ ។

៥២៧ ប្រជាជនមានគ្មានសិទ្ធិសេរីភាពក្នុងការជ្រើសរើសគូស្រករទេ ។ បក្សបានរៀបចំនិងអនុវត្តនូវគោលនយោបាយរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ។ ការអនុវត្តន៍តាមលទ្ធិសាសនាត្រូវបានហាមឃាត់ ដោយសារបក្សបានចាត់ទុកថា សាសនាជាប្រតិកិរិយា រារាំងការអភិវឌ្ឍន៍របស់ប្រទេសជាតិ ។ លោកសង្ឃត្រូវបានផ្សឹក វត្តអារាមត្រូវបានបំផ្លាញ ឬបម្លែងទៅជាឃ្លាំង ឬ មន្ទីរឃុំឃាំង ។ សាសនិកអ៊ីស្លាមត្រូវបានបង្ខំ ឱ្យហូបសាច់ជ្រូក ហើយគម្ពីរកូរអាន (The Koran) របស់គេត្រូវបានដុតបំផ្លាញ ។

៥២៨ ស្ថានភាពបែបនេះ បានធ្វើឱ្យប្រជាជនមានការភ័យខ្លាច មិនហ៊ានចេញស្ដីបាក់ស្បាត ។ ម្នាក់ៗដឹងតែអំពីការងារខ្លួន លាក់បំបួនអត្តសញ្ញាណខ្លួន រក្សាការសម្ងាត់ មិនហ៊ានសួរការងាររបស់អ្នកដទៃ ដោយសារការខ្លាចអង្គការភ្នែកម្នាស់ ចាប់កំហុស និងយកទៅសម្លាប់ ។ មនុស្សរស់នៅក្នុងសភាពភ័យខ្លាចគ្រប់វិនាទី និងស្ថិតនៅមាត់ជ្រោះមរណៈ ។ បក្សបានប្រើប្រព័ន្ធតាមដានឃ្លាំមើលគ្រប់សកម្មភាព គ្រប់ពេលវេលា គ្រប់ទីតាំងនិងអង្គភាព ដោយមានការប្រជុំផ្សព្វផ្សាយគោលនយោបាយ និងការធ្វើជីវទស្សន៍ ដើម្បីរិះរកចំណុចខ្វះខាតដើម្បីកែលំអ ។ ប្រជាជនម្នាក់ៗត្រូវខិតខំធ្វើការងារ មិនហ៊ានឈប់សម្រាក ដោយត្រូវធ្វើតាម



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

ផែនការដែលបក្សបានដាក់ចេញ ដោយគ្មានត្អូញត្អែរ ពេលឈឺថ្កាត់មិនហ៊ានឈប់ ជាមួយការភ័យខ្លាច ក្នុងការចាប់បញ្ជូនទៅរៀនសូត្រ ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គ្មានមន្ទីរពេទ្យ និង ថ្នាំព្យាបាលគ្រប់គ្រាន់ ជារួមជាការផ្តល់សេវាសុខាភិបាលគ្មានគុណភាព ។ ទាំងអស់នេះបានធ្វើឱ្យប្រជាជនបាក់កម្លាំង មានជំងឺ អត់អាហារ និងស្លាប់ជាច្រើនរយពាន់នាក់ ។

៥២៩ ប្រជាជនគ្មានសន្តិសុខ និង សុវត្ថិភាពបុគ្គលទេ ក្នុងបរិបទនៃគោលនយោបាយបង្ក្រាបមានតាំងពីមុនឆ្នាំ១៩៧៥ ។ ជាក់ស្តែង ក្រោយរំដោះឆ្នាំ១៩៧៥ អតីតអ្នករដ្ឋការ និងទាហានសម័យលន់នល់ បញ្ញាវន្ត ព្រមទាំងសាច់ញាតិ ត្រូវបានចាប់ខ្លួន បាត់ខ្លួន និងសម្លាប់ ក្រោមហេតុផលជាខ្មាំងបដិវត្តន៍ ឬជាប់ខ្សែប្រតិកិរិយា សេអ៊ីអា (CIA) កាហ្សេបេ (KGB) ជាដើម ។

៥៣០ ការបង្ក្រាប បានចាប់ផ្តើមពីការចាប់ខ្លួនបណ្តាមេដឹកនាំភូមិភាគមួយចំនួនធំ យកទៅសម្លាប់នៅមន្ទីរសន្តិសុខ ស-២១ ដូចជា ៖ កុយ ធួន ហៅ ធុច រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាអតីតលេខាភូមិភាគឧត្តរ, សោ ភឹម ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស និងជាលេខាភូមិភាគបូព៌ា, វន វេត សមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស, រស់ ញឹម លេខាភូមិភាគពាយ័ព្យ និង កង ចាប ហៅ សែ លេខាភូមិភាគឧត្តរថ្មី ជាអាទិ៍ ។

៥៣១ ការបង្ក្រាបកាន់តែរាលដាល លាតសន្ធឹងទូទាំងប្រទេស ជាពិសេសក្នុងឆ្នាំ១៩៧៦ ក្រោយពីមានសេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៧៦ របស់គណៈកម្មាធិការមជ្ឈិមបក្ស និងស្របពេលដែល ពាក្យ "ខ្មាំង" ត្រូវបានពង្រីកន័យនិងប្រើយ៉ាងទូលាយ រាប់បញ្ចូល អ្នកណាដែលដើរទៅធ្វើការយឺត បើកឡានជាន់ហ្វ្រាំងអូសកង់ ភ្ជួរស្រែធ្វើឱ្យបាក់នង្គ័ល កាប់ដីធ្វើឱ្យរែបមុខចប ស្ទូងស្រូវច្រឡំពូជ ធ្វើឱ្យបែកចាន ធ្វើឱ្យបាក់ស្លាបព្រា ជាអាទិ៍ ។ ពួកគេនឹងត្រូវបានគេចោទថាជាខ្មាំង និងសម្លាប់ចោល ដោយគ្មានរកខុសត្រូវ និងឆ្លងកាត់នីតិវិធីតុលាការឡើយ ។

៥៣២ មន្ទីរសន្តិសុខមានមិនតិចជាង ១៩៦ (មួយរយកៅសិបប្រាំមួយ) កន្លែង ត្រូវបានបង្កើតឡើងនៅទូទាំងប្រទេស ដើម្បីឃុំឃាំង លត់ដំ សួរចម្លើយ ធ្វើទារុណកម្ម និងសម្លាប់សមាជិកភាព



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES · CO-JUGES D'INSTRUCTION

01581473



ក្បត់ទូទាំងប្រទេស ទាំងកម្មាភិបាលជាន់ខ្ពស់ ប្រជាជន ទាំងស៊ីវិល និងទាហាន ។ មាន កម្មាភិបាលជាន់ខ្ពស់ជាង ៦០ (ហុកសិប) រូប និង ប្រជាពលរដ្ឋសរុប ជិត ២.000.000 (ពីរលាន) នាក់ បានស្លាប់និងសម្លាប់ ក្នុងអំឡុងពេល ៣ ឆ្នាំ ៨ ខែ និង ២០ ថ្ងៃ ចាប់តាំងពី ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី០៦ ខែ មករា ឆ្នាំ ១៩៧៩ ។

៥៣៣ គោលនយោបាយ និងការប្រព្រឹត្តខាងលើ ត្រូវរៀបចំដោយកម្មាភិបាលជាន់ខ្ពស់ ហើយផ្សព្វផ្សាយយ៉ាងទូលំទូលាយដល់គ្រប់ទីកន្លែង បន្តដល់ថ្នាក់ក្រោម តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយ ។ ផែនការ និងទិសដៅការងារ ត្រូវតែបានអនុវត្តដោយកម្មាភិបាល តាមតួនាទីដោយគ្មានការដេញដោល ។ ករណីតវ៉ា ឬ មិនបានបំពេញតាមការងារ ឬ ធ្វើខុសនឹងវិន័យអង្គការ កម្មាភិបាលគ្រប់ជាន់ថ្នាក់ទាំងអស់ នឹងត្រូវលត់ដំ និងក្នុងករណីធ្ងន់ធ្ងរ ត្រូវបានចាប់សម្លាប់ ។ **អោ អាន** ធ្លាប់អះអាង ភាពដាច់ខាតដែលគាត់ត្រូវតែគោរព និងការភ័យខ្លាចដល់ជីវិត ប្រសិនបើគាត់មិនគោរពតាម ។

៥៣៤ របបកម្ពុជាប្រជាធិបតេយ្យ ជារបបប្រកាន់និន្នាការដឹកនាំរដ្ឋមួយជាក់លាក់ ឆ្លុះបញ្ចាំងក្នុងគោលនយោបាយធ្វើទុក្ខបុកម្នេញកម្រិតជាតិ អនុវត្តជារូបរាងទូទាំងប្រទេសក្នុងរចនាសម្ព័ន្ធដឹកនាំសមូហភាព ដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់ត្រូវគោរព និងធ្វើតាមបញ្ជា ។ សត្រូវ ឬ ខ្មាំងបដិវត្តន៍មានវិសាលភាពធំធេង គ្របដណ្តប់លើប្រជាពលរដ្ឋខ្លួនឯង ។ អង្គហេតុស្តីអំពីគោលនយោបាយ អត់អាហារ និងការកាប់សម្លាប់ទាំងអស់នេះ មានលក្ខណៈជាសត្យានុម័ត ដែលដឹងឮជាសាធារណៈ ។ បរិបទនៃការប្រព្រឹត្ត និងទម្រង់នៃការគ្រប់គ្រងក្នុងរបបកម្ពុជាប្រជាធិបតេយ្យគឺខុសពីអ្វី ដែលកើតមាននៅប្រទេសយូហ្គោស្លាវី (Yogoslavia) រ៉្វាន់ដា (Rwanda) និង សេរ៉ាឡេអូន (Sierra Leone) ដែលនាំឱ្យបង្កើតមាននូវតុលាការព្រហ្មទណ្ឌអន្តរជាតិស្រដៀងគ្នានឹង អ.វ.ត.ក ដែរ ។ នេះខុសគ្នា នឹងជម្លោះពូជសាសន៍រវាង ហ៊ូទូ (Hutus) និង ទុតស៊ី (Tutsi) ដែលនាំឱ្យមានប្រល័យពូជសាសន៍ នៅប្រទេសរ៉្វាន់ដា (Rwanda)។[1443] នេះខុសគ្នានឹង អំពើប្រល័យពូជសាសន៍ ដោយពួកជាតិនិយមស៊ែប (Serb) ដែលដឹកនាំដោយ អតីតប្រធានាធិបតីលោក ស្លូបូដាន ម៉េឡូសូវិច (Slobodan Milosevic) ទៅលើប្រជាជនក្រូអាត (Croat) និងបូស្នៀ (Bosnia) ។[1444]



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

01581474



៥៣៥ សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ ក្នុងដីកាដំណោះស្រាយនៃសំណុំរឿងលេខ០០៤/១ រួចហើយ ក្នុងបរិបទនេះ បើទោះបីកម្មាភិបាលណាមួយ អាចផ្តួចផ្តើមគម្រោងផែនការងារណាមួយ ក៏មិនអាចឆ្លាយពីបន្ទាត់នយោបាយនិងមិនអាចបង្ហាញថា កម្មាភិបាលរូបនោះមានអំណាចបានដែរ ។ *ករណីបុគ្គលម្នាក់បានបង្កើត ឬ ត្រូវបង្កើតគំនិតផ្តួចផ្តើមរបស់ខ្លួននៅក្នុងកាលៈទេសៈទាំងនេះ ឬក៏យ៉ាងណានោះ គឺពុំមែនជាលក្ខណៈវិនិច្ឆ័យមួយ ដែលអាចនឹងឲ្យបុគ្គលនោះស្ថិតក្នុងប្រភេទអ្នកទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ* ។[1445]

## យុត្តាធិការបុគ្គលតូចចង្អៀត
## ត្រូវបានបង្ហាញក្នុងអំឡុងពេលនៃការការចរចាបង្កើត អ.វ.ត.ក

៥៣៦ ក្នុងការសម្រេចថាតើ **អោ អាន** ជាមេដឹកនាំជាន់ខ្ពស់ ឬ ជាជនទទួលខុសត្រូវខ្ពស់បំផុត ក្រៅពីពិនិត្យមើលសកម្មភាពចូលរួម វាចាំបាច់ផងដែរ ក្នុងការពិនិត្យមើលពីចេតនានៃអ្នករៀបចំសេចក្តីព្រាងច្បាប់ និង កិច្ចព្រមព្រៀង អ.វ.ត.ក ។ នេះមានភាពសមស្រប ក្នុងខណៈដែលខ្លឹមសារច្បាប់និងកិច្ចព្រមព្រៀង មិនបានផ្តល់ន័យដល់ពាក្យ "មេដឹកនាំជាន់ខ្ពស់" ឬ "អ្នកទទួលខុសត្រូវខ្ពស់បំផុត"។

៥៣៧ មុននឹងបង្កើត អ.វ.ត.ក រដ្ឋាភិបាលក្នុងឆ្នាំ១៩៧៩ បានបង្កើតតុលាការជាតិ ដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហមមាន ប៉ុល ពត និង អៀងសារី ចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ ក្នុងបំណងស្វែងរកយុត្តិធម៌និងការពិត ។ បន្ទាប់ពី មានកិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីស ប្រទេសបារាំងនាឆ្នាំ១៩៩១ កម្ពុជាបានបោះឆ្នោតជាសកលនៅឆ្នាំ១៩៩៣ ជាមួយក្តីរំពឹងថា ក្រុមមេដឹកនាំកម្ពុជាប្រជាធិបតេយ្យបានចូលរួម និងនាំមកនូវសន្តិភាព តាមរយៈការបញ្ចប់នូវសង្គ្រាមស៊ីវិលដ៏រ៉ាំរ៉ៃជាង ១០ (ដប់) ឆ្នាំ គិតពីឆ្នាំ១៩៧៩ ។ ផ្ទុយទៅវិញ ក្រុមនេះមិនបានចូលរួមបោះឆ្នោតទេ និងបានបដិសេធលទ្ធផលបោះឆ្នោត និងបន្តការវាយប្រហារមកលើប្រជាជនកម្ពុជា ។ ដើម្បីសន្តិភាពកម្ពុជាបានរៀបចំច្បាប់ដាក់ក្រុមកម្ពុជាប្រជាធិបតេយ្យឲ្យនៅក្រៅច្បាប់ក្នុងឆ្នាំ១៩៩៤ ។ ច្បាប់នេះបានទុករយៈពេល ៦ (ប្រាំមួយ) ខែ ដើម្បីឲ្យក្រុមប្រដាប់អាវុធ មានឋានៈទាបចុះចូល ប្រសិនបើមិនចង់ទទួលនូវការកាត់ទោសទេ ។ គោលបំណងចំបងនៃច្បាប់នេះ ដើម្បីបញ្ចុះបញ្ចូលទាហានខ្មែរក្រហម ឲ្យមករួមរស់ក្នុងសន្តិភាព



INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C *

01581475



ក៏ប៉ុន្តែទន្ទឹមនឹងនេះ ក៏មិនភ្លេចទុកច្រកសម្រាប់កាត់ទោស មេដឹកនាំកម្ពុជាប្រជាធិបតេយ្យ ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះនៃអំពើឧក្រិដ្ឋប្រព្រឹត្ត ក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ផងដែរ។ នេះបានបង្ហាញតាមមាត្រា ៤០ ថ្មី នៃច្បាប់ ដែលមិនផ្តល់ការលើកលែងទោសដល់មេដឹកនាំទាំងនោះ ។

៥៣៨ ក្នុងឆ្នាំ២00៣ តុលាការកម្ពុជា បានកាត់ទោសអតីតកម្មាភិបាលមានឋានៈទាបមាន ឈូក រីន និង នួន ប៉ែត ចំពោះការប្រព្រឹត្តប្រឆាំងនឹងច្បាប់ជាតិកម្ពុជា ។ នេះមិនមានន័យថា កម្ពុជា ផ្តោតលើមុខសញ្ញាកម្មាភិបាលជាន់ទាប ដែលប្រព្រឹត្តបទឧក្រិដ្ឋអន្តរជាតិនោះទេ ។ ក្នុងគោលបំណងបញ្ចប់សង្គ្រាម និង ការបង្រួបបង្រួមជាតិទាំងស្រុង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់បានឡាយព្រះហស្ត លើកលែងទោស មេដឹកនាំកម្ពុជាប្រជា-ធិបតេយ្យក្នុងឆ្នាំ១៩៩៦ ព្រមទាំងបានចាប់ខ្លួន តាម៉ុក ជាមេដឹកនាំជាន់ខ្ពស់មួយរូបដែរ និង ឌុច ដែលគេដឹងឮជាទូទៅថា ជាប្រធានមន្ទីរសន្តិសុខ ស-២១ (គុកទួលស្លែង) ។

៥៣៩ ឆ្នាំ១៩៩៧ ខែមិថុនា រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានសរសេរលិខិតទៅអង្គការសហប្រជាជាតិ ដើម្បីស្នើសុំជួយបង្កើត អ.វ.ត.ក ។ រាជរដ្ឋាភិបាល បានដឹងច្បាស់អំពីការលើកលែងទោស ក៏ប៉ុន្តែ នៅតែមានបំណងបន្តស្វែងរកយុត្តិធម៌ ទើបបានធ្វើសំណើនេះ ។ ក្នុងនោះក៏បានផ្តោតតែលើ ឌុច និង តា ម៉ុក ដែលជាមេដឹកនាំដែលកំពុងតែជាប់ក្នុងមន្ទីរឃុំឃាំង ។

៥៤០ វត្តមាននៃការបង្កើត អ.វ.ត.ក ពុំមែនកើតឡើងដោយចៃដន្យនោះទេ ប៉ុន្តែ ជាលទ្ធផលដែលទទួលបានពីការចរចាជាច្រើនលើករវាង រាជរដ្ឋាភិបាលកម្ពុជា និងអង្គសហប្រជាជាតិអស់រយៈពេលជាង ១០ (ដប់) ឆ្នាំ ចាប់ពីឆ្នាំ១៩៩៧ ដល់ឆ្នាំ២00៧ ។ អ្វីដែលជាគោលបំណងដ៏ពិតប្រាកដនៃការបង្កើត អ.វ.ត.ក នេះឡើង ដើម្បីលុបបំបាត់វប្បធម៌និទណ្ឌភាពបទឧក្រិដ្ឋអន្តរជាតិ ។ ប៉ុន្តែ ដំណើរការនេះត្រូវធ្វើយ៉ាងណា មិនត្រូវឲ្យប៉ះពាល់ដល់សន្តិភាពទេ ។ ជាក់ស្តែង មានការចរចាយ៉ាងស្រួចស្រាវលើបញ្ហាយុត្តាធិការបុគ្គល ។ ចេតនារបស់រាជរដ្ឋាភិបាល ផ្តោតសំខាន់លើមេដឹកនាំជាន់ខ្ពស់ ។ នេះបង្ហាញតាមរយៈការដាក់បន្ថែមនូវពាក្យ “**ជាន់ខ្ពស់**” ទៅលើពាក្យ “**មេដឹកនាំ**” ដែលអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាបានឯកភាព ។ ពាក្យនេះគឺច្បាស់ណាស់សម្រាប់ តាម៉ុក ដែលជាមេដឹកនាំកំពុងជាប់



E.C.C.C * C.E.T.C * INVESTIGATING JUDGES * CO-JUDGES D'INSTRUCTION

01581476



ក្នុងមន្ទីរឃុំឃាំង និង មេដឹកនាំមួយចំនួនទៀត ។ ពាក្យ “ជនដែលទទួលខុសត្រូវខ្ពស់បំផុត” ត្រូវបានដាក់បញ្ចូលនាពេលក្រោយទៅក្នុងបទប្បញ្ញត្តិយុត្តាធិការ ក្រោយពីដឹងថា ឌុច នៅរស់រានមានជីវិត ។ កម្ពុជាបានឯកភាពសម្រាប់ករណី ឌុច ដោយសារគាត់ត្រូវបានចាប់ខ្លួន និងឃុំឃាំង។ ឯកសារចោទប្រកាន់ជនទាំងពីរនោះព្រមទាំងការឃុំខ្លួនអាចពន្យល់នូវចេតនាចង់បញ្ជូនឲ្យពួកគេ មកទទួលការកាត់សេចក្តីក្រោយពី អ.វ.ត.ក ត្រូវបានបង្កើត ។[1446]

៩៤១ នាអំឡុងពេលចរចា ភាគីទាំងពីរបានខ្វែងយោបល់លើចំនួនចៅក្រមនៃអង្គនីមួយៗ ព្រមទាំងយន្តការនៃការដោះស្រាយជម្លោះ ដែលត្រូវបានស្នើជាចំបងដោយភាគីកម្ពុជា ក្នុងការធានានូវអធិបតេយ្យភាព ហើយជាលទ្ធផល ការសម្របសម្រួលត្រូវបានប្រកាន់យក ។ អង្គបុរេ-ជំនុំជម្រះ ត្រូវបានបង្កើតឡើង ដើម្បីដោះស្រាយជម្លោះខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេតជាដើម ។ អង្គនីមួយៗត្រូវមាន សមាសភាពចៅក្រមកម្ពុជាច្រើនជាង ។ ឧទាហរណ៍ ក្នុងអង្គបុរេជំនុំជម្រះមានចៅក្រមកម្ពុជាចំនួន ៣ (បី) រូបនិងចៅក្រមអន្តរជាតិចំនួន ២ (ពីរ) រូប ។ រចនាសម្ព័ន្ធតុលាការពិសេស និង នីតិវិធីដែលចូលរួម ដោយចៅក្រម-ជាតិ និងចៅក្រមអន្តរជាតិនេះ ផ្ទុះបញ្ចាំងអោយឃើញច្បាស់លាស់ ពីយុត្តាធិការជ្រើសរើសយ៉ាងចង្អៀតបំផុតមិនអាចប្រកែកបាន ដូច្នេះ ទោះបីជាមានអង្គហេតុជាក់ស្តែង ពាក់ព័ន្ធនឹងជនត្រូវចោទក៏ដោយ ប៉ុន្តែ តាមការបកស្រាយតាមខ្លឹមសារច្បាប់គឺ ជនត្រូវចោទមិនដល់កម្រិតនៃប្រភេទយុត្តាធិការ “មេដឹកនាំជាន់ខ្ពស់” ឬ “ជនទទួលខុសត្រូវខ្ពស់បំផុត” នៃ អ.វ.ត.ក ដែរ ។ ជាចុងក្រោយ ប្រសិនបើកម្ពុជាមិនមានចេតនាកាត់ទោស មេដឹកនាំខ្មែរក្រហមទេ កម្ពុជាទំនងជានឹងមិនសុំបង្កើត អ.វ.ត.ក ទេ ពីព្រោះ កម្ពុជាដឹងយ៉ាងច្បាស់ថា អៀង សារី ត្រូវបានលើកលែងទោសរួចហើយ ។ មាត្រា ៤០ ថ្មី នៃច្បាប់ស្តីពី អ.វ.ត.ក បានទុកអំណាចជូនតុលាការ ដើម្បីពិចារណាលើការលើកលែងទោស ។ ជាចុងក្រោយ ក្នុងអំឡុងពេលនៃការពិភាក្សា លើសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក តំណាងរាជរដ្ឋាភិបាលបាននិយាយយ៉ាងច្បាស់ នៅក្នុងកិច្ចប្រជុំរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាថា មុខសញ្ញាសម្រាប់ការកាត់ទោសដោយ អ.វ.ត.ក **ត្រូវតែតិចតួច និង តូចចង្អៀត** ។[1447]

01581477



៩៤២ ជាសរុប សកម្មភាព និងចេតនារបស់ភាគីកម្ពុជាទាំងមុន និងអំឡុងពេលនៃការចរចាបង្កើតច្បាប់ អ.វ.ត.ក បង្ហាញពីយុត្តាធិការបុគ្គលដ៏តូចចង្អៀត ដើម្បីរកយុត្តិធម៌ និង រក្សាបានសន្តិភាព ។ មុខសញ្ញាទាំងនោះគឺមេដឹកនាំជាន់ខ្ពស់ និង ឌុច ដែលជាបុគ្គលម្នាក់តែប៉ុណ្ណោះ ដែលជាជនទទួលខុសត្រូវខ្ពស់បំផុត ។ ក្នុងដីកាដំណោះស្រាយ០០៤/១ សហចៅក្រមស៊ើបអង្កេតអះអាងថា៖ ចៅក្រមនៅ អ.វ.ត.ក ត្រូវគោរពតាមសេចក្តីសម្រេចតាមផ្លូវនយោបាយរបស់អ្នកតាក់តែងច្បាប់ ។[1448]

## ការចូលរួមរបស់ អោ អាន មិនសកម្ម មិនកៀកកិត ទៅនឹងអំពើឧក្រិដ្ឋដូចការចូលរួមរបស់ ឌុច

៩៤៣ នៅក្នុងដីកាដំណោះស្រាយសំណុំរឿង០០៤/១ សហចៅក្រមស៊ើបអង្កេត បានអះអាងអំពីភាពអាចប្រៀបធៀបបានរវាងជនសង្ស័យ និង ជនសង្ស័យផ្សេងទៀត ដើម្បីកំណត់ថាពួកគេចូលក្នុងយុត្តាធិការ អ.វ.ត.ក ឬ មិនចូល ។[1449] ទាំងសហព្រះរាជអាជ្ញា និងជនស្ថិតក្រោមការពិនិត្យក៏បានធ្វើដូចនេះដែរ ។[1450] ការធៀបធៀបនេះ ក៏អាចនឹងជួយដល់ ភាពឯកភាពនៃសេចក្តីសម្រេច (uniformity of decision) ។

៩៤៤ **អោ អាន** ជាអនុលេខាតំបន់ ៤១ មានឋានៈខ្ពស់ជាង កាំង ហ្កេកអ៊ាវ ហៅ ឌុច ខណៈដែល ឌុច គ្រាន់តែជាប្រធានមន្ទីរសន្តិសុខ ស-២១ ក្នុងចំណោមមន្ទីរសន្តិសុខប្រមាណជា ១៩៦ (មួយរយកៅសិបប្រាំមួយ) [1451] នៅទូទាំងប្រទេស ។ ប៉ុន្តែ ភ័ស្តុតាងដែលប្រមូលបាន មិនបង្ហាញនូវភាពជាក់លាក់ ពីចំនួនអ្នកនៅក្រោមបង្គាប់ **អោ អាន** និង ភាពសកម្មដោយផ្ទាល់ក្នុងការអនុវត្តន៍នៃអំណាចរបស់ខ្លួនដោយផ្តាច់មុខនោះទេ ។

៩៤៥ ឌុច មានបុគ្គលិកប្រហែល ២០០ (ពីររយ) នាក់ នៅក្រោមបង្គាប់ផ្ទាល់ ដើម្បីប្រតិបត្តិការងារប្រចាំថ្ងៃ ។ **អោ អាន** ទទួលការងារជាអនុលេខាភូមិភាគកណ្តាលដ៏ខ្លី និងជាលេខាតំបន់ ៤១ នេះបានត្រឹមប្រហែលជាងមួយឆ្នាំប៉ុណ្ណោះ ។ មានអ្នកក្រោមបង្គាប់ប្រហែល ៤០ (សែសិប) រូប និងពុំមានតួនាទីខាងយោធាទេ ។ **អោ អាន** ទទួលបន្ទុកជាអ្នកផ្សព្វផ្សាយបន្តនូវគោលនយោបាយ និងណែនាំដល់ប្រជាជន អំពីការខិតខំបង្កបង្កើតផល ដែលខុសផ្ទុយពី កាំង ហ្កេកអ៊ាវ ហៅ ឌុច អតីតប្រធានមន្ទីរសន្តិសុខ ស-២១ ជាការងារខាង



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

សន្តិសុខពាក់ព័ន្ធ រឿងចាប់ខ្លួន សួរចម្លើយ និង សម្លាប់មនុស្ស ។ លើសពីនេះ ឌុច បានកាន់តួនាទីជាប្រធានមន្ទីរស្ទើរពេញមួយរបបកម្ពុជាប្រជាធិបតេយ្យតែម្តង ។

៥៤៦ បុគ្គលមានឋានៈខ្ពស់ ក៏ប៉ុន្តែគាត់អាចមិនសូវមានអំណាច និងឥទ្ធិពល ។ ជាក់ស្តែង ដូចដែលភ័ស្តុតាងខាងលើបានបង្ហាញ **អោ អាន** ស្ថិតនៅក្រោមបង្គាប់របស់ កែ ពក ។ **អោ អាន** មិនមានស្វ័យភាព និងអំណាចតាមការអនុវត្តន៍ (*De Facto Authority*) ទេ ។ **អោ អាន** មិនអាចធ្វើការទាក់ទងជាមួយអង្គការថ្នាក់លើផ្ទាល់ទេ ។ ផ្ទុយទៅវិញ កាំង ហ្គេកអ៊ាវ ហៅ ឌុច ជាតួនាទីមិនធំតែសំខាន់ មានស្វ័យភាពការងារ និងអំណាចពិតប្រាកដតាមការអនុវត្តន៍ ។ មិនតែប៉ុណ្ណោះ មន្ទីរសន្តិសុខ ស-២១ ជាគុកមជ្ឈិមមានសិទ្ធិអំណាចចុះចាប់អ្នកទោសនៅទូទាំងប្រទេស បើទោះបីអ្នកទោសមានតំណែងប៉ុណ្ណាក៏ដោយ រាប់ទាំងក្នុងផ្នែកស៊ីវិល និងយោធា ។ តាមរយៈអំណាច និងការប្រាស្រ័យការងារផ្ទាល់របស់ ឌុច ដំបូងជាមួយ សុន សេន ជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍បក្សហើយចុងក្រោយជាមួយ នួន ជា ជាសមាជិកគណៈកម្មាធិការអចិន្ត្រៃយ៍បក្ស និងជាអនុលេខាបក្ស ។

៥៤៧ ឌុច ជាអ្នកផ្តួចផ្តើមចូលរួមដោយផ្ទាល់ និងការរៀបចំផែនការ តាមរយៈការណែនាំឱ្យអនុវត្ត និងតាមដានការងារ ។ ជាក់ស្តែង ឌុច ធ្លាប់រាយការណ៍ចំនួន អង្ករពន្លើសទៅថ្នាក់លើដើម្បីទទួលបានការសរសើរ ទោះបីជាក់ស្តែង មានការខ្វះខាតនៅ ស-២១ ដែលនាំឱ្យអ្នកទោសអត់អាហារ ។ ឌុច បង្កើតឬឆ្នៃប្រឌិត បែបផែនគ្រប់គ្រងរដ្ឋបាលនៅមន្ទីរសន្តិសុខ ស-២១ យ៉ាងច្បាស់លាស់ ដែលនេះបង្ហាញពីប្រសិទ្ធភាពនៃការងារដ៏ពិតប្រាកដ ។ ជាក់ស្តែង ពេលខ្លះ ឌុច បានចូលរួមដឹកនាំដោយផ្ទាល់ ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋជាមួយកម្មាភិបាលក្រោមបង្គាប់ក៏មាន ។ ជាផលវិបាក មានជនរងគ្រោះរហូតដល់ជិត ២០.០០០ (ពីរម៉ឺន) នាក់ បានស្លាប់ក្រោមកិច្ចប្រតិបត្តិការដឹកនាំដោយផ្ទាល់នៅមន្ទីរសន្តិសុខ ស-២១ ដែលមាន ឌុច ជាប្រធានក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ ។ ភាពសកម្មរបស់ ឌុច ធ្វើទារុណកម្ម សួរយកចម្លើយ វិភាគ ធ្វើចំណារ រាយការណ៍ជូនថ្នាក់លើផ្ទាល់គឺសរសេរដើម្បីបន្តចាប់ ដឹកស្មៅដឹកទាំងឫស ដែលភាពសកម្មនេះ **អោ អាន** មិនមានដូច ។



CO-INVESTIGATING JUDGES *CO-JUGES D'INSTRUCTION* E.C.C.C * C.E.T.C

៩៤៨ ការចូលរួមរបស់ ឌុច នេះជាលក្ខណៈផ្ទាល់ និង ភាពសកម្មខ្ពស់ ហើយដែលលទ្ធផលនេះបានឆ្លុះបញ្ចាំងយ៉ាងច្បាស់នូវអំពើរបស់ ឌុច ដែលជាមេគុកដ៏ឃោរឃៅក្នុងប្រវត្តិសាស្ត្ររបស់មនុស្សជាតិនាចុងសតវត្សរ៍ទី ២០ ។ នេះក៏បានបង្ហាញអំពីតួនាទីចំបងរបស់ ឌុច ដែលស្ទើរតែមិនអាចខ្វះបាន ក្នុងការប្រព្រឹត្តបទឧក្រិដ្ឋហើយក៏បានបង្ហាញនូវភាពលេចធ្លោរបស់ ឌុច ប្រសិនបើធៀបនឹងកម្មាភិបាលទាំងឡាយដែលមានឋានៈជាប្រធានមន្ទីរសន្តិសុខដូចគាត់ ឬ ខ្ពស់ជាងគាត់ ។ ក្នុងន័យនេះការសម្រេចថា ឌុច ជាជនទទួលខុសត្រូវខ្ពស់បំផុតយ៉ាងផ្តាច់មុខជាការត្រឹមត្រូវ និងមានលក្ខណៈសមស្របមែនទែន ក្នុងការដាក់បន្ថែមកម្រងពាក្យថា "**ជនទទួលខុសត្រូវខ្ពស់បំផុត**" សម្រាប់ដាក់ ឌុច ឲ្យទទួលខុសត្រូវ នៅពេលគេបានដឹងថា ឌុច នាពេលនោះនៅរស់រានមានជីវិតនៅឡើយ ។

៩៤៩ **អោ អាន** ចូលរួមប្រជុំស្តីអំពីគោលនយោបាយនៅមន្ទីរភូមិភាគកណ្តាល និងដឹកនាំប្រជុំនៅតំបន់៤១ ចុះទៅពិនិត្យតាមការដ្ឋានធ្វើពលកម្មនិងផ្សព្វផ្សាយ អំពីគោលនយោបាយចុះពិនិត្យតាមមន្ទីរសន្តិសុខមួយចំនួន ។ ឋានៈរបស់ **អោ អាន** ជាតួនាទីដែលមានលក្ខណៈសម្រុះសម្រួលច្រើនជាងដូចជា ពាក់ព័ន្ធការប្រព្រឹត្តលើជនជាតិចាម ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ។ ផ្ទុយទៅវិញ មានភ័ស្តុតាងដ៏តិចតួចបំផុតមែនទែន ដែលបង្ហាញការចេញបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ពី **អោ អាន** ។

៩៥០ ការប៉ាន់ប្រមាណទាញចេញពីភ័ស្តុតាងបានបង្ហាញថា ចំនួនជនរងគ្រោះនៃទីតាំងឧក្រិដ្ឋដែល **អោ អាន** ត្រូវបានចោទថាជាប់ពាក់ព័ន្ធមិនមានចំនួនច្រើនដូចដែល សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា មានប្រហែល ៤០០.០០០ (សែសិបម៉ឺន) នាក់ ទេ ។ មិនតែប៉ុណ្ណោះចំនួនជនរងគ្រោះទាំងនោះ មិនមែនជាចំនួនជនរងគ្រោះផ្ទាល់នៃអំពើរបស់ **អោ អាន** ទេ ។ លើសពីនេះទៀត មិនមានការធ្វើកោសលវិច័យ ដើម្បីបង្ហាញថា តើមានអត្រាជនរងគ្រោះប៉ុន្មាននាក់បានស្លាប់មុន ឬ អំឡុងពេលដែល **អោ អាន** កាន់ការងារនៅភូមិភាគកណ្តាលជាពិសេសតំបន់ ៤១ ។ តើមានការស្លាប់ដោយអត់អាហារមានចំនួនប៉ុន្មាន ហើយការសម្លាប់មានចំនួនប៉ុន្មាននាក់ ? បញ្ហាទាំងនេះសុទ្ធតែស្ថិតក្នុងភាពមិនច្បាស់លាស់ជានិច្ច ។



* E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION

៥៥១ សកម្មភាពចូលរួមរបស់ **អោ អាន** ទាំងអម្បាលមាណមិនបង្ហាញ អំពីភាពលេចធ្លោហួសពីប្រក្រតីភាពនៃការងារ ប្រសិនបើធៀបជាមួយនឹងបុគ្គលមានឋានៈជា លេខាតំបន់ ឬ ជាអនុលេខាភូមិភាគដូច **អោ អាន** អនុលោមទៅតាមគោលការណ៍យុត្តាធិការបែបជ្រើសរើសរបស់ អ.វ.ត.ក ។

## សន្និដ្ឋានសរុប

៥៥២ ក្រោយពីបានបង្ហាញពីតួនាទី អំណាច និងការចូលរួមរបស់ **អោ អាន** ទំនាក់ទំនងរវាង **អោ អាន** និង កែ ពក ព្រមទាំងអំណាច កែ ពក ជាលេខាភូមិភាគ ការប្រៀបធៀបអំណាចតួនាទី និងការចូលរួមរបស់ ឌុច និង **អោ អាន** គោលនយោបាយ និងរចនាសម្ព័ន្ធនៃអំណាចរបស់របបកម្ពុជាប្រជាធិបតេយ្យ និងប្រវត្តិ ព្រមទាំងចេតនានៃភាគីធ្វើកិច្ចព្រមព្រៀង និងច្បាប់ អ.វ.ត.ក យើងសន្និដ្ឋានថា៖ ក. តួនាទីរបស់ **អោ អាន** មិនមានការតែងតាំងជាផ្លូវការទេ ។ ការចូលរួមសកម្មភាពការងារធ្វើឡើង តាមតួនាទី និងការទទួលខុសត្រូវ មិនមានអំណាចជាក់ស្តែង (De facto) ទេ ។ គាត់ត្រូវបានធ្វើឡើង តាមបញ្ជា និងការណែនាំរបស់ កែ ពក ដែលស្ថិតនៅគ្រប់គ្រងដឹកនាំភូមិភាគកណ្តាលជាប្រចាំ ផ្ទាល់ ឬប្រយោល ទោះបីគាត់មានបេសកកម្ម នៅភូមិភាគបូព៌ាម្តងម្កាល ក្នុងរយៈពេលខ្លីក៏ដោយ ។ កែ ពក មានអំណាច និងឥទ្ធិពល ហើយក៏ជាបុគ្គលតែម្នាក់គត់ ក្នុងកម្រិតភូមិភាគដែលរស់រានមានជីវិតក្នុងបរិបទវិសុទ្ធកម្មនៅភូមិភាគកណ្តាល ។

៥៥៣ ការចូលរួមសកម្មភាពរបស់ **អោ អាន** ក្នុងឋានៈជាលេខាតំបន់ ៤១ នៃភូមិភាគកណ្តាលក្នុងរយៈពេលខ្លី ក្នុងបរិបទវិសុទ្ធកម្មរបស់បក្ស ដែលកម្មាភិបាលគ្រប់ជាន់ថ្នាក់បានចូលរួម ។ ប្រសិនបើមានការប្រឆាំងជំទាស់ នឹងមិនរួចផុតពីសេចក្តីស្លាប់ឡើយ ។ ការចូលរួមរបស់ **អោ អាន** មិនមានស្វ័យភាព មិនសកម្ម គ្មានគំនិតផ្តួចផ្តើម និងមិនកៀកកិតនឹងការប្រព្រឹត្តបទល្មើស ដែលនេះមានភាពខុសស្រឡះយ៉ាងខ្លាំងជាមួយនឹង ការចូលរួមយ៉ាងសកម្មកៀកកិតនិងផ្តួចផ្តើមរបស់ ឌុច ។ បន្ថែមលើនេះ **អោ អាន** មិនបានចូលរួមធ្វើគោលនយោបាយរបស់បក្សកុំម្មុយនីស្តកម្ពុជាឡើយ។



E.C.C.C * C.E.T.C * CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION ១៦២

**តាមសំអាងហេតុខាងលើ យើងសម្រេច៖**[1452]

៥៥៤ អ.វ.ត.ក មិនមានយុត្តាធិការបុគ្គលលើ **អោ អាន** ឡើយ ។

៥៥៥ **លើកលែងការចោទប្រកាន់**ប្រឆាំង **អោ អាន** ។

ថ្ងៃព្រហស្បតិ៍ ៥ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ សីហា ឆ្នាំ ២០១៨

**សហចៅក្រមស៊ើបអង្កេតជាតិ**

**National Co-Investigating Judge**

**National Co-juge d'instruction**

**ចៅក្រម យូ ប៊ុនឡេង**

---

[1] D1, ឯកសារជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា, សំណុំរឿងលេខ៖០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស, ភាគីបញ្ជូន៖ការិយាល័យសហព្រះរាជអាជ្ញា, ប្រភេទឯកសារ៖សម្ងាត់, ចុះកាលបរិច្ឆេទ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

[2] D1, ឯកសារជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា, សំណុំរឿងលេខ៖០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស, ភាគីបញ្ជូន ៖ ការិយាល័យសហព្រះរាជអាជ្ញា, ប្រភេទឯកសារ ៖ សម្ងាត់, ចុះកាលបរិច្ឆេទនាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨, គ្រង់កថាខណ្ឌទី ១១៧ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ, ទំ.៤៩-៥០ ។

[3] D1/1.3, ឧបសម្ព័ន្ធI : សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧៦ នៃវិធានផ្ទៃក្នុង, ចុះកាលបរិច្ឆេទនាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ។ D1/1.1, ឧបសម្ព័ន្ធII : សេចក្តីដកស្រង់ការពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ ២០០៩ ។

[4] D1/1, ឯកសារជាសេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរទី ៣, សំណុំរឿងលេខ ៖ ០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស, ភាគីអ្នកដាក់ ៖ សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ។

[5] D41, ឯកសារជាសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឲ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹង ទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ ០០៤ នៅភូមិភាគកណ្តាល និង ការទទួលខុសត្រូវរបស់ជនសង្ស័យឈ្មោះ **តា អាន**, សំណុំរឿងលេខ៖០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ។

[6] D65, ឯកសារជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, សំណុំរឿងលេខ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ការិយាល័យសហព្រះរាជអាជ្ញា, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ។

[7] D191, ឯកសារជាដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ អំពើហិង្សាយេនឌ័រ, សំណុំរឿងលេខ៖០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ភាគីអ្នកដាក់ សហព្រះរាជអាជ្ញា, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤ ។

[8] D334, សេចក្តីជូនដំណឹងអំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន**, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ។

[9] D334/1, ដីកាសម្រេចបំបែកសំណុំរឿង **អោ អាន** ពីសំណុំរឿង០០៤, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ ។

[10] D340, ឯកសារជា "សំណើសុំពន្យាពេលកំណត់ សម្រាប់ការដាក់សំណើសុំបំពេញកិច្ចស៊ើបសួរបន្ថែម បន្ទាប់ពីមានសេចក្តីជូនដំណឹង អនុលោមតាមវិធាន ៦៦", ភាគីដាក់ឯកសារ ៖ **អោ អាន**, កាលបរិច្ឆេទនាថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៦ ។

[11] D340/1, ឯកសារជា"ដីកាសម្រេចលើសំណើរបស់ **អោ អាន** សុំពន្យាររយៈពេលកំណត់ ដើម្បីស្នើសុំបំពេញកិច្ចស៊ើបសួរបន្ថែម ក្រោយពីមានការជូនដំណឹង អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង", សហចៅក្រមស៊ើបអង្កេតអន្តរជាតិ, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ។

[12] D334/2, ឯកសារជា សេចក្តីជូនដំណឹងលើកទី ២ អំពីការបិទកិច្ចស៊ើបសួរប្រឆាំង **អោ អាន**, ចុះកាលបរិច្ឆេទនាថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ។



CO-INVESTIGATING JUDGES * CO-JUGES D'INSTRUCTION * E.C.C.C * C.E.T.C

01581483



[13] D351, ឯកសារជា ដីកាបញ្ជូនសំណុំរឿងទៅពិនិត្យ អនុលោមតាមវិធាន ៦៦ (៤) នៃវិធានផ្ទៃក្នុង, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៧ ។

[14] D351/4, ឯកសារជាដីកាសន្និដ្ឋានស្ដាពរទាក់ទិនករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, ភាគីអ្នកដាក់៖សហព្រះរាជអាជ្ញាជាតិ, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ ។

[15] D351/5, ឯកសារជា ដីកាសន្និដ្ឋានស្ដាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង, សំណុំរឿងលេខ៖០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ ។

[16] D351/6, ឯកសារជាចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ដាពរ របស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦ ដោយមេធាវីស្នើសុំឱ្យ សហចៅក្រមស៊ើបអង្កេត លើកលែងការចោទប្រកាន់លើ អោ អាន, សំណុំរឿងលេខ៖០០៤/២/០៧-០៩-២០០៩ - អ.វ.ត.ក/ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ ។

[17] D350/1, ឯកសារជា សាលដីកាសម្រេចលើពាក្យសុំរបស់ អោ អាន ឱ្យធ្វើមោឃភាពកិច្ចស៊ើបសួរទាំងមូល, សំណុំរឿងលេខ៖០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៧, ត្រង់កថាខណ្ឌទី ១៤, ទំ.០៦ ។

[18] F26/12, ឯកសារជាសេចក្ដីសម្រេចលើសេចក្ដីជំទាស់ ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, ចុះកាលបរិច្ឆេទ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ។ E350/8, ឯកសារជាសេចក្ដីសម្រេចលើភ័ស្តុតាងដែលបានមកដោយការធ្វើទារុណកម្ម, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៦ ។

[19] F26/12, ឯកសារជាសេចក្ដីសម្រេចលើសេចក្ដីជំទាស់ ទៅនឹងបញ្ជីឯកសារសំអាងហេតុពេញលេញ, ចុះកាលបរិច្ឆេទ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ។

[20] ឯកសាររបស់ អ.ស.ប, A/51/930-S/1997/488, សំបុត្ររបស់អគ្គលេខាធិការអង្គការសហប្រជាជាតិ ជូនចំពោះប្រធានក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និង នាយករដ្ឋមន្ត្រីទី ១ និងនាយករដ្ឋមន្ត្រីទី ២ នៃព្រះរាជាណាចក្រកម្ពុជា, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៤ ខែមិថុនា ឆ្នាំ១៩៩៧ ។ ឯកសាររបស់ អ.ស.ប, A/RES/52/135, សេចក្ដីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ស្ដីអំពីស្ថានភាពសិទ្ធិមនុស្សនៅកម្ពុជា, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ១៩៩៨, ត្រង់កថាខណ្ឌទី ១៦ ។ គេហទំព័រ អ.វ.ត.ក https://www.eccc.gov.kh/12278 ។

[21] ឯកសារជាកិច្ចព្រមព្រៀង រវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដែលត្រូវបានចុះហត្ថលេខានៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៣ និងចូលជាធរមាននៅថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ។ ឯកសារ អ.ស.ប ល.A/RES/57/228B (ចុះកាលបរិច្ឆេទនាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣) ដែលអនុម័តយល់ព្រមលើ សេចក្ដីព្រាងកិច្ចព្រមព្រៀងទាក់ទិននឹងការបង្កើត អ.វ.ត.ក ។ ឯកសារ អ.ស.ប.ល. A/60/565, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៣, ត្រង់កថាខណ្ឌទី ៤ ។

[22] ឯកសារជាច្បាប់ស្ដីពី "ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា" ចុះកាលបរិច្ឆេទនាថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ និង ត្រូវបានធ្វើវិសោធនកម្ម ដោយព្រះរាជក្រម ចុះកាលបរិច្ឆេទនាថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ (នស/រកម/១០០៤/០០៦) ("ច្បាប់ស្ដីពី អ.វ.ត.ក") ។

01581484



[23] វិធានផ្ទៃក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិសោធនកម្មលើកទី ៩, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥, វិធាន ៧២ ចំណុចទី ១ បានចែងថា៖ "ក្នុងករណីមានការខ្វែងយោបល់គ្នា រវាងសហចៅក្រមស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬ ទាំងពីរ អាចធ្វើកំណត់ហេតុ អំពីមូលហេតុពិតប្រាកដ នៃការខ្វែងយោបល់នេះ ដោយមានហត្ថលេខា និងចុះកាលបរិច្ឆេទ ដែលត្រូវយកទៅដាក់ចូលក្នុងសំណុំឯកសារ នៃការខ្វែងយោបល់គ្នាដោយឡែកដែលរក្សាទុកដោយក្រឡាបញ្ជីរបស់សហចៅក្រមស៊ើបអង្កេត", ទំ.៨៦ ។

[24] **D1**, ឯកសារជាដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី ៣ របស់សហព្រះរាជអាជ្ញា, សំណុំរឿងលេខ៖០០៤/២០-១១-២០០៨/អ.វ.ត.ក/ក.ស.ច.ស, ភាគីបញ្ជូន៖ការិយាល័យសហព្រះរាជអាជ្ញា, ចុះកាលបរិច្ឆេទ នាថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០៨ ។

[25] **D1/1.3**, ឯកសារជាឧបសម្ព័ន្ធ: សំណៅសាធារណៈមានកោសលុប សេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹង ករណីខ្វែងយោបល់គ្នា រវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ។

[26] **D1/1**, ឯកសារជា សេចក្តីជូនដំណឹងរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី អំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទី ៣, សំណុំរឿងលេខ៖០០៤/២០-១១-២០០៨-អ.វ.ត.ក/ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០០៩ ។

[27] ឯកសាររបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត, អំពីសេចក្តីប្រកាសព័ត៌មាន របស់សហចៅក្រមស៊ើបអង្កេត, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ។

[28] **D3**, ឯកសារក្នុងសំណុំរឿងលេខ៖០០៤/២០-១១-២០០៨- អ.វ.ត.ក/ក.ស.ច.ស, "ដីកាចាត់ឱ្យស៊ើបសួរជំនួសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិឈ្មោះ Marcel LEMONDE", ចុះកាលបរិច្ឆេទ នាថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១០ ។

[29] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានចេញសេចក្តីប្រកាសព័ត៌មាន៖ ស្តីអំពីការតែងតាំងលោកបណ្ឌិត Siegfried BLUNK ជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិថ្មី ដោយបានបញ្ជាក់ថា លោកចៅក្រម Siegfried BLUNK ចាប់ផ្តើមចូលបម្រើក្នុងការិយាល័យរបស់លោក ចាប់ពីថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១០ នេះតទៅ ។

[30] ឯកសារ ការិយាល័យសហចៅក្រមស៊ើបអង្កេត, សេចក្តីប្រកាសព័ត៌មាន, ចុះកាលបរិច្ឆេទ នាថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០១១ ។

[31] **D27**, ឯកសារជា ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញា ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, ចុះកាលបរិច្ឆេទនាថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១ ។

[32] **D41**, ឯកសារជាសំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិ សុំឱ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ០០៤ នៅភូមិភាគកណ្តាល និង ការទទួលខុសត្រូវរបស់ជនសង្ស័យឈ្មោះ តា អាន, សំណុំរឿងលេខ៖០០៤/២/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១១ ។

[33] **D27/1**, ឯកសារជា ដីកាសម្រេចស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, សំណុំរឿងលេខ៖០០៤/២/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១១ ។

01581485



[34] D27/2, ឯកសារជា ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ២០១១ ទាក់ទងនឹង ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម, សំណុំរឿងលេខ៖០០៤/២/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១១ ។

[35] D27/3, ឯកសារជា សេចក្តីសម្រេចស្តីអំពីដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនានា នៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម, សំណុំរឿងលេខ៖០០៤/២/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស, ចុះកាលបរិច្ឆេទ នាថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១១ ។

[36] D65, ឯកសារដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម របស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹង ទីតាំងឧក្រិដ្ឋនានា នៅក្នុងតំបន់១និង ការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម", សំណុំរឿងលេខ៖០០៤/២/០៧-០៩-០៩/អ.វ.ត.ក-ក.ស.ច.ស , ការិយាល័យសហព្រះរាជអាជ្ញា, ចុះកាលបរិច្ឆេទ នាថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ ។

[37] ឯកសារជា សេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទងនឹងដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសំណុំរឿង០០៤ (០០៤/០៧-០៩-២០០៩/អ.វ.ត.ក/ក.ស.ច.ស) , ទំ.០១-០៥ ។

[38] ឯកសារជាសេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ, ចុះកាលបរិច្ឆេទនាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

[39] ឯកសារជា សេចក្តីប្រកាសព័ត៌មាន របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង Laurent Kasper-Ansermet, ចុះកាលបរិច្ឆេទ នាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១ ។

[40] ឯកសារជាសេចក្តីប្រកាសព័ត៌មានរបស់សហចៅក្រមស៊ើបអង្កេតជាតិ, ចុះកាលបរិច្ឆេទនាថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១១។

[41] D110, ឯកសារស្តីពីការជូនដំណឹងអំពីសិទ្ធិរបស់ ជនសង្ស័យ តាមវិធាន ២១.១ ឃ, ដោយសហចៅក្រមស៊ើបអង្កេតបម្រុងអន្តរជាតិ Laurent Kasper-Ansermet, ចុះកាលបរិច្ឆេទនាថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១២ ។

